## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍ត្រួតពិនិត្យ និង តាមដានវឌ្ឍនភាព
# នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ប្រចាំឆ្នាំ២០២២ និងការវាយតម្លៃ
# ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានកំណត់ចក្ខុវិស័យប្រកបដោយមហិច្ឆិតា និង ប្រាកដនិយម ពោលគឺកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យស្របតាមស្តង់ដា និង ឧត្តមានុ-វត្តន៍អន្តរជាតិ ដែលមានគោលដៅផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូល និងមានលក្ខណៈ មជ្ឈការ ឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬ លទ្ធផល និងវិមជ្ឈការ។


ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ផ្លូវលេខ 92 សង្កាត់វត្តភ្នំ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
(+៨៥៥) ៨៥ ៧៧៧ ៩២០

www.facebook.com/gscpfm
gsc@pfm.gov.kh
www.pfm.gov.kh

# បុព្វកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីកែទម្រង់ស្នូលមួយ នៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច តាមរយៈការប្រកាន់ខ្ជាប់ការអនុវត្តនូវ **អភិក្រមជាខឿន ឬជាដំណាក់កាល (Platform Approach)**។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានកំណត់ចក្ខុវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយម ពោលគឺកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ ដែលមានគោលដៅផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬ លទ្ធផល និងវិមជ្ឈការ។ ក្នុងទស្សនវិស័យដ៏ពិសិដ្ឋនេះ, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបាននិងកំពុងធ្វើទំនើបកម្មជាបណ្តើរៗ និងកាន់តែស៊ីជម្រៅលើគ្រប់សមាសធាតុស្នូលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការកសាង និងកែលម្អប្រព័ន្ធ, ក្របខ័ណ្ឌគតិយុត្ត, ស្ថាប័ននីយកម្ម និងធនធានមនុស្ស។

ការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ គឺ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" នៅឆ្នាំ២០១៦ យើងបានប្តេជ្ញាមោះមុត ព្រមទាំងរំពឹងទុកថា យើងនឹងកសាងនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយដោយប្រែក្លាយ"**ថវិកាជាឧបករណ៍គោលនយោបាយ**" ដើម្បីបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព ដែលផ្តោតលើការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងផែនការយុទ្ធសាស្ត្រថវិកា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្សារភ្ជាប់គោលនយោបាយជាតិ (យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិ) តាមរយៈអភិក្រមពីលើចុះក្រោម (Top-down approach) និងពីក្រោមឡើងលើ (Bottom-up approach)។

ជាក់ស្តែង ការដាក់ឱ្យអនុវត្តដំណាក់កាលទី៣នេះ គឺពិតជាត្រូវពេល និងស្របតាមបរិបទនៃការគ្រប់គ្រងម៉ាក្រូ-សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមកម្ពុជា ព្រមទាំងការធ្វើសមាហរណកម្មក្នុងតំបន់ និងសកលលោក ផងដែរ។ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលជាច្រើនក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានផ្តល់ផលវិជ្ជមានទាំងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងប្រសិទ្ធភាពស្ថាប័នរាជរដ្ឋាភិបាល។ សមិទ្ធផលនេះ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចសន្សំនិងបង្ហូរថវិកាកាន់តែច្រើនទៅកាន់វិស័យអាទិភាព ក៏ដូចជាអាចបង្កើនយ៉ាងច្រើននូវធនធានវិនិយោគសាធារណៈក្នុង ស្រុកពិសេសលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាប្រការជួយលើកស្ទួយមួយកម្រិត ដល់ឯករាជ្យភាពផ្នែកថវិការបស់កម្ពុជា។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលមានលទ្ធភាពដំឡើងបៀវត្សជូនមន្ត្រីរាជការ, ប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។ ក្នុងរយៈពេលប្រមាណ ៣ ឆ្នាំ នៃវិបត្តិជំងឺកូវីដ-១៩ កន្លងទៅ, រាជរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយ និងវិធានការអន្តរាគមន៍ទាំងឡាយ ដើម្បីជួយរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជាការរក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជន ដែលបាននិងកំពុងបន្តទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩។

ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តអនុវត្តគោលនយោបាយសារពើពន្ធ មិនមែនសារពើពន្ធ និងវិធានការគន្លឹះមួយចំនួនសំដៅដោះស្រាយបញ្ហាប្រឈម និងហានិភ័យផ្នែកម៉ាក្រូសេដ្ឋកិច្ចនានា, ពិសេសសំដៅកាត់បន្ថយផលប៉ះពាល់ និងសំពាធនៃការឡើងថ្លៃទំនិញ និងសេវា ដែលកើតចេញពីវិបត្តិនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលវិធានការទាំងនោះរួមមាន÷ ១) ការដាក់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារមូលដ្ឋាន, និងកាត់បន្ថយបន្ទុកពន្ធក្នុងវិស័យសំខាន់ៗមួយចំនួន, ២) ការមិនតម្លើងថ្លៃអគ្គិសនី និងថ្លៃទឹកស្អាត និងការឧបត្ថម្ភធនប្រេងឥន្ធនៈ, ៣) ការជំរុញផលិតកម្មក្នុងស្រុក ពិសេសក្នុងវិស័យកសិកម្ម ដូចជា ការចិញ្ចឹមសត្វ, ការដាំដុះ និងការផលិតស្បៀងអាហារ, ៤) ការធានាបាននូវការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងថាមពលអគ្គិសនីគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងស្រុក, ៥) ការសម្រួលពាណិជ្ជកម្មក្រៅប្រទេសសំដៅបំពេញតម្រូវការក្នុងស្រុក, ៦) ការបន្តកម្មវិធីអន្តរាគមន៍ ដូចជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ, កម្មវិធីសាច់ប្រាក់ពលកម្ម, និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់។

ឈរលើមូលដ្ឋាននៃការសម្រេចបានសមិទ្ធផលដ៏ត្រចះត្រចង់ខាងលើ, យើងអាចវាយតម្លៃប្រកបដោយការជឿជាក់ថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងស្ថិតនៅលើមាគ៌ា និងទិសដៅត្រឹមត្រូវ ព្រមទាំងបានជ្រើសរើសយកអភិក្រមអនុវត្ត ដែលមានភាពប្រាកដនិយម និងអាចអនុវត្តបាន, ពិសេសផ្តល់នូវលទ្ធផលជាក់ស្តែងជាបន្តបន្ទាប់នៅតាមដំណាក់កាលនីមួយៗ។ ក្នុងន័យនេះ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាកាន់តែមានភាពជឿទុកចិត្ត (ទាំងទិដ្ឋភាពនៃការគ្រប់គ្រងការប្រមូលចំណូល ចំណាយថវិកា និងបំណុលសាធារណៈ), មានបុរេលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ, មានក្របខ័ណ្ឌថវិកាកម្មវិធីច្បាស់លាស់ ជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលសម្រាប់ទ្រទ្រង់ និងជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ពិសេសការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ, មានមន្ត្រីកាន់តែមានសមត្ថភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, មានការយល់ដឹងកាន់តែច្រើនឡើង សម្រាប់ចូលរួមអនុវត្តកម្មវិធីកែទម្រង់ និងកំពុងកសាងមូលដ្ឋានជាបណ្តើរៗ ឆ្ពោះទៅកាន់គណនេយ្យភាពសមិទ្ធកម្ម។

ជាចុងក្រោយ ខ្ញុំសូមយកឱកាសនេះ វាយតម្លៃខ្ពស់ និងផ្តល់មូលវិចារដ៏ថ្លៃថ្លាចំពោះសហការីនៃរាជរដ្ឋាភិបាលកម្ពុជា, ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ ដែលបានខិតខំប្រឹងប្រែងអនុវត្តសកម្មភាពទាំងឡាយ នៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រហូតសម្រេចបានលទ្ធផលល្អប្រសើរ។ សមិទ្ធផលទាំងនេះ គូសបញ្ជាក់យ៉ាងច្បាស់ពីកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា។ ឆ្លៀតក្នុងឱកាសនេះផងដែរ, ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់សហគមន៍អ៊ឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, មូលនិធិរូបិយវត្ថុអន្តរជាតិ, អង្គការយូនីសែហ្វ, រដ្ឋាភិបាលបារាំង/AFD, រដ្ឋាភិបាលអូស្ត្រាលី, និងស្ថាប័នអន្តរជាតិផ្សេងទៀត ដែលបាន និងគ្រោងបន្តផ្តល់ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់-

កាលទី ៣ នេះ ឱ្យប្រព្រឹត្តទៅដោយរលូន និងមានសន្ទុះល្អទៅមុខ ហើយខ្ញុំរំពឹងទុកចំពោះស្មារតីសហការបែបនេះ ក្នុងដំណាក់កាលទី៤ បន្តទៀត៕

ថ្ងៃសុក្រ ៤រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ មីនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ចក្ខុវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយមរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺដើម្បីកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របតាមឧត្តមានុវត្តន៍ និងស្តង់ដាអន្តរជាតិ សំដៅផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ។ ក្នុងដំណើរឆ្ពោះទៅរកចក្ខុវិស័យនេះ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) បានរៀបចំ និងដាក់ឱ្យអនុវត្តផែនការសកម្មភាពរួម និងពិសេសផែនការសកម្មភាពប្រចាំឆ្នាំ ដែលបូកសរុបពីគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត និងក្រសួង ស្ថាប័ន អនុលោមតាមសារាចររបស់រាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងស្មារតីនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ដែលជាសេនាធិការជូន គ.ហ.ស. រៀបចំរបាយការណ៍ត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅគ្រប់ដំណាក់កាល។ សម្រាប់របាយការណ៍ប្រចាំឆ្នាំ ២០២២ គឺមិនត្រឹមតែជាការតាមដានការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការវាយតម្លៃរួមលើការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី ៣ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” ដែលបានបិទបញ្ចប់ក្នុងឆ្នាំ២០២២ ហើយក៏ជាមូលដ្ឋានឈានឆ្ពោះទៅអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ “**គណនេយ្យភាពសមិទ្ធកម្ម**”។ របាយការណ៍នេះ ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រមួយចំនួន ជាអាទិ៍÷ (ទី១) តាមដានវឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស ក្នុងឆ្នាំ២០២២, ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ និងការប្រមូលធាតុចូលពីសិក្ខាសាលាផ្សព្វផ្សាយនានា ក្នុងនោះរួមមាន បច្ចុប្បន្នភាពផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (ហៅកាត់ថា PEFA) ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ថវិកាយេនឌ័រ និង ការវាយតម្លៃចំណាយសាធារណៈ (ហៅកាត់ថា PER)។ (ទី២) ការប្រមូលព័ត៌មានបន្ថែមនៅរដ្ឋបាលខេត្តចំនួន ៥ ជាអាទិ៍ ខេត្តព្រះសីហនុ, ខេត្តកំពង់ស្ពឺ, ខេត្តកណ្តាល, ខេត្តព្រៃវែង និងខេត្តមណ្ឌលគិរី ព្រមទាំងក្រសួងចំនួន ៥ ជាអាទិ៍ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, និងក្រសួងពាណិជ្ជកម្ម។ (ទី៣) កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ លើការត្រួតពិនិត្យប្រសិទ្ធភាពនៃ ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ហៅកាត់ថា FMIS) ក្រោមជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិ និងការត្រួតពិនិត្យចំណាយសាធារណៈ ក្រោមជំនួយបច្ចេកទេសពីធនាគារពិភពលោក។ និង (ទី៤) ការរៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេសជាបន្តបន្ទាប់ ជាមួយតួអង្គពាក់ព័ន្ធ រួមមាន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត, ក្រសួង ស្ថាប័ន និងបណ្តាដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មានឱ្យកាន់តែមានសង្គតិភាព និងធានាបាននូវភាពគ្រប់ជ្រុងជ្រោយ។

ផ្អែកលើការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣, យើងអាចទាញការសន្និដ្ឋានជារួម ដូចតទៅ÷

ទី១) **ភាពជឿទុកចិត្តនៃថវិកា** នៅតែរក្សាបាននូវស្ថានភាពរឹងមាំ ដែលបានបន្តក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ចដែលស្ថិតក្នុងទស្សនវិស័យសុទិដ្ឋិនិយម ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ មានភាពធូរស្បើយ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តធ្វើពិពិធកម្មចំណូលបន្ថែម និងពង្រឹងការកៀរគរចំណូលឱ្យអស់សក្តានុពល ទន្ទឹមនឹងត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តចំណាយ ពិសេសរំហូរចំណាយតាមត្រីមាស។

ទី២) **បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពហិរញ្ញវត្ថុ** ត្រូវបានកសាង និងពង្រឹងបន្ថែម ដែលឆ្លុះបញ្ចាំងតាមរយៈការពង្រីកការដ្ឋាន និងពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទី៣) **ក្របខ័ណ្ឌថវិកាកម្មវិធី** ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្តទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ទី៤) **បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពសមិទ្ធកម្ម** ត្រូវបាននិងកំពុងរៀបចំបញ្ចប់ ដែលឆ្លុះបញ្ចាំងតាមរយៈការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសេចក្តីព្រាងអនុក្រឹត្យលេខ ៨១ និង ៨២ ដែលរំពឹងថានឹងត្រូវចូលជាធរមានក្នុងឆមាសទី១ ឆ្នាំ២០២៣។ ទន្ទឹមនេះ ត្រូវបន្តយកចិត្តទុកដាក់លើការពង្រឹងការអនុវត្តក្របខ័ណ្ឌតាមដាន និងវាយតម្លៃ និងការអនុវត្តសវនកម្មសមិទ្ធកម្ម និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅតាមក្រសួង ស្ថាប័ន។

ទី៥) **ចលនការនៃការកែទម្រង់** ត្រូវបានបន្តចីរភាព ដែលឆ្លុះបញ្ចាំងតាមរយៈការចូលរួមអនុវត្តអនុវត្តកម្មវិធីកែទម្រង់ពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។

ដោយឡែក របកគំហើញនៃរបាយការណ៍វាយតម្លៃលើប្រសិទ្ធភាពប្រព័ន្ធ និងថវិកា តាមរយៈការប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ (PER) និងការត្រួតពិនិត្យការអនុវត្តប្រព័ន្ធ FMIS ដោយកិច្ចសហប្រតិបត្តិការជាមួយគ្រប់តួអង្គពាក់ព័ន្ធ ដែល អ.គ.ហ. សម្របសម្រួលលើកិច្ចដំណើរការ បានបង្ហាញនូវលទ្ធផលប្រហាក់ប្រហែលគ្នាជាមួយការវាយតម្លៃ PEFA ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការវិភាគកម្រិតគោលនយោបាយ ដែលអាចទាញការសន្និដ្ឋានចំនួន ៤ ចំណុច ដូចតទៅ÷

ទី១) ប្រសិទ្ធភាពចំណាយ, លំហថវិកា, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, មុខងារប្រព័ន្ធ FMIS និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ចាំបាច់ត្រូវបន្តយកចិត្តទុកដាក់។

ទី២) ការវាយតម្លៃថវិកាយេនឌ័របានផ្តល់ជាបន្ទាត់មូលដ្ឋាន សម្រាប់ជំរុញសមភាពយេនឌ័រ ក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំថវិកាប្រចាំឆ្នាំ។

ទី៣) តួនាទីរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ កាន់តែសំខាន់ ក្នុងការរួមចំណែកអនុវត្តវិធានការក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ និង

ទី៤) ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ស្ថិតនៅលើវិថីកែទម្រង់ត្រឹមត្រូវ និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការឈានទៅអនុវត្តថវិកាព័តិមានសមិទ្ធកម្ម ដែលនឹងរួមចំណែកដល់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

ជាមួយនឹងវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ, របាយការណ៍នេះ បានក្លាយជារបាយការណ៍រួមរបស់គ្រប់តួអង្គដែលមានការពាក់ព័ន្ធក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ខ្ញុំរំពឹងថា របាយការណ៍ប្រចាំឆ្នាំ២០២២ នេះ នឹងក្លាយជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងនៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាយថាហេតុរដ្ឋបាលរាជធានី ខេត្ត ដែលនឹងចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ជាមូលដ្ឋានរៀបចំ និងកែសម្រួលផែនការសកម្មភាពរបស់ខ្លួន ឱ្យកាន់តែមានគុណភាព ស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួម តាមដំណាក់-កាល នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាទីបញ្ចប់, ក្នុងនាម អ.គ.ហ. និង រូបខ្ញុំផ្ទាល់ សូមសម្តែងការដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន គ.ហ.ស. ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ និងផ្តល់អនុសាសន៍ណែនាំដ៏មានតម្លៃ និងតម្រង់ទិសទាំងការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចជោគជ័យ និងប្រកដោយចីរភាព។ ជាមួយគ្នានេះ, ខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត និងក្រសួង ស្ថាប័ន ដែលបានចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដៃគូអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ដើម្បីរួមចំណែកទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ គាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីដំណាក់-កាលទី១ រហូតមកដល់ពេលបច្ចុប្បន្ន៕

ថ្ងៃចន្ទ ៧ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកានុក្រម


**បុព្វកថា** ........................................ i

**អារម្ភកថា** ........................................ iv

**សេចក្តីសង្ខេបប្រតិបត្តិ** ........................................ xii

**១. សេចក្តីផ្តើម** ........................................ 1

**១.១. ទិដ្ឋភាពទូទៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ........................................ 1

**១.២. ស្ថានភាពសេដ្ឋកិច្ច** ........................................ 2

**១.៣. ស្ថានភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ........................................ 4

**១.៤. សនិទានកម្ម និងគោលបំណង** ........................................ 6

**២. លទ្ធផលវាយតម្លៃកម្មវិធីកែទម្រង់ និងវឌ្ឍនភាពប្រចាំឆ្នាំ២០២២** ........................................ 8

**២.១. ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២** ........................................ 8

ផ្នែកទី១ ÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ........................................ 8

ផ្នែកទី២ ÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ........................................ 12

ផ្នែកទី៣ ÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ........................................ 18

ផ្នែកទី៤ ÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម ........................................ 22

ផ្នែកទី៥ ÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ........................................ 26

**២.២. វឌ្ឍនភាពតាមអង្គភាពក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន** ........................................ 29

២.២.១. វឌ្ឍនភាពនៃការអនុវត្តតាមអង្គភាពក្រោមឱវាទ កសហវ. ........................................ 29

២.២.២. វឌ្ឍនភាពនៃការអនុវត្តតាមក្រសួង ស្ថាប័ន ........................................ 35

**២.៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ** ........................................ 41

២.៣.១. ការអនុវត្តប្រព័ន្ធ FMIS ........................................ 41

២.៣.២. ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ........................................ 43

២.៣.៣. ការវាយតម្លៃថវិកាយេនឌ័រ ........................................ 45

២.៣.៤. ការវាយតម្លៃចំណាយសាធារណៈ ........................................ 46

២.៣.៥. មតិរបស់ អ.គ.ហ. លើរបកគំហើញនៃរបាយការណ៍វាយតម្លៃ ........................................ 65

**២.៤ ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ........................................ 66

២.៤.១. ការវាយតម្លៃ PEFA ថ្នាក់ជាតិឆ្នាំ២០២១ ........................................ 66

២.៤.២. ការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិឆ្នាំ២០២១ ........................................ 69

**៣. បញ្ហាប្រឈម និងវិធានការដោះស្រាយ** ........................................ 74

**៤. សន្និដ្ឋាន** ........................................ 80

**ឧបសម្ព័ន្ធ** ........................................ 82

ឧបសម្ព័ន្ធទី ១ ÷ វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. ប្រចាំឆ្នាំ២០២២............................83
ឧបសម្ព័ន្ធទី ២ ÷តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់អង្គភាពក្រោមឱវាទ កសហវ. ប្រចាំឆ្នាំ២០២២........92
ឧបសម្ព័ន្ធទី ៣ ÷តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់មន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំឆ្នាំ២០២២...........94
ឧបសម្ព័ន្ធទី ៤ ÷ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់ក្រសួង ស្ថាប័ន ប្រចាំឆ្នាំ២០២២..........................97
ឧបសម្ព័ន្ធទី ៥ ÷ តារាងសង្ខេបវឌ្ឍនភាពប្រចាំឆ្នាំ២០២២ (ទម្រង់ CAP3+2).................................... 101
ឧបសម្ព័ន្ធទី ៦ ÷ បទបង្ហាញស្ដីពីរបាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសទី ៤ និងឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាព នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់កិច្ចប្រជុំ គ.ក.ហ. នៃ កសហវ... 174
ឧបសម្ព័ន្ធទី ៧ ÷ បទបង្ហាញស្ដីពីរបាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសទី៤ និងឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២ (ភាសាខ្មែរ) ........................................................................ 205
ឧបសម្ព័ន្ធទី ៨ ÷ ការឆ្លើយតបទៅនឹងមតិយោបល់របស់ដៃគូអភិវឌ្ឍន៍ (ភាសាខ្មែរ) .............................. 231
ឧបសម្ព័ន្ធទី ៩ ÷បទបង្ហាញស្ដីពីរបាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសទី៤ និងឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២ (ភាសាអង់គ្លេស) ..................................................................... 253
ឧបសម្ព័ន្ធទី ១០ ÷ ការឆ្លើយតបទៅនឹងមតិយោបល់របស់ដៃគូអភិវឌ្ឍន៍ (ភាសាអង់គ្លេស) ........................ 279
ឧបសម្ព័ន្ធទី ១១ ÷ របាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ភាសាអង់គ្លេស) ......................................... 293

# អក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | French Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| BSP | Budget Strategic Plan | ផែនការយុទ្ធសាស្ត្រថវិកា (ផ.យ.ថ) |
| BSRS | Budget System Reform Strategy | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា |
| CAP | Consolidated Action Plan | ផែនការសកម្មភាពរួម |
| CoA | Chart of Accounts | ប្លង់គណនេយ្យ |
| DMFAS | Debt management and financial analysis system | ប្រព័ន្ធវិភាគហិរញ្ញវត្ថុ និងគ្រប់គ្រងបំណុល |
| EFI | Economics and Finance Institute | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វ.ស.ហ.) |
| EFMS | Education Financial Management System | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |
| FMIS | Financial Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| FMWG | FMIS project Management Working Group | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា (អ.ថ.) |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អ.គ.រ.) |
| GDIA | General Department of Internal Audit | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (អ.ស.ក.) |
| GDICDM | General Department of International Cooperation and Debt Management | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ (អ.រ.ជ.) |
| GDP | General Department of Policy<br>Gross Domestic Product | អគ្គនាយកដ្ឋានគោលនយោបាយ (អ.គ.ប.)<br>ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| GDPP | General Department of Public Procurement | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (អ.ល.ស.) |
| GDSNAF | General Department of Sub-National Administration Finance | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ (អ.ហ.ថ.) |
| GDSPNR | General Department of State Property and Non-Tax Revenue | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) |
| GFS | Government Financial Statistics | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល |
| GSC | General Secretariat of Public Financial Management Reform Steering Committee | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| LCs | Legal Council Secretariate | លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម (ល.ក.ន.) |

| | | |
|---|---|---|
| LM | Line ministry | ក្រសួង ស្ថាប័ន |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) |
| MOEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MTBF | Medium-Term Budget Framework | ក្របខ័ណ្ឌថវិការយៈពេលមធ្យម |
| MTFF | Medium-Term Fiscal Framework | ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម |
| NAA | National Audit Authority | អាជ្ញាធរសវនកម្មជាតិ (អ.ស.ជ.) |
| NRMIS | Non-tax Revenue Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PB | Program Budgeting | ថវិកាកម្មវិធី |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFMRC | Public Financial Management Reform Commission | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ក.ហ.ស.) |
| PFMSC | Public Financial Management Reform Steering Committee | គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PPCA | Phnom Penh Capital Administration | រដ្ឋបាលរាជធានីភ្នំពេញ |
| PPCC | Phnom Penh Capital Council | ក្រុមប្រឹក្សារាជធានីភ្នំពេញ |
| SARMIS | State Asset Register Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ |
| WB | World Bank | ធនាគារពិភពលោក |

## បញ្ជីតារាង

តារាងទី 1 ÷ ការប្រែប្រួលក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី២, ៣ និង ៣បូក២ ..... 2
តារាងទី 2 ÷ សូចនាករសេដ្ឋកិច្ច ឆ្នាំ២០១៩-២០២៣ ..... 3
តារាងទី 3 ÷ វឌ្ឍនភាពតាមក្រសួង ស្ថាប័ន..... 35
តារាងទី 4 ÷ បម្រែបម្រួលពិន្ទុ PEFA ឆ្នាំ២០២១ ធៀបទៅនឹងឆ្នាំ២០១៥ និងឆ្នាំ២០១០ ..... 67

## បញ្ជីដ្យាក្រាម

ដ្យាក្រាមទី 1 ÷ ការអនុវត្តការប្រមូលចំណូល ឆ្នាំ២០១៣-២០២២..... 5
ដ្យាក្រាមទី 2 ÷ កំណើនចំណូលចរន្តគិតពិន្ទុភាគរយ នៃ ផសស. ឆ្នាំ២០១៣-២០២២។..... 5
ដ្យាក្រាមទី 3 ÷ ការអនុវត្តថវិការដ្ឋ ឆ្នាំ២០១៣-២០២២ ..... 6
ដ្យាក្រាមទី 4 ÷ រំហូរការអនុវត្តថវិការដ្ឋប្រចាំត្រីមាស ឆ្នាំ២០១៣-២០២២..... 6

ដ្យាក្រាមទី 5÷ ការអនុវត្តថវិកា និង វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ..... 29
ដ្យាក្រាមទី 6÷ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់មន្ទីរ សហវ. រាជធានី ខេត្ត..... 31
ដ្យាក្រាមទី 7÷ ការអនុវត្តថវិកា និង វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត..... 34
ដ្យាក្រាមទី 8÷ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់មន្ទីរ សហវ. រាជធានី ខេត្ត..... 40
ដ្យាក្រាមទី 9÷ ចំណាយលើវិស័យសុខាភិបាល (ធៀបនឹង ផសស.) ..... 55
ដ្យាក្រាមទី 10÷ ចំណាយរបស់ក្រសួងសុខាភិបាល (ថ្លៃបច្ចុប្បន្ន) តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ឯកតា÷លានរៀល)..... 55
ដ្យាក្រាមទី 11÷ ចំណាយបន្ទុកបុគ្គលិករបស់ក្រសួងសុខាភិបាល (២០១៧-២០២១) និងបៀវត្សបុគ្គលិកសុខាភិបាល ..... 56
ដ្យាក្រាមទី 12÷ ថវិកាផ្អែកលើកម្មវិធី (%នៃចំណាយចរន្តសរុប)..... 56
ដ្យាក្រាមទី 13÷ ថវិកាផ្អែកលើកម្មវិធី ឆ្នាំ២០១៧-២០២២..... 57
ដ្យាក្រាមទី 14÷ បម្រែបម្រួលពិន្ទុសូចនាករ ឆ្នាំ២០១០ ឆ្នាំ២០១៥ និងឆ្នាំ២០២១..... 68
ដ្យាក្រាមទី 15÷ ការងារគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា ដោយធៀបនឹងស្តង់ដា PEFA ..... 69
ដ្យាក្រាមទី 16÷ សង្ខេបពិន្ទុនៃប្រព័ន្ធ PFM នៃរដ្ឋបាលរាជធានីភ្នំពេញ ..... 72
ដ្យាក្រាមទី 17÷ ការងារគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា..... 73

១. បទពិសោធន៍ជាអន្តរជាតិ និងរបស់កម្ពុជាខ្លួនឯងផ្ទាល់ក្នុងរយៈពេលជិត ២ ទសវត្សរ៍ បានបង្ហាញថា ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ, ធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, កាត់បន្ថយភាពក្រីក្រ និងជាពិសេសលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈជូនប្រជាពលរដ្ឋ។

២. រាជរដ្ឋាភិបាលនីតិកាល ទី៦ នៃរដ្ឋសភាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អាទិភាព និងចាត់ទុកភាពរឹងមាំ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាឆ្អឹងខ្នងនៃការអនុវត្តរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយជវភាព បរិយាប័ន្ន ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព ឆ្លើយតបទៅនឹងការវិវឌ្ឍសង្គម-សេដ្ឋកិច្ច និងការប្រែប្រួលនៃសកលលោក។

៣. ជាមួយវឌ្ឍនភាពជិត ២ ទសវត្សរ៍នេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងកសាង និងពង្រឹងមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈ“**ការកសាង និងកែលម្អប្រព័ន្ធ÷ អភិបាលកិច្ច, ក្របខ័ណ្ឌគតិយុត្ត, ស្ថាប័នីយកម្ម និងធនធានមនុស្ស**”។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខឿនទី ៣ និងដំណាក់កាលទី៣ ដែលមានរយៈពេល ៧ ឆ្នាំ (ឆ្នាំ២០១៦-២០២២) សម្រេចបានជាសារវ័ន្ត តាមរយៈការរៀបចំលំក្ខខ័ណ្ឌចាំបាច់នានា (រួមមាន ការកសាងប្រព័ន្ធ, យន្តការស្ថាប័ន, លិខិតបទដ្ឋានគតិយុត្ត, និងការអភិវឌ្ឍធនធានមនុស្ស) សម្រាប់អនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង និងបញ្ជ្រាប “**វប្បធម៌សមិទ្ធកម្ម**” នៅក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល និងទូទាំងមន្ត្រីរាជការ។ រាជរដ្ឋាភិបាលបានបន្តបោះជំហានទៅអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ “**គណនេយ្យភាពសមិទ្ធកម្ម**” ប្រកបដោយភាពស្វាហាប់ មានទំនុកចិត្ត ជាមួយនឹងការប្រកាន់ខ្ជាប់នូវអភិក្រមឆ្លងស៊ីងស្ថាបថ្ម។

## ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២

- **ផ្នែកទី១ “ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា”**

៤. គិតត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៣, ក្នុងក្របខ័ណ្ឌថវិកាឆ្នាំ២០២២, ចំណូលថវិកាជាតិ (ចំណូលចរន្ត និងចំណូលមូលធនក្នុងប្រទេស) នៅតែរក្សាបាននូវស្ថានភាពរឹងមាំ ដោយប្រមូលបាន ២៦ ៨៥៧ ប៊ីលានរៀល (១០៦,១% ធៀបនឹងច្បាប់ថវិកា) ក្នុងនោះចំណូលពន្ធគយ និងរដ្ឋាករ ប្រមូលបាន ១០ ៩៦៤ ប៊ីលានរៀល (១០៥,៤% ធៀបនឹងច្បាប់ថវិកា), ចំណូលពន្ធដារ ប្រមូលបាន ១១ ៥២៥ ប៊ីលានរៀល (១១៧,៣% ធៀបនឹងច្បាប់ថវិកា), ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិ ប្រមូលបាន ២ ០៧១ ប៊ីលានរៀល (១០៧,៣% ធៀបនឹងច្បាប់ថវិកា), និងចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី ខេត្ត) ប្រមូលបាន ២ ០៤៩ ប៊ីលានរៀល (១១១,១% ធៀបនឹងច្បាប់)

៥. ចំណាយថវិកាជាតិសរុប គិតត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៣ សម្រេចបាន ២៣ ៤៧៥ ប៊ីលានរៀល (៨១,៦៩% ធៀបនឹងច្បាប់) ក្នុងនោះចំណាយបៀវត្សរ៍សម្រេចបាន ៩ ០៥០ ប៊ីលានរៀល (៩៦,២៣% ធៀបនឹងច្បាប់), ចំណាយទំនិញ-សេវាសម្រេចបាន ៣ ៨៩៣ ប៊ីលានរៀល (៨៣,៧៧% ធៀបនឹងច្បាប់), និងចំណាយមូលធន

សម្រេចបាន ៦ ៣០៤ ប៊ីលានរៀល (៧៤,៥៣ % ធៀបនឹងច្បាប់)។ ក្រឡេកទៅមើលចំណាយតាមត្រីមាស, ចំណាយប្រចាំត្រីមាសទី ៣ នៅមានកម្រិតទាប ពោលគឺសម្រេចបានត្រឹមតែ ៥៨,៦៤% ខណៈគោលដៅដែលបានដាក់ចេញត្រូវសម្រេចឱ្យបាន ៧០%។ ក្នុងន័យនេះ វិហ្វរ និងប្រសិទ្ធភាពចំណាយថវិកាត្រូវបន្តយកចិត្តទុកដាក់បន្ថែម។ ចំពោះកិច្ចលទ្ធកម្ម ពិនិត្យឃើញថាមានវឌ្ឍនភាពល្អប្រសើរ ចំពោះការអនុម័តផែនការលទ្ធកម្មមុនឆ្នាំអនុវត្តថវិកា ពោលគឺអនុម័តបាន៩៦% (១១០/១១៥) ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ប៉ុន្តែការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្មលើថវិកាចរន្ត និងមូលធន ក្នុងឆ្នាំ២០២១ អនុវត្តបានត្រឹម ៥៦% ប៉ុណ្ណោះ ដែលថយចុះប្រមាណ ៥% ធៀបទៅនឹងឆ្នាំ២០២០ (៦១%)។ កិច្ចការនេះ ត្រូវបន្តយកចិត្តទុកដាក់ដើម្បីធានាបាននូវគណនេយ្យភាព និងតម្លាភាព ពិសេសធានាបាននូវតម្លៃនៃលុយ។

- **ផ្នែកទី២ “ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ”**

៦. គម្រោង FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជំហានទី១ នៅឆ្នាំ២០១៤ និងជំហានទី២ នៅឆ្នាំ២០១៧។ មុខងារស្នូល និងចំណាត់ថ្នាក់ថវិកាត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ជាបន្តបន្ទាប់ស្របតាមជំហានយុទ្ធសាស្ត្រនៃប្រព័ន្ធ។ គ្រប់ក្រសួង ស្ថាប័ន, រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត, រតនាគាររាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្តទាំង២៥ បានប្រើប្រាស់ FMIS ជាផ្លូវការ។ មុខងារថ្មីចំនួនពីរ រួមមាន មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ ដែលត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២១ បានបន្តដាក់ឱ្យអនុវត្តនៅតាមក្រសួង ស្ថាប័ន ក្នុងនោះមុខងាររៀបចំផែនការថវិកាបានដាក់ឱ្យអនុវត្តនៅក្រសួង ស្ថាប័នចំនួន ១១ បន្ថែម (សរុបទាំងអស់ ១៣ ក្រសួង ស្ថាប័ន) និងមុខងារលទ្ធកម្មពេញលេញ ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន។

៧. នីតិវិធីចំណាយថវិកាចន្តលើគ្រប់មុខសញ្ញា តាមប្រព័ន្ធ FMIS ទាំងស្រុង ត្រូវបានដាក់ឱ្យអនុវត្តនៅ កសហវ. និងក្រសួងបរិស្ថាន ខណៈនីតិវិធីចំណាយបៀវត្សរ៍ និងនីតិធីចំណាយទូទាត់ត្រង់តាមប្រព័ន្ធ FMIS ទាំងស្រុង ត្រូវបានដាក់ឱ្យអនុវត្តនៅក្រសួង ស្ថាប័នចំនួន ៣៤។[1] ទន្ទឹមនេះ រដ្ឋបាលស្រុកចំនួន ៧៥ និងរដ្ឋបាលឃុំចំនួន ១៨៥ បានប្រើប្រាស់សាកល្បងប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ជាផ្លូវការ។ បន្ថែមពីនេះ ប្រព័ន្ធ FMIS ត្រូវបានធ្វើសន្ធានកម្មជាមួយប្រព័ន្ធខាងក្រៅ និងធនាគារពាណិជ្ជនានា ដើម្បីទទួលបាននូវព័ត៌មាន ឬទិន្នន័យពេញលេញ និងទាន់ពេលវេលា។ ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (EFT) នៅថ្នាក់កណ្ដាល និងនៅថ្នាក់មូលដ្ឋាន បានជួយសម្រួលដល់ការទូទាត់ទៅអ្នកផ្គត់ផ្គត់បានឆាប់រហ័ស និងទាន់ពេលវេលា។ ការបន្តជំរុញការអនុវត្តនីតិវិធីថ្មី តាមប្រព័ន្ធ FMIS ទាំងស្រុង អាចសម្រេចបានជោគជ័យពេញលេញទៅតាមផែនការ តម្រូវឱ្យមានចូលរួមកាន់តែខ្លាំងឡើង និងការគាំទ្រទាំងកម្រិតបច្ចេកទេស និងនយោបាយ ពីគ្រប់ភាគីពាក់ព័ន្ធទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ និន្នាការនេះ ឬឌីជីថលូបនីយកម្ម តម្រូវឱ្យមានការគិតគូរអំពីហត្ថលេខាអេឡិចត្រូនិក និងគោលនយោបាយឌីជីថល។

[1] ស្ថាប័នចំនួន ៣ រួមមាន÷ រដ្ឋសភា ព្រឹទ្ធសភា និង ក្រុមប្រឹក្សាធម្មនុញ្ញ មាននីតិវិធីពិសេសដាច់ដោយឡែក ដែលពុំទាន់អាចអនុវត្តនីតិវិធីចំណាយបៀវត្សរ៍ និងនីតិធីចំណាយទូទាត់ត្រង់តាមប្រព័ន្ធ FMIS បាន។

៨. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ត្រូវបានបន្តដាក់ឱ្យអនុវត្តដល់កម្រិតរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការដាក់ឱ្យអនុវត្តប្រព័ន្ធ SARMIS បានជួយជំរុញឱ្យ ការរៀបចំបញ្ជីសារពើភណ្ឌក្នុងឆ្នាំ២០២១ កើនដល់ ៨៧% (២៦៤៣/៣០៥៣ អង្គភាពប្រើប្រាស់) និងរំពឹងថាមានការកើនឡើងបន្ថែមទៀតបន្ទាប់ពីដាក់ឱ្យអនុវត្តដល់រដ្ឋបាលឃុំ សង្កាត់។

៩. រីឯបំណុលសាធារណៈ ត្រូវបានវាស់វែងដោយសូចនាករគន្លឹះចំនួន ៥។ សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតាន (ឆ្នាំ២០២២ ប៉ាន់) ÷ តម្លៃបច្ចុប្បន្ននៃបំណុលសារធារណៈសរុប ២៥,២% ធៀបនឹង ផសស., តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ២៤,៩០% ធៀបនឹង ផសស. និង៣៣,៩០% ធៀបនឹងការនាំចេញ, សេវាបំណុលសាធារណៈក្រៅ ប្រទេស ២,១០% ធៀបនឹងការនាំចេញ និង ៧,៨% ធៀបនឹងចំណូលថវិកាជាតិ។

១០. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀត។ កិច្ចការនេះ នឹងត្រូវបានពង្រឹងជាបណ្ដើរៗ តាមរយៈការដាក់ឱ្យអនុវត្តលក្ខខណ្ឌវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងការដាក់ចេញនូវឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ដែលឯកសារយុទ្ធសាស្ត្រនេះ រំពឹងថាអាចដាក់ឱ្យអនុវត្ត ក្នុងឆ្នាំ២០២៣។

- **ផ្នែកទី៣ "ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"**

១១. ថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័នចាប់ពីឆ្នាំ២០១៥-២០១៨ និងគ្រប់រដ្ឋបាលរាជធានីខេត្ត ឆ្នាំ២០១៧-២០២១។ គិតត្រឹមឆ្នាំ២០២២ អង្គភាពថវិកាមានចំនួនសរុប ៩៤០ ដែលក្នុងនោះរដ្ឋបាលថ្នាក់កណ្ដាល មានចំនួន ៣៣៧ និងថ្នាក់មូលដ្ឋាន (មន្ទីរជំនាញរាជធានី ខេត្ត)ចំនួន ៦០៣។ សម្រាប់ថ្នាក់កណ្ដាលមានអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៨៧ និងមិនទាន់ផ្ទេរសិទ្ធិពេញលេញចំនួន ២៥០ និងសម្រាប់ថ្នាក់មូលដ្ឋាន គ្រប់អង្គភាពថវិកាទាំងអស់ ត្រូវបានផ្ទេរសិទ្ធិជាអាណាប័កផ្ទេរសិទ្ធិពេញលេញ។ គួរបញ្ជាក់ថា នៅឆ្នាំ២០២២ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញ កើនចំនួន ៩ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញកើនចំនួន ២៨។

១២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) ២០២៣-២០២៥ ត្រូវបានរៀបចំជាសេចក្ដីព្រាង ប៉ុន្តែពុំទាន់ត្រូវបានអនុវត្ត ដោយបន្តអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ថវិកាឆ្នាំ២០២៣ ដោយសារស្ថានភាពសេដ្ឋកិច្ចក្នុងវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ខណៈក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ត្រូវបានអនុវត្តសាកល្បងតាំងពីឆ្នាំ២០១៩ ដោយមានការកំណត់ពិតានថវិកាតាមវិស័យ និងតាមក្រសួង ស្ថាប័ន។ ទន្ទឹមនេះ គ្រប់ក្រសួង ស្ថាប័នក៏បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយមានសូចនាករសមិទ្ធកម្មគន្លឹះ។ គម្លាតរវាងពិតានចំណាយគោលដែលកំណត់ក្នុងសារាចរស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងលទ្ធផលកញ្ចប់ថវិកាប្រចាំឆ្នាំទាបជាង ១៥%។

១៣. ដោយឡែក ចំពោះ MTBF ២០២៣-២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ ប៉ុន្តែពុំទាន់ត្រូវបានដាក់ឱ្យអនុវត្តនៅឡើយ។ ការដាក់ឱ្យអនុវត្ត MTBF នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងជួយពង្រឹងដំណើរការនៃការរៀបចំគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត។ មួយវិញទៀត សមាហរណកម្ម BSP រដ្ឋបាល

រាជធានី ខេត្ត រវាងរដ្ឋបាលរាជធានី ខេត្តជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ នៅគ្រប់រាជធានី ខេត្ត ហើយនិងការតម្រឹមផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រវាងរដ្ឋបាលរាជធានី ខេត្ត ជាមួយនឹងថវិកាមន្ទីរជំនាញ ក៏កំពុងមានវឌ្ឍនភាព ប៉ុន្តែគុណភាពចាំបាច់ត្រូវបន្តយកចិត្តទុកដាក់។

- **ផ្នែកទី៤ "ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម"**

១៤. បទដ្ឋានគតិយុត្តដែលជាមូលដ្ឋានឈានទៅអនុវត្តដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ត្រូវបាន និងកំពុងរៀបចំ និងឈានទៅបញ្ចប់ក្នុងកំឡុងឆមាសទី១ ឆ្នាំ២០២៣។ សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ថ្មី) ត្រូវបានពិនិត្យនិងសម្រេចដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៣ និងត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០២៣ និងបានផ្តល់យោបល់ឯកភាព ដោយព្រឹទ្ធសភាកាលពីថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២៣។ រីឯការកែសម្រួលអនុក្រឹត្យលេខ៨១ អនក្រ.បក និងអនុក្រឹត្យលេខ៨២ អនក្រ.បក ត្រូវបានដាក់បញ្ចូលគ្នា និងកំណត់ឈ្មោះថ្មីជាសេចក្តីព្រាងអនុក្រឹត្យស្តីពី "**ការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ**" ដែលរំពឹងថានឹងត្រូវបញ្ចប់នៅក្នុងកំឡុងឆមាសទី១ ឆ្នាំ២០២៣ នេះ ផងដែរ។

១៥. ទន្ទឹមនេះ កិច្ចព្រមព្រៀងលទ្ធផលក្នុងឆ្នាំរវាង កសហវ. និងក្រសួង ស្ថាប័នចំនួន ៧ ជាអាទិ៍ កសហវ., ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, និងក្រសួងយុត្តិធម៌ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងសម្រាប់ថវិកាឆ្នាំ២០២៣។ ការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងលទ្ធផលក្នុងឆ្នាំនេះ គឺជាចំណុចចាប់ផ្តើម នៃការឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម។ ដោយឡែក ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ និងមុខងារសវនកម្មផ្ទៃក្នុងដែលផ្តោតលើសវនកម្មសមិទ្ធកម្មនិងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងមុខងារអធិការកិច្ច នៅគ្រប់ក្រសួង ស្ថាប័ន ត្រូវពង្រឹងបន្ថែមជាបណ្តើរៗ ដើម្បីធានាថាក្រសួង ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យតាមដានរឹងមាំ ស្របពេលរាជរដ្ឋាភិបាល បាននិងកំពុងធ្វើវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នកាន់តែច្រើន។

១៦. ទោះជាយ៉ាងនេះក្តី ការរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅមានវឌ្ឍនភាពយឺតយ៉ាវ។ ការដាក់ចេញនូវក្របខ័ណ្ឌនិងវិធាននេះ នឹងជួយដោះស្រាយដល់ការស្ទួនមុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច។

- **ផ្នែកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព"**

១៧. ការលើកកម្ពស់ការចូលរួមកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលឆ្លុះបញ្ចាំងតាមរយៈការរៀបចំផែនការសកម្មភាពលម្អិត (GDAP3/PADAP3/MAP3) និងរាយការណ៍អំពីវឌ្ឍនភាពជាប្រចាំ បង្ហាញអំពីឆន្ទៈការចូលរួម និងការទទួលខុសត្រូវក្នុងការងារកែទម្រង់។ លក្ខខ័ណ្ឌយោង តួនាទី ភារកិច្ច នៃសមាជិកក្រុមការងារកែទម្រង់តាមអង្គភាពក្រោមឱវាទ កសហវ រួមទាំមន្ទីរ សហវ. និងក្រសួង ស្ថាប័ន ត្រូវបានរៀបចំតាមយន្តការផ្តល់ប្រាក់ឧបត្ថម្ភ។ ប្រាក់ឧបត្ថម្ភលើកទឹកចិត្តត្រូវបានបើកផ្តល់ប្រមាណ ១៥ ៨៦១ លានរៀល ឬប្រមាណជិត ៤ លានដុល្លារអាម៉េរិក ជូនអង្គភាពក្រោមឱវាទ កសហវ. ចំនួន ៤៨៥ រូប, មន្ទីរ សហវ. រាជធានី ខេត្ត ចំនួន ៧៥ រូប, និងក្រសួង ស្ថាប័ន ចំនួន ៣៤៧។

១៨. ផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌ PFMRP ត្រូវបានរៀបចំ។ សមត្ថភាពជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិញ្ញាបនបត្រ។ ដោយឡែក ចំពោះការកែទម្រង់ក្របខ័ណ្ឌ PFMRP ត្រូវ ចំពោះការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹង PFMRP (ដំណាក់កាលទី៤) ផ្តោតលើការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ នៅពុំទាន់បានរៀបចំនៅឡើយ។ ចលនការឆ្ពោះទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម នឹងតម្រូវឱ្យស្ថាប័ននីតិប្បញ្ញត្តិផ្តោតលើព័ត៌មានសមិទ្ធកម្មច្រើនជាងការអនុវត្តបច្ចុប្បន្ន។

១៩. ការងារកែទម្រង់ប្រទាក់ក្រឡា ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១។

## ◆ របកគំហើញនៃរបាយការណ៍វាយតម្លៃ

២០. ដើម្បីឆ្លុះបញ្ចាំងគ្រប់ទិដ្ឋភាពនៃការកែទម្រង់ ដោយមានការអនុញ្ញាតពី គ.ហ.ស. លើការកែលម្អប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា, អ.គ.ហ. បានស្នើសហការជាមួយដៃគូអភិវឌ្ឍន៍ ជាអាទិ៍ មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក រៀបចំការវាយតម្លៃទៅលើទិដ្ឋភាពចំនួន ៣ រួមមាន÷ ការអនុវត្តប្រព័ន្ធ FMIS, ការវាយតម្លៃថវិកាយេនឌ័រ និងការវាយតម្លៃចំណាយសាធារណៈ។ ការវាយតម្លៃចំណាយសាធារណៈ ផ្តោតលើការពង្រឹងការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, វិស័យធនធានទឹក និងធារាសាស្ត្រ, វិស័យសុខាភិបាល, វិស័យកសិកម្ម និងរដ្ឋបាលថ្នាក់ក្រោមជាតិ(ជ្រើសរើសរដ្ឋបាលខេត្តព្រះសីហនុទាំងបីកម្រិតជាករណីសិក្សា)។ បន្ថែមពីនេះ សហភាពអឺរ៉ុបបានបន្ថែមធាតុចូលមួយចំនួន ពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ។

### - ការអនុវត្តប្រព័ន្ធ FMIS

២១. ចលនការឆ្ពោះទៅឌីជីថលូបនីយកម្ម មានតម្រូវការហត្ថលេខាឌីជីថល និងរៀបចំគោលនយោបាយឌីជីថល។ នៅក្នុងអន្តរកាលនេះ ជំហាននៃការអនុម័តចំណាយមួយចំនួនត្រូវបានលុបចេញ ប៉ុន្តែប្រព័ន្ធ FMIS ផ្តល់នូវជម្រើសសម្រាប់ការត្រួតពិនិត្យ (Review)។ ក្នុងន័យនេះ ឧបករណ៍តាមដាន (Dashboard) ការអនុវត្តចំណាយតាម FMIS នឹងបង្ហាញអំពីពេលវេលាសម្រាប់ការអនុម័តចំណាយ និងកន្លែងកកស្ទះ (blockages)។

២២. ក្រសួង ស្ថាប័ននៅប្រើប្រាស់ Excel សម្រាប់កត់ត្រាការអនុវត្តចំណាយ ដោយសារហេតុផលចម្បងគឺប្រតិបត្តិការចំណាយមួយចំនួនស្ថិតនៅក្រៅគណនីទោលរតនាគារ (TSA)។ IMF ផ្តល់អនុសាសន៍ពង្រីកវិសាលភាពប្រព័ន្ធ FMIS ដោយក្នុងនោះបូកបញ្ចូលទាំងគ្រប់ប្រភពមូលនិធិ ផងដែរ។ មួយវិញទៀត កសហវ. ស្នើក្រសួង ស្ថាប័នរៀបចំចុះហត្ថលេខា និងផ្ញើរបាយការណ៍ផ្អែកលើក្រដាស។ IMF ផ្តល់អនុសាសន៍ធ្វើឌីជីថលូបនីយកម្ម លើរបាយការណ៍នេះ មានន័យថា ត្រូវប្រើប្រាស់ក្នុងប្រព័ន្ធ FMIS តែម្តង។

២៣. ដោយឡែក Web-based Application ដែលត្រូវបានអភិវឌ្ឍ ត្រូវបានប្រើប្រាស់សម្រាប់អង្គភាពចំណាយចំពោះការគ្រោងវិហ្សសាច់ប្រាក់ (Cash flow)។ ប៉ុន្តែ ការអនុវត្តជាក់ស្តែង ក្រសួង ស្ថាប័នជាច្រើនមិនបានផ្តល់ការគ្រោងសាច់ប្រាក់តាមប្រព័ន្ធនេះទេ ឬ ទិន្នន័យមួយចំនួនមិនពេញលេញ។ ដូចនេះ ការព្យាករសាច់ប្រាក់ផ្អែកបឋមលើទិន្នន័យមុនៗ។ IMF ផ្តល់អនុសាសន៍ធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការ-

គ្រប់គ្រងសាច់ប្រាក់ (Cash Management Manual) និងផ្តល់ការបណ្តុះបណ្តាលជូនក្រសួង ស្ថាប័ន។ បន្ថែមពីនេះ IMF ផ្តល់អនុសាសន៍គួរមានការវាយតម្លៃអំពីតម្រូវការដែលប្រព័ន្ធ FMIS អាចគាំទ្រលើការគ្រប់គ្រងសាច់ប្រាក់។

- **សេចក្តីព្រាងនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ**

២៤. ការធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ជាជំហានមួយក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥ ដែលការធ្វើវិសោធនកម្ម មានជាប់ពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្រនេះ។ វិមជ្ឈការគឺជាសមាសធាតុសំខាន់មួយទាំងនៅក្នុងសេចក្តីព្រាងច្បាប់វិសោធនកម្ម និងយុទ្ធសាស្ត្រខាងលើ។ សិទ្ធិគ្រប់គ្រងនិងសម្រេចលើកិច្ចលទ្ធកម្ម នឹងត្រូវបានផ្តល់ជូនជាបណ្តើរៗដល់អង្គភាពអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ សេចក្តីព្រាងច្បាប់វិសោធនកម្ម រំលេចអំពីសិទ្ធិទូទៅសម្រាប់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ក្នុងការត្រួតពិនិត្យតាមក្រោយលើនីតិវិធីលទ្ធកម្មដែលបានបញ្ចប់។ វិសាលភាពនៃការចរចាជាមួយអ្នកដេញថ្លៃតែមួយ (single source procurement) នឹងត្រូវរឹតបណ្តឹង ដែលការណ៍នេះនឹងលើកកម្ពស់ដល់កិច្ចលទ្ធកម្មប្រកួតប្រជែង។ ចំពោះការប្រគល់ទទួលកិច្ចសន្យា, សេចក្តីព្រាងច្បាប់វិសោធនកម្មបង្កើតសិទ្ធិសម្រាប់ការប្រកួតប្រជែង។ អ្នកដេញថ្លៃដែលមិនបានជោគជ័យ អាចទាមទារការពន្យល់ពីអង្គភាពលទ្ធកម្ម អំពីមូលហេតុដែលអ្នកដេញថ្លៃទាំងនោះមិនទទួលបានជោគជ័យ។ បញ្ញត្តិពាក់ព័ន្ធនឹងលទ្ធកម្មប្រកបដោយចីរភាព ត្រូវបានបញ្ចូលជាមូលដ្ឋានសម្រាប់ការបង្កើតលក្ខខណ្ឌ និងគោលយោបាយដេញថ្លៃ (ឧទា. ការគាំពារសង្គម និងបរិស្ថាន)។ ជាចុងក្រោយ កិច្ចលទ្ធកម្មអេឡិចត្រូនិក ជាកម្មវត្ថុនៃបញ្ញត្តិដែលរំលេចអំពីសមាសធាតុសំខាន់ៗ ក្នុងការដាក់ឱ្យអនុវត្ត។

- **ការវាយតម្លៃថវិកាយេនឌ័រ**

២៥. ថវិកាយេនឌ័រ គឺជាអភិក្រមដែលប្រើប្រាស់គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការអភិវឌ្ឍកុមារី និងស្ត្រី។ លទ្ធផលនៃការវាយតម្លៃថវិកាយេនឌ័រ បង្ហាញថាកម្ពុជាមានសមាសធាតុមូលដ្ឋានសម្រាប់ថវិកាយេនឌ័រ ក្នុងនោះរួមមាន÷(១) មូលដ្ឋានគតិយុត្តសម្រាប់សមភាពយេនឌ័រ បានកំណត់ក្នុងច្បាប់រដ្ឋធម្មនុញ្ញ, (២) ការគាំទ្រផ្នែកនយោបាយកម្រិតខ្ពស់លើសមភាពយេនឌ័រ (៣) មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធនឹងយេនឌ័រ (៤) ការចូលរួមយ៉ាងសកម្មពីក្រសួងកិច្ចការនារី (៥) ការបញ្ជ្រាបយេនឌ័រ ត្រូវបានជ្រួតជ្រាបទូទាំងក្រសួង ស្ថាប័ន និងមានការយល់ដឹងអំពីបញ្ហាសមភាពយេនឌ័រ ជាពិសេសមានក្រុមការងារយេនឌ័រ (៦) មានក្របខ័ណ្ឌថវិកាសមិទ្ធកម្ម និងកម្មវិធី (៧) មានទិន្នន័យបែងចែកតាមយេនឌ័រ (ស្ត្រី និងបុរស) និង (៨) មានប្រព័ន្ធ FMIS សម្រាប់ការអនុវត្តថវិកា។

២៦. បន្ថែមពីនេះ របកគំហើញនៃការវាយតម្លៃបានផ្តល់អនុសាសន៍មួយចំនួនជាអាទិ៍÷ (១) ពង្រឹងក្របខ័ណ្ឌស្ថាប័ននិងគតិយុត្តសម្រាប់ថវិកាយេនឌ័រ ដោយរៀបចំមូលដ្ឋានគតិយុត្តអចិន្ត្រៃយ៍, កំណត់រចនាសម្ព័ន្ធស្ថាប័ន, កសហវ. ធ្វើសមាហរណកម្មទិដ្ឋភាពយេនឌ័រចូលក្នុងវដ្តថវិកា, និងពង្រឹងទំនាក់ទំនង និងការយល់ដឹងអំពីថវិកាយេនឌ័រ, (២) ដាក់ឱ្យអនុវត្តនូវឧបករណ៍គាំទ្រថវិកាយេនឌ័រ ផ្តោតលើការវិភាជ និងចំណាយថវិកា ដែលមានបច្ច័យដល់សមភាពយេនឌ័រ, រៀបចំ និងអនុវត្តការវាយតម្លៃបច្ច័យយេនឌ័រ, រៀបចំ និងផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ថវិកា

យេនឌ័រ និងធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំពាក់ព័ន្ធនឹងការរៀបចំថវិកា ដើម្បីឆ្លុះបញ្ចាំងអំពីឧបករណ៍យេនឌ័រ, (៣) សមាហរណកម្មឧបករណ៍ថវិកាយេនឌ័រទៅក្នុងដំណើរការរៀបចំថវិកា ដោយពង្រឹងការកំណត់អាទិភាពសម្រាប់ការរៀបចំគោលនយោបាយ និងការវិភាជធនធាន, កែលម្អក្របខ័ណ្ឌរបាយការណ៍, រៀបចំ និងអនុវត្តក្របខ័ណ្ឌសម្រាប់វាយតម្លៃកម្មវិធី, និងប្រើប្រាស់ប្រព័ន្ធ FMIS, និង (៤) ប្រើប្រាស់យន្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីគាំទ្រការអនុវត្តថវិកាយេនឌ័រ។

- **ការវាយតម្លៃចំណាយសាធារណៈ**

២៧. **ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Fiscal Mangement)**÷ ផ្អែកតាមការវាយតម្លៃ, របកគំហើញបានផ្ដល់អនុសាសន៍មួយចំនួន ជាអាទិ៍ (១) ចំណាយមូលធន និងបៀវត្សរ៍ត្រូវបានបង្កើនខ្លាំង ប៉ុន្តែត្រូវបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពចំណាយ, (២) កែលម្អគណនេយ្យភាព និងសមត្ថភាព ដើម្បីសម្រេចបានលទ្ធផលចុងក្រោយតាមវិស័យ។ ការណ៍នេះ គាំទ្រដល់ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (៣) គិតគូរអំពីបន្ទុកសារពើពន្ធ, និងពង្រីកមូលដ្ឋានពន្ធ (ពន្ធលើរូបវន្តបុគ្គល, ពន្ធលើចំណេញមូលធន, ពន្ធកាបូន និងពន្ធលើសេវាឌីជីថល), និង (៤) គិតគូរទទួលយកគោលនយោបាយហិរញ្ញវត្ថុសាធារណៈផ្អែកតាមគោលការណ៍អាកាសធាតុ ដែលជាផ្នែកនៃការលើកកម្ពស់ភាពធន់ និងលើកទឹកចិត្តការវិនិយោគឯកជន សម្រាប់គម្រោងប្រកបដោយចីរភាព។

២៨. **វិស័យធនធានទឹកនិងឧតុនិយម**÷ របកគំហើញពីការវាយតម្លៃបានផ្ដល់អនុសាសន៍មួយចំនួន ក្នុងនោះរួមមាន÷ ខាងផ្នែកវិភាជថវិកា, ការវិភាជថវិកាត្រូវអនុវត្តតាមអាទិភាពគោលនយោបាយ ដែលផ្សារភ្ជាប់ទៅនឹងកសិកម្ម, ការគ្រប់គ្រងទឹក និងបម្រែបម្រួលអាកាសធាតុ, លើកកម្ពស់សហថាមពល (Synergy) រវាងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងថវិកាជាតិ, ពង្រឹងការវិភាជថវិការវាងថ្នាក់កណ្ដាល មន្ទីរ និងរដ្ឋបាលថ្នាក់ក្រោមជាតិ, និងដោះស្រាយបញ្ហាពង្រាយបុគ្គលិករវាងថ្នាក់កណ្ដាល និងមន្ទីរ។ រីឯខាងផ្នែកប្រតិបត្តិការថវិកា, គួរមានការកែលម្អការវាយតម្លៃ និងជ្រើសរើសគម្រោង និងបង្កើនការប្រកួតប្រជែងកិច្ចលទ្ធកម្ម, គួរមានគោលការណ៍ណែនាំបច្ចេកទេសអំពីការស្ដារប្រព័ន្ធធារាសាស្ត្រ (ផ្សារភ្ជាប់ទៅនឹងប្រែប្រួលអាកាសធាតុ), ព្យាករណ៍ការជួសជុលការខូចខាត ដែលជួយកាត់បន្ថយការងារចំពោះកិច្ច, គិតគូរផ្ទេរថវិកាប្រតិបត្តិការ និងថែទាំ (O&M) ទៅមន្ទីរ (ហោចណាស់ ៣០%), រៀបចំគោលការណ៍ណែនាំច្បាស់លាស់អំពីរបៀបដែលគម្រោង O&M ត្រូវបានជ្រើសរើសសម្រាប់ផ្ដល់ហិរញ្ញប្បទាន, រៀបចំគោលការណ៍ណែនាំបច្ចេកទេសលើការងារ O&M, និងអនុវត្តមុខងារដែលបានផ្ទេរសម្រាប់គាំទ្រសហគមន៍អ្នកប្រើប្រាស់ទឹក។ បន្ថែមពីនេះ ខាងផ្នែកតួអង្គអនុវត្ត, ក្រសួងធនធានទឹកនិងឧតុនិយម គួរផ្ដោតលើការរៀបចំគោលការណ៍ណែនាំបច្ចេកទេស និងប្រព័ន្ធ M&E និងផ្ដោតតិចតួចលើការអនុវត្តជាក់ស្ដែង ខណៈមន្ទីរធនធានទឹក និងឧតុនិយមផ្ដោតលើការអនុវត្តជាក់ស្ដែង។

២៩. **វិស័យសុខាភិបាល**÷ ផ្អែកតាមការវាយតម្លៃបឋម, របកគំហើញបានផ្ដល់អនុសាសន៍មួយចំនួនជាអាទិ៍ កែលម្អការធ្វើសមាហរណកម្មទិន្នន័យចំណាយថ្នាក់ខេត្ត, ពង្រឹងការធ្វើសមាហរណកម្មចំណាយមូលធនហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, ពង្រឹងសង្គតិភាពសូចនាករនីមួយៗក្នុងផែនការយុទ្ធសាស្ត្រថវិកា, ពិនិត្យសូចនាករសមិទ្ធកម្ម,

ដាក់ឱ្យអនុវត្តជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្មនៅក្នុងសំណើថវិកា, តម្រឹមរចនាសម្ព័ន្ធថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា, និងវិភាជចំណាយបន្ទុកបុគ្គលិកតាមកម្មវិធីនីមួយៗ។

៣០. **វិស័យកសិកម្ម÷** របកគំហើញនៃការវាយតម្លៃ បានផ្តល់អនុសាសន៍មួយចំនួនជាអាទិ៍ ពង្រឹងការផ្សារភ្ជាប់ថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា, ពង្រឹងការចូលរួមរៀបចំផែនការថវិកាមូលធនពីក្រសួង ស្ថាប័ន ដោយធ្វើការសម្របសម្រួលជាមួយវិស័យពាក់ព័ន្ធ, ពង្រឹងការរៀបចំម៉ាទ្រីសសមិទ្ធកម្ម, ដាក់បញ្ចូលព័ត៌មានសមិទ្ធកម្មជាបណ្តើរៗ នៅក្នុងសំណើថវិកាប្រចាំឆ្នាំ, សម្រួលដំណើរការអនុវត្តថវិកា និងនីតិវិធីនិយ័តថវិកា, និងពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្ម។

៣១. **រដ្ឋបាលខេត្តព្រះសីហនុ÷** នៅថ្នាក់ខេត្ត, គួរពង្រឹងសមត្ថភាពធ្វើផែនការ (ថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា), កែលម្អសមត្ថភាពព្យាករចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ, ពង្រឹងភាពច្បាស់លាស់នៃមុខងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ពិសេសលើការកសាងហេដ្ឋារចនាសម្ព័ន្ធ និងយន្តការការងារជាមួយវិស័យឯកជន, ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, និងកែលម្អដំណើរការអនុវត្តថវិកា។ នៅថ្នាក់ស្រុក, គួរកែលម្អលទ្ធភាពថវិកា និងភាពច្បាស់លាស់នៃមុខងារ ដោយដោះស្រាយគម្លាតថវិកានៅថ្នាក់ក្រុង ស្រុក និងកំណត់គតិយុត្ត ដែលត្រូវកែសម្រួល ស្របទៅនឹងការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ បន្ថែមពីនេះ គួរកែលម្អការគ្រប់គ្រងធនធានមនុស្ស ដោយដោះស្រាយបញ្ហាកង្វះបុគ្គលិករដ្ឋសម្រាប់សេវាគន្លឹះ (ការផ្គត់ផ្គង់ទឹក និងសំណល់រឹង) និងរៀបចំល័ក្ខខ័ណ្ឌយោងការងារសម្រាប់រដ្ឋបាលក្រុង ស្រុក។ នៅថ្នាក់ឃុំ សង្កាត់, ដោះស្រាយភាពយឺតពេលនៃការរៀបចំ និងអភិវឌ្ឍន៍គម្រោង ដោយគាំទ្រមន្ត្រីឃុំ សង្កាត់អនុវត្តសារាចរពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍។

## ❖ បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### - លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

៣២. ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានប្រើប្រាស់ក្របខ័ណ្ឌ PEFA ដែលធ្លាប់បានប្រើប្រាស់សម្រាប់ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចំនួន ៣ លើក រួចមកហើយគឺនៅឆ្នាំ២០១០, ២០១៥ និងឆ្នាំ២០២១។ បច្ច័យលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ គឺធ្វើការប្រៀបធៀបលើលទ្ធផលទាំង ៣ លើក និងទាញការសន្និដ្ឋានលើលទ្ធផលវាយតម្លៃជាកម្រិតម៉ាក្រូ ក្នុងនោះរួមមាន÷(១) វិន័យថវិកា, (២) ប្រសិទ្ធភាពវិភាជន៍ថវិកា និង (៣) ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

៣៣. របកគំហើយពីការវាយតម្លៃ PEFA ឆ្នាំ២០២១ ដែលប្រើប្រាស់ក្របខ័ណ្ឌ PEFA ឆ្នាំ២០១១ បង្ហាញថាមានការកែលម្អក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងពិន្ទុនៃសូចនាករសមិទ្ធកម្ម (PIs) ចំនួន ១០ ក្នុងនោះរួមមាន ÷ PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI19, PI-21, PI-23 និង PI-25 រីឯ PI-3 ទទួលបានពិន្ទុទាបដោយសារមានគម្លាតខ្ពស់រវាងផែនការ និងលទ្ធផលប្រមូលចំណូលចាប់ពីឆ្នាំ២០១៧, ២០១៨ និង២០១៩។

៣៤. ផ្អែកតាមលទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ អាចទាញការសន្និដ្ឋានជាកម្រិតម៉ាក្រូ ក្នុងនោះ (១) **វិន័យថវិកា÷** ចំពោះការអនុវត្តចំណាយថវិកាបង្ហាញថាមានភាពកាន់តែប្រសើរ ប៉ុន្តែចាំបាច់ត្រូវដោះស្រាយលើបំណុលកកស្ទះ

(ទាំងផ្នែកនិយមន័យ និងបំណុលចាស់) និងការអនុវត្តចំណូលថវិកាត្រូវបន្តពង្រឹងការព្យាករចំណូល, ពង្រឹងរដ្ឋបាលប្រមូលចំណូល ពិសេសអនុលោមភាព និងការគ្រប់គ្រងហានិភ័យ, ព្រមទាំងតាមដានលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។ (២) **ប្រសិទ្ធភាពវិភាជន៍ថវិកា÷** ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំស្របតាមប្រតិទិនថវិកា ប៉ុន្តែចាំបាច់ត្រូវបង្កើនគុណភាពឯកសារថវិកាបន្ថែមទៀត។ ការរៀបចំថវិការយៈពេលមធ្យម គឺស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ដោយហេតុថាក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម ពុំទាន់ត្រូវបានអនុវត្ត និងថវិការយៈពេលមធ្យមត្រូវបានអនុវត្តសាកល្បងចាប់ពីឆ្នាំ ២០១៩។ (៣) **ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ÷** មិនទាន់អនុវត្តបានល្អនៅឡើយ ពិសេសកង្វះប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម, ការប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្មនៅមានកម្រិត, និងតម្លាភាពថវិកាក៏នៅមានកម្រិត ផងដែរ។

- **លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ**

៣៥. ការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ ផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធ និងដំណើរការរបស់រដ្ឋបាលរាជធានីភ្នំពេញ (PPCA)។ ការជ្រើសរើសយករដ្ឋបាលរាជធានីភ្នំពេញសម្រាប់ការវាយតម្លៃ គឺផ្អែកលើសនិទានភាពមួយចំនួន ជាអាទិ៍÷ រាជធានីភ្នំពេញ មិនត្រឹមតែជា រាជធានីដែលមានចំនួនប្រជាជនច្រើនជាងគេ (ក្នុងចំណោមខេត្តដ៏ទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជា) នោះទេ ប៉ុន្តែមានស្ថានភាពលេចធ្លោពាក់ព័ន្ធនឹងសេដ្ឋកិច្ច សកម្មភាពអាជីវកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីនេះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលរាជធានីភ្នំពេញ មានលក្ខណៈខុសប្លែកមួយចំនួន បើធៀបជាមួយនឹងរដ្ឋបាលខេត្តដ៏ទៃទៀត។

៣៦. លទ្ធផលនៃការវាយតម្លៃបង្ហាញថា សូចនាករចំនួន ៤ ក្នុងចំណោម ៣៤ ទទួលពិន្ទុ “A” ឬ “B” ដែលស្របទៅនឹងការអនុវត្តល្អ (Good practice) ជាអន្តរជាតិ; សូចនាករចំនួន ៦ ទទួលបានពិន្ទុ “C” ឬ “C+” ដែលស្ថិតក្នុងកម្រិតមូលដ្ឋាន ហើយសូចនាករចំនួន ១៨ ទទួលបានពិន្ទុ “D” ឬ “D+” ដែលបង្ហាញពីការអនុវត្តខ្សោយ។ ដោយឡែក សូចនាករចំនួន ៣ គឺ “NA-Not Applicable” មានន័យថាពុំមានមុខងារនៅរដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះរួមមានសូចនាករ PI-13, PI-19 និង PI-31 និងសូចនាករចំនួន ៣ គឺ “NU-Not Use” មានន័យថាពុំត្រូវបានប្រើប្រាស់សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះរួមមាន សូចនាករ PI-15, PI-16 និង PI-30។

៣៧. ការវាយតម្លៃ PEFA សម្រាប់ PPCA បង្ហាញថា មានតម្រូវការក្នុងការពង្រឹងការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុង PPCA ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឱ្យ PPCA រៀបចំផែនការប្រមូល និងប្រើប្រាស់ធនធានស្របតាមចំណាយថវិការយៈពេលមធ្យម ក៏ដូចជាផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ។ ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានជាក់ស្តែងនៅមានកម្រិតនៅឡើយ, សមត្ថភាពសម្រាប់ការអនុវត្តក្របខ័ណ្ឌគតិយុត្តនៅមានកម្រិត ហើយការត្រួតពិនិត្យសមិទ្ធកម្មត្រូវបានពង្រឹងគួរឱ្យកត់សម្គាល់។ ចំណុចខ្វះខាតត្រូវបានផ្សារភ្ជាប់ទៅនឹងភាពជឿទុកចិត្តនៃថវិកា ដែលនៅមានកម្រិតទាបផងដែរ ដែលជាឧបករណ៍មួយដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយកម្រិតខ្ពស់។

## សន្និដ្ឋានរួម

៣៨. ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំ២០២២, សកម្មភាពជាច្រើនសម្រេចបានតាមគោលដៅ ខណៈសកម្មភាពមួយចំនួនកំពុងមានវឌ្ឍនភាព និងបន្តអនុវត្តក្នុងផែនការសកម្មភាពរួមចំណាក់កាលទី៤ ហើយសកម្មភាពគន្លឹះពាក់ព័ន្ធនឹងការបញ្ចប់ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ត្រូវបាននិងកំពុងឈានទៅបញ្ចប់ជាបណ្តើរៗ។ ការវាយតម្លៃPEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានផ្តល់ជាបន្ទាត់មូលដ្ឋានអំពីស្ថានភាព នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា និងការពិនិត្យលើប្រសិទ្ធភាពប្រព័ន្ធ និងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ(PER)។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺចាំបាច់ ត្រូវពង្រឹងជាប្រចាំ និងកសាងសមាសធាតុសំខាន់ៗបន្ថែមទៀត ដើម្បីឆ្លើយតបបានទៅនឹងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗដែលអាចកើតមានជាយថាហេតុ។

៣៩. ជារួម កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខឿនទី៣ និងដំណាក់កាលទី៣ ដែលមានរយៈពេល ៧ ឆ្នាំ (២០១៦-២០២២) សម្រេចបានជាសារវ័ន្ត តាមរយៈការកសាងល័ក្ខខ័ណ្ឌចាំបាច់សម្រាប់អនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង និងបញ្ជ្រាប "**វប្បធម៌សមិទ្ធកម្ម**" នៅក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល និងទូទាំងមន្ត្រីរាជការ។ ស្ថាប័នរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តថវិកាសមិទ្ធកម្ម ជាមួយនឹងការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មផ្សារភ្ជាប់នឹងគោលនយោបាយ។ ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលអាចបោះជំហានទៅកាន់ខឿនទី៤ និងដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ប្រកបដោយភាពជឿជាក់ប្រាកដនិយម និងប្រកាន់ខ្ជាប់យន្តការបុរេសកម្ម សកម្ម និងអន្តរសកម្ម។

## ១. សេចក្តីផ្តើម

### ១.១. និន្នាការពីមុន នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៤០. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ ក្នុងគោលបំណងកែប្រែជាជំហានៗ នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅឧត្តមានុវត្តន៍អន្តរជាតិ ដោយប្រកាន់យកអភិក្រមជាខឿន ដែលបែងចែកជាខឿនចំនួន ៤ និងជា ៤ ដំណាក់កាល។

៤១. **ដំណាក់កាលទី១ "ភាពជឿទុកចិត្តនៃថវិកា"** ដែលអនុវត្តចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ បានបញ្ចប់នូវស្ថានភាព កង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ មកជាអតិរេកសាច់ប្រាក់ តាមរយៈការលុបបំបាត់ទាំងស្រុងនូវបំណុលកកស្ទះ នៅរតនាគារជាតិ ដែលជាហេតុធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាដោះស្រាយបាននូវការបើកប្រាក់បៀវត្សទៀងទាត់ និងទាន់ពេលវេលាជូនមន្ត្រីរាជការ។ ការបង្កើតគណនីទោលនៅរតនាគារជាតិ ដែលជាការប្រមូលផ្តុំគណនីទាំងអស់របស់រាជរដ្ឋាភិបាល បានក្លាយជាមូលដ្ឋានដ៏សំខាន់សម្រាប់បោះជំហានទៅរកដំណាក់កាលទី២។

៤២. **ដំណាក់កាលទី២ "គណនេយ្យភាពហិរញ្ញវត្ថុ"** ដែលត្រូវបានអនុវត្តពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ដោយមានការកែលម្អជាច្រើនលើនីតិវិធីអនុវត្តថវិកា ជាពិសេសការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី ព្រមទាំងការដាក់ឱ្យដំណើរការប្រព័ន្ធ FMIS។

៤៣. **ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០២០ ក្នុងគោលបំណងផ្លាស់ប្តូរជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើធាតុចូល និងមជ្ឈការឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹង និងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី និងការអនុវត្តអង្គភាពថវិកា រួមទាំងការពង្រឹងសមិទ្ធផលដែលសម្រេចបានក្នុងដំណាក់កាលទី១ និងទី២ កន្លងទៅ។ ដំណាក់កាលទី៣នេះ ត្រូវបានពន្យារពេលពីរឆ្នាំ ដើម្បីបញ្ចប់ការងារសេសសល់ចាប់តាំងពីដំណាក់កាលទី១, ទី២ និងទី៣។ ដំណាក់កាលអន្តរកាលឆ្ពោះទៅដំណាក់កាលទី៤ មានគោលដៅសំខាន់ឆ្ពោះទៅកសាងនូវល័ក្ខខ័ណ្ឌចាំបាច់ទាំងឡាយ ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង "**វប្បធម៌សមិទ្ធកម្ម**" ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ផែនការសកម្មភាពរួម ពាប្ញក២ មានរយៈពេលពីរឆ្នាំ (ឆ្នាំ២០២១-២០២២) ហើយត្រូវបានរៀបចំដោយពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធនៃផែនការសកម្មភាពរួម ដំណាក់កាលទី៣ ទាំងគោលបំណង និងចង្កោមសកម្មភាព ព្រមទាំងផ្លាស់ប្តូរពីការផ្តោតលើសកម្មភាពមកជាសមិទ្ធកម្មគន្លឹះ សម្រាប់ជាមូលដ្ឋាន ក្នុងការកសាងនូវផែនការសកម្មភាពរួម ដំណាក់កាលទី៤ នៅក្នុងឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧។

៤៤. **ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"** គ្រោងអនុវត្តចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្មក្នុងម៉ូដែលជា "**ថវិកាព័តិមានសមិទ្ធកម្ម**"។ យុទ្ធសាស្ត្រនេះ បានរក្សាទុកគោលបំណងដើមនៃការអនុវត្តថវិកាកម្មវិធីពេញលេញ មានន័យថាប្រើប្រាស់កម្មវិធីជាឧបករណ៍ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយឱ្យបាននៅឆ្នាំ២០២០ ហើយបន្ទាប់ពីនោះ នឹងចាប់ផ្តើមឈានទៅអនុវត្តថវិកាសមិទ្ធកម្មចាប់ពីឆ្នាំ២០២៣ តទៅដោយពង្រឹង

ជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្ម ឬលទ្ធផល និងគណនេយ្យភាព ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនសម្រាប់អនុវត្តថវិកាសមិទ្ធកម្មពេញលេញនៅឆ្នាំ២០២៥។ តារាងទី១ ខាងក្រោម បង្ហាញអំពីបម្រែបម្រួលក្របខ័ណ្ឌផែនការកម្មភាពរួម ចាប់តាំពីដំណាក់កាលទី២ រហូតដល់ដំណាក់កាលទី៣បូក២ ដែលមានគោលដៅកំណត់អាទិភាពច្បាស់លាស់ និងស្របតាមការតម្រង់ទិសរបស់ គ.ហ.ស.។

តារាងទី 1 ៖ ការប្រែប្រួលក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី២, ៣ និង ៣បូក២

| របនាសម្ព័ន្ធ CAP | CAP2 | CAP2 New | CAP3<br>២០១៦-២០២០ | CAP3+2<br>២០២១-២០២២ |
|---|---|---|---|---|
| ផ្នែក | ៣ | ៤ | ៥ | ៥ |
| គោលបំណង | ១៤ | ១៦ | ២១ | ១៩ |
| ចង្កោមសកម្មភាព | ៦២ | ៧១ | ៦៨ | ៥៩ |

ប្រភព៖ អ.គ.ហ.

## ១.២. ស្ថានភាពសេដ្ឋកិច្ច

៤៥. ក្នុងរយៈពេលជិត ៣ ឆ្នាំនេះ កម្ពុជាក៏ដូចជាបណ្តាប្រទេសក្នុងសកលលោក បាននិងកំពុងបន្តដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចដែលបង្កឡើងដោយវិបត្តិជំងឺកូវីដ-១៩ ពិសេសផលវិបាកអវិជ្ជមានជាច្រើនលើជីវភាពប្រចាំថ្ងៃ របស់ប្រជាជន និងបញ្ហាប្រឈមជារចនាសម្ព័ន្ធក្នុងរយៈពេលមធ្យម ដែលបានប៉ះទង្គិចដល់គន្លងអភិវឌ្ឍន៍របស់កម្ពុជាក្នុងរយៈពេលវែង។ បន្ទាប់ពីទទួលបានជោគជ័យលើការប្រយុទ្ធនឹងការរីករាលនៃជំងឺកូវីដ-១៩ និងការគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិជំងឺនេះ សេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញយ៉ាងឆាប់រហ័ស។ ក៏ប៉ុន្តែ ដំណើរការកសាងសេដ្ឋកិច្ចឡើងវិញក្នុងបរិការណ៍នៃការបើកប្រទេសឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ នេះ ត្រូវប៉ះទង្គិចពីវិបត្តិថ្មីមួយទៀត គឺ "**សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន**" ដែលវិបត្តិនេះ បានបង្កផលប៉ះពាល់ដោយប្រយោលដល់សេដ្ឋកិច្ចកម្ពុជាតាមរយៈការរុញឱ្យអត្រាអតិផរណាកើនឡើងកាន់តែខ្ពស់ ពិសេសការឡើងថ្លៃប្រេងឥន្ធនៈ ចំណីអាហារ ជីកសិកម្ម និងទំនិញជាច្រើនប្រភេទ ដែលបង្កផលប៉ះពាល់ដល់សកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជន។

៤៦. ទោះបីស្ថានការណ៍អូសបន្លាយនៃវិបត្តិសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន បានធ្វើឱ្យនិន្នាការកំណើនសេដ្ឋកិច្ចសកលមានសន្ទុះយឺតជាងការរំពឹងទុក ក៏ផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជាពីវិបត្តិនេះមានទំហំតូច ដោយហេតុថាទំនាក់ទំនងសេដ្ឋកិច្ចដោយផ្ទាល់រវាងកម្ពុជាជាមួយប្រទេសមានជម្លោះនៅមានកម្រិតទាប។ ផលប៉ះពាល់នេះត្រូវបានប៉ះប៉ូវមកវិញដោយការសម្រេចបាននូវអត្រាខ្ពស់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ និងការបើកប្រទេសឡើងវិញ ដែលបានអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់ទៅរកប្រក្រតីភាពវិញ។ ការស្តារសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័សពីវិបត្តិនេះ គឺដោយសាររាជរដ្ឋាភិបាលបានអនុវត្តទាន់ពេលវេលា និងប្រកបដោយជោគជ័យនៃ "**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣**" ពិសេសការបង្កើនកញ្ចប់អន្តរាគមន៍ផ្នែកសង្គមនិងសេដ្ឋកិច្ចដើម្បីជួយកាត់បន្ថយផលប៉ះពាលពីការកើនឡើងអតិផរណា និងការបង្កើនការវិនិយោគក្នុងស្រុក ដែលបានលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងការបង្កើតការងារជូនប្រជាជន រួមមាន៖ ការឧបត្ថម្ភសាច់ប្រាក់ដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះ, កម្មវិធីសាច់ប្រាក់ពលកម្ម និងការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិត ក្នុងកំឡុងពេលព្យួរការងារ

ជាដើម ដែលជារួមបានចូលរួមចំណែកទ្រទ្រង់ជីវភាពប្រជាជន និងសកម្មភាពអាជីវកម្ម និងបានទ្រទ្រង់កំណើនសេដ្ឋកិច្ចជារួម។ បន្ថែមលើនេះ ការចាប់ផ្ដើមអនុវត្តច្បាប់ថ្មីស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងជួយធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ និងជំរុញការទាក់ទាញវិនិយោគបន្ថែម ជាពិសេសសម្រាប់ឧស្សាហកម្មដែលបម្រើដល់ការនាំចេញ។ ឈរលើវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ និងវិធានការដ៏មុតស្រួច របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** សេដ្ឋកិច្ចកម្ពុជាបន្តមានសក្ដានុពលខ្ពស់ ក្នុងការសម្រេចបាននូវកំណើនរឹងមាំប្រកបដោយចីរភាពក្នុងរយៈពេលមធ្យមខាងមុខ។

៤៧. សេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០២២ សម្រេចបានកំណើន ក្នុងអត្រា ៥,២% ខ្ពស់ជាងឆ្នាំ ២០២១។ ជាមួយគ្នានេះ អត្រាអតិផរណា បានកើនឡើងក្នុងអត្រា ៥,៣% ដោយសារការកើនឡើងខ្ពស់នៃថ្លៃប្រេងអន្តរជាតិ និងថ្លៃទំនិញផ្សេងៗទៀត ដែលបង្កដោយសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ ចំពោះអត្រាប្ដូរប្រាក់ស្ថិតក្នុងរង្វង់ជាមធ្យមប្រចាំឆ្នាំប្រមាណ ៤ ០៩០ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពថ្លៃ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល។

៤៨. កំណើនសេដ្ឋកិច្ចឆ្នាំ២០២២ ត្រូវបានទ្រទ្រង់ដោយកំណើនតាមវិស័យ ដូចតទៅ៖ វិស័យឧស្សាហកម្ម សម្រេចបានកំណើន ៨,៣% ខ្ពស់ជាងការរំពឹងទុក ដោយសារកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ និងការបន្តកំណើនរឹងមាំនៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់បន្តមានកំណើនទាប; (២) វិស័យសេវាកម្មសម្រេចបានកំណើន ក្នុងអត្រា ៤,៦% ដោយសារការងើបឡើងវិញនៃអនុវិស័យ សណ្ឋាគារ និងភោជនីយដ្ឋាន និងការបន្តនិន្នាការកើនឡើងនៃអនុវិស័យគាំទ្រផ្សេងៗទៀត; និង (៣) វិស័យកសិកម្ម មានកំណើនទាបធៀបនឹងឆ្នាំ ២០២១ ក្នុងអត្រា ០,៧% ដោយសារភាពរអាក់រអួលនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងការកើនឡើងថ្លៃដើមផលិត។ តារាងទី២ ខាងក្រោម បង្ហាញអំពីសមិទ្ធកម្មសេដ្ឋកិច្ច ដោយប្រើប្រាស់សូចនាករសេដ្ឋកិច្ច ឆ្នាំ២០១៩-២០២៣។

តារាងទី 2 ៖ សូចនាករសេដ្ឋកិច្ច ឆ្នាំ២០១៩-២០២៣

| កំណើនតាមវិស័យ (%) | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ប |
|---|---|---|---|---|---|
| កំណើន ផ.ស.ស | ៧,១ | -៣,១ | ៣,០ | ៥,២ | ៥,៦ |
| កសិកម្ម | -០,៥ | ០,៦ | ១,១ | ០,៧ | ១,១ |
| *ដំណាំ* | *០,៦* | *០,៦* | *២,៦* | *១,១* | *១,៧* |
| *ចិញ្ចឹមសត្វ* | *០,៣* | *០,៩* | *២,២* | *១,០* | *១,០* |
| *នេសាទ* | *១,៦* | *០,៩* | *-២,៤* | *០,២* | *០,៤* |
| ឧស្សាហកម្ម | ១១,៣ | -១,៤ | ៨,៦ | ៨,៣ | ៥,៩ |
| *កាត់ដេរ* | *៦,៦* | *-៦,១* | *១០,៨* | *១០,៨* | *៥,៥* |
| *សំណង់* | *២០,៨* | *-១,៨* | *១,១* | *០,៥* | *១,១* |
| *កម្មន្តសាលមិនមែនកាត់ដេរ* | *១០,៣* | *១០,៤* | *១៣,៩* | *១២,២* | *១១,៧* |
| សេវាកម្ម | ៦,២ | -៦,៣ | -១,៩ | ៤,៦ | ៧,៣ |
| *សណ្ឋាគារ និងភោជនីយដ្ឋាន* | *៣,១* | *-៣២,២* | *-៣៩,៥* | *៣០,០* | *៣២,៧* |

| | | | | | |
|---|---|---|---|---|---|
| *លក់ដុំ-រាយ* | *៦,៥* | *-៥,៤* | *១,៦* | *៤,៣* | *៦,៥* |
| *អចលនទ្រព្យ* | *៧,០* | *-៥,០* | *០,៥* | *០,២* | *១,២* |
| *ដឹកជញ្ជូន និងគមនាគមន៍* | *៨,៤* | *-២,៧* | *២,៨* | *៦,១* | *៧,៦* |
| ផ.ស.ស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៧០០ | ១ ៦០៥ | ១ ៦៥៩ | ១ ៧៨៤ | ១ ៩៣២ |
| អត្រាអតិផរណា (កំណើនមធ្យមប្រចាំឆ្នាំជា %) | ១,៨ | ២,៩ | ២,៩ | ៥,៣ | ៣,២ |
| អត្រាប្តូរប្រាក់(រៀល/ ដុល្លារ) | ៤ ០៥៥ | ៤ ០៨០ | ៤ ០៦៨ | ៤ ០៩០ | ៤ ០៦៥ |
| សមតុល្យគណនីចរន្ត (ភាគរយនៃ ផ.ស.ស) | -១៥,០ | -៨,៥ | -៤៥,៤ | -៣១,៤ | -១៣,៨ |
| សមតុល្យពាណិជ្ជកម្ម (ភាគរយនៃ ផ.ស.ស) | -២៦,៧ | -៩,៨ | -៤១,៤ | -៣១,៣ | -១៩,០ |

ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ (២០១៩-២០២០) និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (២០២១-២០២៣)

៤៩. វឌ្ឍនភាពសេដ្ឋកិច្ចបន្ទាប់ពីវិបត្តិដូចបានរៀបរាប់ខាងលើនេះ ពិតជាមិនអាចកាត់ផ្តាច់ពីការរួមចំណែកនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានធ្វើឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាកាន់តែរឹងមាំ និងភាពធន់នឹងវិបត្តិ។ ក្នុងនោះ ការប្រមូលចំណូលរដ្ឋមានភាពរឹងមាំ ដែលបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចសន្សំ និងបង្គរថវិកាកាន់តែច្រើនទៅកាន់វិស័យអាទិភាព ក៏ដូចជាអាចបង្កើនយ៉ាងច្រើន នូវធនធានវិនិយោគសាធារណៈក្នុងស្រុក ដែលធ្វើឱ្យរាជរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយ និងវិធានការអន្តរាគមន៍ទាំងឡាយ ដើម្បីជួយរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជារក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជន ដែលចំណែកសំខាន់នៃការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច។

## ១.៣. ស្ថានភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៥០. វិបត្តិដែលមានរយៈពេល ៣ ឆ្នាំចុងក្រោយនេះ បានបង្ហាញឱ្យឃើញអំពីភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា។ ការប្រមូលចំណូលថវិការដ្ឋមានភាពរឹងមាំ និងមានកំណើនឡើងវិញយ៉ាងឆាប់រហ័ស ក្នុងនោះការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូលថវិការដ្ឋ[2] ឆ្នាំ២០២២ (ទិន្នន័យបណ្តោះអាសន្នគិតត្រឹមថ្ងៃ៣១ ខែមករា ឆ្នាំ២០២៣) សម្រេចបាន ២៦ ៨៥៧ ប៊ីលានរៀល ឬស្មើនឹង ១០៦,១% នៃច្បាប់ថវិកា ក្នុងនោះចំណូលចរន្តសម្រេចបាន ២៦ ៧៤១ ប៊ីលានរៀល ឬស្មើ ១១២,៦៤% នៃច្បាប់ថវិកា និងចំណូលមូលធន សម្រេចបាន ១ ៨៣៤ ប៊ីលានរៀល ឬស្មើ ៨៤,៨% នៃច្បាប់ថវិកា។

៥១. ចំពោះចំណូលសារពើពន្ធថ្នាក់ជាតិសម្រេចបាន ២២ ៤៤៨ ប៊ីលានរៀល ឬស្មើ ១១២,២% នៃច្បាប់ថវិកា ខណៈការប្រមូលចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិសម្រេចបាន ២ ០៧១ ប៊ីលានរៀល ឬស្មើ ១០៧,៣% នៃច្បាប់ហិរញ្ញវត្ថុ។ ចំណែកឯការអនុវត្តចំណូលថវិកាថ្នាក់រដ្ឋបាលរាជធានី ខេត្ត[3] សម្រេចបាន ២ ១៨១ ប៊ីលានរៀល ឬស្មើនឹង ១១១៨,៣% នៃច្បាប់ថវិកា ក្នុងនោះ ចំណូលសារពើពន្ធសម្រេចបាន ១ ៩៣៦ ប៊ីលានរៀល ឬស្មើនឹង ១២២,២% នៃច្បាប់ថវិកា និងចំណូលមិនមែនសារពើពន្ធសម្រេចបាន ២៤៥ ប៊ីលានរៀល ឬស្មើនឹង ៩៤,៣% នៃច្បាប់ថវិកា។

[2] ចំណូលចរន្ត+ មូលធនក្នុងប្រទេស

[3] តួលេខចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិខាងលើ ជាតួលេខថវិការាជធានី-ខេត្ត និងខណ្ឌ

៥២. ដ្យាក្រាមទី១ និងទី២ ខាងក្រោម បង្ហាញអំពីនិន្នាការនៃការប្រមូលចំណូលថវិការដ្ឋ និងកំណើនពិន្ទុភាគរយ នៃ ផសស. ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២២។

ដ្យាក្រាមទី 1 ÷ ការអនុវត្តការប្រមូលចំណូលឆ្នាំ២០១៣-២០២២




ប្រភព÷ អ.វ.ជ (តួលេខឆ្នាំ២០២២ គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣)

ដ្យាក្រាមទី 2 ÷ កំណើនចំណូលចរន្តគិតជាពិន្ទុភាគរយ នៃ ផសស. ឆ្នាំ២០១៣-ឆ្នាំ២០២២




ប្រភព÷ អ.វ.ជ (តួលេខឆ្នាំ២០២២ គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣)

៥៣. ការអនុវត្តថវិការដ្ឋសរុបឆ្នាំ២០២២ (ទិន្នន័យបណ្តោះអាសន្នគិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២) សម្រេចបាន ២៣ ៤៧៥ ប៊ីលានរៀល ឬស្មើ ៨១,៦៩% នៃច្បាប់ថវិកា។ រីឯចំណាយប្រចាំត្រីមាសទី២, ទី៣ និងទី៤ មានភាព-យឺតជាងគោលដៅ ដែលបានកំណត់ក្នុងក្របខ័ណ្ឌផែនការសកម្មភាពរួម នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គោលដៅ ត.ម ១ =១៥%, ត.ម ២= ៤៥%, ត.ម ៣= ៧០% និង ត.ម ៤= ៩៦%)។

ចំណែកងចំណាយថវិកាតាមប្រភេទ (គោលដៅកំណត់មិនត្រូវតិចជាង ៩៨% សម្រាប់បៀវត្ស, ៩៥% សម្រាប់ទំនិញ/ សេវា និង៨៥% សម្រាប់មូលធន) ក្នុងនោះ (១) បៀវត្សសម្រេចបាន ៩៦,២៣% នៃច្បាប់ថវិកា, ទំនិញ/ សេវា សម្រេចបាន ៨៣,៧៧% នៃច្បាប់ហិរញ្ញវត្ថុ និងចំណាយមូលធនសម្រេចបាន ៧៤,៥៣% នៃច្បាប់ថវិកា។ ដ្យាក្រាមទី៣ និងទី៤ ខាងក្រោម បង្ហាញអំពីនិន្នាការចំណាយថវិការដ្ឋធៀបនឹងច្បាប់ថវិកា ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២២ និងវិហ្វកការអនុវត្តថវិការដ្ឋតាមត្រីមាសឆ្នាំ ២០១៣-២០២២។

ដ្យាក្រាមទី 3 ÷ ការអនុវត្តថវិការដ្ឋឆ្នាំ២០១៣-២០២២




ប្រភព÷ អ.វ.ជ (គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣)

ដ្យាក្រាមទី 4 ÷ វិហ្វកអនុវត្តថវិការដ្ឋប្រចាំត្រីមាស ឆ្នាំ ២០១៣-២០២២




ប្រភព÷ អ.វ.ជ (គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣)

## ១.៤. សនិទានកម្ម និងគោលបំណង

៥៤. ការរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២២ អនុលោមតាមសារាចរលេខ ០៩ សរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៨

ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃ លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៥៥. របាយការណ៍នេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយ តាមរយៈការបង្កើនការចូលរួមផ្តល់ជាធាតុចូលពីគ្រប់ភាគីដែលមានការពាក់ព័ន្ធក្នុងនោះរួមមាន÷ អង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរ សហវ. រាជធានី ខេត្ត, ក្រសួង ស្ថាប័ន, រដ្ឋបាលខេត្ត, និងដៃគូអភិវឌ្ឍន៍ ដោយផ្អែកតាមវិធីសាស្រ្តរៀបចំ ដូចខាងក្រោម÷

- ទី១. ការតាមដានវឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស.
- ទី២. ការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក២ (CAP3+2)
- ទី៣. ការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ (GDAP/PDAP/MAP) របស់អង្គភាពក្រោមឱវាទ កសហវ., មន្ទីរ សហវ. រាជធានី ខេត្ត និងក្រសួង ស្ថាប័ន។
- ទី៤. ការប្រមូលព័ត៌មានបន្ថែមនៅរដ្ឋបាលខេត្តចំនួន ៥ (ខេត្តព្រះសីហនុ, កំពង់ស្ពឺ, កណ្តាល, ព្រៃវែង និងមណ្ឌលគិរី) និងក្រសួងចំនួន ៥ (ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, និងក្រសួងពាណិជ្ជកម្ម។
- ទី៥. ការប្រមូលធាតុចូលតាមរយៈការរៀបចំសិក្ខាសាលាមួយចំនួន ជាអាទិ៍÷ បច្ចុប្បន្នភាពផែនការសកម្មភាព BSRS, PEFA ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ថវិកាយេនឌ័រ និង PER។
- ទី៦. ការសំយោគធាតុចូលពីដៃគូអភិវឌ្ឍន៍ទៅលើទិដ្ឋភាពមួយចំនួន រួមមាន÷ (១) ការអនុវត្តប្រព័ន្ធ FMIS, ការវាយតម្លៃថវិកាយេនឌ័រ, និងការវាយតម្លៃចំណាយសាធារណៈ (PER) ដោយផ្តោតលើការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, វិស័យកសិកម្ម, វិស័យធារាសាស្រ្តនិងឧតុនិយម, វិស័យសុខាភិបាល និងរដ្ឋបាលខេត្តព្រះសីហនុ។ កិច្ចការទាំងនេះ គឺក្រោមកិច្ចសហការជាមួយអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង ស្ថាប័នពាក់ព័ន្ធ និងសម្របសម្រួលដោយ អ.គ.ហ.។
- ទី៧. ការរៀបចំកិច្ចប្រជុំពិភាក្សាជាមួយអង្គភាពក្រោមឱវាទ កសហវ., មន្ទីរ សហវ. រាជធានី ខេត្ត, ក្រសួង ស្ថាប័ន ដើម្បីពិនិត្យ និងធ្វើសុពលភាពព័ត៌មាន។ និង
- ទី៨. ការរៀបចំកិច្ចប្រជុំផ្ទៃក្នុង អ.គ.ហ. ដើម្បីពិនិត្យជារួមទៅលើសេចក្តីព្រាងរបាយការណ៍។

៥៦. ដោយឡែក ចំពោះការវាយតម្លៃថវិកាយេនឌ័រ បានផ្តល់ជាបន្ទាត់មូលដ្ឋាន សម្រាប់ជំរុញសមភាពយេនឌ័រ ក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំថវិកាប្រចាំឆ្នាំ ដែលកិច្ចការនេះ មិនមែនជាការបន្ថែមថវិកាសម្រាប់អនុវត្តថវិកាយេនឌ័រនោះទេ ប៉ុន្តែជាការបញ្ជ្រាបទិដ្ឋភាពយេនឌ័រ ក្នុងទូទាំងវដ្តថវិកា។

៥៧. ជារួម តាមរយៈការប្រើប្រាស់វិធីសាស្រ្តខាងលើ, របាយការណ៍ប្រចាំឆ្នាំ២០២២ បានឆ្លុះបញ្ចាំងទាំងទិដ្ឋភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ និងប្រសិទ្ធភាពប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់ឧបករណ៍ស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីកំណត់ថាតើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតលើវិថីកែទម្រង់ដ៏ត្រឹមត្រូវ និងបោះជំហានឈានទៅដំណាក់កាលទី៤ ប្រកបដោយជីវភាព និងគណនេយ្យភាព។

## ២. លទ្ធផលវាយតម្លៃកម្មវិធីកែទម្រង់ និងវឌ្ឍនភាពប្រចាំឆ្នាំ២០២២

### ២.១. ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ បុក២

### ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

៥៨. ផ្នែកនេះផ្តោតលើគោលបំណងចំនួន ៣ រួមមាន (១) បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល (២) ពង្រឹងការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ និង (៣) កែលម្អដំណើរការនៃការអនុវត្តថវិកា។ ទន្ទឹមនេះ ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាស និងប្រចាំឆ្នាំ មានភាពរលូន និងអាចប៉ាន់ស្មានបាន ក្នុងកម្រិតលម្អៀងនៃការអនុវត្តស្ថិតក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា។

*គោលបំណង១១÷ បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល*

៥៩. ក្នុងក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការប្រមូលចំណូលនៅតែមានភាពរឹងមាំ តាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៤-២០១៨, ចំណូលចរន្តមានកំណើនមធ្យមប្រមាណ ១,៤ ពិន្ទុភាគរយ នៃ ផ.ស.ស.ក្នុងមួយឆ្នាំ ខ្ពស់ជាងគោលដៅ ០,៥ ពិន្ទុភាគរយ នៃ ផ.ស.ស. ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រ។ យុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ មានគោលបំណងធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់, កែលម្អបរិយាកាសវិនិយោគ, និងតម្រង់ទិសការវិនិយោគ, ពង្រឹងភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ។

៦០. គោលបំណងនេះ មានសូចនាករសមិទ្ធកម្មចំនួន ២ និងសម្រេចបានដូចខាងក្រោម÷

| សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលគោល | គោលដៅ និងលទ្ធផលសម្រេចបាន | |
|---|---|---|---|
| | | គោលដៅឆ្នាំ២០២២ | លទ្ធផលសម្រេចបាន |
| សគ១. ភាគរយនៃការអនុវត្តចំណូលថវិកាធៀបនឹងច្បាប់ថវិកា | នៅឆ្នាំ២០២១ ចំណូលចរន្តសម្រេចបាន ១០៤,៤៩% នៃច្បាប់ថវិកា | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកា ជារៀងរាល់ឆ្នាំ | ១០៦,១% នៃច្បាប់ថវិកា |
| សគ២. កំណើនចំណូលចរន្តធៀបនឹង ផ.ស.ស. | នៅឆ្នាំ២០២១ ចំណូលចរន្តថយចុះ -២,៦ ពិន្ទុភាគរយ នៃ ផ.ស.ស. ជាមធ្យម | យ៉ាងតិច ០,៣ ពិន្ទុភាគរយ នៃ ផ.ស.ស. | ១,៧៥ ពិន្ទុភាគរយ នៃ ផ.ស.ស. |

៦១. **ការអនុវត្តគោលនយោបាយ និងកែទម្រង់រដ្ឋបាលពន្ធដារ÷** ភាគរយនៃអ្នកជាប់ពន្ធបង់ប្រាក់ពន្ធទាន់ពេលវេលាសម្រេចបាន ៨៨,៧០% នៃអ្នកជាប់ពន្ធសរុប។ ដោយឡែក បណ្តឹងតវ៉ានៃករណីកំណត់ពន្ធឡើងវិញចំនួន ១៦៤ ករណី ត្រូវបានដោះស្រាយដែលស្មើនឹងប្រមាណ ៥៣,០៧% ធៀបនឹងបណ្តឹងតវ៉ាសរុបចំនួន ៣០៩ ករណី។ បំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២១ មានចំនួន ៧ ២៥៩ ប៊ីលានរៀល។ ការប្រមូលបំណុលពន្ធក្នុងឆ្នាំ ២០២២ សម្រេចបានចំនួន ១ ០៧០ ប៊ីលានរៀល ស្មើនឹងប្រមាណ ១៤.៧៤% នៃបំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២១។ **ចំពោះការអនុវត្តគោលនយោបាយ និងកែទម្រង់រដ្ឋបាលគយ÷** ក្នុងឆ្នាំ២០២២ ក្រុមធុរជនល្អបំផុត ត្រូវបានបង្កើនបន្ថែមចំនួន៦។ ទន្ទឹមនេះ យន្តការវាយតម្លៃកម្រិតអនុលោមភាពជើងសាគយ និងប្រតិវេទករ

ត្រូវបានរៀបចំ ដើម្បីពង្រឹងអនុលោមភាពក្នុងការបំពេញបែបបទគយ។ ជាមួយគ្នានេះ ការអនុវត្តការងារសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយប្រចាំឆ្នាំ២០២២ សម្រេចបាន ៨៥% ធៀបនឹងផែនការដែលបានកំណត់។ ដោយឡែក គម្រោងប្រព័ន្ធបញ្ជរតែមួយជាតិ ដំណាក់កាលទី៣ ត្រូវបានរៀបចំរួចរាល់ និងគ្រោងប្រកាសចាប់ផ្តើមនៅខែមករា ឆ្នាំ២០២៣។ ខាងផ្នែកចំណូលមិនមែនសារពើពន្ធ, នៅឆ្នាំ២០២២ បំណុលមិនមែនសារពើពន្ធ ថយចុះ ៧% ធៀបនឹងបំណុលសរុបឆ្នាំ២០២១។

៦២. ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិចំនួន ២៣ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត និងដាក់អនុវត្តនៅរដ្ឋបាលរាជធានី ខេត្ត និងអង្គភាពប្រមូលចំណូលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយបានរៀបចំវគ្គបណ្តុះបណ្តាលស្តីការប្រើប្រាស់ប្រព័ន្ធ NRMIS ជូនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង ២០៣ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។ បន្ថែមពីនេះ ការធ្វើសន្ទានកម្មប្រព័ន្ធ FMIS និងប្រព័ន្ធ NRMIS សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបន្តជំរុញបន្ថែម។ E-payment ត្រូវបានប្រើប្រាស់នៅក្រសួងចំនួន ១០ បន្ថែម រួមមាន ក្រសួងព្រះបរមរាជវាំង, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ, ក្រសួងការបរទេសនិងសហប្រតិបត្តិអន្តរជាតិ, ក្រសួងព័ត៌មាន, ក្រសួងសុខាភិបាល, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងយុត្តិធម៌ (ផ្នែកយុត្តិធម៌, តុលាការកំពូល, សាលាឧទ្ធរណ៍ និងសាលាដំបូងរាជធានី ខេត្ត) អនុលោមតាមសារាចរលេខ ០០៣ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ E-Payment ជំហានទី៣។

៦៣. ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រូវបានអនុម័ត និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២។ ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធបានរៀបចំរួចរាល់ជាភាសាខ្មែរ និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ ជាមួយក្រសួង ស្ថាប័ន, អង្គភាពនីតិបុគ្គលសាធារណៈ, រដ្ឋបាលថ្នាក់ក្រោមជាតិ, ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ សេចក្តីព្រាងឯកសារគោល (Blueprint)នេះ នឹងដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាត្រីមាសទី១ ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងសម្រេចបន្តនីតិវិធី។

៦៤. បន្ថែមពីនេះ ក្របខ័ណ្ឌគោលនយោបាយអាករពិសេស ២០២៣-២០២៨ ត្រូវបានរៀបចំជាសេចក្តីព្រាង ដែលរំពឹងថានឹងត្រូវសម្រេចបានត្រឹមត្រីមាសទី៣ ឆ្នាំ២០២៣ ខណៈសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ត្រូវបានរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច។

### *គោលបំណង ១២÷ ពង្រឹងការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ*

៦៥. គោលបំណងនេះ ផ្តោតលើភាគរយនៃការអនុវត្តចំណាយធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ។ ចំណាយថវិកាជាតិសរុបគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២ សម្រេចបាន ២៣ ៤៧៥ ប៊ីលានរៀល (៨១,៦៩% ធៀបនឹងច្បាប់ថវិកា) ក្នុងនោះ ចំណាយបៀវត្សរ៍សម្រេចបាន ៩ ០៥០ ប៊ីលានរៀល (៩៦,២៣% ធៀបនឹងច្បាប់ថវិកា), ចំណាយទំនិញសេវា សម្រេចបាន ៣ ៨៩៣ ប៊ីលានរៀល (៨៣,៧៧% ធៀបនឹងច្បាប់ថវិកា), និងចំណាយមូលធន សម្រេចបាន ៦ ៣០៤ ប៊ីលានរៀល(៧៤,៥៣% ធៀបនឹងច្បាប់ថវិកា)។ ពិនិត្យមើលចំណាយតាមត្រីមាស, ចំណាយប្រចាំត្រីមាសទី ៣ នៅមានកម្រិតទាប ពោលគឺសម្រេចបានត្រឹមតែ ៥៨,៦៤% ខណៈគោលដៅដែលបានដាក់ចេញត្រូវសម្រេច

ឱ្យបាន ៧០%។ ក្នុងន័យនេះ វិហ្ងរ និងប្រសិទ្ធភាពចំណាយថវិកាត្រូវបន្តយកចិត្តទុកដាក់ ដើម្បីឈានទៅកំណត់ និងដាក់ចេញវិធានការ។

### *គោលបំណង ១៣÷ កែលម្អដំណើរការនៃការអនុវត្តថវិកា*

៦៦. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ បានកំណត់នូវទិសដៅជាយុទ្ធសាស្ត្រ អាទិភាពលើការកែទម្រង់គន្លឹះៗ រួមមាន (១) ការរៀបចំ និងការអនុម័តផែនការលទ្ធកម្ម, (២) ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ, (៣) ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្ម (សវនកម្មកិច្ចលទ្ធកម្ម), (៤) ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា និងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ និង (៥) ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ដែលរួមមានការកែលម្អក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ, ការរៀបចំសៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ, ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក និងការកសាងសមត្ថភាព។

៦៧. គោលបំណងនេះ មានសូចនាករសមិទ្ធកម្មចំនួន ៣ ហើយសម្រេចបានលទ្ធផល ដូចតទៅ÷

*សគ ៤ ភាគរយនៃផែនការលទ្ធកម្មត្រូវបានអនុម័តមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា*

**គោលដៅ÷** ៩៥%នៃផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំនៃការអនុវត្តថវិកា។

៦៨. **វឌ្ឍនភាព÷** គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ស្ថាប័នអនុវត្តលទ្ធកម្ម ដែលបានផ្ញើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៣ មក កសហវ. មានចំនួន ១១៥ ស្ថាប័ន (៩៣.៥០%) និងត្រូវបានអនុម័តរួចរាល់ពី កសហវ. ចំនួន ១១០ ស្ថាប័ន ឬស្មើនឹង ៩៦ %។

*សគ ៥ ភាគរយនៃអង្គភាពថវិការបស់ក្រសួង ស្ថាប័នផ្តល់របាយការណ៍អនុវត្តកិច្ចលទ្ធកម្ម*

**គោលដៅ÷** យ៉ាងតិច ៧១% នៃអង្គភាពថវិកាផ្តល់របាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ.

៦៩. **វឌ្ឍនភាព÷** ក្នុងឆ្នាំ២០២១ អង្គភាពថវិកាផ្តល់របាយការណ៍អនុវត្តកិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ. មានចំនួន ៤៥៧ ក្នុងចំណោមអង្គភាពថវិកាសរុបចំនួន ៦៣៩ ឬស្មើនឹងប្រមាណ ៧១%។

*សគ ៦ ការបោះជំហានទៅបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម*

**គោលដៅ÷** ជំហានទី ២ បង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម នៅឆ្នាំ ២០២២។

៧០. **វឌ្ឍនភាព÷** នៅឆ្នាំ២០១៩ ជំហានទី១ ត្រូវបានដាក់ឱ្យអនុវត្តដោយបានបង្កើនទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈ របស់ស្ថាប័នអនុវត្តកិច្ចលទ្ធកម្ម។ ដោយឡែក សម្រាប់ជំហានទី២, ប្រកាសស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ជំហានទី២ ត្រូវបានរៀបចំជាសេចក្តីព្រាង។

*សគ ៧ កំណើនជាភាគរយនៃការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្ម*

**គោលដៅ÷** យ៉ាងតិច ៦៥% នៃទំហំទឹកប្រាក់ប្រគល់កិច្ចសន្យាសរុប។

៧១. **វឌ្ឍនភាព÷** នៅក្នុងឆ្នាំ២០២១ ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្មលើថវិកាចរន្ត និងមូលធនអនុវត្តបានប្រមាណ ៥៦% នៃទំហំទឹកប្រាក់ប្រគល់កិច្ចសន្យាសរុប។

៧២. បន្ថែមពីនេះ នៅក្រោមគោលបំណងលេខ ១៣, សេចក្តីព្រាងស្តីពីលទ្ធកម្មសាធារណៈ (ថ្មី) ត្រូវបានដាក់ប្រជុំ និងពិភាក្សាក្នុងកម្រិតថ្នាក់ដឹកនាំ កសហវ. កាលពីថ្ងៃទី១៣, ទី១៥ និងទី១៦ ខែធ្នូ ឆ្នាំ២០២២ ដែលដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់ពីកិច្ចប្រជុំផ្ទៃក្នុង កសហវ., អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បាននិងកំពុងកែសម្រួលសេចក្តីព្រាងច្បាប់ស្របតាមស្មារតីសម្រេចរបស់អង្គប្រជុំ ដើម្បីត្រៀមដាក់ប្រជុំពិភាក្សាជាមួយក្រសួងយុត្តិធម៌, អង្គភាពប្រឆាំងអំពើពុករលួយ, និងត្រៀមដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៧៣. ដោយឡែក ចំពោះបំណុលកកស្ទះ ដែលទូទាត់មិនឱ្យលើសពីរយៈពេល ៦០ ថ្ងៃ គឺពុំមាននោះទេ។ ចំពោះក្របខ័ណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាព សម្រាប់ដោះស្រាយបំណុលកកស្ទះ (ការកំណត់និយមន័យថ្មីនៃបំណុលកកស្ទះ), ក្រុមការងារបានរៀបចំកិច្ចប្រជុំ ពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍របកគំហើញរបស់ជំនាញការកាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២។ បច្ចុប្បន្ន, ក្រុមជំនាញការបាននិងកំពុងប្រមូលធាតុចូលបន្ថែមទៀតពីភាគីពាក់ព័ន្ធ។

៧៤. ក្រសួង ស្ថាប័នចំនួន ១៣ បានរៀបចំគោលការណ៍ណែនាំស្តីពីហិរញ្ញវត្ថុសាធារណៈ (FMM) ក្នុងចំណោមនោះមាន ៣ ក្រសួង បានរៀបចំសេចក្តីព្រាង FMM។ ការរៀបចំ FMM នៅមានវឌ្ឍនភាពយឺតនៅឡើយ ដែលគួរត្រូវបានជំរុញការរៀបចំសំដៅសម្រួលដល់ការអនុវត្តនីតិវិធីហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័ន។ រីឯការរៀបចំផែនការឥណទានរជ្ជទេយ្យបុរេប្រទានសម្រាប់ការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំមានវឌ្ឍនភាពប្រសើរឡើង ដោយក្រសួង ស្ថាប័នបានរៀបចំ និងផ្ញើមក កសហវ. ទាន់ពេលវេលា។

៧៥. ចំពោះការបើកប្រាក់បេសសកម្មតាមប្រព័ន្ធធនាគារ នៅមានវឌ្ឍនភាពយឺតនៅឡើយ បើទោះបីជាមានការជំរុញពី កសហវ. យ៉ាងណាក៏ដោយ ពោលគិតត្រឹមឆ្នាំ២០២២ មានក្រសួង ស្ថាប័នចំនួន ២១ / ៣៧ បានបានអនុវត្តការ-បើកប្រាក់បេសកម្មក្នុងប្រទេស ឬស្មើនឹង ៥៥% និងក្រសួង ស្ថាប័នចំនួន ១៣/៣៧ បានអនុវត្តការបើកប្រាក់បេសកម្មក្រៅប្រទេស ឬស្មើនឹង ៣៥%។ កិច្ចការនេះ គួរត្រូវបានជំរុញបន្ថែមទៀត ដើម្បីធានាដល់អត្ថប្រយោជន៍ពេញលេញដល់មន្ត្រីរាជការ។

៧៦. **ជាការសន្និដ្ឋានក្នុងផ្នែកទី១,** ចំណូលថវិកាជាតិនៅតែមានស្ថានភាពរឹងមាំ ប៉ុន្តែវិហ្វរ និងប្រសិទ្ធភាពចំណាយថវិកាត្រូវបន្តយកចិត្តទុកដាក់ខ្ពស់។ ការដាក់ចេញនូវវិធានការនៃការភ្ជាប់ផែនការរជ្ជទេយ្យបុរេប្រទានកំឡុងពេលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ និងការអនុម័តផែនការលទ្ធកម្មប្រចាំឆ្នាំមុនឆ្នាំអនុវត្តថវិកា មានវឌ្ឍនភាពល្អប្រសើរ ប៉ុន្តែពុំទាន់មានបច្ច័យខ្ពស់គ្រប់គ្រាន់នៅឡើយសម្រាប់ពន្លឿនការអនុវត្តថវិកាតាមត្រីមាសនីមួយៗ ពោលគឺ ការអនុវត្តថវិកានៅក្នុងត្រីមាសទី៣ នៅទាបជាងពិតាន (៧០%) ដែលមាននិន្នាការគរការអនុវត្តថវិកានៅចុងឆ្នាំ និងប្រតិបត្តិការថវិកានៅបន្ត។ ការជំរុញបញ្ចប់ការរៀបចំក្របខ័ណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយ ចំណាយកកស្ទះ នឹងរួមចំណែកកំណត់បញ្ហាប្រឈមជាក់ស្តែងនៃការអនុវត្តថវិកានៅចុងឆ្នាំ ខណៈការបញ្ចប់ ការដាក់ឱ្យអនុវត្ត សិទ្ធិសម្រេចលទ្ធកម្ម ជំហានទី២ ក៏នឹងរួមចំណែកដល់ការពន្លឿនការអនុវត្តថវិកាផងដែរ។ ដោយឡែក ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្មនៅមានកម្រិត ដែលកិច្ចការនេះ នឹងត្រូវបានពង្រឹងតាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

៧៧. ផ្នែកនេះផ្តោតលើគោលបំណងចំនួន ៥ រួមមាន (១)ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), (២) ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ថ្មី, (៣) ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ទ្រព្យសកម្មរយៈពេលវែង), (៤) ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធ ប្រកបដោយចីរភាព, និង (៥) ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។

### *គោលបំណង២១៖ ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS*

៧៨. នៅក្នុងគោលបំណងនេះ មានសូចនាករសមិទ្ធកម្មគន្លឹះចំនួន ៣ រួមមាន៖

*សគ ១. ចំនួនមុខសញ្ញាចំណាយ ធ្វើស្វ័យប្រវត្តិកម្មសម្រាប់អនុវត្តថវិកាតាមប្រព័ន្ធ FMIS នៅរដ្ឋបាលថ្នាក់កណ្តាល*

**គោលដៅ៖** នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើនីតិវិធីចំណាយ និងទូទាត់ចំណាយកម្រិត ៣ ត្រូវបានដាក់ឱ្យអនុវត្តផ្លូវការនៅ កសហវ. ព្រមទាំង កម្រិត ១ និង កម្រិត២ ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន។

៧៩. **វឌ្ឍនភាព៖** កសហវ. និងក្រសួងបរិស្ថានត្រូវបានប្រកាស និងដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មីលើនីតិវិធីចំណាយថវិកាចរន្តលើគ្រប់មុខសញ្ញាតាមប្រព័ន្ធ FMIS ទាំងស្រុង នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២។ ក្រសួង ស្ថាប័នបន្ថែមចំនួន ៧ ក្នុងចំណោម ក្រសួង ស្ថាប័ន ១០ ចុងក្រោយ (៣៤/៣៧) (រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិនៅថ្នាក់កណ្តាល) រួមមាន៖ ១-ក្រសួងយុត្តិធម៌, ២-ក្រសួងការពារជាតិ, ៣-ទីស្តីការគណៈរដ្ឋមន្ត្រី, ៤-គណៈកម្មាធិការរៀបចំការបោះឆ្នោត, ៥-អាជ្ញាធរសវនកម្មជាតិ, ៦-អង្គភាពប្រឆាំងអំពើពុករលួយ និង ៧-ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ និងរដ្ឋបាលទូទៅ) ត្រូវបានប្រកាស និងដាក់ឱ្យអនុវត្តនីតិវិធីថ្មីលើនីតិវិធីចំណាយបៀវត្សនិងនីតិវិធីចំណាយទូទាត់ត្រង់តាមប្រព័ន្ធ FMIS ទាំងស្រុង នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២។ ដោយឡែក ស្ថាប័នចំនួន ៣ (រដ្ឋសភា ព្រឹទ្ធសភា និង ក្រុមប្រឹក្សាធម្មនុញ្ញ) មាននីតិវិធីពិសេសដាច់ដោយឡែក និងពុំទាន់អាចអនុវត្តបាន។ ចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប គ្របដណ្តប់លើមុខសញ្ញាចំណាយដូចជា៖ ថ្លៃប្រើប្រាស់អគ្គិសនី, ថ្លៃប្រើប្រាស់ទឹកស្អាត, ថ្លៃប្រមូលសំរាម, ប្រាក់កំរៃភ្នាក់ងារបរទេសជាប់កិច្ចសន្យា, ថ្លៃជាវសៀវភៅរាជកិច្ច, សោហ៊ុយប្រៃសណីយ៍, សោហ៊ុយទូរគមនាគមន៍, ប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា និងស្រាវជ្រាវ, និងលតាប័ត្រសម្រាប់ចំណាយលើការបង់ពន្ធយានយន្តប្រចាំឆ្នាំ។

៨០. បន្ថែមពីនេះ, សន្ទានកម្មការទូទាត់សាច់ប្រាក់តាមអេឡិកត្រូនិក (EFT) ពីប្រព័ន្ធ FMIS ទៅប្រព័ន្ធធនាគារអេស៊ីលីដាទាំងនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២២។ ចំណែកឯសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធ NRMIS ត្រូវបានពង្រីកវិសាលភាពដល់រដ្ឋបាលរាជធានី-ខេត្តទាំង២៥។ ការទូទាត់តាមប្រព័ន្ធ FMIS អ្នកប្រើប្រាស់អាចជ្រើសរើសមធ្យោបាយនៃការទូទាត់ចំនួន ៣ ប្រភេទ រួមមាន ទូទាត់តាមលិខិតបញ្ជាផ្ទេរសាច់ប្រាក់, ទូទាត់តាមមូលប្បទានបត្រចេញពីប្រព័ន្ធ FMIS និង EFT ។ EFT ជាមុខងារនៅក្នុងប្រព័ន្ធ FMIS សម្រាប់ការទូទាត់សាច់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកជូនក្រុមហ៊ុនផ្គត់ផ្គង់ និងក្រសួង ស្ថាប័ន ដោយមិនតម្រូវឱ្យមាន ការបោះផ្សាយមូលប្បទានប័ត្រដោយអគ្គនាយកដ្ឋានរតនាគារជាតិឡើយ។ ការទូទាត់តាម EFT នេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រកាសដាក់ឱ្យដំណើរការពីថ្ងៃទី១ ខែមីនា

ឆ្នាំ២០១៨។ អត្ថប្រយោជន៍នៃការទូទាត់តាម EFT គឺសន្សំសំចៃពេលវេលា និងកាត់បន្ថយចំណាយលើការប្រើប្រាស់ក្រដាសស្នាម ដោយអ្នកប្រើប្រាស់ប្រព័ន្ធ FMIS អាចធ្វើការទូទាត់ និងផ្ទេរសាច់ប្រាក់ទៅកាន់គណនីធនាគាររបស់អ្នកទទួលផលបានឆាប់រហ័សតាមប្រព័ន្ធអេឡិចត្រូនិក។ ជាមួយគ្នានេះ រាល់ប្រតិបត្តិការដែលទូទាត់តាម EFT ពុំចាំបាច់រង់ចាំការជម្រះសាច់ប្រាក់ ទៀតនោះទេ មានន័យថា ប្រព័ន្ធ FMIS និងប្រព័ន្ធធនាគារនឹងទូទាត់កាត់កងសមតុល្យគណនីធនាគារស្របគ្នា ក្នុងថ្ងៃតែមួយ ដែលអាចផ្តល់នូវមូលដ្ឋានដ៏សំខាន់ និងទាន់ពេលក្នុងការផលិតរបាយការណ៍ រំហូរសាច់ប្រាក់ចេញពីប្រព័ន្ធ FMIS និងរបាយការណ៍តាមដានសាច់ប្រាក់ផ្សេងៗ សម្រាប់ថ្នាក់ដឹកនាំក្នុងការសម្រេចចិត្តជាយុទ្ធសាស្ត្រ។ ម្យ៉ាងទៀត ការទូទាត់តាម EFT អាចកាត់បន្ថយនូវការជួបគ្នារវាងអ្នកទទួលផល និងអ្នកបើកផ្តល់ ដែលចូលរួមចំណែកក្នុង ការពង្រឹងតម្លាភាព និង ប្រសិទ្ធភាពសេវាសាធារណៈ ដោយគោលដៅចុងក្រោយនោះ គឺដើម្បីឱ្យការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋបានទាន់ពេលវេលា និងតាមតម្រូវការ។

*សគ ២. មុខងារពីរបន្ថែមថ្មីក្នុងប្រព័ន្ធ FMIS ត្រូវបានពង្រីកការអនុវត្ត*

**គោលដៅ÷** មុខងាររៀបចំផែនការថវិកាត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅក្រសួងយ៉ាងតិច ១០ និង មុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់ក្រសួង ស្ថាប័ន។

៨១. **វឌ្ឍនភាព÷** មុខងារៀបចំផែនការថវិកាបានចាប់ផ្តើមអនុវត្តសាកល្បងនៅក្នុងឆ្នាំ២០២១ នៅ កសហវ. និងក្រសួងកិច្ចការនារី។ សម្រាប់ឆ្នាំ២០២២ នេះបានបន្តដាក់ឱ្យប្រើប្រាស់នៅក្រសួង ស្ថាប័នចំនួន ១១ បន្ថែមទៀត រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល។

៨២. មុខងាររៀបចំផែនការថវិកា គ្រប់គ្រងវដ្តនៃដំណើរការរៀបចំផែនការថវិកាប្រចាំឆ្នាំ ដែលរួមមានការរៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល, ការរៀបចំកញ្ចប់ថវិកា និងការអនុម័តថវិកា ក្នុងក្របខ័ណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រសួង ស្ថាប័ន អាចកត់ត្រាគម្រោងចំណូល-ចំណាយថវិកាប្រចាំឆ្នាំលម្អិតទៅតាមចំណាត់ថ្នាក់ថវិកា ដែលរួមមានទាំងចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់សេដ្ឋកិច្ច និងបញ្ជូនតាមប្រព័ន្ធទៅកាន់ដំណាក់កាលនីមួយៗនៃការរៀបចំផែនការថវិកា។ មុខងាររៀបចំផែនការថវិកាក្នុងប្រព័ន្ធ FMIS មានអត្ថប្រយោជន៍ ដូចជា (១) ទិន្នន័យ និងឯកសារពាក់ព័ន្ធ ត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធតែមួយដែលមានសុវត្ថិភាព និងមិនងាយបាត់បង់, (២) ផ្តល់ភាពងាយស្រួលក្នុងការកែតម្រូវលើគម្រោងចំណូល-ចំណាយថវិកា និងចំណេញពេលវេលា, (៣) អាចត្រួតពិនិត្យគម្រោងថវិកាឆ្នាំចាស់ និងគម្រោងថវិកាឆ្នាំថ្មី, (៤) គ្រប់គ្រងព័ត៌មាន ផ្ទៀងផ្ទាត់ និងបូកសរុបលើកញ្ចប់ថវិកា, (៥) ត្រួតពិនិត្យ និងតាមដានរាល់ចំណាយរបស់អង្គភាពថវិកានីមួយៗ, (៦) កំណត់ពិតានថវិកាក្នុងការរៀបចំគម្រោងចំណូល-ចំណាយប្រចាំឆ្នាំ, (៧) បន្ថយចំណាយលើការប្រើប្រាស់ឯកសារជាក្រដាស, និង (៨) ងាយស្រួលក្នុងការប្រៀបធៀបលើកញ្ចប់ថវិកាដែលបានអនុវត្ត ទៅនឹងផែនការដែលបានគ្រោង។

៨៣. ដោយឡែក ចំពោះមុខងារលទ្ធកម្មពេញលេញ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០២១ នៅក្រសួងចំនួន ៣ រួមមាន កសហវ., ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារី។ ក្នុងឆ្នាំ២០២២ មុខងារនេះត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំងអស់ដែលបាននិងកំពុងប្រើប្រាស់ប្រព័ន្ធ FMIS លើកលែងតែអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ នៃ កសហវ. ដែលទើបបានប្រើប្រាស់ប្រព័ន្ធ FMIS នៅចុងឆ្នាំ២០២២។

៨៤. **មុខងារលទ្ធកម្មពេញលេញ**ក្នុងប្រព័ន្ធ FMIS មានសមត្ថភាពអាចគ្រប់គ្រងរាល់ដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈទាំងអស់ ដែលរួមមាន (១) ការគ្រប់គ្រងបញ្ជីឈ្មោះអ្នកដេញថ្លៃ, (២) ការរៀបចំផែនការលទ្ធកម្ម, (៣) ការគ្រប់គ្រងដំណើរការដេញថ្លៃ និង (៤) ការគ្រប់គ្រងកិច្ចសន្យា។

*សគ ៣. ចំនួនការដ្ឋានអនុវត្តគម្រោង FMIS បន្ថែមថ្មី (ពង្រីកការប្រើប្រាស់មុខងារស្នូលរបស់ប្រព័ន្ធ FMIS ទៅកាន់អង្គភាពថ្នាក់ជាតិ, អង្គភាពថ្នាក់ក្រោមជាតិ, និងគ្រឹះស្ថានសាធារណៈរដ្ឋបាល)*

**គោលដៅ÷** អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មីនៅថ្នាក់កណ្តាលចំនួន១០ យ៉ាងតិច និងរដ្ឋបាលរាជធានី ខេត្តទាំង២៥ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS។ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មីនៅថ្នាក់កណ្តាល ចំនួន២ យ៉ាងតិច និងគ្រឹះស្ថានសាធារណៈរដ្ឋបាលយ៉ាងតិចចំនួន ៥ ត្រូវដំឡើងប្រព័ន្ធ FMIS សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២៣។

៨៥. **វឌ្ឍនភាព÷** ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងឆ្នាំ២០១៤ និងត្រូវបានពង្រីកការប្រើប្រាស់ជាដំណាក់កាលៗ។ ដំណាក់កាលទី១ (២០១៤-២០១៦)÷ គឺជាការកសាងមូលដ្ឋានគ្រឹះប្រព័ន្ធ FMIS ឱ្យមានលក្ខណៈគ្រប់គ្រាន់ និងរៀបចំរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធដ៏រឹងមាំ ដែលមានមុខងារស្នូលចំនួន ៦ (BA, PO, AP, AR, GL, និង CM) ត្រូវបានដាក់ឱ្យអនុវត្តនៅអគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះចំនួន ៨ នៃ កសហវ. រួមមាន (១) អគ្គលេខាធិការដ្ឋាន, (២) អគ្គនាយកដ្ឋានរតនាគារជាតិ, (៣) អគ្គនាយកដ្ឋានថវិកា, (៤) អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល, (៥) អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, (៦) អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, (៧) អគ្គាធិការដ្ឋាន, (៨) អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ព្រមទាំងរតនាគាររាជធានី ខេត្តទាំង ២៥។ ដំណាក់-កាលទី២ (២០១៧-២០២០)÷ ក្រសួង ស្ថាប័នចំនួន ៣៧, អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ២៥ និងមន្ទីរ សហវ. រាជធានី ខេត្តទាំង ២៥ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាជំហានៗ នូវមុខងារស្នូលរបស់ប្រព័ន្ធ FMIS។ ដំណាក់កាលទី៣ (២០២១-២០២៥)÷ បានប្រកាស់ដាក់ឱ្យអនុវត្តនៅអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន២ គឺអគ្គលេខាធិការដ្ឋានជាតិគាំពារសង្គម និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្នុងឆ្នាំ២០២១ និងក្នុងឆ្នាំ២០២២ បានពង្រីកទៅកាន់អង្គភាពថ្នាក់ជាតិ អង្គភាពថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសា-ធារណៈរដ្ឋបាលបន្ថែមទៀតរួមមាន÷ រដ្ឋបាលរាជធានី ខេត្តទាំង២៥, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលចំនួន ១០។ ជាមួយគ្នានេះ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលចំនួន ១០ បន្ថែមថ្មី និងគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន៤ រួមមាន (១) គ្រឹះស្ថានអង្គរ, (២) មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "**តេជោ**", (៣) រាជបណ្ឌិត្យសភាកម្ពុជា និង (៤) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានដំឡើងប្រព័ន្ធ FMIS សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២៣។

៨៦. បន្ថែមពីនេះ, រដ្ឋបាលស្រុកចំនួន ៧៥ និងរដ្ឋបាលឃុំចំនួន ១៨៥ បានប្រើប្រាស់សាកល្បងប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ជាផ្លូវការនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០២២ និងទទួលបានការគាំទ្រលើការប្រើប្រាស់។ ជាមួយគ្នានេះ, ប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ត្រូវបានអភិវឌ្ឍ និង តេស្តសាកល្បងរួចរាល់សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅរដ្ឋបាលក្រុងចំនួន ៦, រដ្ឋបាលស្រុកចំនួន ៦១, រដ្ឋបាលឃុំចំនួន ៤៤៧ និងរដ្ឋបាលសង្កាត់ចំនួន ២៨ ការដ្ឋានបន្ថែម។

*គោលបំណង២២÷ ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ថ្មី*

៨៧. គោលបំណងនេះ មានសូចនាករសមិទ្ធកម្មចំនួន ៣ និងមានវឌ្ឍនភាពដូចតទៅ÷

*សត ៤ ភាពទាន់ពេលវេលានៃការបិទកិច្ចបញ្ជីគណនេយ្យ*

**គោលដៅ÷** ការបិទបញ្ជីគណនេយ្យឱ្យបានទាន់ពេលវេលាក្នុងរយៈពេលពី ៦ ខែ ទៅ ៩ខែ។

៨៨. **វឌ្ឍនភាព÷** ការបិទបញ្ជីគណនេយ្យឆ្នាំ២០២១ នៅក្នុងខែកញ្ញា ឆ្នាំ២០២២។

*សត៥. កម្រិតអនុលោមភាព នៃរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា IPSAS Cash Basis*

**គោលដៅ÷** របាយការណ៍ហិរញ្ញវត្ថុអាចទទួលយកបានស្របតាម IPSAS Cash Basis។

៨៩. **វឌ្ឍនភាព÷** របាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានសាច់ប្រាក់ (IPSAS Cash Basis) ឆ្នាំ២០២០ ត្រូវបានរៀបចំរួចរាល់ ផ្អែកលើមូលដ្ឋានទិន្នន័យពីប្រព័ន្ធ FMIS ព្រមទាំងត្រូវបានវាយតម្លៃដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និង និយ័តករគណនេយ្យនិងសវនកម្ម ថាមានភាពល្អប្រសើរជាងការរៀបចំក្នុងឆ្នាំ២០១៩។ ទោះបីជាយ៉ាងណាក៏ដោយ, ស្តង់ដាគណនេយ្យចំនួន៣ ដោយផ្អែកលើមូលដ្ឋានសេចក្តីព្រាងស្តង់ដាលេខ៧០ (សមមូលនឹងស្តង់ដា IFRS 15÷ ផលរបរពីប្រតិបត្តិការដោះដូរ), លេខ៧១ (ផលរបរពីប្រតិបត្តិការមិនមែនដោះដូរ), និងលេខ៧២ (ចំណាយ ប្រតិបត្តិការមិនមែនដោះដូរ) មិនទាន់ត្រូវបានបញ្ចប់តាមផែនការនៅឡើយ ដែលត្រូវបានពិនិត្យ និងអនុម័ត នៅ កម្រិតក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនៅត្រីមាសទី៣ ឆ្នាំ២០២២ នេះ (នៅរង់ចាំសេចក្តីព្រាង ពីជំនាញការ IMF)។ បន្ថែមពីនេះ យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។

*សត៦. ភាពទាន់ពេលវេលានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ*

**គោលដៅ÷** របាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០២០ ត្រូវបានរៀបចំរួចរាល់ក្នុងត្រីមាសទី១ ឆ្នាំ២០២២។

៩០. **វឌ្ឍនភាព÷** របាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០២០ ត្រូវបានរៀបចំរួចរាល់ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ដោយយកមូលដ្ឋាន ចេញពីប្រព័ន្ធ FMIS។ បន្ថែមពីនេះ សេចក្តីព្រាងបឋមច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំ២០២១ ត្រូវបាន រៀបចំ និងបានផ្ញើជូនអាជ្ញាធរសវនកម្មជាតិនៅខែមិថុនា ឆ្នាំ២០២២។

### *គោលបំណង២៣÷ ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ទ្រព្យសកម្មរយៈពេលវែង)*

៩១. គោលបំណងនេះ មានសូចនាករសមិទ្ធកម្មចំនួន ១ និងមានវឌ្ឍនភាពដូចតទៅ÷

*សត៧. មានរបាយការណ៍បូកសរុបទ្រព្យសម្បត្តិរដ្ឋ (Consolidation report) របស់ក្រសួង ស្ថាប័ន, មន្ទីរអង្គភាព ជំនាញថ្នាក់មូលដ្ឋាននិងរដ្ឋបាលថ្នាក់ក្រោមជាតិ*

**គោលដៅ÷** មានរបាយការណ៍បូកសរុបទ្រព្យសម្បត្តិរដ្ឋ (Consolidation report) កម្រិតក្រសួង ស្ថាប័ន, មន្ទីរអង្គភាព ជំនាញថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៩២. **វឌ្ឍនភាព÷** បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២១ ទទួលបាន ៨៧ % (២៦៤៣/៣០៥៣)។ វឌ្ឍនភាព គួរឱ្យកត់សម្គាល់នេះ ដោយសារការដាក់ឱ្យអនុវត្តនូវប្រព័ន្ធ SARMIS នៅគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់-ក្រោមជាតិ រហូតដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ តាមរយៈផែនការសកម្មភាព នៃយន្តការអន្តរក្រសួង, ក្រុមការងារ បាននិងកំពុងចុះទៅគោលដៅទាំង ២៥ រាជធានី ខេត្ត ដើម្បីពិនិត្យស្ថានភាពដីរដ្ឋ ដើម្បីប្រមូលផ្តុំទិន្នន័យ៣ ប្រភេទ រួមមាន ដីទំនាស់, ដីកំពុងស្ថិតនៅក្នុងនីតិវិធី, និងដីដែលកំពុងចាប់ផ្តើមនីតិវិធី ហើយនឹងបូកសរុបរបាយ-

ការណ៍នៅខែមករា ឆ្នាំ២០២៣។ ជាមួយគ្នានេះ ក្រុមការងារអន្តរក្រសួង បានចុះផ្សព្វផ្សាយ ណែនាំ និងជំរុញការធ្វើប័ណ្ណកម្មសិទ្ធិលើដីរដ្ឋចាប់តាំងពីខែតុលា ឆ្នាំ២០២២ មក ដោយមានរៀបចំជារបាយការណ៍លទ្ធផលជូនគណៈកម្មការអន្តរក្រសួង និងបានរៀបចំសិក្ខាសាលាស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធ SARMIS ជូនគ្រូបង្គោលរបស់មន្ទីរ សហវ. រាជធានី ខេត្តទាំង២៥ ដើម្បីយកទៅបណ្តុះបណ្តាលបន្តដល់រដ្ឋបាលឃុំសង្កាត់នៅក្នុងឆ្នាំ២០២៣។ ជាមួយយន្តការអន្តរក្រសួងនេះ ការដាក់ពាក្យស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិ កើនឡើងរហូតដល់ចំនួន ៥៣៨៨ កន្លែង (ផ្អែកលើទិន្នន័យបឋមពី ១៨ ខេត្ត)។

៩៣. អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ប្រកាសស្តីពីវិធាន និងនីតិវិធីធ្វើនីត្យានុកូលកម្មឡើងវិញនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងដែលមិនមានការឯកភាពពី កសហវ. ត្រូវបានរៀបចំជាសេចក្តីព្រាង។ ប្រកាសនេះ ដើរតួនាទីសំខាន់ក្នុងការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងកិច្ចសន្យា ឬកិច្ចព្រមព្រៀងជួលទ្រព្យសម្បត្តិរដ្ឋ។

៩៤. ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរំកិលកាលរៀបចំទៅឆ្នាំ២០២៣។ ឯកសារគោលនេះនឹងរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជាអាទិ៍÷ ការពង្រឹងគុណភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, ការជំរុញការធ្វើប័ណ្ណកម្មសិទ្ធិដីរដ្ឋ, និងការពង្រឹងយន្តការជម្រះបញ្ជីសារពើ-ភណ្ឌ។ល។

### *គោលបំណង២៤÷ ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធ ប្រកបដោយចីរភាព*

៩៥. គោលបំណងនេះ មានសូចនាករសមិទ្ធកម្មចំនួន ២ និងមានវឌ្ឍនភាពដូចតទៅ÷

#### *សគ៨. សូចនាករបំណុលគន្លឹះទាំង ៥ ធៀបទៅនឹងពិតាន*

**គោលដៅ÷** សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការ-គ្រប់គ្រងបំណុលសាធារណៈ។

៩៦. **វឌ្ឍនភាព÷** សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៩-២០២៣ ក្នុងនោះ (១) អនុបាតតម្លៃបច្ចុប្បន្ន នៃបំណុលសាធារណៈសរុបធៀបនឹង ផសស. ស្ថិតក្នុងរង្វង់ ២៥,២% ធៀបនឹងពិតាន ៥៥%, (២) អនុបាតតម្លៃបច្ចុប្បន្ន នៃបំណុលសាធារណៈ ក្រៅប្រទេសធៀបនឹង ផសស. ស្ថិតក្នុងរង្វង់ ២៤,៩% ធៀបនឹងពិតាន ៤០%, (៣) អនុបាតតម្លៃបច្ចុប្បន្ន នៃ បំណុលសាធារណៈ ក្រៅប្រទេសធៀបនឹងការនាំចេញ ស្ថិតក្នុង រង្វង់ ៣៣,៩% ធៀបនឹងពិតាន ១៨០%, (៤) អនុបាតសេវាបំណុល សាធារណៈក្រៅប្រទេសធៀបនឹងការនាំ ចេញស្ថិតក្នុងរង្វង់ ២,១% ធៀបនឹងពិតាន ១៥%, និង (៥) អនុបាតសេវាបំណុល សាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិ ស្ថិតក្នុងរង្វង់ ៧,៨% ធៀបនឹងពិតាន ១៨%។

#### *សគ៩. ហានិភ័យបំណុលត្រូវបានកំណត់*

**គោលដៅ÷** ការវិភាគហានិភ័យបំណុលពាក់ព័ន្ធ និងហានិភ័យកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវបានរៀបចំដាក់បញ្ចូលនៅក្នុងរបាយការណ៍ដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ។

៩៧. **វឌ្ឍនភាព÷** បានរៀបចំរបាយការណ៍វឌ្ឍនភាព ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានខ្លឹមសារហានិភ័យបំណុលសាធារណៈ ដោយបង្ហាញហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities), ហានិភ័យថវិកា (Fiscal Risk), ហានិភ័យទីផ្សារ (Market Risk), ហានិភ័យប្រតិបត្តិការ (Operational Risk), ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk), ហានិភ័យហិរញ្ញប្បទាននៃគម្រោង (Project Funding Risk) និងហានិភ័យឥណទាន (Credit Risk) ប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០២១, ត្រីមាសទី១, ទី២, និងទី៣ ឆ្នាំ២០២២ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់ អ.ស.ប.។

*គោលបំណង២៥÷ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ*

៩៨. គោលបំណងនេះ មានសូចនាករសមិទ្ធកម្មចំនួន ២ និងមានវឌ្ឍនភាពដូចតទៅ÷

*សគ១០. មានយន្តការច្បាស់លាស់ក្នុងការតាមដានគ្រឹះស្ថានសាធារណៈរដ្ឋបាល កម្រិត កសហវ.*

**គោលបំណង÷** គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានអនុវត្តតាមលក្ខខណ្ឌវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីនេះ, គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២ នឹងត្រូវបានដាក់ឱ្យអនុវត្តសាកល្បងវាយតម្លៃលក្ខខណ្ឌវិនិច្ឆ័យអប្បបរមានេះ។

៩៩. **វឌ្ឍនភាព÷** លក្ខខណ្ឌវិនិច្ឆ័យអប្បបរមាសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានរៀបចំរួចរាល់ និងទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំ កសហវ. នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។ លក្ខខណ្ឌវិនិច្ឆ័យអប្បបរមានេះចែកចេញជា ៦ ប្រភេទ ហើយប្រភេទនីមួយៗ មានសមាសភាពសម្រាប់ជាមូលដ្ឋានវាយតម្លៃ។ **ប្រភេទទី១÷** មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្ម ដែលមានសមាសភាពពាក់ព័ន្ធរួមមាន គណនេយ្យករ, រដ្ឋទេយ្យករបុរេប្រទាន, រដ្ឋទេយ្យករចំណូល, ភ្នាក់ងារបើកផ្តល់, មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ និងមន្ត្រីអង្គភាពលទ្ធកម្ម។**ប្រភេទទី២÷** នីតិវិធីអនុវត្តចំណូលថវិកា រួមមាន អនុវត្តការប្រមូលចំណូល និងសលាកបត្របង់ចំណូលថវិកា។ **ប្រភេទទី៣÷** នីតិវិធីអនុវត្តចំណាយថវិកា ដែលត្រូវអនុលោមតាមដំណាក់កាលនៃបរិបទចំណាយរួមមាន ធានាចំណាយ, កិច្ចលទ្ធកម្ម, ជម្រះបញ្ជី, អាណត្តិកិច្ច និងការទូទាត់។ **ប្រភេទទី៤÷** កិច្ចបញ្ជិការគណនេយ្យ ដែលរួមមាន គណនេយ្យទូទៅ, គណនេយ្យរដ្ឋទេយ្យចំណូល, គណនេយ្យរដ្ឋទេយ្យបុរេប្រទាន។ **ប្រភេទទី៥÷** ប្រព័ន្ធ FMIS ដែលស្របតាមគោលការណ៍ណែនាំរបស់ កសហវ.។ **ប្រភេទទី៦÷** របាយការណ៍ ដែលត្រូវមានរបាយការណ៍អនុវត្តថវិកា, របាយការណ៍សមិទ្ធកម្ម, របាយការណ៍ហិរញ្ញវត្ថុ, តារាងតុល្យភាពរដ្ឋទេយ្យចំណូល, តារាងតុល្យភាពរដ្ឋទេយ្យបុរេប្រទាន, របាយការណ៍លទ្ធកម្ម និងរបាយការណ៍បញ្ជីសារពើភណ្ឌ។ ទោះជាយ៉ាងណាក៏ដោយ, លក្ខខណ្ឌវិនិច្ឆ័យអប្បបរមាសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំ កសហវ. នៅពុំទាន់បានដាក់ឱ្យអនុវត្តសាកល្បងនៅឡើយ។ ទន្ទឹមនេះ, នៅក្នុងឆ្នាំ២០២២ មានគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន២៩ ក្នុងចំណោម ៣០ បានផ្ញើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ មកអគ្គនាយកដ្ឋានរតនាគារជាតិ ហើយមានតែរបាយការណ៍របស់គ្រឹះស្ថានចំនួន២៧ ប៉ុណ្ណោះដែលរៀបចំស្របតាមគោលការណ៍ណែនាំដាក់ឱ្យអនុវត្តសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអាចធ្វើការបូកសរុបបាន។

*សគ១១. មានយន្តការច្បាស់លាស់ក្នុងការតាមដានសហគ្រាសសាធារណៈកម្រិត កសហវ.*

**គោលបំណង÷** សេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសសាធារណៈ ត្រូវបានដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គនីតិបញ្ញត្តិ។

១០០. **វឌ្ឍនភាព÷** ការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ(ឈ្មោះថ្មីសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ) ត្រូវបានពន្យារពេលរៀបចំទៅឆ្នាំ២០២៣ សម្រាប់ដាក់ឆ្លងទៅទីស្តីការគណៈរដ្ឋមន្ត្រី និងដាក់ទៅស្ថាប័ននីតិបញ្ញត្តិ នៅត្រីមាសទី៤ ឆ្នាំ២០២៣។ ការពន្យារពេលនេះ ដោយសារត្រូវរង់ចាំការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ។ ក្រុមការងារបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ លើសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ដោយមានការចូលរួមពីបណ្តាសហគ្រាសសាធារណៈ, ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស, ក្រុមការងារកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ មួយចំនួនទៀត។

១០១. **ជាការសន្និដ្ឋានក្នុងផ្នែកទី២,** ប្រព័ន្ធ FMIS ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ហើយត្រូវបានពង្រីកដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី ខេត្ត។ ទន្ទឹមនេះ ប្រព័ន្ធ FMIS ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ព្រមទាំងការដាក់ឱ្យអនុវត្តមុខងារលទ្ធកម្មពេញលេញ និងមុខងាររៀបចំថវិកា តាមក្រសួង ស្ថាប័នជាបណ្តើរៗ។ ការបន្តជំរុញការអនុវត្តនីតិវិធីថ្មី តាមប្រព័ន្ធ FMIS ទាំងស្រុង អាចសម្រេចបាន ជោគជ័យពេញលេញទៅតាមផែនការ តម្រូវឱ្យមានចូលរួមកាន់តែខ្លាំងឡើង និងការគាំទ្រទាំងកម្រិតបច្ចេកទេស និងនយោបាយ ពីគ្រប់ភាគីពាក់ព័ន្ធទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ និន្នាការនេះឬឌីជីថលូបនីយកម្ម តម្រូវឱ្យមានការគិតគូរអំពីហត្ថលេខាអេឡិចត្រូនិក និងគោលនយោបាយឌីជីថល។ ដោយឡែកការបិទបញ្ជីគណនេយ្យ ត្រូវបន្តយកចិត្តទុកដាក់ ស្របតាមទិសដៅនៃការកែទម្រង់ ដែលកិច្ចការនេះ តម្រូវឱ្យមានការជំរុញពីគ្រប់ភាគីពាក់ព័ន្ធ។ ខាងផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមានកម្រិតដែលនឹងត្រូវបានពង្រឹង តាមរយៈការដាក់ឱ្យអនុវត្តឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ ចំណែកឯការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀត។ វិធានការគន្លឹះទាំងនេះ នឹងជួយពង្រឹងប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងថវិកា។

## ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

១០២. នៅក្នុងផ្នែក**ការ**ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺផ្តោតលើគោលបំណងចំនួន ៤ រួមមាន (១) រៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម, (២) ពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ, (៣) ពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា, និង (៤) ជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

១០៣. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្មក្នុងម៉ូដែលជា "**ថវិកាព័ត៌មានសមិទ្ធកម្ម**" ។ ផែនការសកម្មភាពត្រូវបានបែងចែកជាផ្នែកទាំង ៥ មាន ១៥ គោលបំណង ដែលចែកជាពីរដំណាក់កាល រួមមាន÷ ដំណាក់កាលទី១ ចាប់ពីឆ្នាំ២០១៨-២០២១ ផ្តោតលើការកសាងមូលដ្ឋានចាំបាច់សម្រាប់ការចាប់ផ្តើមអនុវត្តថវិកាសមិទ្ធកម្ម និងដំណាក់កាលទី២ ចាប់ពីឆ្នាំ ២០២២-២០២៥ ផ្តោតលើការអនុវត្តសាកល្បងថវិកាសមិទ្ធកម្ម។ មួយផ្នែកនៃយុទ្ធសាស្ត្រនេះគឺអនុវត្ត ក្នុងផ្នែកទី៣

ដើម្បីកសាង និងបង្កើតប្រព័ន្ធថវិការយៈពេលមធ្យម ដែលផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រចតុកោណ, ផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ។

### *គោលបំណង ៣១÷ រៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម*

១០៤. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន៣ ហើយសម្រេចបានលទ្ធផល ដូចខាងក្រោម÷

*សគ ១.ការដាក់ឆ្លងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម(MTFF) នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងអនុវត្តជាប្រចាំ*

**គោលដៅ÷** ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៣-២០២៥ ត្រូវបានដាក់ឆ្លងនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០២២

១០៥. **វឌ្ឍនភាព**÷សេចក្តីព្រាងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ២០២៣-២០២៥ ត្រូវបានរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច។ អនុវត្តតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្នុងការពន្យាពេលអនុវត្ត ១ឆ្នាំទៀត, អគ្គនាយកដ្ឋានគោលនយោបាយ បានរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ជំនួសក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ២០២៣-២០២៥ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដោយភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយសកល ដែលបណ្តាលមកពីជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរវាងអ៊ុយក្រែន និងរុស្ស៊ី ព្រមទាំងការផ្លាស់ប្តូរកម្រងទិន្នន័យ ផ.ស.ស ដោយប្រើប្រាស់ឆ្នាំគោលថ្មី ដែលនឹងធ្វើឱ្យរចនាសម្ព័ន្ធនៃសេដ្ឋកិច្ច មានការប្រែប្រួល។

*សគ ២. ការអនុម័តក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ដោយមានពិតានថវិកាតាមវិស័យតាមក្រសួង ស្ថាប័ន ដោយប្រមុខរាជរដ្ឋាភិបាល*

**គោលដៅ÷** ក្របខ័ណ្ឌថវិការយៈពេលមធ្យម ដោយមានកំណត់ពិតានថវិកាតាមវិស័យ តាមក្រសួង ស្ថាប័ន ត្រូវបានអនុម័ត ដោយប្រមុខរាជរដ្ឋាភិបាលនៅឆ្នាំ២០២២ និងឆ្នាំបន្តបន្ទាប់

១០៦. **វឌ្ឍនភាព**÷ក្របខ័ណ្ឌថវិការយៈពេលមធ្យមដោយមានកំណត់ពិតានតាមវិស័យ តាមក្រសួង ស្ថាប័ន ត្រូវបានរៀបចំ និងទទួលបានការសម្រេចដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាលនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២។

*សគ ៣. ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំដោយមានសូចនាករសមិទ្ធកម្ម*

**គោលដៅ÷** គ្រប់ក្រសួង ស្ថាប័នរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយមានការកំណត់សូចនាករសមិទ្ធកម្មនៅឆ្នាំ២០២២ សម្រាប់ថវិកាឆ្នាំ ២០២៣។

១០៧. **វឌ្ឍនភាព**÷ គ្រប់ក្រសួង ស្ថាប័នបានរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយមានសូចនាករសមិទ្ធកម្ម។

### *គោលបំណង ៣២÷ ពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ*

១០៨. យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានប្រមុខរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ និងប្រកាសដាក់ឱ្យអនុវត្ត នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្នុងគោលបំណងបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈរួម

មួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតប ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងពង្រឹងសមត្ថភាព ប្រកបដោយចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្នឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។

១០៩. យុទ្ធសាស្ត្រនេះ មានវិសាលភាពគ្របដណ្តប់លើគ្រប់គម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីថវិកាជាតិ, ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន) និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល)។

១១០. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន ៣ ហើយសម្រេចបានលទ្ធផល ដូចតទៅ÷

### *សត ៤. ការរៀបចំយន្តការគ្រប់គ្រងវដ្តគម្រោងវិនិយោគសាធារណៈ*

**គោលដៅ÷** ឯកសារពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈត្រូវបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយ។

១១១. **វឌ្ឍនភាព÷** ក្នុងឆ្នាំ២០២២ ឯកសារស្តីពីនីតិវិធីប្រតិបត្តិរបស់គណៈកម្មការវិនិយោគសាធារណៈត្រូវបានរៀបចំរួចរាល់។ អគ្គនាយកដ្ឋានថវិកាបានរៀបចំ និងដាក់ប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេស និងទទួលបានការអនុម័ត និងដាក់ឱ្យអនុវត្តនូវប្រកាសស្តីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។ ម្យ៉ាងទៀត ប្រកាសស្តីពីនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញ-ប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់) ត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ នាថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២។ គោលការណ៍ណែនាំស្តីពីមូលនិធិអភិវឌ្ឍន៍គម្រោង PPP (PDF) និងអនុក្រឹត្យស្តីពីការអនុវត្តនីតិវិធីប្រតិបត្តិការ (SOP) សម្រាប់រៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ត្រូវបានអនុម័តនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ និងបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២។ គោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការ នៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តផងដែរ។

## *គោលបំណង៣៣÷ ពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា*

១១២. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន៤ ហើយសម្រេចបានលទ្ធផល ដូចតទៅ÷

### *សត ៥. ការញែកបន្ទុកបុគ្គលិកបានតាមកម្មវិធីនីមួយៗឆ្នាំ N+1*

**គោលដៅ÷** បន្ទុកបុគ្គលិកត្រូវបានញែកតាមកម្មវិធីនីមួយៗរបស់ក្រសួង ស្ថាប័ននៅឆ្នាំ ២០២២ សម្រាប់ថវិកាឆ្នាំ ២០២៣។

១១៣. **វឌ្ឍនភាព÷** ដោយហេតុថាបច្ចុប្បន្នបន្ទុកបុគ្គលិកត្រូវបានដាក់ក្នុងកម្មវិធីគាំទ្រ, ក្រសួង ស្ថាប័នមានការលំបាកក្នុងការញែកបន្ទុកបុគ្គលិកទៅតាមកម្មវិធី ដែលចាំបាច់តម្រូវឱ្យមានការសិក្សាច្បាស់លាស់នៅតាមក្រសួង ស្ថាប័ននីមួយៗ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានថវិកាបានផ្លាស់ប្តូរគោលដៅសម្រាប់ឆ្នាំ២០២២ មកត្រឹមការរៀបចំរបាយ-

ការណ៍ចំណាយបន្ទុកបុគ្គលិកដើម្បីពិនិត្យ និងសិក្សាបន្ថែមជាមូលដ្ឋានលើការព្យាករបន្ទុកបុគ្គលិកនេះ។ ជាលទ្ធផលក្នុងឆ្នាំ២០២២ ក្រសួង ស្ថាប័ន បានសាកល្បងធ្វើរបាយការណ៍ចំណាយបន្ទុកបុគ្គលិកតាមកម្មវិធីសម្រាប់ឆ្នាំ២០២១។

*សគ ៦. ការកាត់បន្ថយគម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ (N+1)*

**គោលដៅ ២០២២÷** គម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ (N+1) ត្រូវបានរក្សាមិនឱ្យលើសជា អតិបរមាត្រឹម ២០%។

១១៤. **វឌ្ឍនភាព÷**ក្រសួង ស្ថាប័ន ចំនួន ១៥ ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃបន្ថែមលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។ បន្ថែមពីនេះ គម្លាតរវាងពិតានចំណាយគោលដែលកំណត់ក្នុងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងលទ្ធផលកញ្ចប់ថវិកាប្រចាំឆ្នាំ ទាបជាង ១៥%។

*សគ ៧ (១) ចំនួនក្រសួង ស្ថាប័នត្រួតពិនិត្យលក្ខណៈសម្បត្តិអង្គភាពថវិកា និង(២) ក្របខ័ណ្ឌវាយតម្លៃអង្គភាព ថវិកា*

១១៥. ក្នុងទិសដៅវិមជ្ឈការហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័ន, រាជរដ្ឋាភិបាលបានដាក់ចេញ អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការរៀបចំ អនុវត្តថវិកា ព្រមទាំងត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងថវិកា។ ទន្ទឹមនេះកសហវ. បានចេញប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តថវិកាតាមរយៈការប្រគល់អាណត្តិកិច្ចច្បាស់លាស់ ដើម្បីសម្រេចបានសមិទ្ធកម្មការងារ ។

**គោលដៅ÷** (១) របាយការណ៍បូកសរុបការវាយតម្លៃនៃការបង្កើតអង្គភាពថវិកា ត្រូវបានរៀបចំ និង (២) គ្រប់ក្រសួង ស្ថាប័ន ត្រូវបានធ្វើការវាយតម្លៃ និងបូកសរុប

១១៦. **វឌ្ឍនភាព÷** ក្រសួង ស្ថាប័នចំនួន៣៧ បានត្រួតពិនិត្យលក្ខណៈសម្បត្តិអង្គភាពថវិកា។

*សគ ៨. ចំនួនអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិត្រូវបានបង្កើតអនុលោមតាមគោលការណ៍ណែនាំរបស់ កសហវ.*

**គោលដៅ÷** (១) បន្ថែមចំនួន ៣ អង្គភាពថវិកាជាអាណប័កផ្ទេរសិទ្ធិថែមទៀត និង (២)បន្ថែម ១០ អង្គភាពថវិកានៅតាមក្រសួង ស្ថាប័ន អង្គភាពថវិកា។

១១៧. **វឌ្ឍនភាព÷**អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេលលេញថ្មីចំនួន ៩ បានបង្កើតឡើងក្នុងឆ្នាំ ២០២២ និងអង្គភាពថវិកាថ្មី ចំនួន ២៨ បន្ថែមត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០២២។ គិតត្រឹមឆ្នាំ២០២២ អង្គភាពថវិកាមានចំនួនសរុប ៩៤០ ដែលក្នុងនោះរដ្ឋបាល ថ្នាក់កណ្តាល មានចំនួន ៣៣៧ និង ថ្នាក់មូលដ្ឋាន (មន្ទីរជំនាញរាជធានី ខេត្ត)ចំនួន ៦០៣។ សម្រាប់ថ្នាក់កណ្តាល មានអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ៨៧ និងមិនទាន់ផ្ទេរសិទ្ធិពេញលេញចំនួន ២៥០ និងសម្រាប់ថ្នាក់មូលដ្ឋាន គ្រប់អង្គភាពថវិកាទាំងអស់ ត្រូវបានផ្ទេរសិទ្ធិជាអាណាប័កផ្ទេរសិទ្ធិពេញលេញ។

## *គោលបំណង ៣៤÷ ជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ*

១១៨. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន ២ ហើយសម្រេចបានលទ្ធផលដូចទៅ÷

*សគ ៩. សមាហរណកម្មផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិរវាងរាជធានី ខេត្ត ជាមួយនឹងថវិកាក្រុង ស្រុក និង ថវិកាឃុំ សង្កាត់*

**គោលដៅ÷** សមាហរណកម្មផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិរវាងរាជធានី ខេត្ត ជាមួយនឹងថវិកាក្រុង ស្រុក និង ថវិកាឃុំ សង្កាត់ នៅគ្រប់រាជធានីខេត្ត

១១៩. **វឌ្ឍនភាព÷** ប្រកាសលេខ០១៤៩ ផកប្រ.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ត្រូវបានរៀបចំ និងផ្សព្វផ្សាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០២២ មានរដ្ឋបាលក្រុង ស្រុកចំនួន ១០២ មានផែនការសម្រាប់ធ្វើសមាហរណកម្មនៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

*សគ ១០. ការធ្វើប្រតិភូកម្មសិទ្ធិអំណាចនៃការធ្វើនិយ័តថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិ*

**គោលដៅ÷** ផ្តល់សិទ្ធិដល់រដ្ឋបាលខណ្ឌ ធ្វើនិយ័តក្នុងកម្រិតអនុគណនី និងកម្រិតគណនី នៃជំពូកតែមួយ (ក្នុងសកម្មភាពតែមួយ) ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌដែលមានការយល់ព្រមពីអភិបាលនៃគណៈអភិបាលរាជធានី។

១២០. **វឌ្ឍនភាព÷** រដ្ឋបាលខណ្ឌចំនួន ៥ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងមានមន្ត្រីរដ្ឋបាលខណ្ឌយ៉ាងតិច ៧០ នាក់ត្រូវបានបណ្តុះបណ្តាលនីតិវិធីអនុវត្តថវិកាកម្មវិធី។ ក្រៅពីនេះ គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលខណ្ឌ ក៏បានបញ្ចូលទៅនៅក្នុងសារាចរណែនាំអនុវត្តថវិកាប្រចាំឆ្នាំ២០២២។

១២១. **ជាការសន្និដ្ឋានក្នុងផ្នែកទី៣,** ថវិការយៈពេលមធ្យមបាននិងកំពុងដាក់ឱ្យអនុវត្ត និងកែលម្អ។ ប៉ុន្តែ MTFF ត្រូវបានរៀបចំជាសេចក្តីព្រាង ដោយពន្យារការដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ដោយសារស្ថានភាពសេដ្ឋកិច្ចក្នុងបរិការណ៍ នៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដោយបន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ថវិកាឆ្នាំ២០២៣។ ការបង្កើនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ នៅមានកម្រិតនៅឡើយ ដែលកិច្ចការនេះគួរត្រូវបន្តជំរុញបន្ថែមទៀត ខណៈប្រព័ន្ធថវិកាកម្ពុជា បាននិងកំពុងឈានទៅអនុវត្តថវិកាព័តិមានសមិទ្ធកម្ម ដែលសិទ្ធិអំណាច និងថវិកានឹងត្រូវធ្វើវិមជ្ឈការទៅអង្គភាពអនុវត្តផ្ទាល់កាន់តែច្រើន។ បន្ថែមពីនេះ ការធ្វើសមាហរណកម្មរវាងចំណាយថវិកាមូលធន និងថវិកាចរន្ត ព្រមទាំងគុណភាព BSP និង PB ត្រូវបន្តយកចិត្តទុកដាក់។ ការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្ររដ្ឋបាលរាជធានី ខេត្តរវាងរដ្ឋបាលរាជធានី ខេត្តជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ និងការតម្រឹមជាមួយថវិកាមន្ទីរជំនាញ នឹងរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពនៃការវិភាជ និងការអនុវត្តថវិកា។ ដោយឡែក ត្រូវពង្រឹងវិមជ្ឈការហិរញ្ញវត្ថុ ក្នុងនោះ មុខងារ ៥៥ ពីការិយាល័យជំនាញ ២០ វិស័យ ដែលបានធ្វើសមាហរណកម្មចូលក្នុងរចនាសម្ព័ន្ធ រដ្ឋបាលក្រុង ស្រុក ពុំទាន់អនុវត្តបានរលូននៅឡើយ ដែលកិច្ចការនេះគួរពន្លឿនការដោះស្រាយទាំងការផ្ទេរធនធានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ឱ្យស្របនឹងមុខងារទាំង ៥៥ នេះ។

## ផ្នែកទី៤÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម

១២២. ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្មផ្តោតលើគោលបំណងចំនួន ៤ រួមមាន÷ (១) ដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្ម, (២)ដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងពិនិត្យសមិទ្ធកម្មតាមក្រសួង ស្ថាប័ន,

(៣) ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្មបច្ចេកវិទ្យាព័ត៌មាន (សវនកម្មផ្ទៃក្នុងអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មឯករាជ្យ), និង (៤) លើកកម្ពស់តម្លាភាពថវិកា។

### *គោលបំណង ៤១÷ ដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម*

១២៣. គោលបំណងនេះមានសូចនាករសមិទ្ធកម្មគន្លឹះចំនួន២ ហើយសម្រេចបានលទ្ធផលដូចទៅ÷

*សគ១. សាកល្បងរៀបចំផែនការសមិទ្ធកម្មគន្លឹះ*

**គោលដៅ÷** មានផែនការសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ

១២៤. **វឌ្ឍនភាព÷** ក្នុងការរៀបចំគម្រោងថវិកាឆ្នាំ២០២៣, ក្រសួង ស្ថាប័នបានរៀបចំតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម។ បន្ថែមពីនេះ, កិច្ចព្រៀងសមិទ្ធកម្ម ត្រូវបានរៀបចំ និងផ្សព្វផ្សាយអំពីខ្លឹមសារ និងសេចក្តីពន្យល់លម្អិតអំពីទម្រង់ជូនដល់ក្រសួង ស្ថាប័ន សម្រាប់ត្រៀមអនុវត្តក្នុងឆ្នាំ២០២៣។ កិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ត្រូវបានកំណត់ជា ៣ កម្រិត។ កម្រិតទី១ គឺ រវាង កសហវ. និងក្រសួង ស្ថាប័ន។ កម្រិតទី២ គឺរវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង ស្ថាប័នសាមី។ កម្រិតទី៣ គឺរវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា។ សម្រាប់ការរៀបចំថវិកាឆ្នាំ២០២៣ នេះ ក្រសួង ស្ថាប័ន ចំនួន ៧ ត្រូវបានអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ដែលរួមមាន÷ (១) កសហវ., (២) ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់, (៣) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, (៤) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍, (៥) ក្រសួងអប់រំ យុវជន និងកីឡា, (៦) ក្រសួងសុខាភិបាល, និង (៧) ក្រសួងយុត្តិធម៌។

*សគ២. វិសោធនកម្មអនុក្រឹត្យលេខ៨១ លេខ៨២ និងការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម*

**គោលដៅ÷** ការដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ៨១ អនក្រ.បក និង អនុក្រឹត្យលេខ៨២ អនក្រ.បក (ថ្មី)

១២៥. **វឌ្ឍនភាព÷** អនុក្រឹត្យលេខ៨១ អនក្រ.បក និង៨២ អនក្រ.បក ត្រូវបានរៀបចំជាសេចក្តីព្រាង និងបានដាក់បញ្ចូលគ្នា ហើយត្រូវបានកំណត់ឈ្មោះថ្មី "សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ"។

១២៦. បន្ថែមពីនេះ សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ត្រូវបានឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៣ និងត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០២៣ និងបានផ្តល់យោបល់ឯកភាព ដោយព្រឹទ្ធសភា កាលពីថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២៣។ រីឯប្រកាសស្តីពីតួនាទីនិងភារកិច្ចរបស់អ្នកត្រួតពិនិត្យថវិកា ដោយមានបញ្ចូលនូវមុខងាររបស់អ្នកត្រួតពិនិត្យថវិកា ត្រូវបានរៀបចំជាសេចក្តីព្រាងបឋម។

### *គោលបំណង ៤២÷ ដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងពិនិត្យសមិទ្ធកម្មតាមក្រសួង ស្ថាប័ន*

១២៧. គោលបំណងនេះមានសូចនាករសមិទ្ធកម្មគន្លឹះចំនួន២ ហើយសម្រេចបានលទ្ធផលដូចទៅ÷

*សគ៣. ក្រសួងចំនួន ៦ មានយន្តការតាមដាន និងពិនិត្យសមិទ្ធកម្មនៅគ្រប់ក្រសួង ស្ថាប័ន*

**គោលដៅ÷** ប្រកាសស្តីពីយន្តការរៀបចំថវិកា និងប្រកាសស្តីពីយន្តការតាមដាន និងត្រួតពិនិត្យការអនុវត្តថវិកា ត្រូវបានត្រួតពិនិត្យឡើងវិញ

១២៨. **វឌ្ឍនភាព÷** គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្ត។ ចំណែកឯសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម និងត្រួតពិនិត្យថវិកា (មានមាតិកា) ត្រូវបានផ្លាស់ប្តូរក្របខ័ណ្ឌពេលវេលាថ្មី នៅត្រីមាសទី២ ឆ្នាំ២០២៤។

*សគ៤. ការរៀបចំផែនការប្រតិបត្តិថវិកាប្រចាំឆ្នាំនៅគ្រប់ក្រសួង ស្ថាប័ន*

**គោលដៅ÷** គ្រប់ក្រសួង ស្ថាប័នមានយន្តការគ្រប់គ្រងការអនុវត្ត

១២៩. **វឌ្ឍនភាព÷** ការសិក្សាលើតម្លៃបន្ថែមនៃការរៀបចំផែនការប្រតិបត្តិថវិកាប្រចាំឆ្នាំ ត្រូវបានអនុវត្ត។ ជាលទ្ធផលផែនការប្រតិបត្តិថវិកាប្រចាំឆ្នាំ ត្រូវបានធ្វើសមាហរណកម្មជាមួយកម្មវិធីត្រីមាស ដើម្បីជាយន្តការពង្រឹងការគ្រប់-គ្រងការអនុវត្តថវិកាប្រចាំឆ្នាំ។ ចំពោះទម្រង់ដែលត្រូវរៀបចំ ត្រូវបានផ្លាស់ប្តូរគោលដៅពេលវេលាថ្មី ទៅត្រីមាសទី១ ឆ្នាំ២០២៣។

*គោលបំណង ៤៣÷ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្មបច្ចេកវិទ្យាព័ត៌មាន (សវនកម្មផ្ទៃក្នុងអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មឯករាជ្យ)*

១៣០. គោលបំណងនេះមានសូចនាករសមិទ្ធកម្មគន្លឹះចំនួន៣ និងសម្រេចបានលទ្ធផលដូចទៅ÷

*សគ៥. ការរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ស្របតាមប្រព័ន្ធថវិកាសមិទ្ធកម្ម*

**គោលដៅ÷** ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានដាក់ឱ្យអនុវត្តសាកល្បងក្នុង កសហវ.

១៣១. **វឌ្ឍនភាព÷** ស្របតាមគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣បូក២ ក្នុងខឿនទី៤ "**ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម**", អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បាននិងកំពុងកែលម្អក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធនឹងមុខងារសវនកម្មផ្ទៃក្នុងមួយចំនួន ដោយកំពុងកែសម្រួលបញ្ចប់សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងក្នុងកម្រិត កសហវ.។ ការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យថ្មីនេះ ទាមទារឱ្យមានកិច្ចពិភាក្សាច្រើនលើកច្រើនសារពីមន្ត្រីជំនាញ និងផ្តល់ធាតុចូល ព្រមទាំងពិនិត្យនីត្យានុកូលភាពតាមទម្រង់ច្បាប់នៃអនុក្រឹត្យថ្មីពីក្រុមប្រឹក្សានីតិកម្ម នៃ កសហវ. និងកិច្ចប្រជុំកម្រិតផ្ទៃក្នុង កសហវ. ដើម្បីត្រៀមកិច្ចដំណើរពិភាក្សាកម្រិតអន្តរក្រសួង ស្ថាប័ន បន្តទៀត។

១៣២. ក្នុងបរិការណ៍នៃការវិវត្តសេដ្ឋកិច្ចសង្គម និងបច្ចេកវិទ្យា គោលការណ៍ណែនាំសវនកម្មថ្មីៗចំនួន ៣ ត្រូវបានរៀបចំគឺគោលការណ៍ណែនាំ និងស្តង់ដារសវនកម្មសមិទ្ធកម្ម, គោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន និងគោលការណ៍ណែនាំសវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ នៅខែមិថុនា ឆ្នាំ២០២០។ ក្នុងឆ្នាំ២០២២ នេះ, គោលការណ៍មួយបន្ថែមទៀតស្តីពីការអនុវត្តសវនកម្មអនឡាញ ត្រូវបានរៀបចំរួចរាល់។

១៣៣. អនុក្រឹត្យលេខ១០៨ អនក្រ.បក ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ត្រូវបានដាក់ឱ្យអនុវត្ត និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជូនដល់អង្គភាពរងសវនកម្ម នៅក្រសួង ស្ថាប័ន អង្គភាពថ្នាក់កណ្តាល រដ្ឋបាលខេត្ត សាលាដំបូងខេត្ត រដ្ឋបាលក្រុង ស្រុក មន្ទីរជំនាញ គ្រឹះស្ថានសាធារណៈ រដ្ឋបាល និងសហគ្រាសសាធារណៈនៅក្នុងខេត្តចំនួន ១២ និងមន្ទីរជំនាញក្នុងរាជធានីភ្នំពេញ និងតំណាងរដ្ឋបាលរាជធានីភ្នំពេញ។ បន្ថែមពីនេះ, ស្តង់ដារអធិការកិច្ចហិរញ្ញវត្ថុ ក៏ត្រូវបានប្រកាស និងផ្សព្វផ្សាយឱ្យអនុវត្តកាលពីដើមឆ្នាំ២០២២ ផងដែរ។

១៣៤. ដោយឡែក, ចំពោះការរៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចរបស់រាជរដ្ឋាភិបាលនៅមានវឌ្ឍនភាពយឺតយ៉ាវនៅឡើយ ដោយកំពុងពិភាក្សាជាមួយនឹងទីប្រឹក្សាបារាំង លើសេចក្តីព្រាងរបាយការណ៍នៃការអនុវត្តតួនាទីភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច និងការផ្តល់យោបល់លើទិសដៅនៃការបែងចែកភារកិច្ច។

### *សគ៦. ការអនុវត្តប្រព័ន្ធសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាននៅក្នុងក្រសួង ស្ថាប័ន*

**គោលដៅ÷** បន្តអនុវត្តសាកល្បងសវនកម្មសមិទ្ធកម្ម នៅក្រសួង ស្ថាប័នចំនួន ៦ និងសវនកម្មបច្ចេកវិទ្យាព័ត៌មាននៅក្រសួង ស្ថាប័នចំនួន ៤។

១៣៥. **វឌ្ឍនភាព÷** គោលការណ៍ណែនាំ និងស្តង់ដាសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន (Performance Audit និង IT Audit) ត្រូវបានប្រកាសដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២០ និងបានផ្សព្វផ្សាយជូនសវនករផ្ទៃក្នុងនៃក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈតាមរយៈសិក្ខាសាលារួចរាល់ ព្រមទាំងបានដាក់ឱ្យអនុវត្តសាកល្បងជាបន្តបន្ទាប់។ ***សវនកម្មសមិទ្ធកម្ម÷*** ក្នុងឆ្នាំ២០២០ បានចុះសវនកម្មសាកល្បង ២ គោលដៅ គឺ (១) សវនកម្មលើប្រធានបទ “គម្រោងអង្កេតសហគ្រាសនៅអគ្គនាយកដ្ឋានពន្ធដារ” និង (២) លើប្រធានបទ “គម្រោងស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងការងារពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ”។ ក្នុងឆ្នាំ២០២១ បានអនុវត្តសាកល្បងបន្ថែមទៀតនៅក្រសួងចំនួន ៦ រួមមាន÷ ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំណែកក្នុងឆ្នាំ២០២២ បានអនុវត្តសាកល្បងជាករណីសិក្សានៅក្រសួងចំនួន ៦ បន្ថែមទៀត រួមមាន÷ ក្រសួងផែនការ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងទេសចរណ៍, និងក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា។ ***សវនកម្មបច្ចេកវិទ្យាព័ត៌មាន÷*** ក្នុងឆ្នាំ២០២០ បានចុះសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បង ១ គោលដៅ លើប្រធានបទ “ប្រសិទ្ធភាពស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងការងារពន្ធដារ” និងក្នុងឆ្នាំ២០២១ បានអនុវត្តសាកល្បងនៅក្រសួងចំនួន ១០ រួមមាន ÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងព័ត៌មាន, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងយុត្តិធម៌, ក្រសួងបរិស្ថាន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធម្មការ និងសាសនា, ក្រសួងទេសចរណ៍, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារ និងក្រសួងផែនការ។ ក្នុងឆ្នាំ២០២២ បានរៀបចំរបាយការណ៍ព្រាងសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បងជាករណីសិក្សានៅក្រសួងចំនួន ៤ រួមមាន÷ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងពាណិជ្ជកម្ម, និង ក្រសួងកិច្ចការនារី។

### *សគ៧. ការផលិតរបាយការណ៍សវនកម្មសមិទ្ធកម្មដោយសវនកម្មឯករាជ្យ*

**គោលដៅ÷** មានរបាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៥ ត្រូវបានរៀបចំដោយអាជ្ញាធរសវនកម្មជាតិ និងបញ្ជូនទៅអង្គនីតិបញ្ញត្តិ។

១៣៦. **វឌ្ឍនភាព÷** របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ ចំនួន ២ ត្រូវបានបញ្ចប់ និងរបាយការណ៍លើកិច្ចប្រតិបត្តិការចំនួន ៤ កំពុងរៀបចំរបាយការណ៍ចុងក្រោយ ជូនទៅស្ថាប័ននីតិបញ្ញត្តិ។

### *គោលបំណង ៤៤÷ លើកកម្ពស់តម្លាភាពថវិកា*

១៣៧. គោលបំណងនេះមានសូចនាករសមិទ្ធកម្មគន្លឹះចំនួន១ និងសម្រេចបានលទ្ធផលដូចទៅ÷

*សគ៨. ការផ្តល់ និងទទួលបានព័ត៌មានថវិកាកាន់តែគ្រប់ជ្រុងជ្រោយ និងកាន់តែទូលំទូលាយ*

**គោលដៅ÷** បង្កើនចំណាត់ថ្នាក់នៃសសរស្តម្ភទី២ នៃ PEFA បន្ថែមមួយកម្រិតទៀត

១៣៨. **វឌ្ឍនភាព÷** បានផ្សព្វផ្សាយសារាចររៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាលើគេហទំព័រ។ បន្ថែមពីនេះ, សៀវភៅថវិកាសង្ខេបច្បាប់ថវិកាឆ្នាំ២០២៣ និងខ្លឹមសារសង្ខេបស្តីពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២៣ ត្រូវបានរៀបចំ និងផ្សព្វផ្សាយបន្ទាប់ពីត្រូវបានអនុម័តពីគណៈរដ្ឋមន្ត្រី។

១៣៩. ចំពោះការរៀបចំវេទិកាសាធារណៈស្តីពីក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ ក្នុងគោលបំណងបង្កើនការចូលរួម និងការទទួលបានព័ត៌មានរបស់សាធារណជន ត្រូវបានរៀបចំកាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០២២។

១៤០. **ជាការសន្និដ្ឋានក្នុងផ្នែកទី៤,** ការឈានទៅអនុវត្តដំណាក់កាលទី៤ ត្រូវបានត្រៀមខ្លួនរួចរាល់ចាប់ពីឆ្នាំ២០២៣តទៅ តាមរយៈ សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ ដែលនឹងត្រូវចូលជាធរមាននៅក្នុងកំឡុងឆមាសទី១ ឆ្នាំ២០២៣។ ក្របខ័ណ្ឌតាមដាននិងវាយតម្លៃ និងមុខងារសវនកម្មផ្ទៃក្នុងដែលផ្តោតលើសវនកម្មសមិទ្ធកម្មនិងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងមុខងារអធិការកិច្ច នៅគ្រប់ក្រសួង ស្ថាប័ន ត្រូវពង្រឹងបន្ថែមជាបណ្តើរៗ ដើម្បីធានាថាក្រសួង ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យតាមដានរឹងមាំ ស្របពេលរាជរដ្ឋាភិបាល បាននិងកំពុងផ្ទេរិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័ន កាន់តែច្រើន។ ទោះជាយ៉ាងនេះក្តី មុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅបន្តស្ទួននៅឡើយ ដែលកិច្ចការ នេះនឹងត្រូវបានដោះស្រាយ តាមរយៈការដាក់ឱ្យអនុវត្តក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច។

## ផ្នែកទី៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព

១៤១. ផ្នែកគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ផ្តោតលើគោលបំណងចំនួន ៣ រួមមាន (១) ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាព ក្នុងការគ្រប់គ្រងភាពជាម្ចាស់ និងការទទួលខុសត្រូវ ក្នុងការកែទម្រង់, (២) ធានាចលនាការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និង (៣) ពង្រឹងភាពប្រទាក់ក្រឡាគ្នារវាងការដ្ឋាននៃកម្មវិធីកែទម្រង់ផ្សេងៗទៀត។

១៤២. ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃស្ថាប័នសាធារណៈត្រូវឆ្លុះបញ្ចាំងនូវសមត្ថភាពស្ថាប័ន÷ ការដឹកនាំ និងការអនុវត្ត, ការសម្របសម្រួលស្ថាប័ន/មុខងារ, ការកសាងធនធានមនុស្សទាំងបរិមាណ និងគុណភាព និងការលើកទឹកចិត្ត/សមិទ្ធកម្ម/គុណាធិបតេយ្យ។

### *គោលបំណង ៥១÷ ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាព ក្នុងការគ្រប់គ្រងភាពជាម្ចាស់ និងការទទួលខុសត្រូវ ក្នុងការកែទម្រង់*

១៤៣. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន ២ ហើយសម្រេចបានលទ្ធផល ដូចតទៅ÷

*សគ ១. ភាពទាន់ពេលវេលានៃការផ្តល់ផែនការ GDAP/MAP និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំមក អ.គ.ហ.*

**គោលដៅ ២០២២÷** ផែនការ GDAP, MAP និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវបានផ្តល់ត្រឹមថ្ងៃនៃកាលកំណត់ដោយ អ.គ.ហ។

១៤៤. **វឌ្ឍនភាព**÷ផែនការ GDAP ១៨/១៨ បានផ្ញើមក អ.គ.ហ. និងក្រសួង ស្ថាប័នចំនួន ៤០/៤០ បានផ្ញើផែនការ MAP មក អ.គ.ហ. សម្រាប់ការអនុវត្តក្នុងឆ្នាំ២០២២។ រីឯ ការផ្ញើរបាយការណ៍នៃការអនុវត្ត GDAP ទទួលបាន ១៨/១៨ និងរបាយការណ៍នៃការអនុវត្ត MAP ទទួលបាន ៤០/៤០ បានទាន់ពេលវេលា។

*សគ ២. កសាងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈរយៈពេល ៥ឆ្នាំ (ដំណាក់កាលទី៤) ភ្ជាប់ជាមួយនឹង Certificate Program*

**គោលដៅ** ÷ (១) ផែនការសកម្មភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈរយៈពេល ៥ ឆ្នាំ ត្រូវបានដាក់ឱ្យអនុវត្ត, និង (២) យ៉ាងតិច ៩០% នៃសកម្មភាពក្នុងឆ្នាំរបស់ផែនការសកម្មភាព ត្រូវបានអនុវត្ត

១៤៥. **វឌ្ឍនភាព**÷ ផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌ PFMRP ត្រូវបានរៀបចំ។ ក្នុងឆ្នាំ ២០២២ វិទ្យាស្ថានគ្រោងអនុវត្តការបណ្តុះបណ្តាល និង វិក្រឹតការ ចំនួន ៣៤ វគ្គ សិក្ខាកាម ១ ៥៨២ នាក់ (ត្រីមាសទី៤ មាន៧ វគ្គ សិក្ខាកាម ២៦៧ នាក់) ។ ជាលទ្ធផល ការបណ្តុះបណ្តាល និង វិក្រឹតការ សម្រេចបានសរុបចំនួន ៣២ វគ្គ សិក្ខាកាម ១ ៧៥៦ នាក់ ស្មើនឹង ៩៤% ធៀបនឹងផែនការ។

## *គោលបំណង ៥២÷ ធានាចលនាការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

១៤៦. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន៣ ហើយសម្រេចបានលទ្ធផលដូចតទៅ÷

*សគ ៣. កបហស និងលក្ខខណ្ឌយោង (TOR) ត្រូវបានធ្វើបច្ចុប្បន្នភាព ទៅតាមគោលការណ៍កំណត់ និងតម្រូវការរបស់អង្គភាព*

**គោលដៅ**÷ លក្ខខណ្ឌយោងតួនាទីភារកិច្ចនៃសមាជិកក្រុមការងារកែទម្រង់ PFM គ្រប់ក្រសួង ស្ថាប័ន ត្រូវបានសម្រួច និងតម្រឹមតាមគោលបំណង/សកម្មភាពគន្លឹះក្នុងម៉ាទ្រីសតាមផែនការ GDAP/MAP ឆ្នាំ២០២១

១៤៧. **វឌ្ឍនភាព**÷ លក្ខខណ្ឌយោង តួនាទី ភារកិច្ច នៃសមាជិកក្រុមការងារកែទម្រង់តាមអង្គភាពក្រោមឱវាទ កសហវ. រួមទាំមន្ទីរ សហវ. និងក្រសួង ស្ថាប័ន ត្រូវបានរៀបចំតាមយន្តការផ្តល់ប្រាក់ឧបត្ថម្ភ។

*សគ ៤. ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាពនៃកម្មវិធីកែទម្រង់ត្រូវបានរៀបចំ និងអនុវត្ត*

**គោលដៅ**÷ របាយការណ៍ដាក់ឱ្យអនុវត្តសាកល្បងលើប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព (PMAS) ជំហានទី១ សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើ ៤ ម៉ូឌុល÷ ម៉ូឌុល១ ÷ ផែនការសកម្មភាព (CAP, GDAP/MAP), ម៉ូឌុល២÷រៀបចំថវិកា និងអនុវត្តថវិកា,ម៉ូឌុល៣÷ ក្របខ័ណ្ឌសមិទ្ធកម្ម, និងម៉ូឌុល៤÷ របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និងឆ្នាំត្រូវបានរៀបចំ។

១៤៨. **វឌ្ឍនភាព**÷បានអភិវឌ្ឍលើទម្រង់ Prototype បាន ៩០% ដោយបានសម្រេចលើចំណុចសំខាន់ៗរួមមាន÷ (១) ការគូសទម្រង់ Dashboard (កម្រិតមន្ត្រីជំនាញ, កម្រិតមន្ត្រីជំនាញ, និងកម្រិតថ្នាក់ដឹកនាំ), (២) ទម្រង់លម្អិតនៃការធ្វើវឌ្ឍនភាពលទ្ធផលក្នុងឆ្នាំ, (៣) ទម្រង់ការគ្រប់គ្រងឃ្លាំងឯកសាររបស់ផ្នែក, (៤) ទម្រង់បញ្ជីរបាយការណ៍

(របាយការណ៍សង្ខេប, និងរបាយការណ៍ទូទៅ), (៥) ទម្រង់ប្រតិទិន (បង្ហាញអំពីវឌ្ឍនភាពការងារ, បង្កើតសេចក្ដី-ប្រកាសប្រជុំ, និងបញ្ជីការងារតាមប្រតិទិន), (៦) ទម្រង់សំណើថវិកា, (៧) ទម្រង់ General Ledger ផ្នែកហិរញ្ញវត្ថុ, (៨) ទម្រង់និយ័តថវិកា។ ជាការកត់សម្គាល់ នៅក្នុងដំណាក់កាលទី២នេះ ប្រព័ន្ធ PMAS បានជួបបញ្ហាប្រឈម ដោយសារមានតម្រូវបន្ថែមច្រើនលើការសម្រួលមុខងារក្នុងប្រព័ន្ធ ធ្វើឱ្យចំណាយពេលវេលាច្រើនក្នុងការរចនាឱ្យត្រូវនឹងតម្រូវការរបស់អ្នកប្រើប្រាស់, និងមានតម្រូវការប្រព័ន្ធលើសពីទំហំការងារដែលត្រូវបានកំណត់ក្នុងផែនការអភិវឌ្ឍន៍។

*សគ ៥. ក្របខ័ណ្ឌលើកទឹកចិត្តផ្សារភ្ជាប់សមិទ្ធកម្មក្នុងកម្មវិធីកែទម្រង់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត*

**គោលដៅ÷** របាយការណ៍វឌ្ឍនភាព ត្រូវបានរៀបចំដោយក្រុមការងារ

១៤៩. **វឌ្ឍនភាព÷** ការបើកផ្ដល់ប្រាក់ឧបត្ថម្ភប្រមាណ ១៥ ៨៦១ លានរៀល ឬប្រមាណជិត ៤ លានដុល្លារអាម៉េរិក ក្នុងនោះ បានផ្ដល់ជូនអង្គភាពក្រោមឱវាទ កសហវ. ចំនួន ៤៨៥ រូប, មន្ទីរ សហវ. រាជធានី ខេត្ត ចំនួន ៧៥ រូប, និងក្រសួង ស្ថាប័នចំនួន ៣៤៧។

*គោលបំណង ៥៣÷ ពង្រឹងភាពប្រទាក់ក្រឡាគ្នារវាងការដ្ឋាននៃកម្មវិធីកែទម្រង់ផ្សេងៗទៀត*

១៥០. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន២ ហើយសម្រេចបានលទ្ធផលដូចទៅ÷

*សគ ៦. ការបន្តកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពនៃកម្មវិធីកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល*

**គោលដៅ÷** (១)កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំប្រចាំ, (២)កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំប្រចាំត្រីមាស និងយ៉ាងតិច ៩០% នៃផែនការសកម្មភាពត្រូវបានអនុវត្ត

១៥១. **វឌ្ឍនភាព÷** អ.គ.ហ. បានដឹកនាំកិច្ចប្រជុំសម្របសម្រួលយន្តការកែទម្រង់៣+១ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ និងមានរបាយការណ៍គោរពជូនថ្នាក់ដឹកនាំ។

*សគ ៧. ការកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល*

**គោលដៅ÷** សេចក្ដីព្រាងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ ៣ បូក ១ ស្ដីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ បូក ១។

១៥២. **វឌ្ឍនភាព÷** ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ និងអនុក្រឹត្យត្រូវបានទទួលការឯកភាពពីប្រមុខរាជរដ្ឋាភិបាល កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ និងបានរៀបចំពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២។

*សគ ៨. ការពិពណ៌នាមុខតំណែងផ្អែកលើគោលការណ៍ណែនាំ*

**គោលដៅ÷** ក្រសួង ស្ថាប័នចំនួន ១៥ បានរៀបចំការពិពណ៌នាមុខដំណែងបានត្រឹមត្រូវ

១៥៣. **វឌ្ឍនភាព÷** សេក្ដីព្រាងសេចក្ដីណែនាំស្ដីពីការរៀបចំការពិពណ៌នាមុខដំណែង និងបទដ្ឋានគតិយុត្តស្ដីពីការដាក់ឱ្យអនុវត្តការពិពណ៌នាមុខតំណែង ត្រូវបានបញ្ចប់ការរៀបចំក្នុងកម្រិតបច្ចេកទេស។

១៥៤. **ជាការសន្និដ្ឋានក្នុងផ្នែកទី៥,** ក្រុមការងារកែទម្រង់ នៅតាមអង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរ សហវ. រាជធានី ខេត្ត និងក្រសួងស្ថាប័ន បានអនុវត្តផែនការ និងបានផ្ញើរបាយការណ៍សមិទ្ធកម្មមក អ.គ.ហ. ទាន់ពេលវេលា បើទោះជាមានភាពយឺតយ៉ាវចំពោះក្រសួង ស្ថាប័នតិចតួចក្ដី។ ចលនការនៃការកែទម្រង់ត្រូវបានបន្តចីរភាព ដែលឆ្លុះបញ្ចាំងតាមរយៈការចូលរួមអនុវត្តកម្មវិធីកែទម្រង់ពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។ ការងារកែទម្រង់ប្រទាក់ក្រឡា

ត្រូវបានពង្រឹង តាមរយៈការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ប្លុក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១។ ទោះជាយ៉ាងនេះក្តី ការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹង PFMRP ដំណាក់កាលទី៤ ផ្តោតលើការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ នៅពុំទាន់បានរៀបចំនៅឡើយ។ ចលនការឆ្ពោះទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម នឹងតម្រូវឱ្យស្ថាប័ននីតិប្បញ្ញត្តិ ផ្តោតលើព័ត៌មានសមិទ្ធកម្មច្រើនជាងការអនុវត្តបច្ចុប្បន្ន។ ដោយឡែក តួនាទីមន្ត្រីរាជការនឹងត្រូវបានរៀបចំកាន់តែច្បាស់តាមរយៈការដាក់ឱ្យអនុវត្ត សេចក្តីណែនាំស្តីពីការពិពណ៌នាមុខដំណែង។ បន្ថែមពីនេះ សមត្ថភាពជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិញ្ញាបនបត្រ។

## ២.២. វឌ្ឍនភាពតាមអង្គភាពក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន

១៩៥. របាយការណ៍ត្រួតពិនិត្យនេះ ត្រូវបានធ្វើការបូកសរុប និងវាយតម្លៃផ្អែកលើផែនការសកម្មភាព និងសូចនាករ ឆ្នាំ ២០២២ ដែលសម្រេចបានដោយអង្គភាពទាំង ១៧ ក្រោមឱវាទ កសហវ., មន្ទីរ សហវ. ទាំង២៥ រាជធានី ខេត្ត និងក្រសួង ស្ថាប័ន ។

១៩៦. **គោលការណ៍ដាក់ពិន្ទុទូទៅ៖** វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ ដើម្បីត្រួតពិនិត្យសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០២២ នេះ ផ្អែកលើមូលដ្ឋានចំនួន ២ សំខាន់ គឺ (១) សកម្មភាពការងារសម្រេចបានជាក់ស្តែងធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត, និង (២) លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងសូចនាករគោលដៅ ឬ សូចនាករដែលបានដាក់ចេញ។ ក្នុងនោះ ការផ្តល់និទ្ទេសវាយតម្លៃលើសមិទ្ធកម្មសម្រេចបាន ត្រូវបានកំណត់ជា ៣ កម្រិត សម្រាប់គោលបំណង និងចង្កោមសកម្មភាព គឺ៖ ល្អប្រសើរ (៩៦% - ១០០%), ល្អ (៨៦% - ៩៥%), ល្អបង្គួរ (៧១% - ៨៥%), មធ្យម (៦១% - ៧០%) និង ខ្សោយ (ក្រោម ៦០%) ។

### ២.២.១. វឌ្ឍនភាពនៃការអនុវត្តតាមអង្គភាពក្រោមឱវាទ កសហវ.

១៩៧. របាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពឆ្នាំ២០២២ ក៏បានឆ្លុះបញ្ចាំងសមិទ្ធកម្មតាមអង្គភាពក្រោមឱវាទ កសហវ. ទាំង ១៨។ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់អង្គភាពទាំង ១៨ ទទួលបានលទ្ធផលលើសពី ៨៦% ដូចមានក្នុងដ្យាក្រាមទី៥ ខាងក្រោម។

ដ្យាក្រាមទី 5 ៖ ការអនុវត្តថវិកា និង វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ.




ប្រភព÷ អ.គ.ហ.

១៥៨. ដោយឡែក មន្ទីរ សហវ. រាជធានី ខេត្ត ទាំង ២៥ បានផ្តោតសកម្មភាពកែទម្រង់របស់ខ្លួនលើអាទិភាពការងារចំនួន ៤ គឺ÷(១) ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅថ្នាក់ក្រោមជាតិ, (២) ការធ្វើប័ណ្ណកម្មសិទ្ធិអចលនទ្រព្យរបស់រដ្ឋ, (៣) ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញ និងរដ្ឋបាលរាជធានី ខេត្ត, និង (៤) ការលើកកម្ពស់តម្លាភាពហិរញ្ញវត្ថុនិងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ក្នុងឆ្នាំ២០២២ មន្ទីរ សហវ. រាជធានី ខេត្តទាំង២៥ បានគ្រោងសកម្មភាពសរុបចំនួន ១៨៤ និងសម្រេចបានពេញលេញចំនួន ១៧៦ ដែលសម្រេចបានសមិទ្ធកម្មជារួមស្មើនឹង ៩៨%។ ក្នុងនោះ វឌ្ឍនភាពសម្រេចបានក្នុងឆ្នាំ២០២២ រួមមាន÷

- បានត្រួតពិនិត្យការអនុវត្តសៀវភៅបន្ទុកនៅរាជធានី ខេត្ត សរុបបានចំនួន ៤២៦ ទីតាំងគោលដៅ ដែលស្មើនឹង ៩៩,៧៧% ធៀបនឹងគោលដៅប្រចាំឆ្នាំ២០២២ ចំនួន ៤២៧ ទីតាំងគោលដៅ។
- បានត្រួតពិនិត្យការអនុវត្តប្រកាសស្តីពីការផ្តល់សេវាសាធារណៈ នៅច្រកចេញ-ចូលតែមួយនៅរាជធានី ខេត្ត សរុបបានចំនួន ២៨៨ មន្ទីរ អង្គភាពជំនាញស្មើនឹង ១០០% ធៀបនឹងគោលដៅប្រចាំឆ្នាំ២០២២ ចំនួន ២៨៨ មន្ទីរ អង្គភាពជំនាញ។
- បានធ្វើប័ណ្ណកម្មសិទ្ធិអចលនទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ កសហវ. នៅថ្នាក់មូលដ្ឋានសម្រេចបានចំនួន ១០ ប័ណ្ណ ស្មើនឹង ៩០,៩១% ធៀបនឹងគោលដៅប្រចាំឆ្នាំ២០២២ ចំនួន ១១ ប័ណ្ណ។
- បានធ្វើប័ណ្ណកម្មសិទ្ធិអចលនទ្រព្យនៃមន្ទីរនិងអង្គភាពជំនាញ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សរុបបានចំនួន ២០៥ ប័ណ្ណ ស្មើនឹង ១១៧,៨២% ធៀបនឹងគោលដៅប្រចាំឆ្នាំ២០២២ ចំនួន ១៧៤ ប័ណ្ណ។
- បានរៀបចំតារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២១ របស់មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី ខេត្ត បានសរុបចំនួន ៨២០ មន្ទីរ អង្គភាព ស្មើនឹង ៩៨,៩១% ធៀបនឹងគោលដៅប្រចាំឆ្នាំ២០២២ ចំនួន ៨២៩ មន្ទីរ អង្គភាព។
- បានរៀបចំតារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២១ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សរុបចំនួន ១ ២៥៧ អង្គភាព ស្មើនឹង ៩៩,៦៨% ធៀបនឹងគោលដៅប្រចាំឆ្នាំ២០២២ ចំនួន ១ ២៦១ អង្គភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- បានផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលស្ដីពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដល់រដ្ឋបាល ឃុំ សង្កាត់ សម្រេចបាន ១ ៥៦០ ឃុំ សង្កាត់ ស្មើនឹង ៩៥,៣០% ធៀបនឹងគោលដៅប្រចាំឆ្នាំ២០២២ ចំនួន ១ ៦៣៧។

១៥៩. ដ្យាក្រាមទី៦ ខាងក្រោមបង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់មន្ទីរ សហវ. រាជធានី ខេត្ត។

ដ្យាក្រាមទី 6 ÷ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់មន្ទីរ សហវ. រាជធានីខេត្ត




| | សៀវភៅបន្ទុក | ការអនុវត្តប្រកាសស្ដីពីការផ្ដល់សេវាសាធារណៈនៅមន្ទីរ-អង្គភាពជំនាញ | ប័ណ្ណកម្មសិទ្ធិអចលនទ្រព្យក្រោម គសហវ. នៅថ្នាក់មូលដ្ឋាន | ប័ណ្ណកម្មសិទ្ធិអចលនទ្រព្យនៃមន្ទីរ-អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | តារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២១របស់មន្ទីរ-អង្គភាពជំនាញ | តារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការផ្សព្វផ្សាយនិងបណ្ដុះបណ្ដាលស្ដីពីប្រព័ន្ធSARMIS ដល់រដ្ឋបាលឃុំ សង្កាត់ |
|---|---|---|---|---|---|---|---|
| គោលដៅប្រចាំឆ្នាំ | 427 | 288 | 11 | 174 | 829 | 1261 | 1637 |
| វឌ្ឍនភាពប្រចាំឆ្នាំ | 426 | 288 | 10 | 205 | 820 | 1257 | 1560 |
| % ធៀបប្រចាំឆ្នាំ | 99.77% | 100.00% | 90.91% | 117.82% | 98.91% | 99.68% | 95.30% |

ប្រភព÷ អ.គ.ហ.

១៦០. ក្រៅពីវឌ្ឍនភាពខាងលើ, ក្រោមការគាំទ្រនិងសម្របសម្រួលពី **អ.គ.ហ.** គេហទំព័រផ្លូវការរបស់មន្ទីរ សហវ. ត្រូវបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ព្រមទាំងបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២។ បច្ចុប្បន្ន មន្ទីរ សហវ. កំពុងសាកល្បងប្រើប្រាស់ និងបានផ្សព្វផ្សាយព័ត៌មានផ្សេងៗលើ គេហទំព័រនេះបន្ទាប់ពីទទួលបានការបណ្ដុះបណ្ដាលជាបន្តបន្ទាប់ ដែលផ្ដោតលើការបញ្ចូលទិន្នន័យ, ការសរសេរអត្ថបទផ្សព្វផ្សាយ, ការថតនិងរចនារូបភាព និងរបៀបគ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងមាតិកាគេហទំព័រ។ គេហទំព័រនេះជាឧបករណ៍សម្រាប់លើកកម្ពស់គណនេយ្យភាព និងតម្លាភាពផ្នែកហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាឧបករណ៍សម្រាប់ផ្សព្វផ្សាយអំពីព័ត៌មានសង្គម-សេដ្ឋកិច្ចនៃបណ្ដារាជធានី ខេត្ត។ ម្យ៉ាងទៀត ការរៀបចំនិងដាក់ឱ្យប្រើប្រាស់គេហទំព័រនេះក៏ជាមូលដ្ឋានក្នុងការឈានទៅអនុវត្តរដ្ឋបាលតាមប្រព័ន្ធអេឡិចត្រូនិក និងសេដ្ឋកិច្ចឌីជីថល។

១៦១. ក្នុងឆ្នាំ២០២២ មន្ទីរ សហវ. ក៏បានរៀបចំសេចក្ដីព្រាងបឋមរបាយការណ៍វិភាគភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង (SWOT) ដែលជាមូលដ្ឋានសម្រាប់លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដែលសេចក្ដីព្រាងរបាយការណ៍នេះក៏ត្រូវបានលើកយកមកពិភាក្សាជាមួយរដ្ឋបាលខេត្តចំនួន ៥ និងទទួលបានការសាទរ និងគាំទ្រលើការរៀបចំរបាយការណ៍នេះ។ ក្នុងការរៀបចំ មន្ទីរ សហវ. ទទួលបានការបណ្ដុះបណ្ដាលចំនួន ៤ លើក ដែលផ្ដោតលើការបណ្ដុះបណ្ដាលស្ដីពីវិធីសាស្ត្រមូលដ្ឋានក្នុងការវិភាគទិន្នន័យ រួមមាន វិធីសាស្ត្រក្នុងការរៀបចំតារាងឬក្រាបផ្សេងៗ ដើម្បីបង្ហាញទិន្នន័យ និងការវិភាគ និងបកស្រាយស្ថិតិនិងទិន្នន័យសេដ្ឋកិច្ច, វិធីសាស្ត្រសរសេរ

របាយការណ៍តាមបែបសិក្សាស្រាវជ្រាវ និងការបកស្រាយសូចនាករសេដ្ឋកិច្ច ដែលរួមមាន ការបណ្តុះបណ្តាលពាក់ព័ន្ធនឹងរបៀបរៀបចំការសិក្សាស្រាវជ្រាវ, ការស្វែងរកទិន្នន័យ និងការសរសេរឯកសារយោង និងប្រភពទិន្នន័យ។

១៦២. ទន្ទឹមនឹងនេះ មន្ទីរ សហវ. រាជធានី ខេត្ត ក៏បានលើកឡើងអំពីបញ្ហាប្រឈមមួយចំនួន រួមមាន÷

- ការប្រមូល និងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅថ្នាក់ជាតិនៅមានកម្រិត និងមានបញ្ហាប្រឈមនៅឡើយ។ ក្នុងនោះ ការគ្រប់គ្រងអាជីវកម្មអចលនវត្ថុ និងការគ្រប់គ្រងអាជីវកម្មបញ្ចាំនិងទទួលប្រាតិភោគដោយអនុប្បទាន នៅមានកម្រិតនៅឡើយ ដោយសារការផ្សព្វផ្សាយអំពីគតិយុត្ត និងការអនុវត្តនៅពុំទាន់ទូលំទូលាយ, អាជីវករភាគច្រើនពុំបានចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម និងពុំមានប័ណ្ណប៉ាតង់ (លក្ខខណ្ឌតម្រូវ), យន្តការការងារពុំទាន់ស៊ីសង្វាក់គ្នារវាងមន្ទីរ សហវ., សាខាពន្ធដារ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី, និងការចូលរួមពីអាជ្ញាធរមូលដ្ឋាននៅមានកម្រិត។ កង្វះខាតលក្ខខណ្ឌតម្រូវមួយចំនួន ដូចជា លិខិតអនុញ្ញាតអភិវឌ្ឍដី ប្លង់រួមស្តីពីការអភិវឌ្ឍដី និងឯកសារបំបែកក្បាលដី, ប្រាក់តម្កល់ធានាអាជីវកម្ម ៥%, វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, អាជីវកម្មលក្ខណៈគ្រួសារ មានទំហំទឹកប្រាក់តិចតួច មិនមានសញ្ញាប័ត្រ ឬវិញ្ញាបនប័ត្រពាក់ព័ន្ធសម្រាប់បំពេញតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងគតិយុត្ត។ ទន្ទឹមនឹងនេះ ការប្រមូល ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ពុំទាន់អស់សក្តានុពល ក្នុងនោះ កិច្ចសន្យាដែលកំពុងអនុវត្ត មានរយៈពេលយូរ ឬពុំមានការអភិវឌ្ឍ និងមិនស្របតាមស្ថានភាពកំណើនសេដ្ឋកិច្ចបច្ចុប្បន្ន។ ម្យ៉ាងទៀត បំណុលមិនមែន សារពើពន្ធមួយចំនួននៅពុំទាន់បានដោះស្រាយនៅឡើយ និងមួយចំនួនត្រូវបានបន្តនីតិវិធីទៅសាលាដំបូងខេត្ត។
- ដោយឡែក ការប្រើប្រាស់ប្រព័ន្ធ NRMIS នៅមានបញ្ហាប្រឈមផ្នែកបច្ចេកទេសមួយចំនួន ដូចជា សេវាសាធារណៈថ្មីៗមួយចំនួនពុំទាន់មានលេខកូដសម្រាប់ចុះក្នុងប្រព័ន្ធដែលជាហេតុធ្វើឱ្យពុំអាចចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបាន, ការកត់ត្រាចំណូលតែមួយប្រភេទ តែត្រូវកត់ត្រាច្រើនដងក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងចំណូលរបស់អង្គភាពច្រកចេញចូលតែមួយផង, ប្រព័ន្ធ NRMIS ផង និងប្រព័ន្ធ FMIS, នីតិវិធីនៃការបង់ប្រាក់ នៅមានភាពស្មុគស្មាញ និងចំណាយពេលវេលាច្រើនក្នុងការប្រមូលចំណូល។ ម្យ៉ាងទៀត ការប្រើប្រាស់ប្រព័ន្ធនេះក្នុងបណ្តាខេត្តមួយចំនួន អនុវត្តលើប្រភេទចំណូលមិនមែនសារពើពន្ធដែលបង់ទៅថ្នាក់ជាតិ និងប្រភេទចំណូលពីភាស៊ី។ ក៏ប៉ុន្តែ ចំណូលរបស់មន្ទីរជំនាញលើសេវាសាធារណៈជាគុណប្រយោជន៍របស់ខេត្ត និងចំណូលពីសេវាសាធារណៈរបស់អង្គភាពច្រកចេញចូលតែមួយខេត្ត នៅមិនទាន់អាចអនុវត្តបាននៅឡើយ។ ម្យ៉ាងទៀត ប្រព័ន្ធនេះពុំមានមុខងារដែលមន្ទីរ សហវ. អាចទាញរបាយការណ៍ចំណូលមិនមែនសារពើពន្ធដែលមន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានបញ្ចូល។
- ការធ្វើប័ណ្ណកម្មសិទ្ធិដីរដ្ឋ នៅមានបញ្ហាប្រឈមនៅឡើយ ដូចខាងក្រោម÷
    - អង្គភាពកាន់កាប់ភាគច្រើនពុំទាន់បានយកចិត្តទុកដាក់រៀបចំសំណើសុំធ្វើប័ណ្ណកម្មសិទ្ធិ តាមនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ទោះបីជាមានលិខិតជំរុញពីមន្ទីរ សហវ. និងមានការលើកលែងការបង់ថ្លៃសេវានានាក៏ដោយ ដោយអង្គភាពភាគច្រើនរង់ចាំការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។

ក្រៅពីនេះ ក៏មានអង្គភាពមួយចំនួនយល់ច្រឡំថា ការធ្វើប័ណ្ណកម្មសិទ្ធិដីរដ្ឋនេះត្រូវរង់ចាំការចុះបញ្ជីជាលក្ខណៈប្រព័ន្ធ។

- ទីតាំងដីរដ្ឋមួយចំនួនត្រូវបានប្រជាពលរដ្ឋរំលោភបំពាន ដែលត្រូវបានចាត់ជាដីមានទំនាស់ និងត្រូវដោះស្រាយ មុននឹងអាចសម្រេចចេញប័ណ្ណកម្មសិទ្ធិបាន។
- ទីតាំងដីមួយចំនួនត្រូវបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋស្ទួន ដោយអង្គភាពលើសពីមួយ ដែលពុំអាចដំណើរការវាស់វែងធ្វើប័ណ្ណកម្មសិទ្ធិបាន លុះត្រាតែអង្គភាពកាន់កាប់ទាំងនោះស្រុះស្រួលគ្នា ឬឯកភាពប្រគល់សិទ្ធិកាន់កាប់ជូនអង្គភាពណាមួយជាក់លាក់។ បញ្ហានេះកើតមានភាគច្រើនលើករណីសាលារៀនសាងសង់ក្នុងបរិវេណដីវត្តអារាម និងមណ្ឌលសុខភាព ឬ ប៉ុស្តិ៍នគរបាល សាងសង់ក្នុងដីសាលាស្រុក ឬសាលាឃុំ។
- ទីតាំងដីមួយចំនួនត្រូវបានបញ្ចប់នីតិវិធីរៀបចំប័ណ្ណកម្មសិទ្ធិរួចរាល់ ក៏ប៉ុន្តែអង្គភាពកាន់កាប់ពុំទាន់ទទួលបានប័ណ្ណកម្មសិទ្ធិនៅឡើយ។ ករណីមួយចំនួន អង្គភាពកាន់កាប់បានអះអាងថា បានដាក់ពាក្យស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិរួចរាល់ ក៏ប៉ុន្តែការចុះវាស់វែងនៅមានភាពយឺតយ៉ាវនៅឡើយ។ តាមរយៈ កិច្ចប្រជុំជាមួយរដ្ឋបាលខេត្ត និងមន្ទីរជំនាញ ពាក់ព័ន្ធកន្លងមក ក៏បានលើកឡើងអំពីកង្វះខាតមន្ត្រីនៃមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីចុះបំពេញការងារវាស់វែងទីតាំងដីរដ្ឋដែលអង្គភាពកាន់កាប់បានដាក់ពាក្យស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិផងដែរ។
- ក្រៅពីនេះ ក៏មានទីតាំងដីរដ្ឋមួយចំនួន ដែលបានចុះបញ្ជីសារពើភណ្ឌ តែជាដីដែលពុំអាចចេញប័ណ្ណកម្មសិទ្ធិបានតាមការកំណត់ដោយច្បាប់ជាធរមាន ដូចជា ដីចំណីផ្លូវ, ស្ទឹង ឬទន្លេ ឬជាដីស្ថិតក្នុងតំបន់ ៣នៃបឹងទន្លេសាប ឬក្នុងតំបន់អង្គរ ជាដើម។

- ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ មានវឌ្ឍនភាព ប៉ុន្តែប្រសិទ្ធភាពនិងគុណភាពនៅមានកម្រិត ពោលគឺការរៀបចំពុំទាន់ពេលវេលា គ្រប់ចំនួន និងសុក្រឹត្យភាពនៅឡើយ ពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយសារចំណេះដឹងអំពីនីតិវិធីរៀបចំបញ្ជីសារពើភណ្ឌនៅមានកម្រិត និងកង្វះខាតឧបករណ៍ប្រើប្រាស់។ មន្ទីរ សហវ. រាជធានី ខេត្ត ក៏លើកស្នើចូលរួមក្នុងកិច្ចដំណើរការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញ ដើម្បីគ្រប់គ្រងទិន្នន័យទ្រព្យសម្បត្តិរដ្ឋឱ្យបានគ្រប់ជ្រុងជ្រោយ ដោយសារកន្លងមក ការជម្រះទ្រព្យ-សម្បត្តិរដ្ឋរបស់មន្ទីរជំនាញប្រើប្រាស់យន្តការថ្នាក់ជាតិ ដែលពុំមានសមាសភាពពីមន្ទីរ សហវ. រាជធានី ខេត្ត។ ក្រៅពីនេះ បញ្ហាប្រឈមមួយចំនួនក្នុងការរៀបចំបញ្ជីសារពើភណ្ឌ ដូចខាងក្រោម៖
  - ទីតាំងផ្សារ ចំណតយានជំនិះ និងចំណតជលផល កំពង់ចម្លង សត្តឃាតដ្ឋាន មិនទាន់មានប្លង់កម្មសិទ្ធិ និងពុំទាន់បានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយសារពុំទាន់កំណត់ច្បាស់អំពីអង្គភាពប្រើប្រាស់ដែលត្រូវទទួលបន្ទុកចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។ ដោយឡែក ទីតាំងដីសាធារណៈរបស់រដ្ឋ ដូចជា ទីទួល បឹង អាង ទំនប់ ប្រឡាយ សួនសាធារណៈ ដែលទីតាំងមួយចំនួន មន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដីខេត្ត បានវាស់វែង និងចេញប័ណ្ណកម្មសិទ្ធិរួចរាល់ ក៏ប៉ុន្តែមិនទាន់បានចុះក្នុងបញ្ជីសារពើភណ្ឌនៅឡើយ ដោយសារពុំទាន់កំណត់អំពីអង្គភាពប្រើប្រាស់ជាក់លាក់។

- ការកត់ត្រាការកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពមួយចំនួន ពុំមានឯកសារយោងគ្រប់គ្រាន់ និងការដោះដូរមួយចំនួន ពុំបានអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុនៅឡើយ។ បញ្ហាប្រឈមនេះបានធ្វើឱ្យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋពុំមានបច្ចុប្បន្នភាព និងជាក់ស្តែងនៅឡើយ។

១៦៣. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់មន្ទីរ សហវ. ទាំង ២៥ ទទួលបានលទ្ធផលលើសពី ៩០% ដូចមានក្នុងដ្យាក្រាមទី៧ ខាងក្រោម។

ដ្យាក្រាមទី 7 ÷ ការអនុវត្តថវិកា និង វឌ្ឍនភាព (%) តាមមន្ទី សហវ. រាជធានី ខេត្ត




ប្រភព÷ អ.គ.ហ.

### ២.២.២. វឌ្ឍនភាពនៃការអនុវត្តតាមក្រសួង ស្ថាប័ន

១៦៤. របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព (MAP) របស់ក្រសួង ស្ថាប័ន ទាំង ៤០ ÷ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ស្ថាប័នចំនួន ៥ រួមមាន ÷ (១) ស្ថាប័នសេវាសេដ្ឋកិច្ចមានចំនួន ១១ ក្រសួង ស្ថាប័ន, (២) ស្ថាប័នសេវាហិរញ្ញវត្ថុ ការបរទេស និងសេវាសាធារណៈទូទៅ មានចំនួន ៨ ក្រសួង ស្ថាប័ន, (៣) ស្ថាប័នសេវាការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ មានចំនួន ៥ ក្រសួង ស្ថាប័ន, (៤) ស្ថាប័នសេវាសង្គមកិច្ច មានចំនួន ៦ ក្រសួង ស្ថាប័ន និង (៥) ស្ថាប័ន កំពូល និងឯករាជ្យ មានចំនួន ១១ ក្រសួង ស្ថាប័ន។

១៦៥. ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ តាមដានវឌ្ឍនភាព នៃការអនុវត្ត MAP3+2 ឆ្នាំ២០២២, ការរៀបចំ MAP3+2 មានភាពប្រសើរជាងមុន និងកាត់បន្ថយការរៀបចំសកម្មភាពប្រចាំថ្ងៃ។ ទោះបីជាយ៉ាងនេះក្តី, ការដាក់ចេញផែនការសកម្មភាពកែទម្រង់ (MAP) របស់ក្រសួង ស្ថាប័ន ពុំទាន់ឆ្លើយតបពេញលេញតាមការដ្ឋានកែទម្រង់ អាទិភាពនៅឡើយ ដែលចាំបាច់ធានាក្រសួង ស្ថាប័នចូលរួមអនុវត្តផែនការសកម្មភាពតាមលំដាប់លំដោយអាទិភាព។ អ.គ.ហ. និងអគ្គនាយកដ្ឋានបង្គោលនៃ គសហវ. កំណត់ផែនការសកម្មភាពកែទម្រង់អាទិភាព ដើម្បីជំរុញក្រសួង ស្ថាប័ន រៀបចំ MAP និងអនុវត្តប្រចាំឆ្នាំ។

១៦៦. **ខណៈតួនាទីរបស់**ក្រសួង ស្ថាប័ន**កាន់តែសំខាន់ ក្នុងការចូលរួមចំណែកក្នុង PFMRP ពិសេសក្នុងដំណាក់កាលទី៣ និងទី៤**, ការពង្រឹងសមត្ថភាពអង្គភាពនៃក្រសួង ស្ថាប័ន (អង្គភាពហិរញ្ញវត្ថុ និងអង្គភាពថវិកា) ជាកិច្ចការមួយដែលត្រូវយកចិត្តទុកដាក់ និងជំរុញបន្ថែម ក្រោមការគាំទ្ររបស់អង្គភាពហិរញ្ញវត្ថុ ប្រកបដោយសកម្ម, បុរេសកម្ម និងអន្តរសកម្ម។ ក្រសួង ស្ថាប័នស្ថិតក្នុងវិស័យតែមួយ គួររៀបចំគោលនយោបាយឱ្យមានភាពប្រទាក់ក្រឡាគ្នា ដើម្បីសម្រេចឱ្យបានលទ្ធផលចុងក្រោយ គឺធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ការកំណត់សកម្មភាពអាទិភាពសម្រាប់ការរៀបចំ និងអនុវត្តសម្រាប់ក្រសួង ស្ថាប័ន នៅក្នុងឆ្នាំ២០២២ ជាពិសេសបន្តលើកកម្ពស់ និងពង្រឹងការរៀបចំ និងការអនុវត្ត "**ការពង្រឹងការគ្រប់គ្រងនិងអនុវត្តផែនការប្រមូលចំណូល និងចំណាយ**", "ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ" និង "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ។ លទ្ធផលសម្រេចគន្លឹះសម្រេចបាន និងសង្ខេបដូចក្នុងតារាងទី៣ ខាងក្រោម÷

តារាងទី 3 ÷ វឌ្ឍនភាពតាមក្រសួង ស្ថាប័ន

| សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២២ | វឌ្ឍនភាពឆ្នាំ២០២២ |
|---|---|---|
| **ផ្នែកទី ១ ÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា** | | |
| ១. ចំនួនក្រសួង ស្ថាប័ន ប្រើប្រាស់ប្រព័ន្ធ NRMIS និង E-payment | ការបង់ចំណូលតាម E-Payment ដល់ ១០ ក្រសួង ស្ថាប័នបន្ថែម | - ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធ ចំនួន ២៣ ក្រសួង ស្ថាប័ន និងដាក់អនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិរហូតដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។<br>- គសហវ. បានចេញសារាចរលេខ ០០៣ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ E-payment ជំហានទី៣។ |

| សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២២ | វឌ្ឍនភាពឆ្នាំ២០២២ |
|---|---|---|
| ២. គ្រប់ក្រសួង ស្ថាប័ន ផ្ញើផែនការរជ្ជទេយ្យបុរេប្រទាន មក កសហវ. ទាន់ពេលវេលា | គ្រប់ក្រសួង ស្ថាប័ន ផ្ញើផែនការរជ្ជទេយ្យបុរេប្រទាន មក កសហវ. ទាន់ពេលវេលា | គ្រប់ក្រសួង ស្ថាប័នបានរៀបចំផែនការឥណទានរជ្ជទេយ្យ-បុរេប្រទានសម្រាប់ការចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ បានទាន់ពេលវេលា។ |
| ៣. ចំនួនក្រសួង ស្ថាប័ន ទូទាត់ថវិកាបុរេប្រទាន ទាន់ពេលវេលា សម្រាប់ថវិកាចរន្ត | គ្រប់ក្រសួង ស្ថាប័ន ទូទាត់ថវិកាបុរេប្រទាន (សម្រាប់ថវិកាចរន្ត) ទាន់ពេលវេលា | តួលេខបណ្ដោះអាសន្នលើការទូទាត់បុរេប្រទានគឺមានចំនួន ៧៥.២%។ ការទូទាត់នេះ នឹងមានការកើនឡើងពេលបិទបញ្ចប់ចំណាយ។ |
| ៤. ចំនួនក្រសួង ស្ថាប័ន បើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ | គ្រប់ក្រសួង ស្ថាប័នបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ | ក្រសួង ស្ថាប័ន ចំនួន ២១ បានរៀបចំការបើកប្រាក់បេសសកម្មតាមប្រព័ន្ធធនាគារ ក្នុងនោះមានក្រសួង ស្ថាប័ន ចំនួន ៥ អនុវត្តមិនទាន់ពេញលេញ។ |
| ៥. ភាគរយនៃផែនការលទ្ធកម្មត្រូវបានអនុម័តមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា | ៩០% ផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា | អនុម័តផែនការលទ្ធកម្មឆ្នាំ២០២៣ បាន ១១០/១១៥ ស្ថាប័ន (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ឬប្រមាណ ៩៦%។ |
| ៦. ភាគរយនៃអង្គភាពថវិការបស់ក្រសួង ស្ថាប័ន ផ្ដល់របាយការណ៍អនុវត្តកិច្ចលទ្ធកម្ម | យ៉ាងតិច ៦០% នៃអង្គភាពថវិកាផ្ដល់របាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលាមក កសហវ. | អង្គភាពអនុវត្តកិច្ចលទ្ធកម្ម បានផ្ដល់របាយការណ៍លទ្ធកម្មឆ្នាំ២០២១ បាន ៤៥៧/៦៣៩ (អង្គភាពថវិកា) ឬប្រមាណ ៧១%។ |
| **ផ្នែកទី ២ ÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ** | | |
| ១. ចំនួនមុខសញ្ញាចំណាយធ្វើស្វ័យប្រវត្តិកម្មសម្រាប់អនុវត្តថវិកាតាម FMIS នៅរដ្ឋបាលថ្នាក់កណ្ដាល | នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងៗ កម្រិត ១ និងកម្រិត ២ ត្រូវបានដាក់ឱ្យអនុវត្តផ្លូវការនៅ កសហវ. និង ៧ ក្រសួង ផ្សេងទៀត | - កសហវ. និង ក្រសួងបរិស្ថានបានអនុវត្តនីតិវិធីចំណាយថវិកាចរន្តលើគ្រប់មុខសញ្ញា តាមប្រព័ន្ធ FMIS ទាំងស្រុង។<br>- ក្រសួង ស្ថាប័នចំនួន ៣៤/៣៧ បានអនុវត្តនីតិវិធីចំណាយបៀវត្ស និងនីតិវិធីចំណាយទូទាត់ត្រង់ តាមប្រព័ន្ធ FMIS ទាំងស្រុង។ |
| ២. ចំនួនក្រសួង ស្ថាប័ន ដាក់ឱ្យអនុវត្ត SARMIS | ប្រព័ន្ធ SARMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន | SARMIS ត្រូវដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ រហូតដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| **ផ្នែកទី ៣ ÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | |

| សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២២ | វឌ្ឍនភាពឆ្នាំ២០២២ |
| --- | --- | --- |
| ១. កំណត់អត្រាគម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ | ភាគរយគម្លាតនៃផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំដែលអនុម័តត្រូវបានកាត់បន្ថយ | គម្លាតរវាងពិតានចំណាយគោលដែលកំណត់ក្នុងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងលទ្ធផលកញ្ចប់ថវិកាប្រចាំឆ្នាំ ទាបជាង ១៥%។ |
| ២. ចំនួនក្រសួង ស្ថាប័នរៀបចំថវិកាសមាហរណ-កម្ម ដែលមានកំណត់ក្នុងសារាចរស្តីពីការរៀបចំ BSP និងថវិកាប្រចាំឆ្នាំ | ចំនួន ៤ ក្រសួង ស្ថាប័នត្រូវបានធ្វើសមាហរណកម្មចំណាយចរន្តនិងចំណាយមូលធនរដ្ឋចូលក្នុងកម្មវិធីផ្អែកលើពិតានថវិកា | ក្រសួង ស្ថាប័នចំនួន ៩ ត្រូវបានធ្វើសាមាហរណកម្មចំណាយចរន្ត និងចំណាយមូលរដ្ឋចូលក្នុងកម្មវិធី។ គម្រោងចំណាយមូលធនក្នុងស្រុករបស់ក្រសួង ស្ថាប័ន (ក្រសួងសុខាភិបាល) ចំនួន១ បន្ថែមទៀតត្រូវបានណែនាំដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ទៅតាមកម្មវិធីនីមួយៗ។ |
| ៣. ចំនួនអង្គភាពថវិកា និងចំនួនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិនៅតាមក្រសួង-ស្ថាប័ន | បន្ថែមចំនួន ៣ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ និងបន្ថែម ១០ អង្គភាពថវិកា នៅតាមក្រសួង ស្ថាប័ន អង្គភាពថវិកា | អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធចំនួន ៩ បានបង្កើតឡើង និងអង្គភាពថវិកាថ្មីចំនួន ២៨ បានបង្កើតឡើងនៅឆ្នាំ ២០២២។ |
| ៤. ចំនួនក្រសួង ស្ថាប័នផ្តល់របាយការណ៍អនុវត្តថវិកាកម្មវិធីពាក់កណ្តាលឆ្នាំ២០២២ មក កសហវ. | គ្រប់ក្រសួង ស្ថាប័ន ផ្តល់របាយការណ៍អនុវត្តថវិកាកម្មវិធីពាក់កណ្តាលឆ្នាំ ២០២២ មក កសហវ. | ក្រសួង ស្ថាប័នចំនួន ២៤/៣០ បានផ្តល់របាយការណ៍អនុវត្តថវិកាកម្មវិធីពាក់កណ្តាលឆ្នាំ២០២២ មក កសហវ.។ |
| ៥. ចំនួនក្រសួង ស្ថាប័ន ផ្ញើរបាយការណ៍សមិទ្ធកម្មឆមាស និងប្រចាំឆ្នាំ មក កសហវ. | គ្រប់ក្រសួង ស្ថាប័នផ្ញើរបាយការណ៍សមិទ្ធកម្មឆមាស និងប្រចាំឆ្នាំ មក កសហវ | គ្រប់ក្រសួង ស្ថាប័ន បានផ្ញើរបាយការណ៍សមិទ្ធកម្មឆមាសទី១ ឆ្នាំ២០២២ មកអគ្គនាយកដ្ឋានថវិកា។ |
| **ផ្នែកទី ៤ ÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម** | | |
| ១. ចំនួនក្រសួង ស្ថាប័នបានអនុវត្តសាកល្បងថវិកាសមិទ្ធកម្ម | គ្រប់ក្រសួង ស្ថាប័នបានអនុវត្តសាកល្បងថវិកាសមិទ្ធកម្ម | គ្រប់ក្រសួង ស្ថាប័នបានអនុវត្តសាកល្បងថវិកាសមិទ្ធកម្ម (រៀបចំគម្រោងថវិកាឆ្នាំ ២០២៣ តាមទម្រង់ថវិកាសមិទ្ធកម្ម)។ |
| ២. ចំនួនក្រសួង ស្ថាប័នបានរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម | ក្រសួង ស្ថាប័នចំនួន ៧ បានរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម | ក្រសួងទាំង ០៧ ដែលចាប់ផ្តើមអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្ម ចាប់ពីឆ្នាំ២០២៣÷<br>- កសហវ. |

| សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២២ | វឌ្ឍនភាពឆ្នាំ២០២២ |
|---|---|---|
| | | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសុខាភិបាល<br>- ក្រសួងយុត្តិធម៌ |
| ៣. ចំនួនក្រសួង ស្ថាប័នអនុវត្តសាកល្បងក្របខ័ណ្ឌសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន | - ចំនួន៦ អង្គភាពសវនកម្មតាមក្រសួងស្ថាប័នចាប់ផ្តើមអនុវត្តសាកល្បងក្របខ័ណ្ឌសវនកម្មសមិទ្ធកម្ម<br>- ចំនួន៤ អង្គភាពសវនកម្មតាមក្រសួងស្ថាប័នចាប់ផ្តើមអនុវត្តសាកល្បងក្របខ័ណ្ឌសវនកម្មបច្ចេកវិទ្យាព័ត៌មាន | បានអនុវត្តសវនកម្មសមិទ្ធកម្មសាកល្បងជាករណីសិក្សានៅក្រសួងចំនួន ៦ និងសវនកម្ម បច្ចេកវិទ្យាព័ត៌មាន នៅក្រសួងចំនួន ៤។ |
| ៤. ចំនួនអង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័នផ្ញើរបាយការណ៍សវនកម្មផ្ទៃក្នុងជូន អ.ស.ជ. | គ្រប់អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័នផ្ញើរបាយការណ៍សវនកម្មផ្ទៃក្នុងជូន អ.ស.ជ. | ឆ្នាំ២០២២ របាយការណ៍សវនកម្មផ្ទៃក្នុងមានចំនួន១៥/៣០ ត្រូវបានផ្ញើទៅ អ.ស.ជ ដោយទទួលបានពីក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ។ |
| ៥. ចំនួនអង្គភាពសវនកម្មនៃក្រសួង ស្ថាប័នមានផែនការយុទ្ធសាស្ត្រសវនកម្មផែនការសវនកម្មប្រចាំឆ្នាំ និងរបាយការណ៍សវនកម្មស្តង់ដា | ផែនការយុទ្ធសាស្ត្រសវនកម្ម,ផែនការសវនកម្មរបស់ក្រសួងស្ថាប័នត្រូវបានរៀបចំ | - បានតាមដានលើការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំសម្រេចបាន ក្រសួងចំនួន២៤ ក្នុងនោះ÷ ត្រីមាសទី១ ចំនួន ៦ ក្រសួង, ត្រីមាសទី២ ចំនួន ៦ ក្រសួង, ត្រីមាសទី៣ ចំនួន ៦ ក្រសួង, និង ត្រីមាសទី៤ ចំនួន ៦ ក្រសួង។<br>- បានពិនិត្យប្រសិទ្ធភាពនៃមុខងារ<br>- សវនកម្មផ្ទៃក្នុងនៅក្រសួងចំនួន៨÷<br>- ត្រីមាសទី១ ចំនួន ២, ត្រីមាសទី២ ចំនួន ២ ក្រសួង, ត្រីមាសទី៣ ចំនួន ២ ក្រសួង, និង ត្រីមាសទី២ ចំនួន ២ ក្រសួង។<br>- អនុវត្តសវនកម្មនៃអង្គភាពក្រោមឱវាទ កសហវ សម្រេចបានចំនួន ៦៧អង្គភាពលើ១០០អង្គភាព គិតជាភាគរយ ស្មើ |

| សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២២ | វឌ្ឍនភាពឆ្នាំ២០២២ |
|---|---|---|
| | | នឹង៦៧% (៦៧/១០០) បើធៀបជាមួយគោលដៅសូចនាករ ៨៥% គឺស្មើនឹង ៧៩% (៦៧/៨៥)។<br>- វឌ្ឍនភាពនៃការអនុវត្តផែនការសវនកម្មផ្ទៃក្នុងរបស់ក្រសួង ចំនួន៨ (ផែនការ ១៧៦អង្គភាព បានអនុវត្ត ១៤៧អង្គភាព ស្មើនឹង ៨៤%) បើធៀបជាមួយគោលដៅសូចនាករ ៦៥% គឺស្មើនឹង១២៩% (៨៤/៦៥)<br>- បានពិនិត្យ និងផ្តល់យោបល់កែលម្អលើរបាយការណ៍សវនកម្មផ្ទៃក្នុងរបស់ក្រសួង ស្ថាប័នចំនួន២០ អង្គភាព។ |
| **ផ្នែកទី ៥ ÷ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត** | | |
| ១. ភាពទាន់ពេលវេលានៃការផ្ញើផែនការសកម្មភាព MAP ប្រចាំឆ្នាំ២០២១ | គ្រប់ក្រសួង ស្ថាប័ន រៀបចំផែនការសកម្មភាព MAP និងផ្ញើមក អគហ. ទាន់ពេលវេលា | ក្រសួង ស្ថាប័នចំនួន ១៥/៤១ បានផ្ញើរៀបចំ និងផ្ញើមក អ.គ.ហ. បានទាន់ពេលវេលា។ |
| ២. ភាពទាន់ពេលវេលានៃការផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត MAP ប្រចាំត្រីមាស | ២. ភាពទាន់ពេលវេលានៃការផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត MAP ប្រចាំត្រីមាស | ក្រសួង ស្ថាប័នចំនួន ៤០/៤០ បានផ្ញើរបាយការណ៍វឌ្ឍន-ភាពមក អ.គ.ហ. បានទាន់ពេលវេលា ។ |
| ៣. ភាពទាន់ពេលវេលា នៃការស្នើសមាសភាព កហស ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ប្រចាំឆ្នាំ | គ្រប់ក្រសួង ស្ថាប័ន រៀបចំសមាសភាព កហស ទទួលបានប្រាក់-ឧបត្ថម្ភលើកទឹកចិត្ត ប្រចាំឆ្នាំតាមកាលកំណត់របស់ អគហ. | គ្រប់ក្រសួង ស្ថាប័នបានរៀបចំសមាសភាព ក.ហ.ស. ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត និងផ្ញើមក អ.គ.ហ.។ |

ប្រភព÷ អ.គ.ហ.

១៦៧. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន ទាំង ៤០ ទទួលបានលទ្ធផលលើពី ៨០% សម្រាប់ក្រសួង ស្ថាប័នចំនួន ៣៦ និងក្រោម ៨០% សម្រាប់ក្រសួង ស្ថាប័នចំនួន ៤ ដូចមានក្នុងជ្យាក្រាមទី៨ ខាងក្រោម។

ដ្យាក្រាមទី 8 ÷ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់មន្ទីរ សហវ. រាជធានីខេត្ត




ប្រភព÷ អ. គ. ហ.

## ២.៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ

### ២.៣.១. ការអនុវត្តប្រព័ន្ធ FMIS

១៦៨. ឆ្លើយតបនឹងសំណើរបស់ កសហវ., ការិយាល័យអភិវឌ្ឍន៍សមត្ថភាពនៃ IMF ប្រចាំប្រទេសថៃ (CDOT) បានបំពេញបេសកកម្មគាំទ្រ FMIS លើកទី១៣ ចាប់ពីថ្ងៃទី៣១ ខែតុលា ដល់ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២។ ការបំពេញបេសកកម្មនេះមានការចូលរួមពីលោក Suhas Joshi ទីប្រឹក្សារតនាគារប្រចាំតំបន់, លោក Kris Kauffmann ទីប្រឹក្សាសម្រាប់ប្រព័ន្ធ FMIS និងលោកស្រី Delphine Moretti ទីប្រឹក្សាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំតំបន់នៃ IMF សម្រាប់អាស៊ីអាគ្នេយ៍នៅ CDOT។

១៦៩. បេសកកម្មនេះផ្តោតទៅលើ÷ (១) ការពិនិត្យវឌ្ឍនភាព និងអនុសាសន៍ដែលបានផ្តល់ ទាក់ទងនឹងការសម្រួលនីតិវិធីអនុវត្តការងារ (business process streamlining) និងរៀបចំឡើងវិញ (reengineering) ក្នុងបរិបទនៃការពង្រីកដាក់ឱ្យដំណើរការប្រព័ន្ធ FMIS ដោយផ្តោតលើការអនុវត្តចំណាយថវិកាចរន្ត ដោយរួមបញ្ចូល វិជ្ជទេយ្យបុរេប្រទាន និងបុរេប្រទាន, (២) ផ្តល់យោបល់ស្តីពីការធ្វើឌីជីថលូបនីយកម្មនៃមុខងារគ្រប់គ្រងសាច់ប្រាក់ និងព្យាករណ៍ និង (៣) តាមដានវឌ្ឍនភាពលើរបាយការណ៍ហិរញ្ញវត្ថុផ្ទៃក្នុង និងខាងក្រៅ។

**ការសម្រួលនីតិវិធីអនុវត្តការងារ (Business Process streamlining)**

១៧០. វឌ្ឍនភាពលើផ្នែកនេះគួរឱ្យកត់សម្គាល់ ចាប់តាំងពីបេសកកម្មចុងក្រោយក្នុងការកំណត់ និងដំណើរការរបៀបវារៈសម្រួលនីតិវិធីការងារ និងដាក់ឱ្យដំណើរការការពង្រីកប្រព័ន្ធ FMIS។

១៧១. ដំណាក់កាលទី១ នៃការកែសម្រួលនីតិវិធីអនុវត្តការងារបានបង្ហាញនូវភាពជោគជ័យក្នុងការធ្វើឌីជីថលូបនីយកម្ម (Digitizing) និងការកែសម្រួលនីតិវិធីឱ្យកាន់តែសាមញ្ញសម្រាប់ចំណាយបៀវត្សរ៍ និងអគ្គិសនី ទឹក (utility payments)។ ដំណាក់កាលបច្ចុប្បន្ននៃការសម្រួលនីតិវិធីអនុវត្តការងារផ្តោតសំខាន់លើការធ្វើឌីជីថលនីយកម្ម, ការគ្រប់គ្រង ដោយមានមូលដ្ឋានលើការប្រើក្រដាសសម្រាប់ប្រភេទចំណាយចរន្តបន្ថែមនៅក្នុងក្រសួងចំនួនពីរ (ទោះជាយ៉ាងណាមិនរាប់បញ្ចូលការចំណាយពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម)។ រហូតមកដល់ពេលនេះ ការធ្វើឌីជីថលូបនីយកម្ម រួមទាំងការផ្តល់ឧបករណ៍ដល់ថ្នាក់ស្រុក និងឃុំមួយចំនួន ដើម្បីធ្វើការផ្ទៀងផ្ទាត់ ប័ត្រទូទាត់តាមឌីជីថល ទៅរតនាគារខេត្តគឺមានភាពល្អ។ ជាការពិត ការឈានឆ្ពោះទៅ ការធ្វើឌីជីថលូបនីយកម្មនឹងតម្រូវការនៃការដាក់ឱ្យ ដំណើរការការចុះហត្ថលេខាឌីជីថល និងការរៀបចំគោលនយោបាយលើការអាចចូលប្រើប្រាស់ និងការផ្ទុកទិន្នន័យឌីជីថល។

១៧២. នៅក្នុងដំណាក់កាលអន្តរកាលនេះ ជំហានអនុម័តមួយចំនួនត្រូវបានដកចេញ តែប្រព័ន្ធ IT ផ្តល់នូវជម្រើសក្នុងការរួមបញ្ចូលការត្រួតពិនិត្យមួយចំនួនឡើងវិញ។ ឧបករណ៍តាមដានត្រួតពិនិត្យ ត្រូវបានអភិវឌ្ឍឡើង ដែលនឹងបង្ហាញពីពេលវេលានៃ ការអនុម័ត និងកំណត់ទីតាំងនៃដំណើរការអនុម័តដែលមានការកកស្ទះ។

១៧៣. ការផ្លាស់ប្តូរវិធានបានធ្វើឱ្យមានការថយចុះគួរឱ្យកត់សម្គាល់នៃការប្រើប្រាស់វិជ្ជទេយ្យបុរេប្រទាននៅក្នុងបណ្តាឆ្នាំថ្មីៗទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ ចំណាយបុរេប្រទាន សម្រាប់អង្គភាពថវិកា (និងលទ្ធភាពទូទាត់ទៅឱ្យទៅអ្នកផ្គត់ផ្គង់) ដែលជាបទដ្ឋាននៃការពិនិត្យចំណាយមុននៅតែជាបញ្ហានៃការអនុវត្តថវិកា ដោយសារតម្លាភាពនៅមានកម្រិត។ ក្រុមបេសកកម្មបានផ្តល់អនុសាសន៍ថា យ៉ាងហោចណាស់ វិសាលភាពប្រព័ន្ធ FMIS គួរត្រូវពង្រីកទៅគណនីធនាគាររបស់ក្រសួង ស្ថាប័ន ដើម្បីឱ្យមានតម្លាភាពទាក់ទងនឹងបុរេប្រទាន។ លើសពីនេះ ការកែសម្រួលឡើងវិញនៃនីតិវិធីអនុវត្តការងារគួរមាន មានមហិច្ឆិតាជាងនេះ ដើម្បីដោះស្រាយតម្រូវការមូលដ្ឋានលើល្បឿន និង

ភាពបត់បែនក្នុងការផ្តល់សេវាសាធារណៈ (ដែលជាការលើកទឹកចិត្តចម្បងសម្រាប់ភាពជឿនលឿននៃប្រព័ន្ធ)។ ការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាទូទាត់ឌីជីថល (ត្រូវបានណែនាំដោយបេសកកម្មគាំទ្រលើកមុន) រួមទាំងការទូទាត់តាមរយៈការប្រើប្រាស់កាត និងកម្មវិធីទូទាត់តាមទូរស័ព្ទចល័ត ផ្តល់នូវសក្តានុពលក្នុងការលុបបំបាត់តម្រូវការសាច់ប្រាក់សម្រាប់ការចំណាយលើការធ្វើដំណើរ និងការទិញទំនិញដែលមានតម្លៃតិចតួច។

**របាយការណ៍ចំណាយសាធារណៈ និងហិរញ្ញវត្ថុ**

១៧៤. ប្រព័ន្ធ FMIS បានក្លាយជាប្រភពទិន្នន័យដែលអាចជឿទុកចិត្តបានសម្រាប់ទិដ្ឋភាពភាគច្រើននៃការអនុវត្តថវិកា។ ប្រព័ន្ធ FMIS រួមបញ្ចូលគំរូរបាយការណ៍ស្តង់ដា និងវឌ្ឍនភាពត្រូវបានធ្វើឡើងក្នុងការអភិវឌ្ឍឃ្លាំងផ្ទុកទិន្នន័យ (data warehouse) និងឧបករណ៍វិភាគធុរកិច្ច (business intelligence tool) ដែលគាំទ្រការចែកចាយទិន្នន័យដើម្បីគាំទ្រការគ្រប់គ្រងចំណាយសាធារណៈនិងហិរញ្ញវត្ថុ។ របាយការណ៍ស្តង់ដាពី FMIS ត្រូវបានប្រើប្រាស់ដោយ GDNT សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ IPSAS និងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

១៧៥. ការបំពេញបេសកកម្មនេះបានរកឃើញថា ការបញ្ជូនទិន្នន័យផ្អែកលើក្រដាសនៅតែជាវិធី នៃការរាយការណ៍ការអនុវត្តថវិកា។ ក្រសួង ស្ថាប័នគឺនៅបន្តរក្សាគណនីគោលនៅក្នុងតារាង Excel ដែលនៅខាងក្រៅប្រព័ន្ធ FMIS សម្រាប់កត់ត្រាការអនុវត្តថវិកា។ ក្រៅពីការប្រឈមនឹងការមិនចង់ផ្លាស់ប្តូរ មូលហេតុចម្បងនៃបញ្ហានេះគឺថាប្រតិបត្តិការមួយចំនួន (និងគណនី) ស្ថិតនៅខាងក្រៅគណនីទោលរតនាគារ (TSA) និងនៅក្រៅប្រព័ន្ធ FMIS នោះទេ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រុមបេសកកម្មបានផ្តល់អនុសាសន៍ឱ្យពង្រីកវិសាលភាពរបស់ប្រព័ន្ធ FMIS ជាបណ្តើរៗ (ដើម្បីរួមបញ្ចូលគណនីធនាគារទាំងអស់ ប្រភពមូលនិធិទាំងអស់ និងគ្រប់ដំណាក់កាលនៃការអនុវត្តថវិកាមូលធន) ដោយកាត់បន្ថយតម្រូវការសម្រាប់ប្រព័ន្ធកត់ត្រាបន្ថែម។

១៧៦. ក្នុងករណី កសហវ. តម្រូវឱ្យក្រសួង ស្ថាប័ន (រួមទាំង រតនាគារខេត្ត) រៀបចំ ចុះហត្ថលេខា និងបញ្ជូនរបាយការណ៍ជាក្រដាសស្នាមទាក់ទងនឹងការអនុវត្តថវិកា។ នេះជាយន្តការត្រួតពិនិត្យផ្ទៃក្នុង (ដើម្បីឱ្យមានគណនេយ្យភាព ដោយមន្ត្រីទទួលបន្ទុកចុះហត្ថលេខាលើទិន្នន័យ) បន្ថែមពីលើប្រភពនៃទិន្នន័យប្រតិបត្តិថវិកា។

១៧៧. អភិក្រមប្រកបដោយមហិច្ឆិតាជាងនេះ ដែលលើសពីការអនុវត្តឌីជីថលនាពេលបច្ចុប្បន្ន គឺដាក់ឱ្យដំណើរការការបិទរយៈកាល (period)ផ្លូវការ ដើម្បីធ្វើសុពលភាពនៃទិន្នន័យរួមជាមួយនឹងយន្តការគណនេយ្យភាព និងតម្លាភាពដ៏រឹងមាំ ដែលគាំទ្រដោយប្រព័ន្ធ FMIS ដែលនឹងជៀសវាងតម្រូវការសម្រាប់ការបោះពុម្ព និងចុះហត្ថលេខាជាក់ស្តែង។ អភិក្រមនេះ នឹងមានអត្ថប្រយោជន៍ក្នុងការបង្កើនការគ្រប់គ្រងផ្ទៃក្នុងនៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពថវិកា ដែលផ្តល់លទ្ធផលកែលម្អគុណភាពទិន្នន័យនៅក្នុងប្រព័ន្ធ FMIS។ តាមវិធីសាស្ត្រនេះ ផ្នត់គំនិតនៃភាពជឿទុកចិត្ត ប្រព័ន្ធ FMIS នឹងកើនឡើង ហើយការពឹងផ្អែកលើរបាយការណ៍បំពេញដោយដៃ ដែលជានីតិវិធីខាងក្រៅប្រព័ន្ធនឹងមានតិចតួច។

**ឌីជីថលនីយកម្មនៃការគ្រប់គ្រងសាច់ប្រាក់**

១៧៨. ក្រុមបេសកកម្មបានរកឃើញថា នាពេលបច្ចុប្បន្ន អ.រ.ជ (GDNT) បាននិងកំពុងប្រើប្រាស់ ឧបករណ៍សម្រាប់ការគ្រប់គ្រងសាច់ប្រាក់មិនទាន់មានប្រសិទ្ធភាព (ដោយខ្វះកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ) និងមិនត្រូវបានសមាហរ-ណកម្ម ជាមួយប្រព័ន្ធ FMIS។ ការព្យាករសាច់ប្រាក់ត្រូវបានធ្វើឡើងនៅលើតារាង Excel ដាច់ដោយឡែក ដែលប្រវត្តិទិន្នន័យ ត្រូវបានប្រើ ដើម្បីគណនាគំរូប្រចាំខែ (តាមរដូវកាល) នៅក្នុងការកត់ត្រាចំណូល និងចំណាយ

ថវិកា ដែលត្រូវគិតធៀបនឹងការប៉ាន់ស្មានថវិកាឆ្នាំបច្ចុប្បន្នសម្រាប់គម្រោងវិហ្វរប្រចាំខែ។ GDNT ធ្វើបច្ចុប្បន្នភាពតារាង Excel ជាក់ស្តែងប្រចាំខែ ប៉ុន្តែទំហំនៃការចំណាយជាក់ស្តែងមិនប៉ះពាល់ដល់ការគ្រោងសម្រាប់ ខែបន្ត-បន្ទាប់ទេ។

១៧៩. លើសពីនេះទៀត GDNT ដំណើរការ Web-based Apllication សម្រាប់អង្គភាពថវិកា ដើម្បីផ្តល់ការព្យាករនៃវិហ្វរសាច់ប្រាក់។ ជាការអនុវត្តជាក់ស្តែង ក្រសួង ស្ថាប័នជាច្រើនមិនផ្តល់ការព្យាករសាច់ប្រាក់តាមរយៈប្រព័ន្ធនេះទេ ហើយ/ឬទិន្នន័យដែលបានផ្តល់គឺមិនពេញលេញ។ ជាលទ្ធផល ការព្យាករវិហ្វរសាច់ប្រាក់ដែលធ្វើឡើងដោយ GDNT មិនទាន់មានការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន នៅឡើយ។ ដូច្នេះ ការព្យាករគឺផ្អែកលើលំនាំប្រវត្តទិន្នន័យនៃការអនុវត្តចំណាយថវិកាប៉ុណ្ណោះ។ ក្នុងន័យនេះ ការព្យាករមិនទាន់មានភាពត្រឹមត្រូវដូចដែល GDNT ចង់បាននោះទេ។

១៨០. អាទិភាពជាបន្ទាន់គួរតែធ្វើបច្ចុប្បន្នភាព និងលិខិតណែនាំស្តីពីការគ្រប់គ្រងសាច់ប្រាក់ (CM) ដោយផ្តល់ការបណ្តុះ-បណ្តាលដល់មន្ត្រីបង្គោលតាមក្រសួង ស្ថាប័ន។

១៨១. កាលបើពេលបានបំពេញបុរេលក្ខខ័ណ្ឌទាំងនេះ ប្រព័ន្ធ FMIS នឹងផ្តល់កាលានុវត្តភាព សម្រាប់ការពង្រឹងការប្រមូលទិន្នន័យនៃការអនុវត្តថវិកា ដែលជួយសម្រួលដល់ការធ្វើផែនការសាច់ប្រាក់។ ប្រព័ន្ធ FMIS អាចត្រូវបានកំណត់រចនាសម្ព័ន្ធ (configure) បានល្អប្រសើរសម្រាប់ការចាប់យកទិន្នន័យធានាចំណាយថវិកា (budget commitment) សម្រាប់រាល់ការចំណាយតាមឆន្ទានុសិទ្ធិ (discretionary expenditure), ការត្រួតពិនិត្យលើការធានាចំណាយថវិកា ថវិកាធៀបនឹងថវិកាវិភាជន៍ ដែលរៀបចំឡើងផ្អែកលើផែនការចំណាយ, ការកត់ត្រាប៉ាន់ស្មានការបើកផ្តល់សាច់ប្រាក់ នៅពេលមានការបញ្ជាទិញត្រូវបានបញ្ចូល, ការកត់ត្រាវិក្កយបត្រការទិញ នៅក្នុងប្រព័ន្ធ FMIS, និងការកត់ត្រាវិក្កយបត្រនៅពេលនីមួយៗត្រូវបានទទួល (វិក្កយបត្រឱីជីថលដែលមានសក្តានុពល)។ ជាការណែនាំការវាយតម្លៃតម្រូវការត្រូវបានធ្វើឡើងដែលលម្អិតអំពីប្រភេទទិន្នន័យដែលប្រព័ន្ធ FMIS អាចចាប់យកសម្រាប់ការគាំទ្រការគ្រប់គ្រងសាច់ប្រាក់។

### ២.៣.២. ការរៀបចំសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ

១៨២. សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ជាដំណាក់កាលមួយក្នុងការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩ - ២០២៥ ដោយមានវិសោធនកម្មជាច្រើនមាត្រាពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនេះ។

- វិមជ្ឈការគឺជាសមាសធាតុសំខាន់នៃសេចក្តីព្រាងនិងយុទ្ធសាស្ត្រ។ វិមជ្ឈការមានន័យជាសំខាន់ថាសិទ្ធិក្នុងការធ្វើការសម្រេចចិត្ត និងការគ្រប់គ្រងរាល់កិច្ចសន្យាត្រូវបានប្រតិភូកម្មទៅឱ្យអង្គភាពលទ្ធកម្មផ្ទាល់នីមួយៗជាស្ថាប័នរដ្ឋាភិបាល។ សមត្ថកិច្ចរបស់ថ្នាក់កណ្តាលត្រូវបានរក្សាទុកសម្រាប់កិច្ចសន្យាណាដែលជាយុទ្ធសាស្ត្រ ឬមានភាពរសើប។ ដំណើរការវិមជ្ឈការនឹងមានបញ្ហាប្រឈមកើតឡើង ព្រោះមានតម្រូវការនៃការកសាងសមត្ថភាពផ្នែកលទ្ធកម្មជាសារៈសំខាន់ ហើយត្រូវចំណាយពេលច្រើន។
- សេចក្តីព្រាងច្បាប់ នេះស្ថិតក្នុងសមត្ថភាពកិច្ចរបស់ GDPP ជានិយ័តករពិនិត្យតាមក្រោយបន្ទាប់ពីបានបញ្ចប់នីតិវិធីលទ្ធកម្ម។ ការពិនិត្យតាមក្រោយ អនុញ្ញាតឱ្យមានការអនុវត្តការពិនិត្យលើកម្រិតហានិភ័យជាប្រចាំ និងជាពិសេសនៅក្នុងបរិបទនៃវិមជ្ឈការដែលជាមធ្យោបាយសំខាន់សម្រាប់ GDPP ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានជាទៀងទាត់អំពីដំណើរការនៃប្រព័ន្ធលទ្ធកម្មសាធារណៈ និងដើម្បីកំណត់ចំណុចខ្វះខាត។ សម្រាប់

គោលបំណងរួម សេចក្តីព្រាងច្បាប់នេះក៏អនុញ្ញាតិឱ្យមានអន្តរាគមន៍ក្នុងដំណើរការដែលមានភាពមិនប្រក្រតីដែលត្រូវបានចង្អុលបង្ហាញ។

- លទ្ធភាពនៃការប្រើប្រាស់ការវាយតម្លៃគុណវុឌ្ឍិជាមុន ចំពោះអ្នកដេញថ្លៃ បន្ថែមលើការវាយតម្លៃគុណវុឌ្ឍិតាមក្រោយ ត្រូវបានពង្រីកដោយរួមបញ្ចូលរាល់កិច្ចសន្យាដែលគុណវុឌ្ឍិរបស់អ្នកដេញថ្លៃមានសារៈសំខាន់ជាពិសេសដោយសារលក្ខណៈបច្ចេកទេសនៃកិច្ចសន្យា។ ដំណាក់កាលដំបូងនៃការវាយតម្លៃគុណវុឌ្ឍិមុនដេញថ្លៃជាផ្នែកមួយនៃនីតិវិធីប្រកួតប្រជែង មានន័យថាការអញ្ជើញឱ្យមានការដេញថ្លៃអាចត្រូវបានកំណត់ចំពោះអ្នកដេញថ្លៃដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តែប៉ុណ្ណោះ។
- វិសាលភាពសម្រាប់ការចរចាជាមួយអ្នកដេញថ្លៃមួយ (លទ្ធកម្មប្រភពតែមួយ) ត្រូវបានរឹតបន្តឹង ដោយបន្ថែមលក្ខខណ្ឌបន្ថែមទៀតសម្រាប់ការប្រើប្រាស់វិធីសាស្ត្រនេះ។ នេះនឹងការពារការប្រើប្រាស់លើសលប់ ហើយជាលទ្ធផលលើកកម្ពស់ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង។
- ជាលទ្ធផលនៃវិមជ្ឈការ និងដើម្បីផ្តល់ការណែនាំចាំបាច់សម្រាប់អង្គភាពលទ្ធកម្ម សេចក្តីព្រាងបានគូសបញ្ជាក់ថា តម្រូវការ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសអ្នកដេញថ្លៃត្រូវតែអាចផ្ទៀងផ្ទាត់បាន និងសមស្របទៅនឹងគោលបំណងនៃលទ្ធកម្ម។ ជាមួយគ្នានេះដែរ សេចក្តីព្រាងច្បាប់នេះចែងអំពីល័ក្ខខ័ណ្ឌដែលកិច្ចសន្យាដែលឈ្នះត្រូវបំពេញ រួមទាំងតម្រូវការទាក់ទងនឹងអនុលោមភាព និងចង្អុលបង្ហាញអំពីការប្រើប្រាស់ថ្លៃទាបបំផុតជាលក្ខណៈវិនិច្ឆ័យនៃការផ្តល់លទ្ធកម្មដល់ក្រុមហ៊ុនឈ្នះ។
- សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បើកចំហដោយមានទំនោរទៅក្នុងស្រុក ឧទាហរណ៍សហគ្រាសតូចៗក្នុងស្រុក។ បទប្បញ្ញត្តិលម្អិតត្រូវបានគិតគូរក្នុងលិខិតបដ្ឋានក្រោមច្បាប់ (secondary legislation)។
- បន្ទាប់ពីការប្រគល់កិច្ចសន្យា (contract award) សេចក្តីព្រាងនេះបង្កើតសិទ្ធិសម្រាប់ការប្រកួតប្រជែង, អ្នកដេញថ្លៃបរាជ័យ មានសេចក្តីសង្ខេបអំពីមូលហេតុដែលការដេញថ្លៃចាញ់។ នេះជាសិទ្ធិក្នុងការពន្យល់នេះដែលបំពេញបន្ថែមសិទ្ធិសម្រាប់អ្នកដេញថ្លៃក្នុងការតវ៉ា។ អ្នកដេញថ្លៃអាចពេញចិត្តនឹងការពន្យល់ដែលទទួលបានក្នុងកំឡុងការពិភាក្សា ហើយនឹងមិនចាំបាច់លើកយកបញ្ហានេះបន្តនោះទេ ឬវានឹងជួយសន្សំសំចៃពេលវេលា និងការចំណាយសម្រាប់ភាគីទាំងអស់។ សម្រាប់អ្នកដេញថ្លៃ ការពិភាក្សាអាចបង្កើនសមត្ថភាពក្នុងការរៀបចំការដេញថ្លៃកាន់តែប្រសើរនាពេលអនាគត។
- បញ្ញត្តិទាក់ទងនឹងលទ្ធកម្មប្រកបដោយនិរន្តរភាព ត្រូវបានរួមបញ្ចូលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍បន្ថែមទៀតនៃគោលនយោបាយ និងល័ក្ខខ័ណ្ឌនៃការដេញថ្លៃនៅក្នុងផ្នែកពាក់ព័ន្ធ ពោលគឺជាចម្បង ការការពារបរិស្ថាន និងសង្គម។ បញ្ញត្តិបង្ហាញពីគោលបំណងនៃការអនុវត្តគោលនយោបាយប្រកបដោយនិរន្តរភាព និងបញ្ជាក់បន្ថែម ដោយបង្ហាញពីប្រភេទនៃតម្រូវការក្នុងការធ្វើកិច្ចលទ្ធកម្ម ដែលនិរន្តរភាពជាចំណុចពាក់ព័ន្ធពិសេស រួមទាំងការបង្កើតនូវការកំណត់លក្ខណៈបច្ចេកទេស។ ការអនុវត្តនឹងតម្រូវឱ្យមានបទប្បញ្ញត្តិលម្អិតបន្ថែមទៀតក្នុងលិខិតបទដ្ឋានក្រោមច្បាប់ (secondary legislation)។
- លទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-procurement) ត្រូវបានធ្វើឡើងដោយអនុលោមតាមបទប្បញ្ញត្តិស្រដៀងគ្នាដែលរៀបរាប់ពីធាតុសំខាន់ៗក្នុងការណែនាំអំពីលទ្ធកម្មអេឡិចត្រូនិក។ នេះរួមបញ្ចូលទាំងការបន្ថែមទៅលើ

ស្ថានភាពស្មើគ្នានៃប្រព័ន្ធផ្សព្វផ្សាយដែលផ្អែកលើក្រដាស និងឌីជីថលនូវតម្រូវការសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងភាពអាចរកបាន/ការតភ្ជាប់នៃកម្មវិធី និងបូរណភាពនៃការបញ្ជូន និងការផ្ទុកឯកសារ។ ដូចគ្នានេះ នៅក្នុងករណីនៃលទ្ធកម្មតាមអេឡិចត្រូនិក (e-procurement) នឹងត្រូវបានរំពឹងទុកដើម្បីចេញបទប្បញ្ញត្តិបន្ថែមទៀតក្នុងលិខិតបទដ្ឋានក្រោមច្បាប់ ។

### ២.៣.៣. ការវាយតម្លៃថវិកាយេនឌ័រ

១៨៣. ក្នុងរយៈពេល ២៥ ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាទទួលបានការរីកចម្រើនគួរកត់សម្គាល់ ក្នុងការដោះស្រាយវិសមភាពយេនឌ័រ និងលុបបំបាត់គម្លាតឱកាសរវាងបុរស និងស្ត្រី ក្នុងគោលដៅក្លាយជា ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០។

១៨៤. ដើម្បីសម្រេចបានតាមបំណងប្រាថ្នាដែលបានដាក់ចេញ ការយល់ដឹងទូទៅអំពីទស្សនាទាននៃថវិកាយេនឌ័រ និងការកែទម្រង់ថវិកាយេនឌ័រទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេស ពិតជាមានសារៈសំខាន់ ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ។

១៨៥. ថវិកាយេនឌ័រ គឺមិនមែនជាមូលដ្ឋានសម្រាប់កម្មវិធីចំណាយថវិកាសម្រាប់ស្ត្រី និងក្មេងស្រី ហើយក៏មិនមែនជាថវិកាដាច់ដោយឡែកផងដែរ ជារួមថវិកាយេនឌ័រ គឺជាមធ្យោបាយជាក់លាក់មួយរបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការវិភាជថវិកាក្នុងវដ្តថវិកា រួមមាន÷ សារាចរស្តីពីថវិកាយេនឌ័រ, ការវាយតម្លៃបច្ច័យយេនឌ័រ, ការតាមដាន និងត្រួតពិនិត្យលើការចំណាយថវិកាលើយេនឌ័រ, ការឆ្លើយតបថវិកាយេនឌ័រ នៅក្នុងបរិបទនៃថវិកាកម្មវិធី និងការអនុវត្ត, និងរបាយការណ៍ស្តីពីថវិកាយេនឌ័រ។

១៨៦. ការផ្តួចផ្តើមវាយតម្លៃថវិកាយេនឌ័រនៅក្នុងបរិបទកម្ពុជានេះ គឺក្នុងគោលបំណងជារួម ដើម្បីពិនិត្យវឌ្ឍនភាពនៃការកែទម្រង់ថវិកាយេនឌ័រ និងវាយតម្លៃការអនុវត្តថវិកាយេនឌ័រនៅកម្រិតគោលនយោបាយ និងកម្រិតក្រសួងស្ថាប័ន។ រីឯគោលបំណងជាក់លាក់គឺដើម្បីពិនិត្យលើការរៀបចំស្ថាប័នគាំទ្រដល់ការកែទម្រង់ថវិកាយេនឌ័រ, ពិនិត្យគុណភាព និងប្រសិទ្ធភាពនៃឧបករណ៍ថវិកាយេនឌ័រដែលបាននិងកំពុងអនុវត្តបច្ចុប្បន្នផ្សារភ្ជាប់នឹងបទពិសោធន៍ល្អពីបណ្តាប្រទេសផ្សេងៗទាំងក្នុងតំបន់ និងអន្តរជាតិ, រៀបចំឧបករណ៍ថវិកាយេនឌ័រដែលអាចនឹងផ្តល់តម្លៃបន្ថែមដល់ការអនុវត្តបច្ចុប្បន្ន, ព្រមទាំងពង្រឹងការផ្សារភ្ជាប់ និងសមាហរណកម្មឧបករណ៍ថវិកាយេនឌ័របន្ថែមនេះ នៅក្នុងវដ្តថវិកា។

១៨៧. ផ្អែកលើលទ្ធផលបឋមនៃការវាយតម្លៃថវិកាយេនឌ័រ តាមរយៈការគាំបច្ចេកទេសដោយមូលនិធិរូបិយវត្ថុអន្តរជាតិបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការលើកម្ពស់សមភាពយេនឌ័រ របស់រដ្ឋាភិបាលកម្ពុជា ដោយបញ្ចូលសមភាពយេនឌ័រនៅក្នុងរដ្ឋធម្មនុញ្ញ, យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ក្របខ័ណ្ឌគោលនយោបាយ ដោយមានក្រសួងកិច្ចការនារី ដែលជាស្ថាប័នរដ្ឋាភិបាលដឹកនាំ រៀបចំ សម្របសម្រួល និងជំរុញដំណើរការអនុវត្តផែនការសកម្មភាពបញ្ជ្រាបសមភាពយេនឌ័រតាមវិស័យជាដើម។ ការបញ្ជ្រាបយេនឌ័រ ត្រូវបានជ្រួតជ្រាបទូទាំងក្រសួង ស្ថាប័ន និងមានការយល់ដឹងអំពីបញ្ហាសមភាពយេនឌ័រ ជាពិសេសមានក្រុមការងារបញ្ជ្រាបយេនឌ័រ និងមានទិន្នន័យបែងចែកតាមយេនឌ័រ (ស្ត្រី និងបុរស) ក្នុងស្ថាប័ន រួមនឹងការអនុវត្តថវិកាតាមអភិក្រមថវិកាកម្មវិធី និងមានប្រព័ន្ធ FMIS សម្រាប់ការអនុវត្ត។

១៨៨. ទោះជាយ៉ាងនេះក្តី, នៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ថវិកាយេនឌ័រជារបកគំហើញថ្មីមួយទៀត ដែលជាបញ្ហាប្រឈមត្រូវយកចិត្តទុកដាក់រួមមាន÷

- មិនទាន់មានការយល់ដឹងរួមអំពីទស្សនាទាននៃថវិកាយេនឌ័រ
- មិនទាន់មានភាពច្បាស់លាស់ចំពោះការរៀបចំយន្តការស្ថាប័ន សម្រាប់ថវិកាយេនឌ័រ និងតួនាទីរបស់ កសហវ.
- ដំណើរការថវិកា និងដំណើរការយេនឌ័រ បច្ចុប្បន្ន ត្រូវបានអនុវត្តស្របគ្នា ប៉ុន្តែមិនទាន់សមាហរណកម្មជាមួយគ្នា
- ផែនការតាមវិស័យ និងផែនការជាតិ មិនទាន់ភ្ជាប់គ្នាបានល្អទៅនឹងផែនការថវិកា
- យេនឌ័រ មិនទាន់ជាសមាសធាតុសម្រាប់រៀបចំថវិកា និងមិនទាន់សមាហរណកម្មចូលក្នុង BSP និង PB
- មិនទាន់មានអភិក្រមជាប្រព័ន្ធ សម្រាប់កំណត់កម្មវិធី និងគោលនយោបាយដែលមានបច្ច័យលើវិសមភាពយេនឌ័រ។

១៨៩. លទ្ធផលនៅក្នុងរបាយការណ៍វាយតម្លៃថវិកាយេនឌ័រ ក៏បានរំលេចនូវវិធីសាស្ត្រមួយចំនួនដើម្បីដោះស្រាយ កង្វះខាតមួយចំនួនខាងលើដូចខាងក្រោម÷

- លើកកម្ពស់ការចូលរួម និងចែករំលែកចំណេះដឹងស្តីពីថវិកាយេនឌ័រ ទាំងកម្រិតរដ្ឋាភិបាល ទាំងកម្រិតបច្ចេកទេស
- ការអនុវត្តប្រកបដោយជោគជ័យនៃការកែទម្រង់ថវិកាយេនឌ័រ គឺតម្រូវឱ្យមានការដឹកនាំយ៉ាងសកម្មដោយ កសហវ. ដើម្បីផ្សារភ្ជាប់យេនឌ័រទៅនឹងដំណើរការរៀបចំថវិកា
- កំណត់ក្របខ័ណ្ឌថវិកាយេនឌ័រឱ្យបានច្បាស់លាស់ នៅក្នុងលិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នរដ្ឋាភិបាល
- បង្កើតឧបករណ៍តាមដានការអនុវត្តថវិកាយេនឌ័រ និងវាយតម្លៃបច្ច័យថវិកាយេនឌ័រ
- សមាហរណកម្មឧបករណ៍ថវិកាយេនឌ័រ ទៅក្នុងវដ្តថវិកា និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយចាប់ផ្តើមអនុវត្តសាកល្បងក្រសួង ស្ថាប័នអាទិភាព
- ដាក់បញ្ចូលកម្មវិធីកែទម្រង់ថវិកាយេនឌ័រ នៅក្នុងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ. ដើម្បីតាមដាន ត្រួតពិនិត្យនិងវាយតម្លៃប្រចាំត្រីមាស និងប្រចាំឆ្នាំ។

១៩០. ទោះជាយ៉ាងនេះក្តី ខាងលើនេះជាលទ្ធផលលើកដំបូង នៃការចាប់ផ្តើមវាយតម្លៃថវិកាយេនឌ័រ ក្នុងបរិបទកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ នឹងសហការបន្ថែមទៀតជាមួយ អ.គ.ហ. ជាពិសេសអគ្គនាយកដ្ឋានថវិកា នៃ កសហវ. និងក្រសួងកិច្ចការនារី ដើម្បីកំណត់នូវវិធីសាស្ត្រ ឬឧបករណ៍ចាប់អនុវត្តថវិកាយេនឌ័រនៅកម្ពុជាជាបន្តបន្ទាប់។

### ២.៣.៤. ការវាយតម្លៃចំណាយសាធារណៈ

#### ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Fiscal Management)

១៩១. មុនវិបត្តិជំងឺកូវីដ-១៩, កំណើនសេដ្ឋកិច្ចកម្ពុជាមានភាពរឹងមាំ និងប្រកបដោយបរិយាប័ន្ន។ ប្រទេសកម្ពុជាមាននិរន្តរភាពចំពោះអត្រាកំណើន ផ.ស.ស. ពិតប្រចាំឆ្នាំជាមធ្យម ៧,៦% នៅចន្លោះឆ្នាំ ១៩៩៥ និង ២០១៩ ដែលបានក្លាយជាប្រទេសមួយដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតនៅលើពិភពលោក។ កំណើននេះ គឺរួមបញ្ចូលជាមួយនឹងអត្រានៃការប្រើប្រាស់ក្នុងមនុស្សម្នាក់សម្រាប់ប្រជាជនក្រីក្របំផុត (Consumption per capita for the poorest) ស្មើ ៤០% នៃកំណើនប្រជាជនជាមធ្យម ២% ក្នុងមួយឆ្នាំ និងអត្រាចំនួនប្រជាជនក្រីក្រ (poverty headcount) ធ្លាក់ចុះពី ៣៣.៨% មកត្រឹម ១៧.៨% នៅចន្លោះឆ្នាំ ២០០៩ និង ២០១៩។

១៩២. កំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាបានថយចុះនៅដើមឆ្នាំ ២០២០ ដោយសារតែការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ជាសកល ដែលបានគម្រាមកំហែងដល់ការអភិវឌ្ឍក្នុងប្រទេសកម្ពុជា និងបានកាត់បន្ថយទំហំលំហសារពើពន្ធក្នុងប្រទេសផងដែរ។ ប្រសិនបើគ្មានវិធានការកាត់បន្ថយសំខាន់ៗទាន់ពេលវេលានោះទេ ជំងឺកូវីដ-១៩ នឹងបណ្តាលឱ្យមានការកើនឡើងយ៉ាងខ្លាំងនៃភាពអត់ការងារធ្វើ (ពី ៨៥៩ ០០០ ទៅ ៩៥០ ០០០នៃចំនួននយោជិត) និងការកើនឡើងនៃភាពក្រីក្រ (ចន្លោះពី ៥,៤ និង ៦,០ ភាគរយ)។ ជំងឺរាតត្បាតកូវីដ-១៩ បានវាយលុកសេដ្ឋកិច្ច កម្ពុជាយ៉ាងខ្លាំង។ ប្រាក់ចំណូលសរុបរបស់រាជរដ្ឋាភិបាល រួមទាំងជំនួយដែលបានកើនឡើងដល់ ២៧ ភាគរយ នៃ ផសស. ក្នុងឆ្នាំ ២០១៩ និងបានធ្លាក់ចុះមកវិញត្រឹម ២៤.១ % នៃ ផសស. ក្នុងឆ្នាំ ២០២០ ដោយសារការប្រមូលចំណូលទាំងសារពើពន្ធ និងមិនមែនសារពើពន្ធបានធ្លាក់ចុះ។

១៩៣. គោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ ត្រូវបានប្រើប្រាស់ដើម្បីទប់ទល់ផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ខាងផ្នែកហិរញ្ញវត្ថុសាធារណៈ ចំណាយរបស់ រាជរដ្ឋាភិបាលឈានដល់ប្រមាណ ២៦,៩ % នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០២០ ធៀបនឹង ២៥,៥ % នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៩ ដោយសារអន្តរាគមន៍របស់រាជរដ្ឋាភិបាលដែលរួមបញ្ចូលចំណាយកម្មវិធីសង្គម (ឧបត្ថម្ភធន និងការផ្ទេរ) ក៏ដូចជាចំណាយមូលធនផងដែរ។ ខាងផ្នែរូបិយវត្ថុ ធនាគារកណ្តាលបាន កាត់បន្ថយអត្រានៃតម្រូវការឥណទានបម្រុង និងបានដាក់ចេញវិធានការរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ។ មាត្រដ្ឋានត្រូវបានកាត់បន្ថយមកត្រឹម ៧% សម្រាប់ទាំងប្រាក់បញ្ញើរូបិយប័ណ្ណក្នុងស្រុក និងរូបិយប័ណ្ណបរទេស, សម្រាប់រូបិយប័ណ្ណក្នុងស្រុកធ្លាក់ចុះពី ៨% និង ១២,៥% សម្រាប់ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសសម្រាប់ រយៈពេលប្រាំមួយខែដែលចាប់ផ្តើមនៅក្នុងខែមេសា ឆ្នាំ ២០២០។ លើសពីនេះ, ធនាគារកណ្តាលបានចេញ សេចក្តីណែនាំមួយដល់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុទាំងអស់ ដើម្បីរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ ខណៈពេលដែលការបន្ទុះបន្ថយបន្ទុករបស់កូនបំណុលដែលប្រឈមនឹងការធ្លាក់ចុះនៃ ប្រាក់ចំណូលដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ នេះ។ ដោយបានដាក់ឱ្យអនុវត្តនៅខែមេសា ឆ្នាំ ២០២០ វិធានការរៀបចំរចនាសម្ព័ន្ធបំណុលដែលរងឥទ្ធិពលដោយជំងឺកូវីដ-១៩ ទាំងនេះបានបញ្ចប់នៅខែមិថុនា ឆ្នាំ ២០២២ ដោយសារសេដ្ឋកិច្ចបានចាប់ផ្តើមប្រសើរឡើង។

១៩៤. គោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកាត់បន្ថយផលប៉ះពាល់នៃការរាតត្បាតនៃជំងឺកូវីដ-១៩ លើប្រជាជនក្រីក្រ ប៉ុន្តែការកែលម្អគុណភាពនៃការចំណាយគឺត្រូវការជាចាំបាច់នៅពេលខាងមុខ។ ការបង្កើនការចំណាយសាធារណៈរបស់ប្រទេសកម្ពុជាត្រូវបានជំរុញមួយផ្នែកដោយការដំឡើងប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការទាំងអស់។ ប័ណ្ណប្រាក់ឈ្នួលសម្រាប់វិស័យសាធារណៈបានកើនឡើងនិងឈានដល់កម្រិត ៨,១% នៃ ផសស. ក្នុងឆ្នាំ ២០២០ កើនឡើងពី ៤,៤% នៃ ផសស. ក្នុងឆ្នាំ ២០១០។ ប័ណ្ណប្រាក់ឈ្នួលក្នុងវិស័យសាធារណៈបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មុនការកើតឡើងនូវជំងឺរាតត្បាតកូវីដ-១៩។ ការប្រៀបធៀបថ្នាក់តំបន់បង្ហាញថា ការចំណាយលើប្រាក់ឈ្នួលក្នុងវិស័យសាធារណៈរបស់កម្ពុជា ជាចំណែកនៃចំណាយសាធារណៈ និងចំណូលក្នុងស្រុកគឺស្ថិតនៅកម្រិតខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងប្រាក់ឈ្នួលក្នុងវិស័យសាធារណៈមិនបាននាំមកនូវភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងការផ្តល់សេវាសាធារណៈនោះទេ។

១៩៥. កម្ពុជាអាចជំរុញការប្រមូលចំណូលក្នុងស្រុកបានយ៉ាងច្រើន ដោយសារការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពជោគជ័យ ប៉ុន្តែការប្រមូលចំណូលបានរងគ្រោះដោយសារជំងឺរាតត្បាតកូវីដ-១៩។ បន្ទាប់ពីជួបប្រទះឱនភាពសារពើពន្ធជាច្រើនឆ្នាំ កម្ពុជាសម្រេចបានអតិរេកសារពើពន្ធក្នុងឆ្នាំ ២០១៨ និង ២០១៩ (ប្រហែល ០,៤ ភាគរយ និង ១,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប)។ អាជ្ញាធរប្រមូលប្រាក់បញ្ញើរបស់រដ្ឋាភិបាល ឬទុនបំរុងសារពើពន្ធដែលបានឡើងដល់កម្រិតកំពូលក្នុងឆ្នាំ ២០២០ ឈានដល់ ២៣.៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ទុនបម្រុងសារពើពន្ធត្រូវបានប្រើប្រាស់ជាបណ្តុំលំហរសារពើពន្ធ។ ជំងឺកូវីដ-១៩ បានធ្វើឱ្យដំណើរការនៃប្រាក់ចំណូលរបស់កម្ពុជាធ្លាក់ចុះ ដែលឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះនៃប្រាក់ចំណូលសារពើពន្ធរបស់កម្ពុជាសម្រាប់មាត្រដ្ឋានផលិតផលក្នុងស្រុកសរុបពី ១៨,០% ក្នុងឆ្នាំ ២០១៩ មកត្រឹម ១៦,០% ក្នុងឆ្នាំ ២០២១ ដោយធ្លាក់ចុះជិតដល់មេដ្យាននៃបណ្តាប្រទេសក្នុងតំបន់ដែលត្រូវបានជ្រើសរើសមកប្រៀបធៀបប្រហែល ១២,១%។

១៩៦. ខណៈពេលដែលកម្ពុជា បាននឹងកំពុងពឹងផ្អែកលើភាគលាភនៃផ្នែកសារពើពន្ធក្នុងការជំរុញការវិនិយោគការកសាងភាពធន់នៃហិរញ្ញវត្ថុសាធារណៈឡើងវិញ គឺមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជាក្នុងរយៈកាលក្រោយកូវីដ-១៩។ ការវិភាគបឋមលើការចំណាយសារពើពន្ធ បង្ហាញថាការបន្ធូរបន្ថយពន្ធដែលបានផ្តល់ឱ្យក្រោមរបបលើកទឹកចិត្តការវិនិយោគរបស់ប្រទេសកម្ពុជាគឺមានភាពសប្បុរសណាស់។ ទិន្នន័យដែលមាននាពេលបច្ចុប្បន្នបង្ហាញថាប្រទេសកម្ពុជាបាត់បង់ប្រាក់ចំណូលជិតមួយភាគបីនៃប្រាក់ចំណូលសក្តានុពលរបស់ខ្លួនពីការនាំចូល។ នៅឆ្នាំ ២០២១ កម្ពុជាបានដាក់ចេញនូវច្បាប់ថ្មីស្តីពីការវិនិយោគ ដែលមានលក្ខណៈទូលំទូលាយជាងច្បាប់មុន។ អាស្រ័យហេតុនេះហាក់បីដូចជាសមហេតុផលក្នុងការរំពឹងថា ប្រទេសកម្ពុជានឹងអាចរកចំណូលបានកាន់តែច្រើននៅក្នុងឆ្នាំខាងមុខ។ មានអំណះអំណាងគួរឱ្យកត់សម្គាល់មួយចំនួន ដែលមានគោលដៅដើម្បីជំរុញវិស័យជាក់លាក់ខ្លះ ដែលទោះយ៉ាងណាក៏ដោយ បណ្តុំនៃវិធានការបច្ចុប្បន្នហាក់ដូចជាខ្វះភាពជាក់លាក់ដែលត្រូវការ ដើម្បីធានាបាននូវការប្រើ-ប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពបំផុត។

១៩៧. កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីបង្កើតទំហំសារពើពន្ធ ខណៈដែលផលប៉ះពាល់អវិជ្ជមាននៃជំងឺរាតត្បាតកូវីដ-១៩ បានធូរស្រាល ខណៈដែលសេដ្ឋកិច្ចបានចាប់ផ្តើមងើបឡើងវិញ។ ការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូលថ្មីសម្រាប់ឆ្នាំ ២០២៤-២៨ បានកំពុងដំណើរការ។ នៅក្រោមសកម្មភាពកែទម្រង់ប្រព័ន្ធសារពើពន្ធ ការវាយតម្លៃលើការគ្រប់គ្រងពន្ធគយ និងសារពើពន្ធ (DIAMOND និង TADAT) ត្រូវបានធ្វើឡើង ខណៈពេលដែលការណែនាំអំពីសក្តានុពលនៃពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល កំណែទម្រង់ពន្ធគយ និងការវិភាគការចំណាយសារពើពន្ធកំពុងត្រូវបានពិភាក្សា។ MTFF និង MTBF កំពុងត្រូវបានរៀបចំ ដើម្បីធានាបាននូវការគ្រប់គ្រងហិរញ្ញវត្ថុ និងគោល-នយោបាយសារពើពន្ធបានល្អ។

**អនុសាសន៍គោលនយោបាយ**

១៩៨. ខណៈពេលដែលបរិមាណនៃចំណាយកើនឡើង ជាមួយនឹងការកែលម្អទំហំនៃលំហសារពើពន្ធ, គុណភាពនៃចំណាយ - តម្លៃនៃលុយ - នៅតែជាបញ្ហាប្រឈមដ៏គួរឱ្យកត់សម្គាល់។ ការសិក្សាបច្ចុប្បន្នបានបង្ហាញថា មានទំនាក់ទំនងខ្សោយរវាងការកើនឡើងនៃចំណាយ និងការកែលម្អលទ្ធផលនៃការអភិវឌ្ឍន៍ដែលវាស់វែងដោយសូចនាករផ្នែកអប់រំ និងសុខាភិបាល។ ដើម្បីសម្រេចបាននូវភាគលាភនៃការអភិវឌ្ឍន៍នៃការវិនិយោគបន្ថែម កម្ពុជាចាំបាច់ត្រូវផ្តោតលើគុណភាពនៃការចំណាយ។ លើសពីនេះ លទ្ធផលនៃការវាយតម្លៃក៏នឹងត្រូវបានប្រើដើម្បីផ្តល់ដំណឹងដល់

របៀបវារៈកែទម្រង់ PFM នៅពេលដែលរដ្ឋាភិបាលរៀបចំដើម្បីឆ្លោះទៅរកដំណាក់កាលទីបួននៃ PFMRP (គណនេយ្យភាពសមិទ្ធកម្ម)។ វាមានសារៈសំខាន់ណាស់ក្នុងការផ្ដោតលើការកែលម្អគណនេយ្យភាពសមិទ្ធកម្ម និងសមត្ថភាពស្ថាប័ន។ ខឿនទី ៤/ដំណាក់កាលទី ៤ នៃ PFMRP ដែលផ្ដោតលើការសម្រេចបាននូវគណនេយ្យភាពសមិទ្ធកម្ម គឺជាជំហានដ៏សំខាន់មួយក្នុងទិសដៅដ៏ត្រឹមត្រូវ។

១៩៩. ការសិក្សាបានបង្ហាញកាន់តែច្បាស់ថា ការកែលម្អលើប្រាក់ឈ្នួលក្នុងវិស័យសាធារណៈតែឯងគឺមិនគ្រប់គ្រាន់នោះទេ។ អាទិភាពនៃការចំណាយបានផ្លាស់ប្ដូរទៅផ្នែកសង្គមដែលគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ក្រោមកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ធនធានមនុស្ស។ ការសិក្សាថ្មីៗនេះបានចង្អុលបង្ហាញ តម្រូវការក្នុងការបង្កើនគណនេយ្យភាព និងសមត្ថភាពនៅកម្រិតតាមវិស័យ។ ការវិភាគតាមវិស័យជាច្រើនដូចជា ផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩ លើការសិក្សា និងការរកប្រាក់ចំណូលក្នុងប្រទេសកម្ពុជា (ខែធ្នូ ឆ្នាំ ២០២១) គណនេយ្យភាពនៃគ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្សានុសិស្ស និងការវិនិយោគលើអនាគតរបស់កម្ពុជា÷ សុខភាព និងអាហារូបត្ថម្ភសម្រាប់កុមារតូចៗ (ខែឧសភា ២០១៩) បានផ្ដល់ជាភស្តុតាង ថាការកែលម្អគណនេយ្យភាព និងសមត្ថភាពគឺជាការចាំបាច់ដើម្បីសម្រេចបានលទ្ធផលតាមវិស័យ។

២០០. ការអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលថ្មីៗនេះផ្ដោតលើវិស័យមួយចំនួន ប្រហែលជាមិនគាំទ្រដល់ការគាំពារសម្រាប់ជនក្រីក្រ (pro-poor) នោះទេ។ សន្តិសុខសង្គម និងការគាំទ្រសង្គមនាពេលថ្មីៗនេះត្រូវបានទទួលបានការយកចិត្តទុកដាក់កាន់តែខ្លាំង។ ការជំរុញការបង្កើតការងារអាចជាយុទ្ធសាស្ត្រគាំពារសង្គមដ៏មានប្រសិទ្ធភាពបំផុត (កម្មវិធីបង្វែរសាច់ប្រាក់) ដើម្បីទប់ស្កាត់ភាពក្រីក្រ។ ការសិក្សាថ្មីស្ដីពី "ការជះឥទ្ធិពលដល់សេដ្ឋកិច្ចសង្គមនៃកម្មវិធីបង្វែរសាច់ប្រាក់ដើម្បីឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ នៅកម្ពុជា" បានរកឃើញបច្ច័យវិជ្ជមានសំខាន់ៗនៃកម្មវិធីបង្វែរសាច់ប្រាក់នេះដល់ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងសូចនាករសេដ្ឋកិច្ចសង្គម រួមមានសន្តិសុខស្បៀង, អាហារូបត្ថម្ភ, ការអប់រំរបស់កុមារ, ការសន្សំប្រាក់, ការសងបំណុល, ផលិតភាព, ការថែទាំសុខភាព, ការផ្ដល់សិទ្ធិអំណាចយេនឌ័រ, និងការយល់ឃើញរបស់រដ្ឋាភិបាលក្នុងតំបន់ និងថ្នាក់ជាតិ។

២០១. កំណើនសេដ្ឋកិច្ចទំនងជាពឹងផ្អែកលើការនាំចេញ និងកសិកម្ម។ ការដោះស្រាយនៃការលុបបំបាត់ការប្រកួតប្រជែងខាងក្រៅគឺជាកត្តាចាំបាច់។ ដូច្នេះ ការពិចារណាលើគោលនយោបាយសំខាន់មួយគឺការទាញយកអត្ថប្រយោជន៍ពីលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) ខ្លាំង។ ទំនាក់ទំនងទៅវិញទៅមករវាងវិស័យ FDI និងវិស័យសហគ្រាសធុនតូច និងមធ្យមក្នុងស្រុកគួរត្រូវទទួលបានការជំរុញខ្លាំង ដោយទាញយកអត្ថប្រយោជន៍ពី FTA ទ្វេភាគី និងពហុភាគី ដើម្បីជំរុញការបង្កើតការងារ និងកំណើនសេដ្ឋកិច្ច។

២០២. ពាក់ព័ន្ធលើការទទួលបានឯករាជ្យភាពគោលនយោបាយរូបិយវត្ថុឡើងវិញ។ ការចេញមូលប័ត្រប្រាក់រៀល របស់រដ្ឋាភិបាលគឺជាជំហានមួយក្នុងទិសដៅដ៏ត្រឹមត្រូវ។ តួនាទីនៃវិស័យហិរញ្ញវត្ថុបានកើនឡើងយ៉ាងខ្លាំងក្នុង រយៈពេលជាច្រើនទសវត្សរ៍កន្លងមក ក៏ដូចជាតួនាទីនៃគោលនយោបាយរូបិយវត្ថុផងដែរ។ ការលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក, ការសន្សំលុយក្នុងស្រុក និងផលិតកម្មសម្រាប់ការនាំចេញក៏នឹងជួយដោះស្រាយឱនភាពគណនីចរន្តដ៏ច្រើនរបស់ប្រទេសកម្ពុជាផងដែរ។

២០៣. ការរកឃើញពីការវិភាគលើការចំណាយសារពើពន្ធបង្ហាញថា ច្បាប់ថ្មីស្តីពីការវិនិយោគនឹងប៉ះពាល់ដល់ការប្រមូលចំណូល ដោយសារកម្ពុជាត្រូវបានរំពឹងថានឹងកាត់បន្ថយចំណូលសារពើពន្ធបន្ថែមទៀតនៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ អំណះអំណាងគួរឱ្យកត់សម្គាល់មួយចំនួនសម្រាប់ដំណោះស្រាយមានគោលដៅត្រឹមត្រូវដើម្បីជំរុញវិស័យជាក់លាក់មួយចំនួន។ ទោះបីជាយ៉ាងណាក៏ដោយ បណ្តុំនៃវិធានការបច្ចុប្បន្នហាក់ដូចជាខ្វះភាពជាក់លាក់ដែលត្រូវការ ដើម្បីធានាបាននូវការប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពបំផុត។ ម៉ាទ្រីសសង្ខេបខាងក្រោមបង្ហាញពីអនុសាសន៍សំខាន់ៗ ដើម្បីធ្វើការបែងចែកការចំណាយសារពើពន្ធនៅកម្ពុជា។

| សេចក្តីសង្ខេបរួមនៃអនុសាសន៍គោលនយោបាយសម្រាប់បែងចែកចំណាយសារពើពន្ធរបស់កម្ពុជា | |
|---|---|
| **អាទិភាពរយៈពេលខ្លី** | - កសាងសមត្ថភាពសម្រាប់គំរូនៃចំណាយសារពើពន្ធ<br>- រៀបចំរបាយការណ៍ចំណាយសារពើពន្ធ<br>- បង្កើតមូលដ្ឋានទិន្នន័យអ្នកជាប់ពន្ធពេញលេញសម្រាប់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (GDCE) និងអគ្គនាយកដ្ឋានពន្ធដារ (GDT)<br>- បង្កើតសិទ្ធិសម្រាប់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) និង តំបន់សេដ្ឋកិច្ចស្វយ័តពិសេស (SEZ) ដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌលទ្ធផល ដែលស្ថិតនៅក្រោមការផ្ទៀងផ្ទាត់ និងការធ្វើសវនកម្មត្រឹមត្រូវ។<br>- GDT និង GDCE គួរទទួលខុសត្រូវចំពោះការធ្វើសវនកម្ម បើទោះបីជាទំនួលខុសត្រូវសម្រាប់ការគ្រប់គ្រង និងការលុបចោលនៃស្ថានភាព QIP ជាមួយ CDC ក៏ដោយ។<br>- ទប់ស្កាត់ការរំលោភបំពានដោយមិនអនុញ្ញាតឱ្យមានការពន្លឿនការរំលោះ (depreciate) លើការទិញទ្រព្យសកម្មដែលបានប្រើរួច<br>- ដោយពិចារណាលើការដាក់កម្រិតលើបរិមាណនៃការលើកទឹកចិត្តសារពើពន្ធសម្រាប់ QIP នីមួយៗ - ប្រទេសថៃមានការកំណត់ "មិនលើសពី 100% នៃតម្លៃនៃការវិនិយោគ (មិនរាប់បញ្ចូលថ្លៃដី និងមូលធនសម្រាប់ប្រើប្រាស់ (working capital))" នៅក្នុងកំឡុងពេលមិនអនុវត្តការប្រមូលពន្ធ (tax holidays)<br>- ការកាត់ចេញ ១៥០% ត្រូវការនិយមន័យច្បាស់លាស់នៃកម្រិតវិសាលភាពនៃសកម្មភាពដូចជា R&D, នវានុវត្តន៍ និងសុខុមាលភាពបុគ្គលិក ដើម្បីការពារការរំលោភបំពាន<br>- បន្ថែមច្បាប់សម្រាប់ដោះស្រាយប្រតិបត្តិការទាំងឡាយដែលងាយរងគ្រោះដល់ការប្រមូលពន្ធ (antifragmentation rules) និងជៀសវាងការអូសបន្លាយពេលយូរ ដើម្បីកាត់បន្ថយឱកាសសម្រាប់អាជីវកម្មធំៗ សម្រាប់បន្តការបង្កើតបណ្តាញនៃក្រុមហ៊ុនតូចៗ<br>- ពិចារណាឡើងវិញអំពីការបន្ថែមការលើកទឹកចិត្តពន្ធដល់ការពង្រីកសកម្មភាពវិនិយោគ និងការរួម-បញ្ចូលគ្នានូវ QIPs ដើម្បីបន្តការបន្តការចំណាយពន្ធ។ |
| **អាទិភាពរយៈពេលមធ្យម** | - ពិនិត្យមើលឡើងវិញនូវការកំណត់គោលដៅនៃការលើកទឹកចិត្តពន្ធ (ឧ.វិស័យដែលផ្តោតលើការនាំចេញ)<br>- ការលើកលែងពន្ធលើតម្លៃបន្ថែមអាចត្រូវដកចេញបន្ទាប់ពីឥណទានធាតុចូល (input credit) VAT ត្រូវបានកែសម្រួល<br>- បញ្ឈប់ការលើកទឹកចិត្តពន្ធដោយផ្អែកលើប្រាក់ចំណេញ (ជម្រើសទី ១) តាមរយៈ sun-setting<br>- ការវិភាគថ្លៃអត្ថប្រយោជន៍យ៉ាងហ្មត់ចត់សម្រាប់ការចំណាយសារើពន្ធ ២-៣ ក្នុងមួយឆ្នាំ |

| | |
|---|---|
| | - ការប្តេជ្ញាក្នុងការផ្សព្វផ្សាយចំណាយសារពើពន្ធប្រចាំឆ្នាំ<br>- GDT និង GDCE គួរតែធ្វើការវាយតម្លៃសវនកម្មផ្អែកលើហានិភ័យ<br>- កំណត់គម្លាតទិន្នន័យ និងចំណុចខ្សោយ |

### ❖ វិស័យធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹក

២០៤. PER នេះ វាយតម្លៃលើប្រសិទ្ធភាពនៃការវិភាជ និងប្រតិបត្តិការនៃថវិការបស់ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM)។ វិស័យនេះសមនឹងទទួលបានការយកចិត្តទុកដាក់ជាគោលនយោបាយ ដោយសារជាវិស័យមានសារៈសំខាន់ក្នុងការអភិវឌ្ឍវិស័យកសិកម្ម (ពិសេសដំណាំ) ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងការស្តារសេដ្ឋកិច្ចឡើងវិញរបស់ប្រទេស។ ទោះបីជាមានចែងក្នុងកម្មវិធីគ្រប់គ្រងធនធានទឹក និងធារាសាស្ត្រប្រកបដោយនិរន្តរភាព និងផែនទីបង្ហាញផ្លូវឆ្នាំ ២០១៩-២០២៣យ៉ាងនេះក្តី ការកែទម្រង់វិស័យនេះតម្រូវឱ្យមានចក្ខុវិស័យ និងឆន្ទៈរយៈពេលវែង ដែលជាផ្នែកសំខាន់មួយគឺការរៀបចំថវិកា និងការគ្រប់គ្រងវិនិយោគសាធារណៈ ដែលភ្ជាប់ទៅនឹងរបៀបវារៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

២០៥. ការចំណាយរបស់ MoWRAM គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ សម្រាប់ការវិនិយោគ។ ដូចគ្នានឹងហិរញ្ញប្បទានក្នុងស្រុកដែរ និន្នាការកើនឡើងពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៩ ត្រូវបានទទួលរងឧបសគ្គហិរញ្ញវត្ថុសាធារណៈដែលបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ ក្នុងកំឡុងឆ្នាំ ២០២០ និង ២០២១។ ក្រសួងមានកម្មវិធីចំនួន៥។ កម្មវិធីទី ១÷ ការស្តារប្រព័ន្ធធារាសាស្ត្រ និងជួសជុលនិងថែទាំ បានទទួលចំណែកថវិកាខ្ពស់បំផុត(ប្រហែល ៧៥% ប្រចាំឆ្នាំ) បន្ទាប់មកគឺកម្មវិធីទី ៥÷រដ្ឋបាលទូទៅ។ បើគិតតាមមុខងារ វិស័យកសិកម្មទទួលបានចំណែកធំបំផុត (ជាង ៩០%)។ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច ថវិកា ស្ថិតក្នុង ជំពូកទី ២១ (ថវិកាមូលធន), ជំពូកទី ៦១ (ជួសជុល និងថែទាំ) និងជំពូកទី ៦៤ (បុគ្គលិក)។ ថវិកាសម្រាប់ជួសជុល និងថែទាំ (O&M) ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺតែជាបញ្ហាសម្រាប់អនុវត្តឱ្យមាននិរន្តរភាព។

២០៦. ការអនុវត្តថវិកាមានភាពរលូនតាមសមាសធាតុថវិកា (budget line item) លើកលែងតែ ជំពូកទី ២១ (ថវិកាមូលធន) ដែលការអនុវត្តលើសកម្រិតបានក្លាយជាបទដ្ឋាន (លើកលែងឆ្នាំ ២០១៩)។ ការគ្រប់គ្រងការវិនិយោគសាធារណៈគឺចាំបាច់ និងកែលម្អបន្ថែម។ នេះរួមបញ្ចូលទាំងដំណាក់កាលផ្សេងៗនៃវដ្តនៃការគ្រប់គ្រងការវិនិយោគសាធារណៈចាប់តាំងពីដំណាក់កាលវាយតម្លៃគម្រោងជាមុន (project pre-appraisal), ការធ្វើនិយ័តកម្មថវិកា (ការគណនាថ្លៃដើមរយៈពេលមធ្យម និងមូលធន និងសមាហរណកម្ម ថវិកា O&M), ការអនុវត្តថវិកា (ការយោងឥណទានថវិកា និងលទ្ធកម្ម) និងការពិនិត្យមើល គម្រោងតាមក្រោយ (ការវាយតម្លៃបញ្ច័យ និងការចុះបញ្ជីទ្រព្យ-សម្បត្តិ)។

២០៧. លក្ខណៈពិសេសមួយដែលអាចមើលឃើញអំពីថវិកា MoWRAM គឺវិសហមជ្ឈការ និងវិមជ្ឈការនៅមានកម្រិត។ សរុបមក ថ្នាក់កណ្តាលត្រូវបានវិភាជ ប្រហែល ៩០% នៃថវិកា MoWRAM សរុប។ ថ្នាក់កណ្តាលប្រើប្រាស់ចំណែកដ៏ធំនៃចំណាយចរន្តផងដែរ÷ លើសពី ៥០% នៃបន្ទុកបុគ្គលិក និង ៨០% នៃមិនមែនបន្ទុកបុគ្គលិក។ ការចាត់ថ្នាក់ថវិកាបែបនេះបង្ហាញឱ្យមានការត្រួតពិនិត្យស៊ីជម្រៅបន្ថែមទៀត ជាពិសេសលើធនធានមន្ត្រី និង O&M។ MoWRAM ជាស្ថាប័ន ដែលមានកម្រិតនៅក្នុងការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអនុញ្ញាតឱ្យរដ្ឋបាល

ថ្នាក់ក្រោមជាតិមានតួនាទីកាន់តែច្រើនក្នុងប្រព័ន្ធធារាសាស្ត្រ O&M អាចមានប្រយោជន៍ ក្នុងការផ្តល់សេវាផ្គត់ផ្គង់ធនធានទឹកសម្រាប់ផលិតកម្មកសិកម្ម។

២០៨. ជាមួយគ្នានេះ ទាក់ទងនឹងសមធម៌ ការសិក្សានេះរកឃើញថា ការវិភាជថវិកាប្រព័ន្ធធារាសាស្ត្រនាពេលថ្មីៗនេះដល់ថ្នាក់រដ្ឋបាលខេត្តហាក់ដូចជាមានកម្រិតសមធម៌គួរសម។ ទិន្នន័យបង្ហាញថា ខេត្តដែលមានកម្រិតក្រីក្រកាន់តែខ្ពស់ គឺថវិកាត្រូវបានវិភាជឱ្យកាន់តែខ្ពស់។

២០៩. ទាក់ទងនឹងការផ្តល់សេវាក្នុងតំបន់ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃធនធានសាធារណៈគឺគ្រាន់តែជាផ្នែកមួយនៃភាពប្រទាក់ក្រឡានេះ (puzzle) ប៉ុណ្ណោះ។ ទំហំនៃតម្រូវការ និងទីផ្សារដែលជំរុញដោយធម្មជាតិនៃវិស័យធារាសាស្ត្រ (និងកសិកម្ម) តម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតចំពោះការរួមចំណែករបស់វិស័យឯកជន និងការគិតគូរឡើងវិញអំពីតួនាទីរបស់គណៈកម្មាធិការកសិករប្រើប្រាស់ទឹក (FWUCs)។ ក្នុងការពិភាក្សានាពេលបច្ចុប្បន្នលើសំណួរទាំងនេះ ការសិក្សាបានរកឃើញថា នៅតែមានភាពច្របូកច្របល់ជាមួយនឹងកង្វះទិន្នន័យ និងការសន្មត់ដែលមិនមានការធ្វើតេស្តសាកល្បង។ ទោះជាយ៉ាងណាក៏ដោយ សក្តានុពលជាច្រើន និងមេរៀន និងបទពិសោធន៍ថ្មីនៅនឹងកន្លែងផ្ទាល់ ។ លើសពីនេះ គម្រោងភាពជាដៃគូរដ្ឋ និងឯកជន(PPP) នាពេលខាងមុខនៅក្នុង O&M ប្រព័ន្ធធារាសាស្ត្រអាចផ្តល់នូវគំនិតថ្មីៗ និងកែតម្រូវផ្នត់គំនិតអំពីរបៀបនាំយកមកជាមួយនូវវិស័យឯកជន។

២១០. ការវាយតម្លៃចំណាយសាធារណៈលើប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹក បានផ្តល់អនុសាសន៍ណែនាំសកម្មភាពកែទម្រង់ជាក់លាក់ និងចំណុចសម្រាប់ការផ្ទៀងផ្ទាត់ និងសិក្សាស្វែងយល់បន្ថែមដូចខាងក្រោម÷

| | | |
|---|---|---|
| **ប្រសិទ្ធភាពវិភាជន៍** | | |
| ប្រភពហិរញ្ញប្បទាន | 1- | ប្រមូល និងវិភាគទិន្នន័យបានល្អប្រសើរជាងមុនលើប្រភពហិរញ្ញប្បទានផ្សេងៗ រួមទាំងពីវិស័យឯកជនផងដែរ។ |
| សហថាមពលជាមួយវិស័យកសិកម្ម | 2- | វាយតម្លៃស៊ីជម្រៅលើការរួមផ្សំគ្នា (ឬកង្វះខាត) រវាងថវិកា MoWRAM និង MAFF (និងការផ្តល់សេវា) ដែលរួមបញ្ចូលទាំងនៅថ្នាក់មូលដ្ឋាន។ |
| វិភាជថវិកាសម្រាប់បន្ទុកបុគ្គលិក | 3- | ធ្វើការវិភាគស៊ីជម្រៅលើតម្រូវការបន្ទុកបុគ្គលិក ការពង្រាយ និងការបែង-ចែកបន្ទុកបុគ្គលិក (ពិសេស រវាងថ្នាក់កណ្តាល និងថ្នាក់ខេត្ត)។ |
| ការបែងចែកថវិកាថ្នាក់កណ្តាលធៀបនឹង មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត (PDWRAM) | 4- | ធ្វើការវិភាគស៊ីជម្រៅលើអំណះអំណាង (ឬកង្វះ) សម្រាប់ការបែងចែកថវិកាបច្ចុប្បន្នរវាងកម្រិតថ្នាក់កណ្តាល និងមន្ទីរ សម្រាប់កម្មវិធី និងអនុ-កម្មវិធី ដែលត្រូវបានជ្រើសរើស (ពិសេស O&M ប្រព័ន្ធធារាសាស្ត្រ, ការគាំទ្រដល់ FWUC និងការឆ្លើយតបបន្ទាន់) |
| ការបែងចែកថវិកាសម្រាប់មុខងារគ្រប់គ្រងធនធានទឹក | 5- | ផ្តួចផ្តើមការពិភាក្សាអំពីគោលនយោបាយអំពីអត្ថន័យនៃមុខងារ "ការគ្រប់គ្រងធនធានទឹក" របស់ MoWRAM ពីទស្សនៈថវិកា (ដោយសារបច្ចុប្បន្នមានចំណែកតិចតួចខ្លាំង)។ |
| **ប្រសិទ្ធភាពប្រតិបត្តិការ** | | |

| | |
|---|---|
| ការតម្រឹមរចនាសម្ព័ន្ធកម្មវិធីរវាងក្រសួង MoWRAM ថ្នាក់កណ្តាល និង មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត PDRAM | 6- ពិចារណាលើទំនាក់ទំនងច្បាស់លាស់រវាង SP1.1 និង SP1.7 ដើម្បីរាប់បញ្ចូលទាំងចំណែកថវិការបស់ថ្នាក់កណ្តាល និងមន្ទីរ សម្រាប់ប្រព័ន្ធធារាសាស្រ្ត O&M<br>7- ពិចារណាលើទំនាក់ទំនងច្បាស់លាស់រវាង SP2.1 និង SP2.3 ដើម្បីរាប់បញ្ចូលទាំងចំណែកថវិការបស់ ថ្នាក់កណ្តាល និង មន្ទីរធនធានទឹកនិងឧតុនិយម សម្រាប់ការឆ្លើយតបគ្រោះរាំងស្ងួត និងទឹកជំនន់។ |
| ការកែលម្អការគ្រប់គ្រងថវិកាវិនិយោគ និង PIM | 8- ដំណាក់កាលវាយតម្លៃគម្រោងជាមុន÷ ១) ធានាថាជម្រើសជាច្រើនត្រូវបានពិចារណា, ២) ពិនិត្យមើលបញ្ហានិរន្តរភាព, និង៣) ផ្តោតសំខាន់លើសក្កា-នុពលសម្រាប់វិស័យឯកជន និងការសម្របភាពជាដៃគូរវាងរដ្ឋ និងឯកជន។<br>9- ដំណាក់កាល ថវិកានីយកម្ម÷ ១) កែលម្អគុណភាពនៃការប៉ាន់ស្មានរយៈពេលមធ្យមនៃថវិកាមូលធន និង ២) សមាហរណកម្មO&M (ចរន្ត) និងថវិកាមូលធន<br>10- ដំណាក់កាលអនុវត្តថវិកា÷ ១) រួមមានការអនុវត្តថវិកាមូលធនក្នុងមុខងារ PO របស់ FMIS, ២) បង្កើនភាគរយនៃការដេញថ្លៃដោយបើកចំហ/កិច្ចសន្យាខាងក្រៅ ជាជាង លទ្ធកម្មដាច់ដោយឡែក (ផ្ទៃក្នុង)និង ៣) ប្រើប្រាស់មុខងារលទ្ធកម្មពេញលេញនៅក្នុង FMIS។<br>11- ដំណាក់កាលវាយតម្លៃគម្រោង÷ ត្រូវមានព័ត៌មានអំពីផលប៉ះពាល់នៃចំណាយ (ជាពិសេសលើការស្តារប្រព័ន្ធធារាសាស្រ្ត (ជំពូកទី ២១) ប្រព័ន្ធធារាសាស្រ្ត O&M (ជំពូកទី៦១) និងការគាំទ្រដល់ FWUC)។<br>12- ការចុះបញ្ជី និងការគ្រប់គ្រងទ្រព្យសកម្ម÷ បញ្ជាក់អំពីវិធានការ និងវិធីសាស្រ្តក្នុងការចុះបញ្ជីហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងប្រព័ន្ធធារាសាស្រ្តជាទ្រព្យ-សម្បត្តិរដ្ឋ។ |
| **ការផ្តល់សេវាក្នុងតំបន់** | |
| ការផ្ទេរមុខងារ និងថវិកាទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ) | 13- ពិនិត្យឡើងវិញលើមុខងារដែលបានផ្ទេរថ្មីៗទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាពិសេសលើទិដ្ឋភាពចំណាយ និងបញ្ហាបុគ្គលិក។<br>14- ធ្វើប្រតិបត្តិការផ្ទេរមុខងារអនុលោមតាមអនុក្រឹត្យឆ្នាំ ២០១៩។ |
| ប្រសិទ្ធភាពនៃការគាំទ្រ FWUC | 15- វាយតម្លៃប្រសិទ្ធភាព FWUC កំណត់បញ្ហាជាប្រព័ន្ធ និងស្នើវិធីសាស្រ្តកែលម្អ/កែតម្រូវគំរូបច្ចុប្បន្ន។<br>16- បញ្ជាក់ទំនាក់ទំនងរវាង FWUC ជាមួយ MoWRAM និង SNAs (ទាក់ទងនឹងការផ្ទេរមុខងារថ្មីៗ)។ |

| | |
|---|---|
| ការចូលរួមនៃវិស័យឯកជន | 17- ធ្វើការត្រួតពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយអំពីស្ថានភាព, ឱកាស, ឧបសគ្គ និងការឆ្លើយតបគោលនយោបាយដែលមានស្រាប់ អំពីរបៀបចូលរួម និង ទាក់ទាញការវិនិយោគពីវិស័យឯកជនឱ្យកាន់តែប្រសើរឡើង ជាពិសេសលើ O&M ប្រព័ន្ធធារាសាស្ត្រ។<br>18- ពិចារណាអំពីតួនាទីសក្តានុពលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង មន្ទីរ ធនធានទឹកនិងឧតុនិយម រាជធានី ខេត្ត ក្នុងការធ្វើការជាមួយ វិស័យឯកជន (ដោយមានការ-ផ្ទេរមុខងារថ្មីៗ) |
| ការដាក់ដំណើរការ និងការ-ពង្រីកវិសាលភាពនៃគំរូនៃភាពជាដៃគូរវាងរដ្ឋនិងឯកជននៅក្នុងវិស័យធារាសាស្ត្រ | 19- ពង្រីកគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) ក្នុងវិស័យធារាសាស្ត្រ និងទាញមេរៀនគោលនយោបាយ/និយតកម្មជាក់ស្តែងសម្រាប់ការពង្រីកបន្ថែម។<br>20- ពិចារណាអំពីតួនាទីសក្តានុពលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង មន្ទីរ ធនធានទឹកនិងឧតុនិយម រាជធានី ខេត្ត ក្នុងការធ្វើការជាមួយវិស័យឯកជន (ទាក់ទងនឹងការផ្ទេរមុខងារថ្មីៗ) |

### សុខាភិបាល

#### ហិរញ្ញប្បទានសុខាភិបាល

២១១. កម្ពុជាចំណាយលើការថែទាំសុខភាពច្រើនជាងប្រទេសជិតខាង (ដូចមានបង្ហាញក្នុងដ្យាក្រាមទី៩ ខាងក្រោម) បើទោះបីជាការចំណាយរបស់រដ្ឋាភិបាលមានកម្រិតទាបក៏ដោយ។ ទោះបីជាមានការពង្រីកសេវាថែទាំសុខភាពសាធារណៈនៅទស្សវត្សចុងក្រោយក៏ដោយ ការប្រើប្រាស់សេវានៅមានកម្រិតនៅឡើយ។ ជម្រើសដំបូងក្នុងការប្រើ-ប្រាស់សេវារបស់ប្រជាជន ភាគច្រើនទៅកាន់មូលដ្ឋានសុខាភិបាលឯកជន ក្នុងនោះរួមទាំងឱសថស្ថានផង ដែលមិនមែនជាកន្លែងផ្តល់សេវាថែទាំសុខភាព (របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០២១)។

#### ចំណាយ និងហិរញ្ញប្បទានរបស់ក្រសួងសុខាភិបាល សម្រាប់ការឆ្លើយតបនឹងជំងឺកូវីដ-១៩

២១២. ចំណាយមូលធនពឹងផ្អែកលើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។ ការកើនឡើងនៃថ្លៃចំណាយបច្ចុប្បន្ន (nominal spending) របស់ក្រសួងសុខាភិបាលគឺភាគច្រើនដោយសារបន្ទុកបុគ្គលិក (ជំពូក៦៤) និងអត្ថប្រយោជន៍សង្គម (ជំពូក៦២)។ ចំណាយអត្ថប្រយោជន៍សង្គម (ជំពូក៦២) មានដូចជា ការចំណាយលើអ្នកជំងឺ និងការធ្វើដំណើរនៅមណ្ឌលសុខភាព ការទិញថ្នាំ និងការផ្គត់ផ្គង់ផ្សេងៗសម្រាប់ផ្នែកវេជ្ជសាស្ត្រ។ ថវិការបស់ក្រសួងសុខាភិបាល ភាគច្រើនគឺចំណាយផ្នែកមិនមែនបន្ទុកបុគ្គលិក ដែលនៅឆ្នាំ២០២២ ថវិកាសម្រាប់បន្ទុកបុគ្គលិក មានទំហំស្មើនឹងមួយភាគបី (ឬ ២៩,៩០%) ប៉ុណ្ណោះ នៃថវិកាសរុប។

ដ្យាក្រាមទី 9 ÷ ចំណាយលើវិស័យសុខាភិបាល (ធៀបនឹង ផសស.)




ប្រភព÷ World Development Indicator, 2022

ដ្យាក្រាមទី 10 ÷ ចំណាយរបស់ក្រសួងសុខាភិបាល (ថ្លៃបច្ចុប្បន្ន) តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ឯកតា÷លានរៀល)




ប្រភព÷ កសហវ.

កំណត់សម្គាល់÷ ចំណាយរបស់ក្រសួងសុខាភិបាល មិនបូកបញ្ចូលចំណាយលើការប្រយុទ្ធប្រឆាំងទៅនឹងកូវីដ-១៩ នោះទេ។

ដ្យាក្រាមទី 11÷ ចំណាយបន្ទុកបុគ្គលិករបស់ក្រសួងសុខាភិបាល (២០១៧-២០២១) និងបៀវត្សបុគ្គលិកសុខាភិបាល




ប្រភព÷ កសហវ.

២១៣. ចំពោះការអនុវត្តតាមចំណាត់ថ្នាក់កម្មវិធី, ក្រសួងសុខាភិបាលបានដាក់ចេញកម្មវិធីចំនួន៤ ក្នុងនោះរួមមាន÷

- កម្មវិធីទី១÷ សុខភាពបន្តពូជ, យុវជន, មាតា, ទារក និងកុមារ និងអាហារូបត្ថម្ភ
- កម្មវិធីទី២÷ ការគ្រប់គ្រងជំងឺឆ្លង
- កម្មវិធីទី៣÷ ការគ្រប់គ្រងជំងឺដែលមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត
- កម្មវិធីទី៤÷ ពង្រឹងប្រព័ន្ធសុខាភិបាល។

២១៤. កម្មវិធីទី៤“ពង្រឹងប្រព័ន្ធសុខាភិបាល” មានទំហំថវិកាធំជាងគេនៃថវិកាចរន្ត។ ចំណែកឯ ថវិកាសម្រាប់ថ្នាក់ក្រោមជាតិ មានត្រឹមមួយភាគបីនៃថវិការបស់ក្រសួងប៉ុណ្ណោះ។

ដ្យាក្រាមទី 12÷ ថវិកាផ្អែកលើកម្មវិធី (%នៃចំណាយចរន្តសរុប)




ប្រភព÷ កសហវ.

ដ្យាក្រាមទី 13÷ ថវិកាផ្អែកលើកម្មវិធី ឆ្នាំ២០១៧-២០២២




ប្រភព÷ កសហវ.

**អនុសាសន៍**

- កែលម្អការសមាហរណកម្មទិន្នន័យនៃការចំណាយថ្នាក់ខេត្ត[4]
- ពង្រឹងការធ្វើសមាហរណកម្ម ចំណាយមូលធនដោយដៃគូអភិវឌ្ឍន៍
  - ពិចារណាលើការកែសម្រួលក្របខ័ណ្ឌពេលវេលានៃដំណើរការពិនិត្យ និងជ្រើសរើសគម្រោង ដើម្បីជាព័ត៌មានអំពីមុខងាររៀបចំផែនការ និងការអភិវឌ្ឍន៍ BSP របស់ MOH។ នេះអាចពាក់ព័ន្ធនឹងការផ្លាស់ប្តូរផែនការថវិកាមូលធនទៅថ្ងៃមុខ និងការកំណត់ជាមុននៃការចង្អុលបង្ហាញការបែងចែកថវិកាមូលធនកម្រិតក្រសួងថ្នាក់កណ្តាល។
- ពង្រឹងក្របខ័ណ្ឌសមិទ្ធកម្ម (អាចដោះស្រាយតាមរយៈក្របខ័ណ្ឌ PIB ថ្មី)
  - លើកទឹកចិត្តលើសង្គតិភាពនៅក្នុងសូចនាករបង្កើតពី BSP មួយទៅមួយ
  - រៀបចំឡើងវិញនូវសូចនាករសមិទ្ធកម្ម ដើម្បីឆ្លុះបញ្ចាំងពីគោលដៅជាក់ស្តែង និងអាចផ្ទៀងផ្ទាត់បានបន្ថែមទៀត ដែលស្របនឹងធនធានដែលមាន
  - ណែនាំអំពីព័ត៌មានសមិទ្ធកម្មជាបណ្តើរៗទៅក្នុងសំណើថវិកានៅក្នុង BSP។ សំណើថវិកាគួរតែភ្ជាប់ដោយផ្ទាល់ទៅនឹងសូចនាករនីមួយៗ។
- ពង្រឹងការផ្សាភ្ជាប់ BSP និង PB
  - តម្រឹមរចនាសម្ព័ន្ធ PB និង BSP, ឧទាហរណ៍ ដោយរួមបញ្ចូលចំណាយបន្ទុកបុគ្គលិកក្នុងកម្មវិធីនីមួយៗក្នុងឯកសារទាំងពីរ

[4] ធនាគារពិភពលោកនឹងបន្តធ្វើការប្រមូលទិន្នន័យវិស័យសុខាភិបាលដើម្បីធ្វើការវិភាគស៊ីជម្រៅបន្ត

- ការត្រួតពិនិត្យរយៈពេលវែង និងធ្វើការផ្លាស់ប្តូរក្របខ័ណ្ឌច្បាប់ ដើម្បីពង្រឹងក្របខ័ណ្ឌថវិកាកម្មវិធីនៅក្នុងច្បាប់ រួមទាំងការអនុម័តច្បាប់ថវិកា ផ្អែកលើមូលដ្ឋានកម្មវិធី។

### ◆ វិស័យកសិកម្ម

២១៥. អត្រាភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះស្ទើរពាក់កណ្តាលចន្លោះពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៩ ដែលមានប្រជាជនកម្ពុជាជិត ២ លាននាក់បានរួចផុតពីភាពក្រីក្រ តាមរយៈការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជា ដែលកម្មករបានផ្លាស់ប្តូរពីវិស័យកសិកម្មទៅប្រកបការងារផ្សេងទៀតដែលមាន តម្លៃបន្ថែមខ្ពស់ជាង។ ការពង្រីកផលិតកម្មមិនមែនកសិកម្ម និងសេវាកម្ម បាននាំឱ្យមានការថយចុះជាលំដាប់នៃការរួមចំណែកវិស័យកសិកម្មនៅក្នុង ផ.ស.ស. ពី ៣៦% ក្នុងឆ្នាំ ២០០០ មកនៅប្រហែល ២២% នៃផលិតផលក្នុងស្រុកសរុបនាពេលបច្ចុប្បន្ន។ ទោះជាយ៉ាង-ណាក៏ដោយ វិស័យកសិកម្មនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា ហើយជាប្រភពការងារ និងប្រាក់ចំណូលដ៏សំខាន់ ជាពិសេសសម្រាប់នៅតំបន់ជនបទក្រីក្រ ដែល ៣៥% នៃកម្លាំងពលកម្មសរុបគឺស្ថិតក្នុងវិស័យកសិកម្ម។

២១៦. ខណៈពេលដែលកម្ពុជាអាចបង្កើនផលិតភាពកសិកម្មដូចបណ្តាប្រទេសជិតខាងក្នុងតំបន់ វិស័យនេះប្រឈមមុខនឹងការប្រកួតប្រជែងក្នុងទីផ្សារនាំចេញដែលនៅសេសសល់។ តម្លៃកសិផលនៅប្រទេសកម្ពុជានៅបន្តមានការប្រកួត-ប្រជែង ទោះយ៉ាងណាក៏ដោយ ថ្លៃអគ្គិសនីសម្រាប់សហគ្រាសកែច្នៃកសិផល (agro-processing), ថ្លៃឡូជីស្ទីក (logistic costs) និងថ្លៃនាំចេញ (shipping costs) ផលិតផលកសិកម្មគឺមិនមានការប្រកួតប្រជែងនោះទេ។ លើសពីនេះ វិស័យនេះប្រឈមនឹងហានិភ័យចំពោះកំណើន និងបញ្ហាប្រឈមដាច់ដោយឡែកដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងកង្វះកម្លាំងពលកម្ម ដោយសារទាំងកត្តាតម្រូវការ និងការផ្គត់ផ្គង់។ ការអនុវត្តគោល-នយោបាយកសិកម្ម និងគុណភាពចំណាយសាធារណៈ ក្នុងវិស័យនេះ គឺមានសារៈសំខាន់ក្នុងការជំរុញកំណើនផលិតភាពកសិកម្មបន្ថែមទៀត និងការលើកកម្ពស់សេដ្ឋកិច្ចជនបទឱ្យរស់រវើក។

២១៧. ការដំណោះស្រាយបញ្ហាប្រឈមក្នុងវិស័យកសិកម្មនឹងទាមទារឱ្យមានការពង្រឹងការសម្របសម្រួលរវាងក្រសួង ស្ថាប័នក្នុងវិស័យកសិកម្ម និងដៃគូអភិវឌ្ឍន៍។ វិស័យ កសិកម្មពឹងផ្អែកលើការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលមានប្រហែល ៤៣% នៃការចំណាយលើវិស័យសាធារណៈក្នុងឆ្នាំ ២០២០។ ដើម្បីធានាឱ្យបាននូវការតម្រឹមស្និតរមួតជាមួយនឹងគោលដៅរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យនេះ ការចូលរួមប្រកបដោយបុរេ-សកម្មជាងមុនជាមួយដៃគូអភិវឌ្ឍន៍ ទាំងក្នុងដំណាក់កាលជ្រើសរើសគម្រោង ការរៀបចំគម្រោង និងការអនុវត្តគម្រោងគឺជាការចាំបាច់ ខណៈដែល បន្តពឹងផ្អែកខ្ពស់ លើម្ចាស់ជំនួយ ដើម្បីគាំទ្រការវិនិយោគលើ វិស័យកសិកម្ម។

២១៨. កម្រិតនៃចំណាយសាធារណៈសម្រាប់វិស័យកសិកម្មដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ដែលជាចំណែកនៃការចំណាយសរុបរបស់រដ្ឋាភិបាលគឺទាបជាងមធ្យមភាគក្នុងតំបន់ ក្នុងទំហំប្រហែល ២% នៃថវិកាសរុបរបស់រដ្ឋាភិបាលកម្ពុជាចន្លោះឆ្នាំ ២០១៦ និង ២០២១ ធៀបនឹងមធ្យមភាគថវិកាប្រហែល ៤% នៅ ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។ លើសពីនេះ ការចំណាយថវិកា ត្រូវបានគ្របដណ្តប់កាន់តែខ្លាំងឡើងលើបន្ទុកបុគ្គលិកជាមួយនឹងសក្តានុពលក្នុងការកាត់បន្ថយទំហំលំហរហិរញ្ញវត្ថុសាធារណៈ ដែលមានសម្រាប់ការចំណាយលើការ-អភិវឌ្ឍ និងការផ្តល់ទំនិញសាធារណៈកសិកម្មសំខាន់ៗ។ ឧទាហរណ៍ ការវិនិយោគលើការស្រាវជ្រាវកសិកម្ម និង

ការគ្រប់គ្រងជំងឺឆ្លង ក៏ដូចជាការចំណាយលើសកម្មភាពលើកកម្ពស់ការធ្វើពិពិធកម្មកសិកម្ម និងផលិតភាព គឺស្ថិតក្នុងកម្រិតទាបនៅឡើយ។

២១៩. ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា (BSP) និងការសាកល្បងនៃគម្រោងថវិកាកម្មវិធី (PB) គឺជាជំហានយុទ្ធសាស្ត្រដ៏សំខាន់ ស្ថិតក្នុងដំណាក់កាលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល និងការខិតខំប្រឹងប្រែងដើម្បីកែលម្អគុណភាពនៃការចំណាយសាធារណៈ។ បទពិសោធន៍របស់ MAFF លើការងារកែទម្រង់បង្ហាញថា ជំហានទាំងនេះបានជួយពង្រឹងសមាសធាតុនៃដំណើរការរៀបចំផែនការ ប៉ុន្តែនៅមិនទាន់មានបច្ច័យ ដល់ប្រព័ន្ធគ្រប់គ្រងថវិកា និងការរៀបចំថវិកានៅឡើយ។ លំដាប់លំដោយនៃការកែទម្រង់ PB និង BSP គឺជាគន្លឹះនៃការអនុវត្តប្រកបដោយជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលឆ្ពោះទៅរកការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម (PIB)។ នេះរួមបញ្ចូលទាំង (i) ការពង្រឹងខ្លឹមសារ BSP; (ii) ការតម្រឹមឯកសារ និងដំណើរការរៀបចំ BSP ជាមួយនឹង PB និងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ និង (iii) សមាហរណកម្មBSP និងតក្ក កម្មវិធីទៅក្នុងដំណើរការចរចា, ការគ្រប់គ្រងថវិកា, ការត្រួតពិនិត្យ និងការវាយតម្លៃ និងក្របខ័ណ្ឌច្បាប់។

**សេចក្ដីសង្ខេប និងអនុសាសន៍**

| បញ្ហាប្រឈម | រយៈពេលខ្លី |
|---|---|
| ការផ្សារភ្ជាប់រវាង BSP និង PB នៅមានកម្រិត។ ការចរចាថវិកាគឺនៅមិនទាន់អនុវត្តតាមតក្ក កម្មវិធីនៅឡើយ។ | - តម្រឹមរចនាសម្ព័ន្ធ PB និង BSP ។ ឧទាហរណ៍: ការរួមបញ្ចូលការចំណាយលើបន្ទុកបុគ្គលិកសម្រាប់ការចំណាយតាមខេត្ត។<br>- ប្រើទម្រង់របាយការណ៍ដូចគ្នាសម្រាប់ចំណាយខេត្ត<br>- សមាហរណកម្ម ដំណើរការ និងការរៀបចំឯកសារ PB និង BSP<br>- រៀបចំគោលការណ៍ណែនាំដើម្បីបញ្ជាក់អំពីតួនាទី និងទំនួលខុសត្រូវរបស់មន្ទីរកសិកម្មរាជធានី ខេត្ត (PDAFFs) ក្នុងការរៀបចំ MAFF BSP។ ពង្រឹងវិធីសាស្ត្រចែករំលែកព័ត៌មានរវាង PDAFFs ទៅ MAFF នៅតាមស្ថាប័ន។ |
| | ចេញជាសេចក្ដីណែនាំដល់ MAFF (និង ក្រសួង ស្ថាប័ន ផ្សេងទៀត) ដើម្បីពន្យល់ខ្លឹមសារសម្រាប់សកម្មភាពផ្អែកលើកម្មវិធី រួមទាំងការចំណាយមូលធនដែលផ្ដល់ហិរញ្ញប្បទានដោយថវិកាជាតិ និងដៃគូអភិវឌ្ឍន៍។ |
| ការចូលរួមមានកម្រិតរបស់ក្រសួង ស្ថាប័នក្នុងការរៀបចំផែនការថវិកាមូលធន | ពិចារណាលើការកែសម្រួលក្របខ័ណ្ឌពេលវេលានៃដំណើរការពិនិត្យ និងជ្រើសរើសគម្រោងដើម្បីជូនដំណឹងអំពីមុខងារធ្វើផែនការរបស់ MAFF និងការរៀបចំ BSP។ នេះអាចពាក់ព័ន្ធនឹងការផ្លាស់ប្ដូរផែនការថវិកាមូលធនទៅមុខ និងការកំណត់ជាមុននៃការបែងចែកថវិកាមូលធនដែលបានចង្អុលបង្ហាញនៅកម្រិតក្រសួង ស្ថាប័នថ្នាក់កណ្ដាល។ |
| | ពង្រឹងការសម្របសម្រួលអន្តរក្រសួងទូទាំងវិស័យកសិកម្មសម្រាប់គម្រោងមូលធនផ្ដល់ដោយហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ សម្រាប់ក្រសួងគន្លឹះទាំងបីក្នុងវិស័យនេះ តាមរយៈគណៈកម្មាធិការអន្តរក្រសួង (IMCs) ដែលទើបបង្កើតថ្មី។ |
| ម៉ាទ្រីសសមិទ្ធកម្មស្មុគស្មាញ និងមិនអាចអនុវត្តបាន។ | កាត់បន្ថយ និងសម្រួលចំនួនសូចនាករសមិទ្ធកម្ម (ឧ. សូចនាករសំខាន់ៗ ៥-១៥ សូចនាករ)។ តុល្យការសូចនាកររវាងលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ។ |
| | លើកទឹកចិត្តឱ្យមានសង្គតិភាពនៅក្នុងសូចនាករពី BSP មួយទៅមួយទៀត។ |

| | |
|---|---|
| | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការត្រួតពិនិត្យគ្រប់ជ្រុងជ្រោយរៀងរាល់ឆ្នាំដ៏នូវសមិទ្ធកម្មធៀបនឹងគោលដៅលទ្ធផលប្រចាំឆ្នាំ និងលទ្ធផលសម្រេចបាន ដូចដែលបានរាយ-ការណ៍នៅក្នុង BSP។ នេះអាចត្រូវបានបំពេញបន្ថែមដោយការបង្កើតយន្តការដើម្បីប្រើប្រាស់លទ្ធផលជាធាតុបញ្ចូលនៅក្នុង BSP ជាបន្ទាប់។ |
| | រៀបចំឡើងវិញនូវសូចនាករសមិទ្ធកម្ម ដើម្បីឆ្លុះបញ្ចាំងពីគោលដៅជាក់ស្តែង និងអាចផ្ទៀងផ្ទាត់បានបន្ថែមទៀត ដែលសមស្របនឹងធនធានដែលមាន។ |
| | កម្មវិធីពង្រឹងសមត្ថភាពលើការរៀបចំ ការត្រួតពិនិត្យ ការរាយការណ៍ និងការប្រើប្រាស់វង្វាស់សមិទ្ធកម្ម។ |
| វង្វាស់ BSP និងសមិទ្ធកម្មមិនទាន់បានពិចារណាសម្រាប់ការចរចា និងការបែងចែកថវិកានោះទេ។ | MAFF ណែនាំជាបណ្តើរៗនូវព័ត៌មានអំពីសមិទ្ធកម្មទៅក្នុងសំណើថវិកានៅក្នុង BSP។ សំណើថវិកាគួរត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងសូចនាករ។ ផ្តោតលើការបង្ហាញអំពីគោលបំណង និងបង្ហាញថាតើលទ្ធផលអាចត្រូវបានតាមដាន និងត្រួតពិនិត្យដែរឬទេ។ |
| | ប្រើក្របខ័ណ្ឌ PIB ដើម្បីចង្អុលបង្ហាញការអភិវឌ្ឍបឋមនៃទស្សនាទាននៃរចនាសម្ព័ន្ធនៃក្របខ័ណ្ឌរបាយការណ៍សមិទ្ធកម្មគ្រប់ជ្រុងជ្រោយ រួមទាំងទម្រង់របាយការណ៍ និងដំណើរជាប្រចាំ។ |
| ច្បាប់/វិធាននិយ័តកម្មតឹងរ៉ឹង និងការផ្តល់ថវិកាមានរយៈពេលយូរ | បញ្ចេញថវិកាជាមុនប្រចាំត្រីមាស តាមថវិកាដែលបានអនុម័ត។ |
| | ការធ្វើប្រតិភូកម្មសិទ្ធិអំណាចដើម្បីគាំទ្រភាពបត់បែនរបស់អ្នកគ្រប់គ្រងក្នុងការអនុវត្តថវិកា - ឧ. ការវិភាជលើការធ្វើនិយ័តរវាងសមាសធាតុចំណាយមួយចំនួនក្នុងកំឡុងពេលអនុវត្ត ឧទា-ហរណ៍ ចំពោះសមាសធាតុដែលស្ថិតនៅក្រោមអនុកម្មវិធីដូចគ្នា។ មូលដ្ឋានចំណាយ នឹងរាយការណ៍អំពីការប្រើប្រាស់មូលនិធិនៅកម្រិតអនុកម្មវិធី។ ការធ្វើនិយ័ត នៅកម្រិតចំណាយមូលដ្ឋានអាចកើតឡើងនៅក្នុងអនុកម្មវិធី ប៉ុន្តែនៅកម្រិតខ្ពស់សម្រាប់អង្គភាព។ ប្រធានគ្រប់គ្រងអនុកម្មវិធីនឹងរាយការណ៍ចំពោះការប្រតិបត្តិកម្មវិធី។ |
| | កសហវ. និង MAFF ធ្វើការត្រួតពិនិត្យនីតិវិធីអនុវត្តការងារសម្រាប់ធានាចំណាយ និងដំណើរការកិច្ចលទ្ធកម្ម ដែលស្រដៀងទៅនឹងវិធីសាស្ត្រក្រោមកំណែទម្រង់ FMIS។ |
| | MAFF ដើម្បីរៀបចំផែនការលទ្ធកម្មជាមុន និងកែសម្រួលក្របខ័ណ្ឌពេលវេលាសម្រាប់ការរៀបចំឯកសារចាំបាច់ រួមជាមួយនឹងប្រតិទិននៃលទ្ធកម្ម។ |
| | ក្រសួងធនធានទឹក និងឧតុនិយម រៀបចំផែនការអនុវត្តថវិកា, ចែករំលែកជាមួយប្រធានគ្រប់គ្រងកម្មវិធី, ដែលបញ្ជាក់ពីគម្រោងបើកផ្តល់ធនធានថវិកាក្នុងឆ្នាំ។ ការចេញកាលវិភាគនឹងបញ្ជាក់ចំនួនដែលត្រូវបញ្ចេញទៅក្នុងកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព, និងសមាសធាតុចំណាយពេញមួយឆ្នាំ ដោយផ្អែកលើធនធានដែលមាន។ |
| ការត្រួតពិនិត្យផ្ទៃក្នុង សវនកម្ម និងការត្រួតពិនិត្យ | ពង្រឹងអង្គភាពសវនកម្មផ្ទៃក្នុង MAFF និងតួនាទី និងទំនួលខុសត្រូវនៃក្រុមអធិការកិច្ច សម្រាប់ការគ្រប់គ្រងថវិកាផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព និងផ្តោតលើសមិទ្ធកម្ម។ |

| **បញ្ហាប្រឈម** | **រយៈពេលមធ្យម** |
|---|---|
| | |

| | |
|---|---|
| ការផ្សារភ្ជាប់រវាង BSP និង PB នៅមានកម្រិត។ ការចរចាថវិកាមិនអនុវត្តតាមតក្កភាពរបស់កម្មវិធីទេ។ | ពិនិត្យ និងធ្វើការផ្លាស់ប្តូរច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨ ដើម្បីពង្រឹងក្របខ័ណ្ឌថវិកាកម្មវិធីនៅក្នុងច្បាប់ រួមទាំងការអនុម័តថវិកានីតិបញ្ញត្តិលើមូលដ្ឋានកម្មវិធី។ |
| | តម្រឹម BSP ស្របតាមទៅនឹង MTFF។ ការចំណាយច្បាស់លាស់ដែលបានស្នើឡើងថ្មីចំពោះអនុកម្មវិធី ចង្កោមសកម្មភាព, គំនិតផ្តួចផ្តើមគោលនយោបាយ, ចំណាយនិយោគ និងតម្រូវការថវិកាដើម្បីបន្តសកម្មភាពដែលមានស្រាប់។ នេះអាចរួមបញ្ចូលការចំណាយទាក់ទងនឹងហានិភ័យផ្សេងៗដូចជាការប្រែប្រួលអាកាសធាតុជាដើម។ |
| ភាពទន់ខ្សោយនៃការចូលរួមរបស់ ក្រសួង ស្ថាប័នក្នុងការរៀបចំផែនការថវិកាមូលធន | ពង្រឹងតួនាទីរបស់ MAFF ក្នុងការធ្វើការសិក្សាអំពីសមិទ្ធិលទ្ធភាព តាមរយៈមូលនិធិ ដែលមានមុខសញ្ញា និងការកសាងសមត្ថភាព។ |
| | ដាក់ឱ្យសាកល្បង គម្រោងកញ្ចប់ថវិកាប្រចាំឆ្នាំ កម្រិតក្រសួង ដែលបង្ហាញរយៈពេលមធ្យម ៣ ឆ្នាំសម្រាប់ MAFF (ឬ ក្រសួង ស្ថាប័នអាទិភាពផ្សេងទៀត)។ ការតម្រឹមពេលវេលាជាមួយការរៀបចំ BSP (តាមរយៈការចេញសារាចរ)។ |
| | ការប្រគល់ជាបណ្តើរៗចំពោះ គម្រោងនីមួយៗសម្រាប់សកម្មភាព MAFF ដែលជាផ្នែកមួយនៃឯកសារ BSP។ |
| ម៉ាទ្រីសសមិទ្ធកម្មស្មុគស្មាញ និងមិនអាចអនុវត្តបាន។ | តម្រឹមជាមួយផែនការយុទ្ធសាស្ត្រនៃការប្រែប្រួល អាកាសធាតុតាមវិស័យ (SCCSP) និងគោលដៅយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រនៃបម្រែបម្រួលអាកាសធាតុនៅកម្ពុជា (CCCSP) ២០១៤-២០២៣, ម៉ាទ្រីសសមិទ្ធកម្មអាចរួមបញ្ចូល ១ (ឬ) ២ សូចនាករនៃបម្រែបម្រួលអាកាសធាតុ ដូចជា “ពង្រឹងសេវាបណ្តុះបណ្តាលក្រៅប្រព័ន្ធលើការផ្តល់បច្ចេកវិទ្យា ដើម្បីសុវត្ថិភាពចំណីអាហារ”។ |
| | កម្មវិធីពង្រឹងសមត្ថភាពលើការរចនាសម្ព័ន្ធ ការត្រួតពិនិត្យ រាយការណ៍ និងរង្វាស់សមិទ្ធកម្ម។ |
| BSP និងរង្វាស់សមិទ្ធកម្មមិនទាន់ត្រូវបានពិចារណាសម្រាប់ការចរចា និងវិភាជថវិកា | លើកទឹកចិត្តឱ្យមានទំនាក់ទំនងកាន់តែរឹងមាំរវាងព័ត៌មានសមិទ្ធកម្មនៅក្នុង BSP និងការ-ចរចាថវិកា។ កសហវ. ធ្វើសមាហរណកម្មព័ត៌មានសមិទ្ធកម្មជាផ្លូវការទៅក្នុងដំណាក់កាលចរចាថវិកា ដោយទាមទារឱ្យមានការធ្វើនីយកម្មថវិកាផ្អែកលើលទ្ធផលដែលបង្ហាញរួមជាមួយសំណើថវិការបស់ MAFF (និង ក្រសួង ស្ថាប័នផ្សេងទៀត)។ ជាដំណាក់កាលការអនុម័តរបស់ កសហវ. លើការបែងចែកធនធានដើម្បីភ្ជាប់ កាន់តែច្បាស់ទៅនឹងលទ្ធផលក្នុងឆ្នាំ (និងលទ្ធផលចុងក្រោយ) រំពឹងទុក នៅក្នុងរចនាសម្ព័ន្ធ PB។ |
| ច្បាប់/វិធានការនិយ័តកម្មតឹងរ៉ឹង និងការផ្តល់ថវិកាមានរយៈពេលយូរ | ឥណទានថវិកាប្រចាំឆ្នាំតាមមូលដ្ឋានកម្មវិធី។ បញ្ចេញថវិកា តាមកម្មវិធី និងអនុកម្មវិធី ដើម្បីអនុញ្ញាតឱ្យមានភាពបត់បែនក្រោមអនុកម្មវិធី។ ថវិកាសរុបសម្រាប់អនុកម្មវិធីនីមួយៗ នៅតែអាចកំណត់បានដោយការរួមបញ្ចូលគ្នានៃវិធីសាស្ត្រពីលើចុះក្រោម និងពីក្រោមឡើងលើ។ ទោះយ៉ាងណាក៏ដោយ នៅកម្រិតនៃមូលដ្ឋានចំណាយ មូលនិធិមិនគួរត្រូវបានបែងចែកតាមសកម្មភាព ឬមូលដ្ឋានសមាសធាតុចំណាយតាមដែលអាចធ្វើបានឡើយ ផ្ទុយទៅវិញ អង្គភាពថវិកាគួរដំណើរការលើ “**ថវិកាសកល**” ជាមួយនឹងភាពទន់ភ្លន់ ក្នុងការបែងចែកមូលនិធិនៅទូទាំងសកម្មភាព និងមាតិកាថវិកា។ |

| | |
|---|---|
| | ដំណាក់កាលនៃការអនុវត្តថវិកាគួរគាំទ្រដល់ការប្រើប្រាស់ធនធានស្របតាមថវិកាដែលអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ។ ការបែងចែកថវិកាដូចដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ និងបានកត់ត្រាក្នុងឯកសារថវិកា គប្បីបញ្ជាក់ពីការបែងចែកនៅតាមកម្រិតកម្មវិធី និងអនុកម្មវិធី។ នេះចាំបាច់ត្រូវបំពេញបន្ថែមដោយផែនការប្រតិបត្តិថវិកាដែលនឹងលម្អិតបន្ថែមទៀតអំពីភាពអាចរកបាននៃធនធានសម្រាប់ប្រធានគ្រប់គ្រងកម្មវិធី និងអនុកម្មវិធី។ |
| ការត្រួតពិនិត្យផ្ទៃក្នុង, សវនកម្ម និងពិនិស្ស័យ | រៀបចំ និងអនុវត្តផែនទីបង្ហាញផ្លូវនៃក្របខ័ណ្ឌត្រួតពិនិត្យផ្ទៃក្នុង។ ផ្សព្វផ្សាយរបាយការណ៍សវនកម្មរបស់ MAFF ដោយអាជ្ញាធរសវនកម្មជាតិ។ |

### រដ្ឋបាលខេត្តព្រះសីហនុ

២២០. របាយការណ៍វាយតម្លៃសាធារណៈ បានផ្តោតលើរដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីកម្រិត ប៉ុន្តែផ្តោតលើរដ្ឋបាលខេត្តច្រើនជាង ។ រដ្ឋបាលខេត្តព្រះសីហនុ មានទំហំថវិកាដែលស្មើនឹង៤៥% នៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់មន្ទីរជំនាញនៅជុំវិញ ខេត្ត។ រដ្ឋបាលខេត្តព្រះសីហនុក៏មានចំណូលពីប្រភពផ្ទាល់ខ្លួនច្រើនជាងគេផងដែរ បើប្រៀបធៀបទៅនឹងថ្នាក់ក្រុង ស្រុក និង ឃុំ សង្កាត់។ ចំណូលទាំងអស់ភាគច្រើន (ដែលច្រើនជាង ៨០%) បានមកពីចំណូលសារពើពន្ធ។ ជាង ៧០% នៃថវិការដ្ឋបាលខេត្តព្រះសីហនុ គឺចំណាយលើការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ដែលភាគច្រើនជាផ្លូវក្រុង។ ការចំណាយដ៏ច្រើនលើការជួសជុល និងថែទាំនេះឆ្លុះបញ្ចាំងពីភាពចាស់ទ្រុឌទ្រោមនៃហេដ្ឋារចនាសម្ព័ន្ធក្រុង និងតម្រូវការសម្រាប់ការធ្វើឱ្យប្រសើរឡើងជាមួយនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃខេត្តព្រះសីហនុ។

២២១. ការរៀបចំថវិការបស់រដ្ឋបាលខេត្តព្រះសីហនុបង្ហាញវឌ្ឍនភាព ជាពិសេសបន្ទាប់ពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ ២០២០។ ទោះជាយ៉ាងណា ប្រសិទ្ធភាពនៃការវិភាជ អាចពង្រឹងបន្ថែមទៀតប្រសិនបើមានការ ប្រគល់មុខងារកាន់តែច្បាស់ ពិសេសរវាងរដ្ឋបាលខេត្ត និងក្រុង ស្រុក ពាក់ព័ន្ធនឹងការស្តារ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ។ កត្តារាំងផ្សេងទៀតរួមមានកង្វះការគ្រប់គ្រងទិន្នន័យ សមត្ថភាពព្យាករណ៍ប្រាក់ចំណូល (ពិសេសលើពន្ធ) និងការធ្វើសមាហរណកម្មរវាងផែនការរបស់រដ្ឋ និងឯកជាតិ (spatial planning) និងផែនការសេដ្ឋកិច្ច-សង្គមនៅមានកម្រិត។

២២២. ការវិភាគវាយតំលៃលើ ការទទួលបានការគាំពារសម្រាប់ជនក្រីក្រ (pro-poorness) នៃការចំណាយរបស់រដ្ឋាភិបាលលើសេវាសាធារណៈផ្សេងៗនៅថ្នាក់ក្រោមជាតិដោយប្រើវិធីសាស្ត្រវិភាគ benefit incidence analysis-BIA។ BIA អនុញ្ញាតឱ្យមានការពិនិត្យលើវិសាលភាពនៃការទទួលបានអត្ថប្រយោជន៍លើសេវាសាធារណៈ របស់ប្រជាជនមកពីក្រុមចំណូលផ្សេងៗគ្នា បើទោះបីជាថវិកា/ ការចំណាយលើការអប់រំ និងសុខាភិបាលគឺនៅមិនទាន់ត្រូវបានគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ។ នៅក្នុងវិស័យអប់រំ ការចំណាយរបស់រដ្ឋាភិបាលត្រូវបានចែកចាយដោយស្មើភាពគ្នាសម្រាប់ការអប់រំផ្នែកបឋម ប៉ុន្តែហាក់ដូចជាអនុគ្រោះខ្លាំងដល់ក្រុមដែលមានចំណូលខ្ពស់សម្រាប់កម្រិតផ្សេងទៀត។ សម្រាប់វិស័យសុខាភិបាល ការចំណាយសាធារណៈហាក់ផ្តល់អាទិភាពគាំទ្រសម្រាប់ជនក្រីក្រ ទោះបីជាការចំណាយមានទំនោរឆ្ពោះទៅរកក្រុមចំណូលខ្ពស់ជាងគេទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក៏ដោយ។ ពាក់ព័ន្ធនឹងលទ្ធភាពទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដូចជា អគ្គិសនី ទឹកស្អាត និងប្រព័ន្ធធារាសាស្ត្រ ការចំណាយសាធារណៈផ្តល់ផលប្រយោជន៍ដល់ក្រុមចំណូលទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ ចំណាយលើការប្រើប្រាស់ទឹកស្អាត (pipe-borne water) ហាក់បីដូចជាមានទំនោរទៅក្រុមមានចំណូលខ្ពស់ជាងក្រុមចំណូលទាប។

២២៣. ចំពោះការអនុវត្តថវិកាសម្រាប់រដ្ឋបាលខេត្តព្រះសីហនុ គម្លាតខុសគ្នាខ្លាំងរវាងការគ្រោងថវិកា និងការអនុវត្តថវិកាគឺមានប្រហែល ១៧០% ក្នុងឆ្នាំ២០១៨ និង ២០១៩ ប៉ុន្តែបានធ្លាក់ចុះមកត្រឹមតែ ៧៥% ប៉ុណ្ណោះ ដោយសារបញ្ហាការប្រមូលចំណូល សារពើពន្ធពាក់ព័ន្ធនឹងជំងឺកូវីដ-១៩។ ផែនការធៀបនឹងបំរែបំរួលថវិកាជាក់ស្តែងមានន័យថាមានការព្យាករក្នុងកម្រិតទាបលើផ្នែកព្យាករណ៍ចំណូល និងនិយ័តកម្មថវិកា ដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការបែងចែកថវិកា។ ការអនុវត្តបានរលូនសម្រាប់ចំណាយចរន្ត (ចំណាយបន្ទុកបុគ្គលិក (ជំពូកទី ៦៤) ការទិញទំនិញ (ជំពូកទី ៦០) និងសេវាកម្ម (ជំពូកទី ៦១) ប៉ុន្តែមានការពន្យារពេលសម្រាប់ថវិកាវិនិយោគ (អនុគណនី ៦១០៥៣ និងជំពូកទី ២១)។

២២៤. ការពន្យារនេះបណ្តាលមកពីកត្តាពីររួមបញ្ចូលគ្នា÷ ១) សំណើយឺតយ៉ាវ និងការអនុម័តលើការបន្ថែមឥណទានថវិកា និង ២) ការរៀបចំគម្រោងវិនិយោគ និងដំណើរការលទ្ធកម្មពុំមានប្រសិទ្ធភាព។ ការទូទាត់បំណុលកកស្ទះ មិនត្រូវបានរកឃើញថាជាបញ្ហាធ្ងន់ធ្ងរសម្រាប់ការចំណាយមិនឆ្លងលទ្ធកម្មទេ។ នៅក្នុងលក្ខខណ្ឌនៃការចំណាយឆ្លងកិច្ច-លទ្ធកម្ម នោះគឺមិនអាចកំណត់ការទូទាត់បំណុលកកស្ទះ ដោយហេតុថាកង្វះចន្លោះក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិបច្ចុប្បន្ន និងការកត់ត្រា (រួមទាំងនៅក្នុង FMIS) បាននោះទេ។

២២៥. នៅក្នុងកម្រិតក្រុង ស្រុក, ការផ្ទេរមុខងារដែលមានល្បឿនយឺតខ្លាំង (រួមជាមួយនឹងការផ្ទេរថវិកា និងការផ្ទេរមន្ត្រីដើម្បីបម្រើការងារ) ដល់ ក្រុង ស្រុក បានក្លាយទៅជាបញ្ហាសម្រាប់ការផ្តល់សេវាសាធារណៈតាមក្រុង ស្រុក ទាំងមូល និងការកែទម្រង់ថវិកា។ ទាក់ទងនឹងការផ្តល់សេវាក្នុងតំបន់ ចំណុចដែលត្រូវបានមើលរំលងដ៏សំខាន់គឺការចូលរួមរបស់វិស័យឯកជនក្នុងការផ្តល់សេវាក្នុងតំបន់។ បច្ចុប្បន្ននេះ មានការពិភាក្សាហាក់បីដូចជាមានការទំនោរជុំវិញថវិកាជាតិមួយចំនួនតូចដែលអាចត្រូវបានវិភាជ និងប្រើប្រាស់ឡើងវិញ ដែលជាធរមាន បានច្រានចោលនូវតម្រូវការសម្រាប់ ក្រុង ស្រុក ដើម្បីដើរតួនាទីជានីតិប្បញ្ញត្តិ និងសម្របសម្រួលក្នុងការស្វែងរកការរួមចំណែកបន្ថែមពីវិស័យឯកជន។ សម្រាប់កម្រិត ឃុំ សង្កាត់ ការផ្តោតសំខាន់ក្នុងរយៈពេលដ៏ខ្លីនេះគួរ ផ្តោតលើការកែលម្អដំណើរការកិច្ចលទ្ធកម្ម ជាពិសេសបន្ទាប់ពីការកែប្រែច្បាប់លទ្ធកម្មបច្ចុប្បន្ន។

២២៦. ផ្អែកតាមរបកគំហើញនិងការឆ្លុះបញ្ចាំងពីទិសដៅកែទម្រង់ដ៏ទូលំទូលាយរបស់រដ្ឋាភិបាល សកម្មភាពដែលត្រូវបានណែនាំខាងក្រោមត្រូវបានស្នើឡើងដូចតទៅ:

| **ថ្នាក់ខេត្ត** | |
|---|---|
| ពង្រឹងសមត្ថភាពការរៀបចំផែនការ | 1- បន្តកែលម្អការរៀបចំ BSP ថ្នាក់ខេត្ត ការធ្វើសមាហរណកម្មផែនការរបស់ ក្រុង ស្រុក និង ឃុំ សង្កាត់ ទៅក្នុង BSP និងផែនការថវិកាកម្មវិធី។<br>2- ពង្រឹងការគ្រប់គ្រងទិន្នន័យ និងសមត្ថភាពដើម្បីជួយក្នុងការរៀបចំផែនការ និងការអនុវត្តថវិកាជាមួយនឹងការបង្កើនការប្រើប្រាស់ប្រព័ន្ធ ICT សម្រាប់ការប្រមូលទិន្នន័យ ការរក្សាទុក និងការចែករំលែក (រួមទាំងការវិនិយោគថ្នាក់ជាតិ ការវិនិយោគឯកជន និងហិរញ្ញប្បទានដោយអង្គការសង្គមស៊ីវិល)។<br>3- កែលម្អ និងធ្វើសមាហរណកម្មផែនការរដ្ឋនិងឯកជនជាមួយផែនការសេដ្ឋកិច្ច-សង្គមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |

| | |
|---|---|
| បង្កើនសមត្ថភាពព្យាករណ៍ចំណូលសារពើពន្ធ | 4- កែលម្អការព្យាករណ៍ចំណូលសារពើពន្ធ និងការគ្រប់គ្រង និងពង្រឹងបន្ទាត់គណនេយ្យភាពរវាងអគ្គនាយកដ្ឋានពន្ធដារ និងរដ្ឋបាលខេត្ត។<br>5- ពិចារណាលើការបង្កើនភាគរយនៃការបែងចែកចំណូលសារពើពន្ធពីកម្រិតខេត្ត ទៅកម្រិតក្រុង ស្រុក និង ឃុំ សង្កាត់ ដើម្បីកាត់បន្ថយអតុល្យភាពនាពេលបច្ចុប្បន្នក្នុងខ្សែបណ្ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>6- បន្តពិភាក្សាកម្រិតគោលនយោបាយអំពីលទ្ធភាពនៃការចាត់ចែងចំណូលពើពន្ធបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| កែលម្អការព្យាករណ៍ចំណូលមិនមែនសារពើពន្ធ (NTR) | 7- កែលម្អការព្យាករ និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពីទ្រព្យសម្បត្តិរដ្ឋ<br>8- កែលម្អប្រព័ន្ធ, ដំណើរការ, និងសមត្ថភាពរបស់អ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូល (រួមទាំងការប្រើប្រាស់ NRMIS)<br>9- បន្តផ្ទេរមុខងារចំណូលមិនមែនសារពើពន្ធ បន្ថែមទៀតពីក្រសួង ស្ថាប័ន ទៅរដ្ឋបាលខេត្ត និងថ្នាក់ក្រុង ស្រុក |
| ភាពច្បាស់លាស់នៃការប្រគល់មុខងារ | 10- បញ្ជាក់ឱ្យកាន់តែច្បាស់បន្ថែមពីការប្រគល់មុខងារ ពិសេស រវាងរដ្ឋបាលខេត្ត និងក្រុង ស្រុក លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ<br>11- តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគាំពារសង្គម (ជាពិសេសការចូលរួមជួយដល់សង្គម ដូចជាគម្រោងផ្ទេរប្រាក់) គួរត្រូវបានលើកឡើងបញ្ជាក់ឱ្យច្បាស់ និងរៀបចំបង្កើតជាស្ថាប័ននីយកម្ម។<br>12- រៀបចំ កែសម្រួល និងពង្រឹងយន្តការ និងដំណើរការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការជាមួយវិស័យឯកជន (រួមទាំងការផ្ដល់អាជ្ញាប័ណ្ណ) ដើម្បីកែលម្អការផ្ដល់សេវា។ |
| ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់) | 13- វាយតម្លៃលើវិសាលភាពនៃសារពើភ័ណ្ឌទ្រព្យសកម្មបច្ចុប្បន្នមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លុះបញ្ចាំងតតភាពជាក់ស្ដែង ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសកម្ម និងតម្លៃទ្រព្យសកម្ម។<br>14- រៀបចំអភិបាលកិច្ចឱ្យកាន់តែរឹងមាំសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដោយចាប់ផ្ដើមពីក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ។ |
| កែលម្អដំណើរការអនុវត្តថវិកា | 15- កែលម្អពេលវេលានៃការរៀបចំគម្រោង និងលទ្ធកម្ម ដើម្បីឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោង និងការចំណាយប្រកបដោយគុណភាព។<br>16- បន្តអនុវត្តយុទ្ធសាស្ត្រលទ្ធកម្មសាធារណៈដើម្បីធ្វើវិមជ្ឈការសិទ្ធិ និងអំណាចបន្ថែមទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>17- ពិចារណាលើបទប្បញ្ញត្តិនានា ដើម្បីអនុញ្ញាតឱ្យមានការអនុវត្តថវិកាសម្រាប់គម្រោងវិនិយោគក្នុងឆ្នាំ ដើម្បីយោងអនុវត្ត<br>18- បញ្ជាក់ និងកែតម្រូវCOA ដែលមានស្រាប់ និងការកត់ត្រាប្រតិបត្តិការជាក់លាក់ (ដូចជាចំណូលមិនមែនពន្ធមួយចំនួន ការចំណាយមូលធន និងការបែងចែកការលើកទឹកចិត្ត) |
| | 19- កែលម្អភាពច្បាស់លាស់នៃសេចក្ដីណែនាំស្ដីពីការអនុវត្តថវិកា |

| | |
|---|---|
| | 20- កសាងសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយនឹងការសម្របសម្រួលកាន់តែប្រសើរឡើង (រួមទាំងជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA)) និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការគាំទ្របន្ថែមទៀត (និងមិនផ្តោតលើការបណ្តុះបណ្តាលខ្លាំងពេក)។<br>21- ធានាបាននូវការណែនាំទាន់ពេលវេលា និងច្បាស់លាស់អំពីនីតិវិធី/ការផ្លាស់ប្តូរថ្មី (ឧ. តាម SNA-BSRS)។ ចំពោះបញ្ហានេះ គួរពិចារណាផងដែរអំពីការបង្កើតនីតិវិធីដំណើរការការងារស្តង់ដារសាមញ្ញ (ឧ. មេរៀនពីនីតិវិធីដំណើរការការងារ ក្នុងប្រព័ន្ធ FMIS) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ថ្នាក់ក្រុង ស្រុក | |
| កែលម្អលទ្ធភាពទទួលបានថវិកា និងភាពច្បាស់លាស់នៃការប្រគល់មុខងារ | 22- រៀបចំឱ្យមានការចំណាយលម្អិតនៃមុខងារជាក់លាក់។<br>23- ដំណោះស្រាយគម្លាតថវិកានៅកម្រិត ក្រុង ស្រុក ដែលជាបញ្ហាបន្ទាន់។<br>24- កំណត់បទប្បញ្ញត្តិតាមវិស័យពាក់ព័ន្ធ ដែលត្រូវកែសម្រួលឱ្យសមស្របតាមការកែទម្រង់ D&D, ធានាឱ្យបានថាមន្ទីរជំនាញបានអនុវត្តក្នុងការផ្ទេរមុខងារថ្មីនៅក្នុងការអនុវត្តផែនការ និងថវិកាជាប្រចាំ និងដោះស្រាយភាពមិនស៊ីសង្វាក់គ្នានៃការប្រើប្រាស់ទិន្នន័យសម្រាប់ការធ្វើផែនការ និង គោលបំណងនៃ ត្រួតពិនិត្យ និងវាយតម្លៃ (M&E)<br>25- ជំរុញ/តម្រូវឱ្យរដ្ឋបាល ក្រុង ស្រុក រៀបចំយន្តការច្បាស់លាស់ និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីការចូលរួមរបស់វិស័យឯកជនក្នុងការផ្តល់សេវា និងការអភិវឌ្ឍ។ |
| កែលម្អការគ្រប់គ្រងធនធានមនុស្ស | 26- ដោះស្រាយកង្វះបុគ្គលិកសម្រាប់សេវាសំខាន់ៗ (ឧ. ការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង)<br>27- បញ្ជាក់ និងពន្យល់ពីរបៀបដែលមន្ត្រីបច្ចេកទេសនៅរដ្ឋបាល ក្រុង ស្រុក គួរអនុវត្តការងារប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួនក្រោមការរៀបចំរបៀបរបបការងារថ្មី។ |
| ថ្នាក់ឃុំ សង្កាត់ | |
| ដោះស្រាយការយឺតយ៉ាវនៃការអភិវឌ្ឍន៍ និងការរៀបចំគម្រោង | 28- គាំទ្រដល់មន្ត្រី ឃុំ សង្កាត់ អនុវត្តសារាចរដែលទាក់ទងនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍ តាម ឃុំ សង្កាត់ ដើម្បីទប់ស្កាត់ការពន្យារពេលនៃ នៃការអភិវឌ្ឍ និងការរៀបចំគម្រោង។<br>29- តាមដានការអនុវត្ត និងប្រមូលមតិកែលម្អសម្រាប់ការកែតម្រូវ និងពង្រឹងនាពេលអនាគត។ |

### ២.៣.៥. មតិរបស់ អ.គ.ហ. លើរបកគំហើញនៃរបាយការណ៍វាយតម្លៃ

- **ការអនុវត្តប្រព័ន្ធ FMIS÷** គិតគូររៀបចំហត្ថលេខាអេឡិចត្រូនិក និងគោលនយោបាយឌីជីថល, ពង្រឹងការប្រើប្រាស់ឧបករណ៍គ្រប់គ្រងសាច់ប្រាក់, ពង្រីកវិសាលភាពប្រព័ន្ធ FMIS ដោយប្តូកបញ្ចូលទាំងគ្រប់ប្រភពមូលនិធិ, និងឌីជីថលូបនីយកម្មទៅការរៀបចំ និងការផ្ញើរបាយការណ៍។
- **ច្បាប់លទ្ធកម្មសាធារណៈ÷** ការធ្វើវិសោធនកម្មច្បាប់ស្តីលទ្ធកម្មសាធារណៈ ជាជំហានមួយក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥។ សិទ្ធិគ្រប់គ្រង និងសម្រេចលើកិច្ចលទ្ធកម្ម នឹងត្រូវបានផ្តល់ជូនជាបណ្តើរៗដល់អង្គភាពអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ វិសាលភាពនៃការចរចាជាមួយអ្នកដេញថ្លៃតែមួយ ត្រូវបានរឹតបណ្តឹង ដែលការណ៍នេះ នឹងលើកកម្ពស់ដល់កិច្ចលទ្ធកម្មប្រកួតប្រជែង។

- **ការវាយតម្លៃថវិកាយេនឌ័រ÷** គិតគូររៀបចំហត្ថលេខាអេឡិចត្រូនិក និងគោលនយោបាយឌីជីថល, ពង្រឹងការ-ប្រើប្រាស់ឧបករណ៍គ្រប់គ្រងសាច់ប្រាក់, ពង្រីកវិសាលភាពប្រព័ន្ធ FMIS ដោយបូកបញ្ចូលទាំងគ្រប់ប្រភពមូលនិធិ, ឌីជីថលូបនីយកម្មទៅការរៀបចំ និងការផ្ញើរបាយការណ៍។
- **ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Fiscal Management)÷** បន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពចំណាយគិតគូរអំពីបន្ទុកសារពើពន្ធ, និងពង្រីកមូលដ្ឋានពន្ធ (ពន្ធលើប្រាក់បៀវត្សបុគ្គល, ពន្ធលើចំណេញមូលធន, ពន្ធកាបូន និងពន្ធលើសេវាឌីជីថល)។
- **វិស័យធនធានទឹកនិងឧតុនិយម÷** កំណត់តួនាទីភារកិច្ចរបស់ថ្នាក់កណ្តាល និងថ្នាក់មន្ទីរ, អនុវត្តមុខងារដែលបានផ្ទេរទៅក្រុងស្រុក, លើកកម្ពស់សហថាមពល (Synergy) រវាងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងថវិកាជាតិនិងពង្រឹងសហថាមពល (Synergy) ជាមួយវិស័យកសិកម្ម ផ្សារភ្ជាប់នឹងបម្រែបម្រួលអាកាសធាតុ។
- **វិស័យសុខាភិបាល÷** តម្រឹមរចនាសម្ព័ន្ធ PB និង BSP, ដាក់ឱ្យអនុវត្តជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្មនៅក្នុងសំណើថវិកា, ពង្រឹងការធ្វើសមាហរណកម្មចំណាយមូលធនហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, វិភាជចំណាយបន្ទុកបុគ្គលិកតាមកម្មវិធីនីមួយៗ។
- **វិស័យកសិកម្ម÷** តម្រឹមរចនាសម្ព័ន្ធ PB និង BSP, ដាក់បញ្ចូលព័ត៌មានសមិទ្ធកម្មជាបណ្តើរៗនៅក្នុងសំណើថវិកាប្រចាំឆ្នាំ, ពង្រឹងការសម្របសម្រួលក្នុងវិស័យពាក់ព័ន្ធកសិកម្ម, ប្រតិភូកម្មសិទ្ធិអំណាចនិយ័តថវិកា ដើម្បីគាំទ្រភាពបត់បែនក្នុងការអនុវត្តថវិកា។
- **រដ្ឋបាលខេត្តព្រះសីហនុ÷** ពង្រឹងសមត្ថភាពរៀបចំផែនការ (BSP&PB), កែលម្អសមត្ថភាពព្យាករចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ និងពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ពង្រឹងការអនុវត្តមុខងារទាំង ៥៥, គាំទ្រមន្ត្រីឃុំ សង្កាត់អនុវត្តសារាចរពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍។

## ២.៤ ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ២.៤.១ ការវាយតម្លៃ PEFA ថ្នាក់ជាតិឆ្នាំ២០២១

២២៧. ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ឬ ហៅកាត់ថា PEFA ត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ដែលសរុបការវាយតម្លៃទាំងអស់ចំនួនបីលើក គឺនៅឆ្នាំ២០១០, ឆ្នាំ២០១៥ និងឆ្នាំ២០២១។ អភិក្រមនៃការវាយតម្លៃ គឺប្រៀបធៀបលើលទ្ធផលទាំងបីលើកនេះ ហើយទាញការសន្និដ្ឋានលើលទ្ធផលវាយតម្លៃជាកម្រិតម៉ាក្រូ ដោយក្នុងនោះរួមមាន÷ (១) វិន័យថវិកា, (២) ប្រសិទ្ធភាពវិភាជន៍ថវិកា និង (៣) ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

២២៨. របកគំហើញពីការវាយតម្លៃ PEFA ឆ្នាំ២០២១ ដែលប្រើប្រាស់ក្របខ័ណ្ឌ PEFA ឆ្នាំ២០១១ បង្ហាញថាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាត្រូវបានកែលម្អ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងពិន្ទុ នៃសូចនាករសមិទ្ធកម្ម (PIs) ចំនួន ១០ ក្នុងនោះរួមមាន÷ PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI-19, PI-21, PI-23 និង PI-25។ រីឯ PI-3 ទទួលបានពិន្ទុទាបដោយសារមានគម្លាតខ្ពស់រវាងផែនការ និងលទ្ធផលប្រមូលចំណូលចាប់ពីឆ្នាំ២០១៧, ២០១៨ និង២០១៩។ តារាងទី៤ និងដ្យាក្រាមទី៩ ខាងក្រោម បង្ហាញអំពីការកើនឡើងពិន្ទុ PEFA ឆ្នាំ២០២១ ធៀបទៅនឹងឆ្នាំ២០១៥ និង ២០១០។

តារាងទី 4៖ បម្រែបម្រួលពិន្ទុ PEFA ឆ្នាំ២០២១ ធៀបទៅនឹងឆ្នាំ២០១៥ និងឆ្នាំ២០១០

| ល.រ | សូចនាករ | ពិន្ទុ ២០១០ | ពិន្ទុ ២០១៥ | ពិន្ទុ ២០២១ | បម្រែបម្រួល |
|---|---|---|---|---|---|
| ១ | លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៖ ភាពជឿទុកចិត្តនៃថវិកា | | | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | B | A | A | មិនមាន |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | D | D+ | B+ | ᐱ |
| PI-3 | ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | A | A | D | V |
| PI-4 | សន្និធិបំណុលកកស្ទះនិងការត្រួតពិនិត្យតាមដានចំណាយកកស្ទះ | C+ | D+ | D+ | មិនមាន |
| ២ | ការងារត្រួតស៊ីគ្នាសំខាន់ៗ ៖ ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា | | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | C | C | C | មិនមាន |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | B | C | B | ᐱ |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | C | C | B | ᐱ |
| PI-8 | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល (ថ្នាក់ជាតិនិងក្រោមជាតិ) | C+ | B | B | មិនមាន |
| PI-9 | ការត្រួតពិនិត្យហានិភ័យថវិកា ពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ | C+ | C+ | C+ | មិនមាន |
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | C | D | C | ᐱ |
| ៣ | វដ្តថវិកា | | | | |
| ៣.១ | ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | | | | |
| PI-11 | កាលានុក្រម និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | A | A | A | មិនមាន |
| PI-12 | ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកាគោល-នយោបាយចំណាយ និងការរៀបចំថវិកា | B | C+ | C+ | មិនមាន |
| ៣.២ | ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា | | | | |
| PI-13 | តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | B | C+ | B | ᐱ |
| PI-14 | ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធនិងការវាយតម្លៃពន្ធ | C | D+ | C+ | ᐱ |
| PI-15 | ប្រសិទ្ធភាពនៃការប្រមូលពន្ធ | D+ | D+ | NA | មិនអាចធៀប |
| PI-16 | ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ | C+ | C+ | C+ | មិនមាន |
| PI-17 | ការកត់ត្រា និងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា | C+ | C+ | C+ | មិនមាន |

| | | | | | |
|---|---|---|---|---|---|
| PI-18 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស | D+ | D+ | D+ | មិនមាន |
| PI-19 | តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | NA | D | C+ | ∧ |
| PI-20 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស | C | C | C | មិនមាន |
| PI-21 | ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង | D+ | C | C+ | ∧ |
| ៣.៣ | គណនេយ្យ, ការកត់ត្រា និងរបាយការណ៍ | | | | |
| PI-22 | ភាពទាន់ពេល និងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី | C | C | C | មិនមាន |
| PI-23 | អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា | C | D | B | ∧ |
| PI-24 | គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | C+ | C+ | C+ | មិនមាន |
| PI-25 | គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | D+ | D+ | C+ | ∧ |
| ៣.៤ | ការត្រួតពិនិត្យ និងសវនកម្មខាងក្រៅ | | | | |
| PI-26 | វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មពីខាងក្រៅ | D+ | NR | NA | មិនអាចធៀប |
| PI-27 | ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិបញ្ញត្តិ | NU | C+ | C+ | មិនមាន |
| PI-28 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅដោយអង្គនីតិបញ្ញត្តិ | NU | B | B | មិនមាន |
| ៤ | ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ | | | ពុំវាយតម្លៃ | |

ប្រភព៖ អ.ត.ហ.

ដ្យាក្រាមទី 14៖ បម្រែបម្រួលពិន្ទុសូចនាករឆ្នាំ២០១០ ឆ្នាំ២០១៥ និង ឆ្នាំ២០២១




ប្រភព៖ អ.ត.ហ.

២២៩. លទ្ធផលនៃការវាយតម្លៃPEFA ថ្នាក់ជាតិ ឆ្នាំ២០២១ បានឆ្លុះបញ្ចាំងថា វឌ្ឍនភាពនៃយុទ្ធសាស្ត្រគន្លឹះទាំង៥ កំពុងរួមចំណែកក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែទាមទារឱ្យមានការបន្តពង្រឹងបន្ថែម ក្នុងនោះរួមមាន (១) **វិន័យថវិកា÷** ផ្នែកលើការអនុវត្តចំណាយថវិកាបង្ហាញថាមានភាពកាន់តែមានល្អប្រសើរ ប៉ុន្តែចាំបាច់ត្រូវដោះស្រាយលើបំណុលកកស្ទះ (ទាំងផ្នែកនិយមន័យ និងបំណុលមរតក) និងការអនុវត្តចំណូលថវិកា ត្រូវបន្តពង្រឹងការព្យាករចំណូល, ពង្រឹងរដ្ឋបាលប្រមូលចំណូលជាពិសេសអនុលោមភាព និងការគ្រប់គ្រងហានិភ័យ, ការតាមដានលើគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ, (២) **ប្រសិទ្ធភាពវិភាជន៍ថវិកា÷** ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំស្របតាមប្រតិទិនថវិកា ប៉ុន្តែចាំបាច់ត្រូវបង្កើនគុណភាពឯកសារថវិកាបន្ថែមទៀត។ ការរៀបចំថវិការយៈពេលមធ្យម គឺស្ថិតក្នុងដំណាក់កាលជាបណ្តើរៗនៅឡើយ ដោយសារ MTFF ពុំទាន់ត្រូវបានអនុវត្ត (៣) **ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ÷** មិនទាន់អនុវត្តបានល្អនៅឡើយ ក្នុងនោះដោយសារកង្វះប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម, កិច្ចលទ្ធកម្មសាធារណៈនៅមិនទាន់មានការប្រកួតប្រជែងពេញលេញ, ការផ្សព្វផ្សាយឯកសារថវិកាសម្រាប់ក្រសួង ស្ថាប័នដែលផ្តល់សេវាសាធារណៈ និងតម្លាភាពថវិកា នៅមានកម្រិត។ ជាមួយគ្នានេះ ការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងនឹងជួយលើកកម្ពស់ប្រព័ន្ធត្រួតពិនិត្យ (Internal control system) ដើម្បីធានាប្រសិទ្ធភាពចំណាយថវិកា និងសមិទ្ធកម្ម។ ដ្យាក្រាមទី15 ខាងក្រោម បង្ហាញអំពីការងារគន្លឹះដែលត្រូវពង្រឹងតាមវដ្តថវិកា។

ដ្យាក្រាមទី 15 ÷ ការងារគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា ដោយផ្អៀបនឹងស្តង់ដា PEFA




ប្រភព÷ អ.គ.ហ.

## ២.៤.២ ការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិឆ្នាំ២០២១

២៣០. ក្របខ័ណ្ឌ PEFA គឺជាឧបករណ៍សម្រាប់វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលអាចត្រូវបានប្រើប្រាស់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ខណៈពេលដែលផ្តោតលើយុត្តាធិការរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រដ្ឋបាលរាជធានីភ្នំពេញ (PPCA), ការវាយតម្លៃ PEFA នេះក៏កំណត់ចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធ

គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) ជាទូទៅ។ ការជ្រើសរើសរដ្ឋបាលរាជធានីភ្នំពេញ ត្រូវបានប្រើប្រាស់ការវាតម្លៃជាបរិមាណតាមសសរស្តម្ភ PEFA ទាំងប្រាំពីរដូចខាងក្រោម÷

- សសរស្តម្ភ SNG÷ ទំនាក់ទំនងថវិកាអន្តររដ្ឋបាល
- សសរស្តម្ភទី១÷ ភាពជឿទុកចិត្តនៃថវិកា
- សសរស្តម្ភទី២÷ តម្លាភាពនៃហិរញ្ញវត្ថុសាធារណៈ
- សសរស្តម្ភទី៣÷ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងបំណុល
- សសរស្តម្ភទី៤÷ យុទ្ធសាស្ត្រសារពើពន្ធផ្អែកលើគោលនយោបាយ និងថវិកា
- សសរស្តម្ភទី៥÷ ការព្យាករ និងការគ្រប់គ្រងក្នុងការអនុវត្តថវិកា
- សសរស្តម្ភទី៦÷ គណនេយ្យ និងរបាយការណ៍
- សសរស្តម្ភទី៧÷ ការពិនិត្យពិនិស្ស័យ និងសវនកម្មផ្ទៃក្រៅ។

២៣១. ការវាយតម្លៃនេះ ត្រូវបានប្រើប្រាស់សូចនាករ PEFA (PIs) ចំនួន ៣៤ និងសមាសធាតុនៃការអនុវត្ត ១០១ ដោយមានសូចនាករបន្ថែមចំនួន ៣ ដើម្បីពិនិត្យមើលការផ្ទេរប្រាក់ពីរដ្ឋាភិបាលថ្នាក់កណ្តាល ដែលហៅថា ទំនាក់ទំនងថវិកាអន្តររដ្ឋាភិបាល និងការពិគ្រោះយោបល់ជាសាធារណៈ។ ការវាយតម្លៃនេះក៏ផ្តល់នូវរបាយការណ៍អនុវត្តរួមបញ្ចូលគ្នា ដែលវិភាគលទ្ធផលនៅទូទាំងសូចនាករទាំងអស់ ដោយសង្ខេបអំពីផលប៉ះពាល់សម្រាប់ ការអនុវត្តធៀបនឹងលទ្ធផលថវិកាស្នូលចំនួន ៣ ក្នុងនោះរួមមាន÷ វិន័យថវិកា, ប្រសិទ្ធភាពវិភាជន៍ធនធាន និង ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ លទ្ធផលនៃការវាយតម្លៃ PPCA នេះ មិនអាចអនុវត្តសម្រាប់រដ្ឋបាលខេត្តផ្សេងទៀតបានទេ ដោយសារផ្អែកតាមលក្ខណៈពិសេសរបស់រាជធានី។ ប៉ុន្តែលទ្ធផលនេះ គឺជាមូលដ្ឋានសម្រាប់ ការវាយតម្លៃបន្ទាប់ ក៏ដូចជាការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

២៣២. ការវាយតម្លៃ PPCA នេះ មានវិសាលភាពលើមុខងារប្រតិបត្តិ, ទីចាត់ការ, អង្គភាពចំណាយ និងក្រុមប្រឹក្សា និងការផ្តល់សេវាសាធារណៈក្នុងសមត្ថកិច្ច និងសកម្មភាពទំនាក់ទំនងជាមួយថ្នាក់ជាតិ។ ក្នុងដែនសមិត្ថកិច្ចរបស់ PPCA គឺមិនមានគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬសហគ្រាសសាធារណៈដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ PPCA ទេ។ ដោយឡែក ចំពោះទិន្នន័យគឺប្រើប្រាស់រយៈពេល ៣ ឆ្នាំ (២០១៨, ២០១៩ និង២០២០) សម្រាប់សូចនាករមួយចំនួនធំ ខណៈយោងទៅលើដំណើរការ និង/ឬទិន្នន័យក្នុងឆ្នាំ ២០២១ ផ្អែកតាមតម្រូវការសូចនាករសមិទ្ធកម្មជាក់លាក់មួយចំនួន។

២៣៣. លទ្ធផលនៃការវាយតម្លៃបង្ហាញថា សូចនាករចំនួន ៤ ក្នុងចំណោម ៣៤ ទទួលពិន្ទុ “A” ឬ “B” ដែលស្របទៅនឹងការអនុវត្តល្អ (Good practice) ជាអន្តរជាតិ; សូចនាករចំនួន ៦ ទទួលបានពិន្ទុ “C” ឬ “C+” ដែលស្ថិតក្នុងកម្រិតមូលដ្ឋាន ហើយសូចនាករចំនួន ១៨ ទទួលបានពិន្ទុ “D” ឬ “D+” ដែលបង្ហាញពីការអនុវត្តខ្សោយ។ ដោយឡែក សូចនាករចំនួន ៣ គឺ “NA-Not Applicable” មានន័យថាពុំមានមុខងារនៅរដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះរួមមានសូចនាករ PI-13, PI-19 និង PI-31 និងសូចនាករចំនួន ៣ គឺ “NU-Not Use” មានន័យថាពុំ ត្រូវបានប្រើប្រាស់សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះរួមមាន សូចនាករ PI-15, PI-16 និង PI-30។

២៣៤. ការវាយតម្លៃ PEFA របស់ PPCA មានបច្ច័យដល់លទ្ធផលចុងក្រោយថវិកាដូចខាងក្រោម÷

**វិន័យថវិកា**

២៣៥. សរុបមក វិន័យថវិកានៅតែជាបញ្ហាកង្វល់សម្រាប់ទាំងការចំណាយ និងការប្រមូលចំណូលដែលមិនមានភាពជាក់ស្តែង និងអនុវត្តដូចដែលបានអនុម័ត។ ការផ្ទេរពីកម្រិតខ្ពស់នៃរដ្ឋាភិបាល (HLG-1 "D") និងវិធានថវិកា និងការត្រួតពិនិត្យស្ថានភាពថវិកា (HLG-2 "C+")។ លទ្ធផលនៃការចំណាយបានបង្ហាញពីសមិទ្ធកម្មខ្សោយ (PI-1 "D" និង PI-2 "D+"); ចំណាយកកស្ទះនៅតែប្រឈមនឹងការខ្វះខាតនៃនិយមន័យត្រឹមត្រូវសម្រាប់ចំណាយកកស្ទះដែលស្របតាមស្តង់ដាអន្តរជាតិ កង្វះដំណើរការត្រួតពិនិត្យលើការចំណាយប្រកបដោយប្រសិទ្ធភាព (PI-22 "D*") និងកង្វះការត្រួតពិនិត្យនៅថ្នាក់ក្រោមជាតិ (PI-10 "D")។

២៣៦. លទ្ធផល នៃការអនុវត្តផែនការប្រមូលចំណូល (PI-3 "D") បង្ហាញថាលទ្ធផល និងការគ្រោងគឺមានគម្លាតដ៏ធំដែលត្រូវការពង្រឹងការព្យាករប្រាក់ចំណូល។ បញ្ហាជាមូលដ្ឋានមួយនៃប្រាក់ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ គឺការកំណត់ការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងសារពើភណ្ឌ ដោយសារកង្វះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ PPCA រៀបចំ និងត្រួតពិនិត្យថវិការបស់ខ្លួនដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចតែប៉ុណ្ណោះ។ ឯកសារថវិការួមមានការចាត់ថ្នាក់សេដ្ឋកិច្ច (PI-4 "D") និងគុណភាពនៃការអនុវត្ត និងរចនាសម្ព័ន្ធនៃកម្មវិធីត្រូវកែលម្អបន្ថែមទៀត ដោយសារការរៀបចំ BSP របស់ PPCA មិនបានរួមបញ្ចូលនូវផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំង ការតម្រឹមផែនការរបស់ PPCA និងមន្ទីរជំនាញ។ BSP របស់ PPCA ក៏កំណត់យ៉ាងច្បាស់នូវលទ្ធផល និងលទ្ធផល ដែលរំពឹងទុក (PI-8 "D")។

## យុទ្ធសាស្ត្រវិភាជន៍ធនធាន

២៣៧. ចំណុចខ្វះខាតនៅតែកើតមានជាមួយនឹងកង្វះភាពគ្រប់ជ្រុងជ្រោយឯកសារថវិកា និងការធ្វើចំណាត់ថ្នាក់ (PI-5 "D" និង PI-4 "D") និងកង្វះព័ត៌មានដែលអាចទុកចិត្តបាន និងទាន់ពេលវេលាដែលបានផ្តល់ជូនលើការផ្ទេរទៅ PPCA, ខណ្ឌ និង សង្កាត់ដែលរៀបចំថវិកាផ្ទាល់ខ្លួន (PI-7 "C")។ តម្លាភាពចំពោះសាធារណជនមានកម្រិតដោយសារកង្វះការផ្សព្វផ្សាយព័ត៌មានថវិកា (PI-9 "D") និងការចូលរួមជាសាធារណៈនៅក្នុងវដ្តថវិកា (PI-9bis "D+")។

២៣៨. ពេលវេលាសម្រាប់ការរៀបចំ BSP គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ PPCA ដើម្បីមានពេលវេលាគ្រប់គ្រាន់ ក្នុងការបង្រួបបង្រួម និងធ្វើឱ្យវាស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ផែនការអភិវឌ្ឍ ៥ ឆ្នាំ, PIP, និង BSP របស់មន្ទីរជំនាញ។ លើសពីនេះទៀត គុណភាពនៃ BSP រួមទាំងរចនាសម្ព័ន្ធកម្មវិធី និង KPIs សម្រាប់លទ្ធផល ក្នុងឆ្នាំ និងលទ្ធផលចុងក្រោយគឺនៅតែជាចំណុចខ្សោយ ដោយសារតែការមិនត្រូវបានកំណត់ច្បាស់លាស់ និងផ្តល់គុណភាពល្អសម្រាប់ការវាស់វែងសមិទ្ធកម្ម (PI-14 'D")។

២៣៩. PPCC ពិនិត្យជាចម្បងលើព័ត៌មានលម្អិតនៃចំណូល និងការចំណាយរួមបញ្ចូលក្នុងសំណើថវិកា ប៉ុន្តែខ្វះគោលការណ៍ពិភាក្សា និងចំណាយថវិការយៈពេលមធ្យម (PI-18 "D+" និង PI-31 "NA")។

## ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានសម្រាប់ផ្តល់សេវា

២៤០. កម្រិតមធ្យមនៃការព្យាករនៅក្នុងមូលនិធិដែលមានសម្រាប់ PPCA កំឡុងពេលអនុវត្តថវិកា (PI-21.2 "B") និងដល់ខណ្ឌ (PI-7.2 "C") គាំទ្រការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មសម្រាប់ការផ្តល់សេវាត្រូវតែត្រូវបានបង្កើតឡើងសម្រាប់ PPCA (PI-8 "D") និងភ្ជាប់ជាមួយការអនុវត្តជាមូលដ្ឋាននៃការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ (PI-12 "C+")។ PPCC ពិនិត្យលើការចំណាយថវិការយៈពេលមធ្យម

(PI-14 “D”) ដែលប្រឈមមុខនឹងបញ្ហាដោយសាររយៈពេលខ្លីបំផុតដែលត្រូវបានអនុញ្ញាតក្នុងការអនុវត្តសម្រាប់ដំណើរការនេះ និងជំនួយបច្ចេកទេសដើម្បីធានាឱ្យមានយន្តការត្រួតពិនិត្យ និងសមតុល្យ។

២៤១. តម្លៃនៃកិច្ចសន្យាទាំងអស់ដែលទទួលបានតាមរយៈវិធីសាស្ត្រប្រកួតប្រជែងក្នុងឆ្នាំហិរញ្ញវត្ថុ ដែលបានបញ្ចប់ចុងក្រោយមានចំនួនតិចជាង ១០% នៃតម្លៃសរុបកិច្ចសន្យាទាំងអស់ ដែលមានន័យថាភាគច្រើននៃលទ្ធកម្មត្រូវបានធ្វើឡើងដោយប្រើវិធីសាស្ត្រមិនប្រកួតប្រជែងប្រហែល ៩០% (PI-24 “D+”)។ គួបផ្សំនឹងចំណាយកកស្ទះ (PI-22 “D*”) ទំនងជាមិនបង្កើតតម្លៃល្អសម្រាប់លុយ (Value for money) លើការចំណាយជាតិទេ។

២៤២. កង្វះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (PI-23.4 “D”, PI-25.2 “C” និង PI-25.3 “C” និង PI-26 “D”) ទោះបីជាមានការត្រួតពិនិត្យទាន់ពេលវេលា និងពិនិត្យដោយស្ថាប័ននីតិប្បញ្ញត្តិក៏ដោយ (PI-31, វាយតម្លៃ ‘NA“) និងតម្លាភាពសាធារណៈ (PI-9 ‘D“) គឺនៅមានកម្រិត ដែលមិនទាន់អាចឆ្លុះបញ្ចាំងនូវប្រសិទ្ធភាពនៅមានកម្រិតក្នុងការប្រើប្រាស់ធនធានសាធារណៈ។ ដ្យាក្រាមទី16 ខាងក្រោមបង្ហាញអំពីពិន្ទុនៃការវាយតម្លៃទៅតាមសមាសធាតុ និងសូចនាករនីមួយៗ។

ដ្យាក្រាមទី 16÷ សង្ខេបពិន្ទុនៃប្រព័ន្ធ *PFM* នៃរដ្ឋបាលរាជធានីភ្នំពេញ




ប្រភព÷ អ.គ.ហ.

២៤៣. ផ្អែកតាមលទ្ធផលនៃការវាយតម្លៃខាងលើ បានបង្ហាញថាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ PPCA ដែលនៅតែស្ថិតក្នុងដំណាក់កាលដំបូង នៃការអភិវឌ្ឍ ត្រូវការពេលវេលាបន្ថែមទៀតដើម្បីកែលម្អ។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍នេះគឺPPCA ពឹងផ្អែកលើចំណូលប្រភពផ្ទាល់ខ្លួន និងការចែករំលែកចំណូលពន្ធ និងការរៀបចំថវិកាប្រចាំឆ្នាំស្របតាមប្រតិទិនផ្ញើជូន កសហវ. ទាន់ពេលវេលា និងភ្ជាប់ជាមួយធាតុសំខាន់ៗភាគច្រើន។

២៤៤. ទោះជាយ៉ាងនេះក្តី ចំណុចខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ PPCA ត្រូវបានឆ្លុះបញ្ចាំងតាមរយៈកិច្ចការមួយចំនួន ជាអាទិ៍÷ (១) កង្វះខាតការសម្របសម្រួលសម្រាប់ការរៀបចំថវិកា (២) យន្តការត្រួតពិនិត្យ និងតុល្យភាពមានកម្រិតរវាងគណៈអភិបាល និងក្រុមប្រឹក្សារាជធានី។ ក្រុមប្រឹក្សារាជធានី កង្វះការគាំទ្រផ្នែកបច្ចេកទេសដើម្បីពិនិត្យ និងវាយតម្លៃលើការចំណាយថវិការយៈពេលមធ្យម ផែនការថវិកាប្រចាំឆ្នាំ និងការអនុវត្តព្រមទាំងរបាយការណ៍សវនកម្ម (៣) កង្វះតម្លាភាព ដោយសារកង្វះការផ្សព្វផ្សាយឯកសារថវិកាដល់សាធារណជន

និងការចូលរួមជាសាធារណៈក្នុងវដ្តថវិកា។ បញ្ហានេះអាចប៉ះពាល់មិនត្រឹមតែសាធារណជនទូទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការរៀបចំផ្ទៃក្នុងរបស់រដ្ឋបាលរាជធានីភ្នំពេញ ដើម្បីធានាថាសកម្មភាព និងប្រតិបត្តិការរបស់រដ្ឋាភិបាលដែលកំពុងប្រព្រឹត្តទៅ ក្នុងក្របខ័ណ្ឌគោលនយោបាយសារពើពន្ធ របស់រដ្ឋាភិបាល ហើយជាកម្មវត្ថុនៃការគ្រប់គ្រងថវិកា និងការរៀបចំរបាយការណ៍ឱ្យបានគ្រប់គ្រាន់។ (៤) កង្វះការប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មសាធារណៈ ប្រកួត-ប្រជែងជាសាធារណៈ។ វិធីសាស្ត្រប្រកួតប្រជែងនេះគឺដើម្បីធានាបាននូវតម្លៃនៃលុយ (value for money), សន្សំសំចៃ និងគណនេយ្យភាព។ (៥) កង្វះយន្តការតាមដាន និងវាយតម្លៃ និងការចាត់ចែងផ្ទៃក្នុងដើម្បីធានាថា ផែនការផ្តល់សេវាសាធារណៈ ត្រូវបានកំណត់ដោយកម្មវិធី និងដំណើរការមួយជំហានទៅមុខ។ (៦) កង្វះជំនាញហិរញ្ញវត្ថុក្នុងការផ្តល់ជំនួយបច្ចេកទេសឱ្យត្រូវនឹងល្បឿននៃការទម្រង់។ (៧) កង្វះខាតគុណភាព BSP និង PB តាមកម្មវិធីអនុកម្មវិធី លទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅ និង (៨) ការប៉ាន់ប្រមាណការអនុវត្តថវិកាគឺនៅមានកម្រិត។

២៤៥. សរុបមក ការវាយតម្លៃ PEFA សម្រាប់ PPCA បង្ហាញថា មានតម្រូវការក្នុងការពង្រឹងការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុង PPCA ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឱ្យ PPCA រៀបចំផែនការប្រមូល និងប្រើប្រាស់ធនធានស្របតាមចំណាយថវិការយៈ-ពេលមធ្យម ក៏ដូចជាផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ។ ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានជាក់ស្តែងនៅមានកម្រិតនៅឡើយ, សមត្ថភាពសម្រាប់ការអនុវត្តក្របខ័ណ្ឌគតិយុត្តនៅមានកម្រិត ហើយការត្រួតពិនិត្យសមិទ្ធកម្មត្រូវបានពង្រឹងគួរឱ្យកត់សម្គាល់។ ចំណុចខ្វះខាតត្រូវបានផ្សារភ្ជាប់ ទៅនឹងភាពជឿទុកចិត្តនៃថវិកា ដែលនៅមានកម្រិតទាបផងដែរ ដែលជាឧបករណ៍មួយដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយកម្រិតខ្ពស់។ ដ្យាក្រាមទី17 ខាងក្រោម បង្ហាញអំពីកិច្ចការដែលត្រូវបន្តពង្រឹង។

ដ្យាក្រាមទី 17 ÷ ការងារគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា




ប្រភព÷ អ.គ.ហ.

## ៣. បញ្ហាប្រឈម និងវិធានការដោះស្រាយ

២៤៦. តាមរយៈការបូកសរុបរបាយការណ៍វឌ្ឍនភាព និងប្រមូលទិន្នន័យបន្ថែមតាមរយៈការចុះទៅរដ្ឋបាលខេត្តចំនួន ៥ និងក្រសួងចំនួន ៥ ព្រមទាំងការវិភាគទៅលើធាតុចូលរបស់ដៃគូអភិវឌ្ឍន៍ និងធាតុចូលពីការរៀបចំសិក្ខាសាលា និងដៃគូអភិវឌ្ឍន៍, អ.គ.ហ. ពិនិត្យឃើញថាមានបញ្ហាប្រឈមចំនួន ១៦ ចំណុច ដូចខាងក្រោម÷

| ល.រ | បញ្ហាប្រឈម | វិធានការដោះស្រាយ |
|---|---|---|
| *ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា* | | |
| ០១ | ការប្រមូលចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ មិនទាន់ អស់សក្តានុពល ដែលទាមទារឱ្យមានការត្រួតពិនិត្យ គ្រប់កិច្ចសន្យាជួលឡើងវិញ។ | - អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ រៀបចំជាផែនការសកម្មភាពលម្អិតសម្រាប់ត្រួតពិនិត្យ និងកែសម្រួលកិច្ចសន្យាជួលជាជំហានៗ<br>- ទន្ទឹមនេះ ស្នើក្រសួង ស្ថាប័នផ្តល់ការគាំទ្រលើការត្រួតពិនិត្យកិច្ចសន្យាជួល។ |
| ០២ | ការបង្កើតរដ្ឋទេយ្យបុរេប្រទានមិនឱ្យលើស ៣០% សម្រាប់គណនី និងអនុគណនី ដែលមានកញ្ចប់ថវិកា តូច(ឧទា. ២០ ឬ១០ លានរៀលចុះ) បានផ្តល់ជាបញ្ហា ប្រឈមចំពោះការអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសម្រាប់ឥណទានថវិកានៅសល់ក្រោយដករដ្ឋទេយ្យបុរេប្រទាន។ | អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានរតនាគារជាតិ ពន្លឿនការដោះ-ស្រាយឱ្យបានរួចរាល់ត្រឹមឆ្នាំ២០២៣ សំដៅសម្រួលដល់ការអនុវត្តថវិកាទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាល ថ្នាក់ក្រោមជាតិ។ |
| ០៣ | ការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារនៅមានវឌ្ឍនភាពយឺតនៅឡើយ។ គិតត្រឹមឆ្នាំ ២០២២ មានក្រសួង ស្ថាប័នចំនួន ២១ ប៉ុណ្ណោះ ដែលបានអនុវត្តការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ។ | - អគ្គនាយកដ្ឋានរតនាគារជាតិ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យពាក់ព័ន្ធនឹងការជំរុញការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ<br>- ទន្ទឹមនេះ ស្នើក្រសួង ស្ថាប័នដែលពុំទាន់បានអនុវត្ត ជំរុញការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ ត្រឹមឆ្នាំ២០២៣។ |
| ០៤ | ការរៀបចំគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ (FMM) នៅតាមក្រសួង ស្ថាប័ន នៅមានវឌ្ឍនភាពយឺតនៅឡើយ ដោយមានក្រសួងស្ថាប័នចំនួនតិចតួចប៉ុណ្ណោះ បានបញ្ចូលសកម្មភាពរៀបចំ FMM ទៅក្នុង MAP ឆ្នាំ២០២២ | ស្នើគ្រប់ក្រសួង ស្ថាប័ន ជំរុញការរៀបចំ FMM ត្រឹមឆ្នាំ២០២៣ ដើម្បីសម្រួលដល់ការអនុវត្តនីតិវិធីហិរញ្ញវត្ថុនៅផ្ទៃក្នុងក្រសួង ស្ថាប័ន។ |

| | | |
|---|---|---|
| | ហើយមានក្រសួង ស្ថាប័នចំនួនតិចតួច មានជាសេចក្តីព្រាង FMM។ | |
| ០៥ | ឧបករណ៍ Web-based ត្រូវបានប្រើប្រាស់សម្រាប់គ្រោងវិហូរសាច់ប្រាក់ (Cash flow)។ ប៉ុន្តែ ការអនុវត្ត ជាក់ស្តែង ក្រសួង ស្ថាប័នជាច្រើនមិនបានផ្តល់ការគ្រោង សាច់ប្រាក់តាមប្រព័ន្ធនេះទេ ឬក៏ទិន្នន័យមួយចំនួនមិនពេញលេញ។ ដូចនេះ ការព្យាករសាច់ប្រាក់ផ្អែកបឋមលើទិន្នន័យមុនៗ។ | ស្នើគ្រប់ក្រសួង ស្ថាប័ន គាំទ្រការប្រើប្រាស់ឧបករណ៍ Web-based ឱ្យបានពេញលេញ សម្រាប់ការគ្រោងវិហូរសាច់ប្រាក់ សំដៅកែលម្អការព្យាករវិហូរសាច់ប្រាក់នៅតាមត្រីមាសនីមួយៗ ប្រកបដោយប្រសិទ្ធភាព។ |
| ***ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ*** | | |
| ០៦ | ទម្រង់របាយការណ៍ដែលទាញចេញពីប្រព័ន្ធ FMIS មិនទាន់មានសង្គតិភាពជាមួយទម្រង់របាយការណ៍ដែលកំណត់ក្នុងសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា ដែលជាហេតុនាំឱ្យអង្គភាពអនុវត្ត ត្រូវធ្វើការងារស្ទួនសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុ មានន័យថាត្រូវទាញចេញពីប្រព័ន្ធផង និងបំពេញទិន្នន័យដោយដៃផង។ | ក្រុមការងារគ្រប់គ្រងគម្រោង FMIS រៀបចំទម្រង់របាយការណ៍ក្នុងប្រព័ន្ធ FMIS ឱ្យមានសង្គតិភាពជាមួយទម្រង់របាយការណ៍ក្នុងសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា។ |
| ០៧ | រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងអនុវត្តប្រព័ន្ធ NRMIS, ប្រព័ន្ធ FMIS និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាពច្រកចេញចូលតែមួយ។ ប្រព័ន្ធ NRMIS និងប្រព័ន្ធ FMIS នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធ្វើសន្ធានកម្មរួចរាល់ ប៉ុន្តែពុំទាន់ធ្វើសន្ធានកម្មជាមួយប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានរបស់អង្គភាពច្រកចេញចូលតែមួយនៅឡើយ ដែលផ្តល់ជាបន្ទុកការងារ ដល់អ្នកអនុវត្តប្រព័ន្ធ។ | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សហការជាមួយក្រសួងមហាផ្ទៃ ធ្វើសន្ធាន-កម្មរវាងប្រព័ន្ធ NRMIS និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាពច្រកចេញចូលតែមួយ។ |
| ០៨ | រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ត្រូវបានស្នើឱ្យកែសម្រួលគម្រោងថវិកាប្រចាំឆ្នាំ បើទោះបី ជាគម្រោងថវិកានេះ បានឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត និងកិច្ចប្រជុំចចារថវិកានៅកសហវ នាខែសីហារួចហើយក៏ដោយ។ ការកែសម្រួលនេះ អាចប៉ះពាល់ដល់ផែនការថវិកា និងផែនការលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិពង្រឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |

| | | |
|---|---|---|
| ០៩ | បញ្ហាប្រឈមនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរួមមាន÷<br>- ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមានវឌ្ឍនភាព ប៉ុន្តែប្រសិទ្ធភាពនិងគុណភាពនៅមានកម្រិត(ការរៀបចំពុំទាន់ពេលវេលា និងគ្រប់ចំនួន)<br>- ការធ្វើប័ណ្ណកម្មសិទ្ធិដីរដ្ឋមានភាពយឺតយ៉ាវ ដែលទាមទារឱ្យមានការជំរុញ គាំទ្រ និង ត្រួតពិនិត្យតាមដានជាប្រចាំ និងការចូលរួមពីអង្គភាពនៅគ្រប់កម្រិត<br>- យន្តការជម្រះបញ្ជីសារពើភណ្ឌនៅមានកម្រិត។ | - អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ជំរុញការរៀបចំបញ្ចប់ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រឹមឆ្នាំ ២០២៣។<br>- ជាមួយគ្នានេះ ស្នើក្រសួង ស្ថាប័ន សហការជំរុញការរៀបចំប័ណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ។ |
| ***ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*** | | |
| ១០ | ការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសគុណភាពនៃការរៀបចំ និងការអនុវត្តសូចនាករកម្មវិធី នៅមានកម្រិត ដែលឆ្លុះបញ្ចាំងតាមរយៈការអនុវត្តថវិកានៅតែផ្តោតសំខាន់លើមាតិកាសេដ្ឋកិច្ច។ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បន្តជំរុញ និងពង្រឹងការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ១១ | មុខងារ ៥៥ បានផ្ទេរទៅរដ្ឋបាលក្រុង ស្រុក ដែលរដ្ឋបាលក្រុង ស្រុក ទទួលបានថវិកាតិច និងមិនមានការផ្ទេរថវិកាទៅតាមមុខងារទាំង ៥៥។ ថវិកាមួយចំនួនត្រូវបានផ្ទេរទៅរដ្ឋបាល ក្រុង ស្រុក ប៉ុន្តែនីតិវិធីនៃការអនុវត្តថវិកា ពុំទាន់យល់ជាទស្សនាទានរួមគ្នានៅឡើយ។ ចំពោះទ្រព្យសម្បត្តិរដ្ឋរបស់ការិយាល័យក្រុង ស្រុក មានការយល់ខុសគ្នា ថាតើគួរផ្ទេរទៅរដ្ឋបាលក្រុងស្រុក ឬទុកជូនមន្ទីរជំនាញរាជធានី ខេត្ត។ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ វាយតម្លៃការផ្ទេរមុខងារ ៥៥ នេះ ក្នុងគោលដៅ សម្របសម្រួល និងធានាថាធនធានហិរញ្ញវត្ថុ, ធនធានមិនមែនហិរញ្ញវត្ថុ (រួមទាំងធនធានមនុស្ស) និងចំណូលដែលបាន ផ្ទេរទៅដល់អង្គភាពអនុវត្តផ្ទាល់ នឹងមានភាពសមស្របទៅនឹងមុខងារដែលបានប្រគល់ជូនរដ្ឋបាលក្រុង ស្រុង។ ជំរុញបញ្ចប់ការដោះស្រាយឱ្យបានរួចរាល់នៅក្នុងឆ្នាំ២០២៣ ដើម្បីចៀសវាងបច្ច័យលើការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ***ផ្នែកទី៤÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម*** | | |
| ១២ | ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម នឹងជួបប្រទះទៅបញ្ហាប្រឈម បើសិនក្រសួង ស្ថាប័ន ពុំទាន់ត្រៀមខ្លួនឱ្យបានរួចរាល់ ជាពិសេសយន្តការនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃថវិកាសមិទ្ធកម្ម ខណៈហិរញ្ញវត្ថុនឹងត្រូវវិមជ្ឈការកាន់តែច្រើនឡើងទៅក្រសួង ស្ថាប័ន។ | ស្នើក្រសួង ស្ថាប័ន ចាប់ផ្តើមរៀបចំយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃថវិកា សមិទ្ធកម្មនៅផ្ទៃក្នុងក្រសួង ស្ថាប័ន។ |

| | | |
|---|---|---|
| ១៣ | ក្រសួង ស្ថាប័នមួយចំនួនធំ ពុំទាន់គិតគូរចាប់ផ្ដើមសាកល្បងអនុវត្តសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ខណៈនិន្នាការនៃការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម តម្រូវឱ្យមានការពង្រឹងការធ្វើសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ | ស្នើក្រសួង ស្ថាប័ន ចាប់ផ្ដើមគិតគូរសាកល្បងធ្វើសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ |
| ១៤ | ការស្ទួនមុខងារសវកម្មផ្ទៃក្នុង និងអធិការកិច្ច នៅតែបន្តជាបញ្ហាប្រឈម។ អង្គភាព មួយអាចទទួលការត្រួតពិនិត្យ ៦ ដងក្នុងមួយឆ្នាំ ក្នុងនោះពីសមត្ថកិច្ចផ្ទៃក្នុងរបស់ ខ្លួន គឺអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង។ រីឯសមត្ថកិច្ចផ្ទៃក្រៅ រួមមាន÷ ក្រសួង ទំនាក់ទំនងសភា ព្រឹទ្ធសភា និងអធិការកិច្ច, អាជ្ញាធរសវនកម្មជាតិ, អគ្គាធិការដ្ឋាន កសហវ, និងសវនកម្មលទ្ធកម្ម កសហវ។ | - អគ្គាធិការដ្ឋាន និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បន្តជំរុញការរៀបចំក្របខ័ណ្ឌ និង វិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច។<br>- ក្នុងអន្តរកាលនេះ ស្នើក្រសួង ស្ថាប័ន បន្តសម្របសម្រួលការអនុវត្តសវនកម្មផ្ទៃក្នុង និងអធិការកិច្ចតាមស្មារតីអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ២០២០ ស្ដីពី ក្របខ័ណ្ឌមុខងារភារកិច្ចរបស់សនកម្មផ្ទៃក្នុង និងអធិការកិច្ច។ |
| *ផ្នែកទី៥÷ ការកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡានៃការកែទម្រង់* | | |
| ១៥ | ការបែងចែកប្រាក់រង្វាន់ពីចំណូលសេវាសាធារណៈនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានគោលការណ៍រួម (គោលការណ៍បែងចែកប្រាក់រង្វាន់ផ្ទៃក្នុងស្ថាប័ន, ឧទា. ការអនុវត្តប្រកាស ៦១៦ របស់ កសហវ.) ដែលពុំទាន់ធានាបាននូវប្រសិទ្ធភាពនៃការបែងចែក ក្នុងការលើកកម្ពស់ការផ្ដល់សេវា-សាធារណៈ។ | អ.គ.ហ. សិក្សាអំពីការរៀបចំបទដ្ឋានគតិយុត្តស្ដីពីគោលការណ៍រួមសម្រាប់ការបែងចែករង្វាន់លើកទឹកចិត្តទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសំដៅធានាសមធម៌ តម្លាភាព និងជាពិសេសការកសាងស្ថាប័ន និងលើកកម្ពស់ការផ្ដល់សេវាសាធារណៈ។ |
| ១៦ | ការរៀបចំផែនការ និងការរាយការណ៍របស់អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង ស្ថាប័ន ក្នុងក្របខ័ណ្ឌ PFMRP មានភាពប្រសើរឡើងជាលំដាប់។ ប៉ុន្តែពុំទាន់មានសង្គតិភាពពេញលេញទៅនឹងផែនការសកម្មភាពរួម (CAP) នៅឡើយ។ | អ.គ.ហ. គិតគូររៀបចំជាកិច្ចព្រមព្រៀងសមិទ្ធកម្មក្នុងក្របខ័ណ្ឌ PFMRP ដោយផ្សារភ្ជាប់ ជាមួយការផ្ដល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត។ |

២៤៧. បន្ថែមពីលើវិធានការដោះស្រាយបញ្ហាប្រឈមខាងលើ, គ.ហ.ស. បានដាក់ចេញនូវវិធានការបន្ថែមដូចខាងក្រោម÷

ទី១. **ស្នើក្រសួង ស្ថាប័ន**ប្រមូលចំណូលមិនមែនសារពើពន្ធ ដាក់បញ្ចូលការរៀបចំ និងកែសម្រួលប្រកាសអន្តរក្រសួងពាក់ព័ន្ធ ក្នុង MAP ឆ្នាំ២០២៣ បន្ទាប់ពីសេចក្ដីព្រាងអនុក្រឹត្យស្ដីពីគោលការណ៍ និងនីតិវិធីបន្ថែម

សម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកវិលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ចូលជាធរមាន។ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ប្រកាសអន្តរក្រសួងពាក់ព័ន្ធចំនួន ៨៧ របស់ក្រសួង ស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធ នឹងត្រូវពិនិត្យកែសម្រួល ខណៈត្រូវរៀបចំប្រកាសបន្ថែមប្រមាណជាង ២០ ប្រកាសអន្តរក្រសួង។

ទី២. **ស្នើក្រសួង ស្ថាប័ន** រួមមាន÷ ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេក-វិទ្យា និងនវានុវត្តន៍, ក្រសួងអប់រំ យុវជន និងកីឡា, និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, រៀបចំវេទិកាសាធារណៈអំពីកញ្ចប់ថវិកាប្រចាំឆ្នាំ និងរៀបចំសៀវភៅថវិកាពលរដ្ឋ ដោយពិនិត្យលទ្ធភាពយកគំរូតាមសៀវភៅថវិកាសង្ខេបដែលចេញដោយ កសហវ.។

ទី៣. **ក្រុមការងារគ្រប់គ្រងគម្រោង FMIS និងក្រសួងមុខងារសាធារណៈ** ជំរុញការធ្វើសន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិល ឱ្យបានពេញលេញ។ សម្រាប់ការធ្វើសន្ទានកម្មកន្លងមក ប្រព័ន្ធ FMIS ត្រូវបានធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងបៀវត្ស មន្ត្រីរាជការស៊ីវិល (ចាស់) ប៉ុន្តែនៅមិនទាន់ពេញលេញនៅឡើយ ខណៈបច្ចុប្បន្ន ក្រសួងមុខងារសាធារណៈ បានរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិលថ្មីមួយទៀត ដើម្បីបំពេញមុខងារដែលប្រព័ន្ធ ចាស់មិនមាន។

ទី៤. **អគ្គនាយកដ្ឋានគោលនយោបាយ** ជំរុញការរៀបចំស្តង់ដាតម្លៃ ដែលជាគន្លឹះជួយដល់ផ្នែកចរចាថវិកាការអនុវត្តកិច្ចលទ្ធកម្ម និងសវនកម្ម។ កិច្ចការនេះ ត្រូវបានសម្រេចក្នុងអង្គវិបស្សនារបស់ កសហវ. ប្រចាំឆ្នាំ២០២១ កាលពីថ្ងៃទី ២២ ខែមីនា ឆ្នាំ២០២២។

ទី៥. **អគ្គនាយកដ្ឋានថវិកា** បន្តបណ្តុះបណ្តាលនូវក្របខ័ណ្ឌអំពីការរៀបចំ និងក្របខ័ណ្ឌនៃការតាមដាន និងវាយតម្លៃការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ជូនក្រសួង ស្ថាប័ន ដោយការយល់ដឹងរបស់ក្រសួង ស្ថាប័ននៅមានកម្រិតនៅឡើយ។ អគ្គនាយកដ្ឋានថវិកា បាននិងកំពុងរៀបចំក្របខ័ណ្ឌនៃការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ទន្ទឹមគ្នានឹងការរៀបចំអក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ (ថ្មី)។ ក្នុងបរិ-ការណ៍នៃការឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ក្រសួង ស្ថាប័នគួរត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការរៀបចំ ការអនុវត្ត និងការតាមដាន ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម។

ទី៦. **ក្រុមការងារគ្រប់គ្រងគម្រោង FMIS** បន្តជំរុញការរៀបចំការអនុវត្ត FMIS តាមអនឡាញសម្រាប់ថ្នាក់-ដឹកនាំ ដើម្បីងាយស្រួលក្នុងការអនុម័តចំណាយនៅពេលមានបេសកកម្មនៅក្នុង និងក្រៅប្រទេស។ កិច្ចការនេះ នឹងជួយសម្រួលដល់ការអនុម័តចំណាយទាន់ពេលវេលា បើទោះជាថ្នាក់ដឹកនាំមានបេសកកម្មក៏ដោយ។

ទី៧. **អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និង អ.ត.ហ.** សិក្សាបញ្ចូលរដ្ឋបាលរាជធានី ខេត្ត ចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខណៈរដ្ឋបាលរាជធានី ខេត្តបាននិងកំពុងដើរតួនាទីសំខាន់ក្នុងការអនុវត្តវិធានការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បច្ចុប្បន្ន រដ្ឋបាលរាជធានី ខេត្តបាននិងកំពុងអនុវត្តវិធានការ ដែលមានចែងក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោម-ជាតិឆ្នាំ២០១៩-២០២៥។ ក្នុងន័យនេះ ការស្នើបញ្ចូលរដ្ឋបាល រាជធានី ខេត្តចូលរួមអនុវត្តកម្មវិធីកែទម្រង់

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងជួយជំរុញល្បឿននៃការកែទម្រង់ និងជាពិសេសតាមទាន់នូវសភាព-ការណ៍ទិសដៅជារួមនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទី៨. **អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ** ជំរុញការសិក្សាបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅតាមរដ្ឋបាលរាជធានី ខេត្ត ជាដំណាក់ៗ។ រដ្ឋបាលរាជធានី ខេត្ត ពុំទាន់មានអង្គភាពសវនកម្មផ្ទៃក្នុង ដែលជាយន្តការសម្រាប់ធានាប្រតិតុល្យការ រវាងក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈអភិបាលរាជធានី ខេត្ត។ តាមរយៈរបាយការណ៍ PEFA ថ្នាក់ក្រោមជាតិ បានបង្ហាញថារដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់មានសវនកម្មផ្ទៃក្នុងដែលជាយន្តការធានាប្រតិតុល្យការ នៅឡើយ។

ទី៩. **អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ** ពង្រឹងគុណភាពបញ្ជីសារពើភណ្ឌទ្រព្យ-សម្បត្តិរដ្ឋ ដែលកិច្ចការនេះ រួមចំណែកជួយដល់ផ្នែកចរចាថវិកាទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទី១០. រៀបចំផែនការលម្អិតសម្រាប់អនុវត្តវិធានការ ដែលសម្រេចដោយ គ.ហ.ស.។ ដើម្បីបន្តជំរុញការអនុវត្តវិធានការដែលបានដាក់ចេញដោយ គ.ហ.ស., អង្គភាព/ស្ថាប័នពាក់ព័ន្ធគួររៀបចំផែនការសកម្មភាពលម្អិតដើម្បីធានាថាវិធានាការទាំងនេះនឹងសម្រេចតាមគោលដៅ។

## ៤. សន្និដ្ឋាន

២៤៨. ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំ២០២២, សកម្មភាពជាច្រើនសម្រេចបានតាមគោលដៅ ខណៈសកម្មភាពមួយចំនួនកំពុងមានវឌ្ឍនភាព និងបន្តអនុវត្តក្នុងផែនការសកម្មភាពរួមចំណាក់កាលទី ៤ ហើយ សកម្មភាពគន្លឹះពាក់ព័ន្ធនឹងការបញ្ចប់ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ត្រូវបាននិងកំពុងឈានទៅ បញ្ចប់ជាបណ្ដើរៗ។ គុណភាពនៃការរៀបចំ GDAP/PDAP/MAP និងរបាយការណ៍ មានភាពប្រសើរជាងមុន ប៉ុន្តែការពង្រឹងសង្គតិភាពឱ្យបានពេញលេញទៅនឹងផែនការសកម្មភាពរួម ត្រូវបន្តយកចិត្តទុកដាក់។

២៤៩. ការវាយតម្លៃ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានផ្ដល់ជាបន្ទាត់មូលដ្ឋានអំពីស្ថានភាព នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា និងការពិនិត្យលើប្រសិទ្ធភាពប្រព័ន្ធ និងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់ PER ដែលជាធាតុចូលសម្រាប់រៀបចំ ក្របខ័ណ្ឌផែនការសកម្មភាពរួម តាមរយៈ ការកំណត់ការងារអាទិភាព។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺចាំបាច់ត្រូវពង្រឹងជាប្រចាំ និងកសាង សមាសធាតុសំខាន់ៗបន្ថែមទៀត ដើម្បីឆ្លើយតបបានទៅនឹងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗដែលអាចកើតមាន ជាយថាហេតុ។

២៥០. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ តាមរយៈការធានានូវកំណើនសេដ្ឋកិច្ចដែលស្ថិតក្នុងនិន្នាការសុទិដ្ឋិនិយម និងប្រកបដោយបរិយាប័ន្ន និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈដល់ប្រជាជន ព្រមទាំងរួមចំណែកសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា។

២៥១. ភាពជឿទុកចិត្តនៃថវិកា នៅតែរក្សាបាននូវស្ថានភាពរឹងមាំ ដែលបានបន្តក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច ដែលស្ថិតក្នុងទស្សនវិស័យសុទិដ្ឋិនិយម ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ មានភាពធូរស្បើយ។ ប៉ុន្តែត្រូវធ្វើពិពិធកម្មចំណូលបន្ថែម និងពង្រឹងការកៀរគរចំណូលឱ្យអស់សក្តានុពល ទន្ទឹមនឹងត្រូវពង្រឹងប្រសិទ្ធភាព នៃការអនុវត្តចំណាយ ជាពិសេសរំហូរចំណាយតាមត្រីមាស។

២៥២. បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពហិរញ្ញវត្ថុ ត្រូវបានកសាង និងពង្រឹងបន្ថែម ដែលជាឆ្លុះបញ្ចាំងតាមរយៈការពង្រីកការដ្ឋាន និងពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ប្រព័ន្ធគណនេយ្យនឹងត្រូវពង្រឹងបន្ថែមទៀត តាមរយៈការអនុវត្តជាដំណាក់កាលនូវយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១។

២៥៣. ក្របខ័ណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្តទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបករណ៍សំខាន់ សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ប៉ុន្តែត្រូវបន្តយកចិត្ត-ទុកដាក់លើការបង្កើនអង្គភាពថវិកា និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ខណៈការឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម សិទ្ធិអំណាច និងថវិកានឹងត្រូវធ្វើវិមជ្ឈការ ទៅអង្គភាពអនុវត្តផ្ទាល់កាន់តែច្រើន។

២៥៤. បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពសមិទ្ធកម្ម ត្រូវបាននិងកំពុងរៀបចំបញ្ចប់ ដែលឆ្លុះបញ្ចាំងតាមរយៈ ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យ

សាធារណៈ ដែលរំពឹងថានៅត្រូវចូលជាធរមានក្នុងឆមាសទី១ ឆ្នាំ២០២៣។ ទន្ទឹមនេះ ត្រូវបន្តយកចិត្តទុកដាក់លើការពង្រឹងការអនុវត្តក្របខ័ណ្ឌតាមដាន និងវាយតម្លៃ និងការអនុវត្តសវនកម្មសមិទ្ធកម្ម និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅតាមក្រសួង ស្ថាប័ន។

២៥៥. ចលនការនៃការកែទម្រង់ត្រូវបានបន្តចីរភាព ដែលឆ្លុះបញ្ចាំងតាមរយៈការចូលរួមអនុវត្តអនុវត្តកម្មវិធីកែទម្រង់ពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។ ការស្នើឱ្យរដ្ឋបាលរាជធានី ខេត្ត ចូលរួមអនុវត្តកាងារកែទម្រង់ នឹងក្លាយជាចំណែកមួយក្នុងការជំរុញល្បឿនការងារកែទម្រង់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ ការងារកែទម្រង់ប្រទាក់ក្រឡា ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១។

២៥៦. ជារួម កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខឿនទី៣ និងដំណាក់កាលទី៣ ដែលមានរយៈពេល ៧ ឆ្នាំ (២០១៦-២០២២) សម្រេចបានជាសារវ័ន្ត តាមរយៈការកសាង និងកែលម្អប្រព័ន្ធ គតិយុត្ត យន្តការស្ថាប័ន និងធនធាន មនុស្ស ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់អនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង និងបញ្ជ្រាប "**វប្បធម៌សមិទ្ធកម្ម**" នៅក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល និងទូទាំងមន្ត្រីរាជការ។

២៥៧. ស្ថាប័នរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តថវិកាសមិទ្ធកម្ម ជាមួយនឹងការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មផ្សារភ្ជាប់នឹងគោលនយោបាយ(NSDP/BSP/PB) ដែលមានបច្ច័យដល់(១) ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច, (២) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង(៣) ការផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

២៥៨. ផ្អែកលើមូលដ្ឋាននេះ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ស្ថិតនៅលើវិថីកែទម្រង់ត្រឹមត្រូវ និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ដែលនឹងរួមចំណែកដល់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ រាជរដ្ឋាភិបាលអាចបោះជំហានទៅកាន់ខឿនទី៤ និងដំណាក់កាលទី៤"គណនេយ្យភាពសមិទ្ធកម្ម" ប្រកបដោយភាពជឿជាក់ ប្រាកដនិយម និង ប្រកាន់ខ្ជាប់នូវអភិក្រមឆ្លងស្ទឹងស្ទាបថ្ម ព្រមទាំងយន្តការ បុរេសកម្មសកម្ម និងអន្តរសកម្ម។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ ÷ វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. ប្រចាំឆ្នាំ២០២២

a. វឌ្ឍនភាពសម្រេចបាន

| ល.រ. | ការសម្រេចរបស់ គ.ហ.ស. | វឌ្ឍនភាពសម្រេចបាន |
|---|---|---|
| ១ | ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | ត្រូវបានដាក់ឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២។ |
| ២ | របាយការណ៍ PEFA ថ្នាក់ក្រោមជាតិ ឆ្នាំ២០២១ | ទទួលបាន PEFA Check និងទទួលបានគោលការណ៍អនុម័តដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** កាលពីត្រីមាសទី៣ ឆ្នាំ២០២២។ |
| ៣ | ចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | បានទទួលការឯកភាព និងអនុម័តពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២។ គ្រោងផ្សព្វផ្សាយក្នុងខែកុម្ភៈ ឆ្នាំ២០២៣។ |
| ៤ | យុទ្ធសាស្រ្តស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ | បានទទួលគោលការណ៍ឯកភាពពីប្រមុខរាជរដ្ឋាភិបាល នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ និងបានផ្សព្វផ្សាយដាក់ឱ្យអនុវត្តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។ |
| ៥ | របាយការណ៍វាយតម្លៃលើបច្ច័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | បានបញ្ចប់ការរៀបចំរបាយការណ៍វាយតម្លៃ និងធ្វើបទបង្ហាញជូន គ.ក.ហ. នៅក្នុងត្រីមាសទី២ ឆ្នាំ២០២២។ បានផ្សព្វផ្សាយរបាយការណ៍នៅក្នុងខែមករា ឆ្នាំ២០២៣។ |
| ៦ | ឯកសារចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ | បានទទួលការឯកភាពពីប្រមុខរាជរដ្ឋាភិបាលនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ និងបានដាក់ឱ្យប្រើជាផ្លូវការនៅថ្ងៃទី ៧ ខែធ្នូ ឆ្នាំ២០២២។ |
| ៧ | របាយការណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ក្របខ័ណ្ឌ TADAT | បញ្ចប់ជាផ្លូវការនៅថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២២។ |
| ៨ | របាយការណ៍វាយតម្លៃការអនុវត្តក្របខ័ណ្ឌថវិកា (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) តាមរយៈការប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ: PER) | អ.គ.ហ. សម្របសម្រួលជាមួយធនាគារពិភពលោកបានបញ្ចប់ការវាយតម្លៃចំណាយសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលខេត្តព្រះសីហនុ។ បន្ថែមពីនេះ របាយការណ៍វាយតម្លៃចំណាយសាធារណៈរបស់ក្រសួងសុខាភិបាល, ក្រសួងធនធានទឹក និងឧតុនិយម គ្រោងនឹងបញ្ចប់នៅត្រីមាសទី២ ឆ្នាំ២០២៣។ |

| | | |
|---|---|---|
| ៩ | បច្ចុប្បន្នភាព គ.ហ.ស., គ.ក.ហ.និង ក.ហ.ស. ក្នុងក្របខ័ណ្ឌ PFMRP | ទទួលបានការអនុម័តដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ និងប្រមុខរាជរដ្ឋាភិបាល។ |
| ១០ | ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ | បន្តរៀបចំសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២២-២០២៨។ |
| ១១ | ការជំរុញ និងត្រួតពិនិត្យការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ តាមរយៈយន្តការ MAP4 | ជាវឌ្ឍនភាព, មាន ២១ក្រសួង ស្ថាប័ន (ក្នុងនោះមាន ៥ អនុវត្តមិនទាន់ពេញលេញ) បានអនុវត្តការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ។ បន្ថែមពីនេះ អ.គ.ហ. បានជំរុញ និងរៀបចំលិខិតជូនដំណឹងទៅគ្រប់ក្រសួង ស្ថាប័ន ឱ្យរៀបចំសកម្មភាពកែទម្រង់ពាក់ព័ន្ធការបើកប្រាក់បេសកម្មតាមប្រព័ន្ធធនាគារ នៅក្នុង MAP4 ឆ្នាំ២០២៣។ |
| ១២ | ការពិនិត្យលើការផ្ទេរមុខងារចំនួន ៥៥ ទៅរដ្ឋបាលក្រុង ស្រុក និងថវិកាឱ្យស្របតាមមុខងារទាំង ៥៥ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បានប្រជុំពិភាក្សាជាមួយក្រសួងមហាផ្ទៃ និង គជអប និងក្រសួងស្ថាប័នពាក់ព័ន្ធ លើមុខងារ ទំហំថវិកា និងចំនួនមន្ត្រីអនុវត្តមុខងារ និងត្រៀមប្រជុំជាមួយអគ្គនាយកដ្ឋានថវិកា ដើម្បីធ្វើការវិភាគមុខងារ ដែលបានផ្ទេរ និងតម្រូវការថវិកា។ កិច្ចការនេះ នឹងបន្តដោះស្រាយទាំងការផ្ទេរធនធានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។ |
| ១៣ | ការជំរុញការអនុវត្ត SARMIS ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បានរៀបចំវគ្គបណ្តុះបណ្តាលជូនអ្នកប្រើប្រាស់ជាច្រើនលើក។ យន្តការគ្រូបង្គោលប្រព័ន្ធ SARMIS ដែលជាមន្ត្រីនៃ មន្ទីរសហវ ត្រូវបានរៀបចំបណ្តុះបណ្តាល ដើម្បីត្រៀមការដាក់ឱ្យអនុវត្តជាផ្លូវការនៅកម្រិតរដ្ឋបាលរាជធានីខេត្ត។ |
| ១៤ | ការជំរុញការរៀបចំប័ណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ | ផែនការសកម្មភាពនៃយន្តការអន្តរក្រសួងត្រូវបានរៀបចំ និងបាននិងកំពុងចុះទៅខេត្តគោលដៅទាំង ២៥ រាជធានី ខេត្ត ដែលគ្រោងបញ្ចប់នៅខែធ្នូ ឆ្នាំ២០២២ ពិនិត្យស្ថានភាពដីរដ្ឋ |

| | | |
|---|---|---|
| | | ដើម្បីប្រមូលផ្តុំទិន្នន័យ ៣ ប្រភេទ÷ (១)ដីទំនាស់ (២)ដីកំពុងស្ថិតក្នុងនីតិវិធី និង (៣)ដីដែលពុំទាន់ចាប់ផ្តើមនីតិវិធី។ |
| ១៥ | ការជំរុញក្រសួង ស្ថាប័នអាទិភាពចំនួន ០៥-០៧ រៀបចំ FMM | ក្រសួង ស្ថាប័នចំនួន ១៣ (MEF, MOEYS, MOWRAM, MCS, MORP, MOJ, MOE, MOSVY, MLVT,MOC, MAFF, MLMUPC, និង MOH) បានរៀបចំបញ្ចូលសកម្មភាព "រៀបចំ FMM" នៅក្នុងផែនការសកម្មភាពកែទម្រង់របស់ខ្លួននៅក្នុងឆ្នាំ២០២២ នេះ (MAP3 2022)។ បច្ចុប្បន្ន ក្រសួងចំនួន ៣ (MEF, MOEYS, និង MOSVY) បានរៀបចំចេញជាសេចក្តីព្រាងរួចរាល់។ |
| ១៦ | ការបង្កើតក្រុមការងារអន្តរអគ្គនាយកដ្ឋាន នៃ កសហវ. សិក្សា និងវាយតម្លៃអំពីមុខងាររបស់មន្ទីរ សហវ. និង លិខិតបទដ្ឋានគតិយុត្ត តាមរយៈសេចក្តីសម្រេចលេខ ១២០ សហវ. ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២២។ | ជំហានបន្ត ក្រុមការងារនេះ នឹងចុះសិក្សា និងវាយតម្លៃមុខងារមន្ទីរមុខងារភារកិច្ចរបស់មន្ទីរ សហវ. រាជធានី ខេត្ត ស្របតាមទិសដៅយុទ្ធសាស្ត្រកែទម្រង់ក្រោមPFMRP និង សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ |

## ៦. ផែនការសកម្មភាពសម្រាប់អនុវត្តការសម្រេចរបស់ គ.ហ.ស. ដែលបន្តតាមដាន

| ល.រ. | វិធានការ | អង្គភាពទទួលបន្ទុក | វឌ្ឍនភាពភាព | ក្របខ័ណ្ឌពេលវេលាសម្រាប់បញ្ចប់វិធានការនីមួយៗ (២០២៣) | | | |
|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
| ០១ | សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) | *GDB* | សេចក្តីព្រាងច្បាប់ ត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ និងបានផ្តល់យោបល់ឯកភាពដោយព្រឹទ្ធសភា កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣។ | | សេចក្តីព្រាងច្បាប់ ត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ។ | | |
| ០២ | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ | *GDSPNTR* | បានរៀបចំជាទម្រង់ និងខ្លឹមសាររួចរាល់ ដោយរង់ចាំយុទ្ធសាស្ត្រកែទម្រង់សហគ្រាសសាធារណៈ។ | សេចក្តីព្រាងបឋមដាក់ឆ្លងកម្រិតក្រុមការងារ កសហវ. និងថ្នាក់ដឹកនាំ កសហវ.។ | រៀបចំសិក្ខាសាលាប្រមូលធាតុចូលពីអន្តរអគ្គនាយកដ្ឋាននៃកសហវ និងដាក់ឆ្លងថ្នាក់ដឹកនាំ កសហវ.។ សេចក្តីព្រាងបឋមផ្លូវការដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សេចក្តីព្រាងផ្លូវការ ដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី | សេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសសាធារណៈ ត្រូវបានដាក់ឆ្លងអង្គនីតិប្បញ្ញត្តិ។ |
| ០៣ | ការកែសម្រួលអនុក្រឹត្យលេខ ៨១ និងអនុក្រឹត្យលេខ៨២ | *GDB & GDNT* | សេចក្តីព្រាងអនុក្រឹត្យលេខ ៨១+៨២ ត្រូវបានបញ្ចូលគ្នា និងកំណត់ឈ្មោះថ្មី “ការគ្រប់គ្រង | | អនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ ត្រូវបានអនុម័ត។ | | |

| ល.រ. | វិធានការ | អង្គភាពទទួលបន្ទុក | ទិន្នផលភាពគោល | ក្របខ័ណ្ឌពេលវេលាសម្រាប់បញ្ចប់វិធានការនីមួយៗ (២០២៣) | | | |
|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
| | | | ថវិកា និងគណនេយ្យសាធារណៈ"។ | | | | |
| ០៤ | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងល័ក្ខខ័ណ្ឌនៃការផ្ទេរ មុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | *GSC & GDSPNR & GDB & GDNT & GDSNAF & LCs* | ក្រុមការងារទទួលបន្ទុកបាននិងកំពុងកែសម្រួលសេចក្ដីព្រាងអនុក្រឹត្យចុងក្រោយតាមចំណារដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យដើម្បីបន្តនីតិវិធីគោរពជូនប្រមុខរាជរដ្ឋាភិបាលអនុម័តដ៏ខ្ពង់ខ្ពស់។ | ដាក់ឆ្លងថ្នាក់ដឹកនាំ កសហវ.។ | ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត។ | | |
| ០៥ | គោលការណ៍ណែនាំរួមស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល(PFMM) | GSC | មានជាសេចក្ដីព្រាងគោលការណ៍ណែនាំរួម | ធ្វើបច្ចុប្បន្នកម្មសេចក្ដីព្រាង PFMM | សិក្ខាសាលាពិគ្រោះយោបល់ | កែសម្រួលសេចក្ដីព្រាងបន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់ | ដាក់សេចក្ដីព្រាងជូនថ្នាក់ដឹកនាំពិនិត្យផ្ដល់យោបល់ និងសម្រេច |
| ០៦ | ក្របខ័ណ្ឌរួមផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ | GSC | | មានរបកគំហើញបឋម | មានជាសេចក្ដីព្រាងក្របខ័ណ្ឌរួមផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ | -រៀបចំសិក្ខាសាលាពិគ្រោះយោបល់<br>-កែសម្រួលសេចក្ដីព្រាងបន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់ | ដាក់សេចក្ដីព្រាងជូនថ្នាក់ដឹកនាំពិនិត្យ ផ្ដល់យោបល់ និងសម្រេច |
| ០៧ | កម្មវិធីសិក្សាភ្ជាប់វិញ្ញាបនបត្រ (Certificate Program) ដោយផ្សារភ្ជាប់មុខតំណែងឱ្យបានគ្រប់ជ្រុងជ្រោយ | EFI | ឯកសារទស្សនាទានស្ដីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំពិគ្រោះយោបល់ជាមួយគ្រប់ | សេចក្ដីព្រាងអនុក្រឹត្យត្រូវបានពិគ្រោះយោបល់ និងរៀបចំកម្រិត វសហ | សេចក្ដីព្រាងអនុក្រឹត្យដាក់ឆ្លងកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាននៃកសហវ និងក្រសួងស្ថាប័ន និង | អនុក្រឹតត្រូវបាន បញ្ជូនទៅគណៈរដ្ឋមន្ត្រីដើម្បីអនុម័ត | |

| ល.រ. | វិធានការ | អង្គភាពទទួលបន្ទុក | វឌ្ឍនភាពភាព | ក្របខ័ណ្ឌពេលវេលាសម្រាប់បញ្ចប់វិធានការនីមួយៗ (២០២៣) | | | |
|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
| | | | ក្រសួងស្ថាប័ន និង អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃ កសហវ ដើម្បី រៀបចំជាអនុក្រឹត។ | | ដាក់ឆ្លងដាក់ឆ្លងថ្នាក់ ដឹកនាំ កសហវ. | | |
| ០៨ | ឯកសារគោលស្តីពីការគ្រប់-គ្រងទ្រព្យសម្បត្តិរដ្ឋ | *GDSPNTR* | បានរៀបចំផែនការ សកម្មភាពលម្អិត ដើម្បី ធ្វើការជាមួយអ្នកពាក់-ព័ន្ធ។ ក្រុមការងារចាប់-ផ្តើមប្រមូលធាតុចូលពី ក្រសួង ស្ថាប័ន សំខាន់ៗ ដើម្បីសរសេរឯកសារ។ | រៀបចំសេចក្តីព្រាង កម្រិតក្រុមការងារ អន្តរអគ្គនាយកដ្ឋាន កសហវ. | រៀបចំសេចក្តីព្រាង កម្រិតក្រុមការងារអន្តរ-អគ្គនាយកដ្ឋាន នៃកសហវ. | សេចក្តីព្រាងបឋមផ្លូវ ការដាក់ជូនថ្នាក់ដឹកនាំ កសហវ. | សេចក្តីព្រាងបឋមផ្លូវការ ដាក់ឆ្លងគណៈកម្មាធិការ គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ឯកសារគោល ត្រូវបានអនុម័ត និងដាក់ឱ្យ អនុវត្ត។ |
| ០៩ | ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធ គ្រប់គ្រងចំណូលមិនមែន សារពើពន្ធ | *GDSPNTR* | បានរៀបចំសិក្ខាសាលា ពិគ្រោះយោបល់រួចរាល់ នាខែ វិច្ឆិកា ឆ្នាំ ២០២២ ជាមួយក្រសួង ស្ថាប័ន សង្គមស៊ីវិល រួចរាល់។ ហើយគ្រោងនឹងដាក់ ឆ្លងគណៈកម្មាធិការ គោលនយោបាយសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុ នាត្រី-មាសទី ១ ឆ្នាំ២០២៣។ | ដាក់ឆ្លងគណៈកម្មាធិការ គោលនយោបាយសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុ នា ត្រីមាសទី ១ ឆ្នាំ ២០២៣។ | អនុម័ត និងផ្សព្វផ្សាយ អនុវត្ត។ | | |
| ១០ | សេចក្តីព្រាងផែនការរៀបចំ ក្របខ័ណ្ឌនិងវិធានស្តីពី | *GI & GDIA* | សេចក្តីព្រាងរបាយ-ការណ៍សិក្សាស្រាវជ្រាវ | សេចក្តីព្រាងរបាយ-ការណ៍របស់ ទីប្រឹក្សា | របាយការណ៍ទីប្រឹក្សា បារាំងត្រូវបានដាក់ | លទ្ធផលនៃកិច្ចប្រជុំ ក្រុមការងារអន្តរ- | សេចក្តីព្រាងផែនការរៀបចំ ក្របខ័ណ្ឌនិងវិធានស្តីពី |

| ល.រ. | វិធានការ | អង្គភាពទទួលបន្ទុក | វឌ្ឍនភាពភាព | គ្រប់ខណ្ឌពេលវេលាសម្រាប់បញ្ចប់វិធានការនីមួយៗ (២០២៣) | | | |
|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
| | សវនកម្មផ្ទៃក្នុងនិងអធិការ-កិច្ច | | របស់ ទីប្រឹក្សាបារាំង លើមុខងារភារកិច្ចរបស់ សវនកម្មផ្ទៃក្នុង និង អធិការកិច្ច | ត្រូវបានពិនិត្យ ពិភាក្សា ក្នុងក្របខ័ណ្ឌអគ្គាធិ-ការដ្ឋាន កសហវ. | ពិភាក្សាជាមួយក្រុម-ការងារអន្តរក្រសួង | ក្រសួងលើបាយ-ការណ៍ ត្រូវបាន សម្រេចដោយ ថ្នាក់ដឹកនាំ កសហវ. | សវនកម្មផ្ទៃក្នុងនិងអធិការ-កិច្ចត្រូវបានរៀបចំ |
| ១១ | មូលនិធិ PFMRP គ្រប់ជ្រុង-ជ្រោយ | *GSC* | បានរៀបចំសេចក្តីព្រាង អនុក្រឹត្យស្តីពីការបង្កើត មូលនិធិកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ។ | គោរពជូន ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ពិនិត្យនិងសម្រេច ដើម្បីបន្តនីតិវិធីគោរព ជូនប្រមុខរាជរដ្ឋាភិ-បាលដើម្បីអនុម័តនៅ ក្នុងខែមករា ឆ្នាំ ២០២៣។ | | | |
| ១២ | សន្ទានកម្មរវាង FMIS និង EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា | *FMWG & MoEYS* | ក្រុមការងារទាំងពីរបាន ប្រជុំពិភាក្សា និង ផ្តល់ នូវទិន្នន័យសំខាន់ៗ សម្រាប់បង្កើតប្រតិបត្តិ-ការក្នុងប្រព័ន្ធ FMIS និង ពន្យល់លម្អិតពីអត្ថ-ន័យនៃទិន្នន័យនីមួយៗ នៅក្នុង មុខងារការ ទិញ (PO) និង មុខងារ គណនីត្រូវសង (AP) ក៏ដូចជាការប្រើប្រាស់ មាតិកាថវិកាផងដែរ | ឯកសារលក្ខខណ្ឌ តម្រូវការសម្រាប់ អភិវឌ្ឍសន្ទានកម្មរវាង ប្រព័ន្ធទាំងពីរលើមុខ-ងារការទិញ (PO) ត្រូវ សិក្សា និង រៀបចំ រួចរាល់ | សន្ទានកម្មរវាងប្រព័ន្ធ ទាំងពីរ លើមុខងារការទិញ (PO) ត្រូវបានអភិវឌ្ឍ និង ធ្វើតេស្តរួចរាល់ | ការធ្វើសន្ទានកម្មរវាង ប្រព័ន្ធទាំងពីរលើមុខ ងារការទិញ (PO) ត្រូវ បានដាក់បញ្ចូលក្នុង មជ្ឈដ្ឋានប្រើប្រាស់ និងដាក់ឱ្យអនុវត្តជា ផ្លូវការ | សន្ទានកម្មរវាងប្រព័ន្ធទាំង ពីរលើមុខងារគណនីត្រូវសង (AP) ត្រូវបានចាប់ផ្តើមសិក្សា និងរៀបចំ ដើម្បីបន្តការអភិវឌ្ឍ |

| ល.រ. | វិធានការ | អង្គភាពទទួលបន្ទុក | វឌ្ឍនភាពភាព | ក្របខ័ណ្ឌពេលវេលាសម្រាប់បញ្ចប់វិធានការនីមួយៗ (២០២៣) | | | |
|---|---|---|---|---|---|---|---|
| | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
| | | | សម្រាប់ជាធាតុចូលក្នុងការអភិវឌ្ឍបន្ថែមលើប្រព័ន្ធ EFMS | | | | |
| ១៣ | ការដកស្រង់បទពិសោធន៍ និងការសិក្សាឧត្តមានុវត្តន៍អន្តរជាតិអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំក្របខ័ណ្ឌគតិយុត្តបន្ថែម និងយន្តការ នៃការ-គ្រប់គ្រងគ្រឹះស្ថាន។ | ក្រុមការងារបច្ចេក-ទេសកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាល (GDB) | | | | | របាយការណ៍លទ្ធផលនៃការ-សិក្សាស្រាវជ្រាវឯកសារណាក់ព័ន្ធនិងជំនួយពីជំនាញការបារាំងស្តីពីខណ្ឌគតិយុត្តបន្ថែម និងយន្តការ នៃការគ្រប់គ្រងគ្រឹះស្ថាន |
| ១៤ | ការរៀបចំឯកសារយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងសហ-គ្រាសសាធារណៈ | ក្រុមការងារបច្ចេកទេសកែទម្រង់សហគ្រាសសាធារណៈ (GDSNTR) | ប្រជុំពិនិត្យកែសម្រួលខ្លឹមសារ ដែលបានព្រាងរួចទាំងអស់ ដើម្បីឈានទៅរក សេចក្តីព្រាងបឋម។ | សេចក្តីព្រាងបឋម ដាក់ឆ្លងកម្រិតក្រុម-ការងារ កសហវ. | សេចក្តីព្រាងបឋម ផ្លូវការដាក់ជូន ថ្នាក់ដឹកនាំ កសហវ. | សេចក្តីព្រាងបឋមផ្លូវការដាក់ឆ្លងគណៈ-កម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | យុទ្ធសាស្ត្រស្តីពីការកែទម្រង់សហគ្រាសសាធារណៈត្រូវបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាល។ |
| ១៥ | របាយការណ៍សិក្សានិងវាយតម្លៃអំពីមុខងារភារកិច្ចរបស់មន្ទីរ សហវ. រាជធានី ខេត្តស្របតាមទិសដៅយុទ្ធសាស្ត្រកែទម្រង់ក្រោម PFMRP និងសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ | GSMEF | បានបង្កើតក្រុមការងារសិក្សានិងវាយតម្លៃអំពីមុខងារភារកិច្ចរបស់មន្ទីរ សហវ. និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ | រៀបចំផែនការសកម្មភាពដែលក្រុមការងារត្រូវអនុវត្តបន្ត។ | រៀបចំកិច្ចប្រជុំរវាងក្រុមការងារនិងអង្គភាពពាក់-ព័ន្ធដើម្បីផ្តល់ធាតុចូល។ | រៀបចំគោលការណ៍ពាក់ព័ន្ធជាមួយមន្ទីរ។ | |

# ឧបសម្ព័ន្ធទី២៖ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់អង្គភាពក្រោមឱវាទ កសហវ. ប្រចាំឆ្នាំ២០២២

## តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២២

| ល.រ | អង្គភាពក្រោមឱវាទ កសហវ. | ថវិកាឆ្នាំ២០២២ (គិតជាពាន់រៀល) | | | | #សកម្មភាព សម្រេចបាន | ពិន្ទុភាគរយ ប្រចាំឆ្នាំ២០២២ |
|---|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ឧបត្ថម្ភលើក-ទឹកចិត្ត PFM | ឧបត្ថម្ភលើកទឹក-ចិត្តក្រៅ PFM | ថវិកាសរុប | | |
| ១ | អគ្គនាយកដ្ឋានគោលនយោបាយ | 574,875 | 868,703 | - | 1,443,578 | 20/21 | 100% |
| ២ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 169,457 | - | - | 169,457 | 12/13 | 99% |
| ៣ | អគ្គនាយកដ្ឋានពន្ធដារ | 466,393 | - | - | 466,393 | 19/25 | 98% |
| ៤ | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | 546,369 | - | - | 546,369 | 10/13 | 90% |
| ៥ | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | 862,848 | - | - | 862,848 | 55/69 | 92% |
| ៦ | អគ្គនាយកដ្ឋានថវិកា | 397,694 | 748,364 | 257,291 | 1,403,349 | 52/56 | 96% |
| ៧ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | 476,005 | 575,438 | - | 1,051,443 | 39/49 | 93% |
| ៨ | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | - | 273,275 | - | 273,275 | 9/13 | 91% |
| ៩ | អគ្គនាយកដ្ឋានរតនាគារជាតិ | 581,667 | 465,713 | 664,580 | 1,711,960 | 37/37 | 100% |
| ១០ | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | 156,093 | 172,408 | - | 328,501 | 7/12 | 87% |
| ១១ | អគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 379,144 | 673,852 | 1,707,028 | 2,760,024 | 30/32 | 97% |
| ១២ | អគ្គាធិការដ្ឋាន | 109,192 | 239,639 | - | 348,831 | 11/14 | 97% |
| ១៣ | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | 284,655 | 478,264 | 114,609 | 877,528 | 14/16 | 98% |
| ១៤ | វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 192,797 | 311,828 | 259,523 | 764,148 | 14/17 | 98% |
| ១៥ | អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន | - | 83,990 | - | 83,990 | 5/8 | 98% |
| ១៦ | ក្រុមការងារ FMIS | 23,681,038 | 2,593,225 | - | 26,274,263 | 26/29 | 98% |
| ១៧ | លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម | 718,535 | 1,228,189 | - | 1,946,724 | 8/8 | 100% |
| ១៨ | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា | 152,058 | - | - | 152,058 | 1/1 | 100% |
| | **សរុបរួម** | **29,748,821** | **8,712,888** | **3,003,031** | **41,464,740** | **-** | **-** |

# ឧបសម្ព័ន្ធទី៣៖ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់មន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំឆ្នាំ២០២២

## តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត ប្រចាំឆ្នាំ២០២២

| ល.រ. | អង្គភាពក្រោមឱវាទ កសហវ. | ថវិកាឆ្នាំ២០២២ (គិតជាពាន់រៀល) | | | | # សកម្មភាព សម្រេចបាន | ពិន្ទុភាគរយ ប្រចាំឆ្នាំ២០២២ |
|---|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ឧបត្ថម្ភលើក-ទឹកចិត្ត PFM | ឧបត្ថម្ភលើកទឹក-ចិត្តក្រៅ PFM | ថវិកាសរុប | | |
| ១ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ | 22,480 | 21,774 | - | 44,254 | 7/7 | 100% |
| ២ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបាត់ដំបង | 11,513 | 21,774 | - | 33,287 | 6/7 | 96% |
| ៣ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ចាម | 22,883 | 21,774 | - | 44,657 | 7/7 | 100% |
| ៤ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង | 19,604 | 21,774 | - | 41,378 | 7/7 | 100% |
| ៥ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ស្ពឺ | 4,495 | 21,774 | - | 26,269 | 8/8 | 100% |
| ៦ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ធំ | 12,141 | 21,774 | - | 33,915 | 8/8 | 100% |
| ៧ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពត | 10,946 | 21,774 | - | 32,720 | 8/8 | 100% |
| ៨ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្ដាល | 21,260 | 21,774 | - | 43,034 | 7/8 | 93% |
| ៩ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង | 6,900 | 20,032 | - | 26,932 | 7/8 | 96% |
| ១០ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តក្រចេះ | 9,086 | 20,032 | - | 29,118 | 7/7 | 100% |
| ១១ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តមណ្ឌលគីរី | 6,459 | 20,032 | - | 26,491 | 8/8 | 100% |
| ១២ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ | - | 20,032 | - | 20,032 | 7/7 | 100% |
| ១៣ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រះវិហារ | 2,690 | 18,290 | - | 20,980 | 7/7 | 100% |
| ១៤ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រៃវែង | 17,948 | 20,032 | - | 37,980 | 8/8 | 100% |
| ១៥ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តពោធិ៍សាត់ | 7,199 | 20,032 | - | 27,231 | 7/7 | 100% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៦ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តរតនគិរី | 712 | 15,677 | - | 16,389 | 4/7 | 86% |
| ១៧ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តសៀមរាប | - | 20,032 | - | 20,032 | 6/8 | 96% |
| ១៨ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រះសីហនុ | 11,333 | 20,032 | - | 31,365 | 7/7 | 100% |
| ១៩ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តស្ទឹងត្រែង | - | 20,032 | - | 20,032 | 7/7 | 100% |
| ២០ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តស្វាយរៀង | 9,722 | 20,032 | - | 29,754 | 7/7 | 100% |
| ២១ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តតាកែវ | 19,000 | 20,032 | - | 39,032 | 7/7 | 100% |
| ២២ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តឧត្តរមានជ័យ | 9,960 | 20,032 | - | 29,992 | 7/7 | 99% |
| ២៣ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកែប | 7,180 | 20,032 | - | 27,212 | 7/7 | 100% |
| ២៤ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តប៉ៃលិន | 8,596 | 20,032 | - | 28,628 | 8/8 | 100% |
| ៥២.១. រៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព (PMAS) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | អ.គ.ហ | **សច ១១.** ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាពនៃកម្មវិធីកែទម្រង់ត្រូវបានអភិវឌ្ឍន៍ និងប្រើប្រាស់ | ការគ្រប់គ្រងសមិទ្ធកម្មត្រូវបានប្រមូលផ្តុំជាទម្រង់ Excel មានច្រើនដំណាក់កាល និងបង្ហាញព័ត៌មានសមិទ្ធកម្មពុំទាន់ពេលវេលា | កិច្ចដំណើរការ (Business Process) និងអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព(PMAS) | សិក្សាកិច្ចដំណើរប្រព័ន្ធ PMAS ដំណាក់កាលទី២ និងការអភិវឌ្ឍមុខងារក្នុងប្រព័ន្ធ សម្រាប់អង្គភាពក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | បានបញ្ចប់ការរចនា UI/UI Mobile App ប្រព័ន្ធ PMAS ដំណាក់កាលទី២ និងបានរៀបចំសៀវភៅផែនការអភិវឌ្ឍប្រព័ន្ធ PMAS ដំណាក់កាលទី២។ ប្រព័ន្ធ PMAS ដំណាក់កាលទី២ នឹងដាក់ឱ្យអនុវត្តនៅដើមឆ្នាំ ២០២៣។ | សេចក្តីប្រកាសដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព (PMAS) | |
| ៥២.២. រៀបចំ និងអនុវត្តយន្តការលើកទឹកចិត្តសម្រាប់មូលនិធិកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ | អ.គ.ហ ក្រសួង ស្ថាប័ន | **សច ១២.** រៀបចំគោលការណ៍ណែនាំការគ្រប់គ្រងផ្អែកលើលទ្ធផល | សេចក្តីព្រាងគោលការណ៍ណែនាំការគ្រប់គ្រងផ្អែកលើលទ្ធផល | សៀវភៅគោលការណ៍ណែនាំការគ្រប់គ្រងផ្អែកលើលទ្ធផល និងចំនួនវគ្គបណ្តុះបណ្តាល | N/A | -បានផ្សព្វផ្សាយចំនួន១លើក នៅថ្ងៃទី២០ កញ្ញា ២០២២ ជាមួយគ្រប់អង្គភាព និងបានលើកយកទៅបង្ហាញជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ចំនួន ១លើក នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២។<br>-បានដាក់ជូនគ្រប់អង្គភាពផ្តល់យោបល់ និងកំពុងកែសម្រួលចុងក្រោយ | សេចក្តីប្រកាសដាក់ឱ្យគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងផ្អែកលើលទ្ធផល | |
| | | **សច ១៣.** ភាពទាន់ពេលវេលានៃការស្នើសមាសភាព កហស ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ប្រចាំឆ្នាំ | សន្ទត ÷ គ្រប់ក្រសួង ស្ថាប័ន និងអង្គភាព កសហវ រៀបចំសំណើទាន់ពេលវេលា | យ៉ាងយូរ ៥ ថ្ងៃ បន្ទាប់ពីកាលកំណត់។ ការយឺតយ៉ាវក្នុងកំឡុងពេលនេះគឺត្រូវបានពិន្ទុពេញ | គ្រប់ក្រសួង ស្ថាប័នរៀបចំសមាសភាព កហស ទទួលបានប្រាក់ឧបត្ថម្ភលើក-ទឹកចិត្ត ប្រចាំឆ្នាំតាមកាលកំណត់របស់ អគហ | សេចក្តីសម្រេចទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តមុខងារកែទម្រង់ របស់ក្រសួង ស្ថាប័ន បានទទួលការអនុម័តពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** | សេចក្តីសម្រេចស្តីពីការទទួលស្គាល់ កហស ទទួលបានការលើកទឹកចិត្តសម្រាប់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | |

| គោលបំណង/ចង្កោមសកម្មភាព | អង្គភាពអនុវត្ត | សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលគោល (Baseline) | វិធីសាស្ត្រវាស់វែង (Measuring Method) | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ ២០២២ | វឌ្ឍនភាពសម្រេចបានក្នុងឆ្នាំ២០២២ | ភស្តុតាង/ឯកសារអំណះអំណាង | ពណ៌ |
|---|---|---|---|---|---|---|---|---|
| | | <u>**សច ១៤.**</u><br>ក្របខ័ណ្ឌលើកទឹកចិត្តផ្សារភ្ជាប់សមិទ្ធកម្មកម្មវិធីកែទម្រង់ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | មិនទាន់មានក្របខ័ណ្ឌផ្សេងទៀត ក្រៅពីប្រកាស លេខ ៣៥១ សហវ.ប្រក | ការទទួលស្គាល់អង្គភាពឬស្ថាប័នមានស្នាដៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធា-រណៈប្រចាំឆ្នាំ | រៀបចំនិងដាក់ឱ្យអនុវត្តក្របខ័ណ្ឌលើកទឹកចិត្តផ្សារភ្ជាប់សមិទ្ធកម្ម | បច្ចុប្បន្នការលើកទឹកចិត្តត្រូវបានធ្វើឡើងតាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភក្រោម PFMRP ប៉ុន្តែនៅមិនទាន់បានផ្សារភ្ជាប់ជាមួយសមិទ្ធកម្មពេញលេញនៅឡើយ។ | ប្រកាស/ សេចក្តីសម្រេចស្តីពីលក្ខណៈវិនិច្ឆ័យវាយតម្លៃទទួលស្គាល់ អង្គភាពឬស្ថាប័នមានស្នាដៃលើការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន | |
| **៥៣. ពង្រឹងភាពប្រទាក់ក្រឡាគ្នារវាងការដ្ឋាននៃកម្មវិធីកែទម្រង់ផ្សេងៗទៀត** | **គ.ជ.អ.ប[9]<br>អ.គ.ហ<br>គ.ក.រ[10]<br>គ.ក.ច.យ[11]<br>ក្រសួង ស្ថាប័ន** | <u>**សគ ៦.**</u><br>**ការបន្តកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពនៃកម្មវិធីកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល** | **បានរៀបចំកិច្ចប្រជុំផ្លាស់វេនយ៉ាងតិច ១ ដង/ត្រីមាស តាមសេ-ចក្តីសម្រេចអន្តរក្រសួងលេខ ០០៦** | **ចំនួនកិច្ចប្រជុំត្រូវបានរៀបចំ (យ៉ាងតិច ៤ ដង/ឆ្នាំ) និងលទ្ធផលសម្រេចបានជា % ធៀបនឹងផែនការសកម្មភាពប្រចាំឆ្នាំ** | **- កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំប្រចាំ<br>- កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំប្រចាំត្រីមាស និង យ៉ាងតិច ៩០% នៃផែនការសកម្មភាពត្រូវបានអនុវត្ត** | **-បានរៀបចំកិច្ចប្រជុំអន្តរកែទម្រង់ចំនួន ៦ លើក<br>-អ.គ.ហ. បានដឹកនាំកិច្ចប្រជុំសម្របសម្រួលយន្តការកែទម្រង់៣+១ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ និងមានរបាយការណ៍គោរពជូនថ្នាក់ដឹកនាំ។<br>-សិក្ខាសាលាពិគ្រោះយោបល់ចំនួន ១ លើក** | **របាយការណ៍ប្រជុំកម្មវិធីកែទម្រង់៣ បូក ១** | |
| | | <u>**សគ ៧.**</u><br>**ការកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល** | **ពុំទាន់មានគោលបំណងនិងយុទ្ធសាស្ត្ររួមនៃកម្មវិធីកែទម្រង់ ៣ បូក ១** | **ឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធ-សាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានទទួលការឯកភាព ពីប្រមុខរាជរដ្ឋាភិបាល ឬប្រធាន** | **សេចក្តីព្រាងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ ៣ បូក ១ ស្តីពីចក្ខុវិ-ស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ បូក ១** | **ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ និងអនុក្រឹត្យត្រូវបានទទួលការឯក-ភាពពីប្រមុខរាជរដ្ឋាភិបាលកាលពីថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២២ និងបានរៀបចំពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២។** | **- ឯកសារទស្សនាទានផ្លូវការ<br>- របាយការណ៍កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១** | |

[9] គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

[10] គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.រ)

[11] គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (គ.ក.ច.យ)

| គោលបំណង/ចង្កោមសកម្មភាព | អង្គភាពអនុវត្ត | សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលគោល (Baseline) | វិធីសាស្ត្រវាស់វែង (Measuring Method) | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ ២០២២ | វឌ្ឍនភាពសម្រេចបានក្នុងឆ្នាំ២០២២ | ភស្តុតាង/ឯកសារអំណះអំណាង | ពណ៌ |
|---|---|---|---|---|---|---|---|---|
| | | | | គណៈកម្មាធិការ ទាំងបួន | | | សេចក្តីព្រាងផែនការសកម្មភាពរួម | |
| | | **<u>សគ ៨.</u>**<br>**ចំនួនក្រសួង ស្ថាប័នបានរៀបចំការពិពណ៌នាមុខតំណែង ផ្អែកលើគោលការណ៍ណែនាំ** | **សេចក្តីព្រាងគោល-ការណ៍ណែនាំ ស្តីពីការពិពណ៌នាមុខតំណែង** | **- គោលការណ៍ណែនាំត្រូវបានដាក់ឱ្យអនុវត្តដោយបទដ្ឋានគតិយុត្ត**<br>**- ចំនួនក្រសួងស្ថាប័នដែលបានរៀបចំការពិពណ៌នាមុខតំណែងបានត្រឹមត្រូវស្របតាមគោលការណ៍ណែនាំ** | **ក្រសួង ស្ថាប័នចំនួន ១៥បានរៀបចំការពិពណ៌នាមុខតំណែងបានត្រឹមត្រូវ** | **សេក្តីព្រាងសេចក្តីណែនាំស្តីពីការរៀបចំការពិពណ៌នាមុខតំណែង និងបទដ្ឋានគតិយុត្តស្តីពីការដាក់ឱ្យអនុវត្តការពិពណ៌នាមុខតំណែង ត្រូវបានបញ្ចប់ការរៀបចំក្នុងកម្រិតបច្ចេកទេស។** | **- ឯកសារផ្លូវការនៃគោលការណ៍ណែនាំ និងផែនការសកម្មភាពស្តីពីការពិពណ៌នាមុខតំណែង**<br>**- របាយការណ៍វឌ្ឍនភាពនៃការរៀបចំពិពណ៌នាមុខតំណែងរបស់ក្រសួង ស្ថាប័ន** | |
| ៥៣.១. រៀបចំយន្តការសម្របសម្រួលអន្តរ-កម្មវិធីកែទម្រង់ក្នុងក្របខ័ណ្ឌអគ្គ/លេខាធិការដ្ឋានកែទម្រង់ ៣ បូក ១ | គ.ជ.អ.ប<br>អ.គ.ហ<br>គ.ក.រ<br>គ.ក.ច.យ | **<u>សច ១៥.</u>**<br>យន្តការសម្រប-សម្រួលអន្តរកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំបច្ចុប្បន្នភាព និងអនុវត្ត | សេចក្តីសម្រេចអន្តរក្រសួងលេខ ០០៦ ស្តីពី យន្តការសម្រប-សម្រួលអន្តរការដ្ឋានកែទម្រង់បី (ពុំបានបញ្ចូលកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌) | សេចក្តីសម្រេចអន្តរ-ក្រសួងលេខ ០០៦ ស្តីពីយន្តការសម្របសម្រួលអន្តរការដ្ឋានកែទម្រង់ ៣ បូក ១ ត្រូវបានកែសម្រួលនិងទទួលបានការឯកភាពដោយប្រធានស្ថាប័ន/ ប្រធានគណៈកម្មាធិការទាំង ៤ | យន្តការថ្មី ត្រូវបានអនុវត្ត និងកិច្ចប្រជុំត្រូវបានរៀបចំយ៉ាងតិច ១ដង/ឆ្នាំ | បានរៀបចំកិច្ចប្រជុំសម្របសម្រួលយន្តការកែទម្រង់៣+១ (១៦ កុម្ភៈ ២០២២) និងមានរបាយការណ៍គោរពជូនថ្នាក់ដឹកនាំ។ | លិខិតបទដ្ឋានគតិយុត្ត ឬសេចក្តីសម្រេចអន្តរ-ក្រសួង ឬសេចក្តី-សម្រេចរាជរដ្ឋាភិបាលភិបាល | |
| | | **<u>សច ១៦.</u>**<br>វិបស្សនា ឬកិច្ចសន្ទនារវាងថ្នាក់ដឹកនាំកម្មវិធីកែទម្រង់ ៣ បូក ១ | ពុំធ្លាប់មានការរៀបចំកម្រិតថ្នាក់ដឹកនាំកម្មវិធីនីមួយៗ | ចំនួនដង នៃការរៀបចំវិបស្សនា/ឆ្នាំ | យ៉ាងតិច ១ ដង ជារៀងរាល់ ២ ឆ្នាំម្តង គិតចាប់ពីឆ្នាំ ២០២២ | ឯកឧត្តមបណ្ឌិត **ហែល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) និងជាអគ្គ-លេខាធិការរងនៃ អ.គ.ហ. តំណាងឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ | របាយការណ៍វិបស្សនា ឬ កិច្ចសន្ទនា | |

| គោលបំណង/ចង្កោមសកម្មភាព | អង្គភាពអនុវត្ត | សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលគោល (Baseline) | វិធីសាស្ត្រវាស់វែង (Measuring Method) | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ ២០២២ | វឌ្ឍនភាពសម្រេចបានក្នុងឆ្នាំ២០២២ | ភស្តុតាង/ឯកសារអំណះអំណាង | ពណ៌ |
|---|---|---|---|---|---|---|---|---|
| | | ត្រូវបានរៀបចំជាប្រចាំ | | | | នៃ កសហវ. និងជាអគ្គលេខាធិការនៃ អ.គ.ហ. បានរៀបចំវិបស្សនាកម្មវិធីកែទម្រង់ ៣ បូក ១ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០២២ សហដឹកនាំវិបស្សនាជាមួយនឹង ឯកឧត្តម **ជិន ម៉ាលីន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ឯកឧត្តម **ចាន់ សុធា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ ការ-អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងឯកឧត្តម **ហួត ស៊ីនាដ** អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈនិងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | | |
| ៥៣.២. រៀបចំឯកសារទស្សនាទានស្តីពីយុទ្ធសាស្ត្រ និង ចក្ខុវិស័យ រួមនៃកម្មវិធីកែទម្រង់ ៣ បូក ១ របស់រដ្ឋាភិបាល | គ.ជ.អ.ប<br>អ.គ.ហ<br>គ.ក.រ<br>គ.ក.ច.យ | **<u>សច ១៧.</u>** ឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំ | ពុំទាន់មានឯកសារទស្សនាទាន | ឯកសារទស្សនាទាន ត្រូវបានទទួលការឯកភាពពីប្រមុខរាជរដ្ឋាភិបាល ឬ ប្រធានគណៈកម្មាធិការទាំង ៤ | សេចក្តីព្រាងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ ៣ បូក ១ ស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ បូក ១ | ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រនិងអនុក្រឹត្យត្រូវបានទទួលការឯក-ភាពពីប្រមុខរាជរដ្ឋាភិបាលកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ និងបានរៀបចំពិធីប្រកាសដាក់ឱ្យប្រើជាផ្លូវការនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ | - ឯកសារទស្សនាទានផ្លូវការ<br>- របាយការណ៍កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣បូក១<br>- សេចក្តីព្រាងផែនការសកម្មភាពរួម | |

| គោលបំណង/ចង្កោមសកម្មភាព | អង្គភាពអនុវត្ត | សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលគោល (Baseline) | វិធីសាស្ត្រវាស់វែង (Measuring Method) | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ ២០២២ | វឌ្ឍនភាពសម្រេចបានក្នុងឆ្នាំ២០២២ | ភស្តុតាង/ឯកសារអំណះអំណាង | ពណ៌ |
|---|---|---|---|---|---|---|---|---|
| ៥៣.៣. គ្រប់គ្រងធនធានមនុស្សឆ្លើយតបនឹងតម្រូវការការងារកែទម្រង់ និងទិសដៅរបស់អង្គភាព និងស្ថាប័ន | ក្រសួងមុខងារសាធារណៈ: ក្រសួង ស្ថាប័ន | **<u>សច ១៨.</u>** ចំនួនក្រសួង ស្ថាប័នបានរៀបចំការពិពណ៌នាមុខតំណែងផ្អែកលើគោលការណ៍ណែនាំ | សេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការពិពណ៌នាមុខ-តំណែង | - គោលការណ៍ណែនាំត្រូវបានដាក់ឱ្យអនុវត្តដោយបទដ្ឋានគតិយុត្ត<br>- ចំនួនក្រសួង ស្ថាប័នដែលបានរៀបចំការពិពណ៌នាមុខតំណែងបានត្រឹមត្រូវស្របតាមគោលការណ៍ណែនាំ | ក្រសួង ស្ថាប័នចំនួន ១៥បានរៀបចំការពិពណ៌នាមុខតំណែង | សេក្តីព្រាងសេចក្តីណែនាំស្តីពីការរៀបចំការពិពណ៌នាមុខតំណែង និងបទដ្ឋានគតិយុត្តស្តីពីការដាក់ឱ្យអនុវត្តការពិពណ៌នាមុខតំណែង ត្រូវបានបញ្ចប់ការរៀបចំក្នុងកម្រិតបច្ចេកទេស។ | - ឯកសារផ្លូវការនៃគោលការណ៍ណែនាំ និងផែនការសកម្មភាពស្តីពីការពិពណ៌នាមុខតំណែង<br>- របាយការណ៍វឌ្ឍនភាពនៃការរៀបចំពិពណ៌នាមុខតំណែងរបស់ក្រសួង ស្ថាប័ន | |

**<u>សម្គាល់÷</u>**

| | | | |
|---|---|---|---|
| CAP | ផែនការសកម្មភាពរួម | អ.រ.ជ | អគ្គនាយកដ្ឋានរតនាគារជាតិ |
| GDAP | ផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អ.ស.ជ | អជ្ញាធរសវនកម្មជាតិ |
| MAP | ផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន | អ.គ.ហ | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| សគ | សូចនាករគោលបំណង | គ.ជ.អ.ប | គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| សច | សូចនាករចង្កោមសកម្មភាព | គ.ក.រ | គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ |
| សស | សូចនាករសកម្មភាព | គ.ក.ច.យ | គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ |
| ក.ស.ហ.វ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| អ.ព.ដ | អគ្គនាយកដ្ឋានពន្ធដារ | MWRAM | ក្រសួងធនធានទឹក និង ឧតុនិយម |
| អ.គ.រ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| FMWG | ក្រុមការងារគ្រប់គ្រងគម្រោងព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| ន.គ.ស | និយ័តករគណនេយ្យនិងសវនកម្ម | PFMM | គោលការណ៍ណែនាំហិរញ្ញវត្ថុសាធារណៈ |
| ក.ន | ក្រុមប្រឹក្សានីតិកម្ម | ASYCUDA | ប្រព័ន្ធស្វ័យប្រវត្តកម្មទិន្នន័យគយ (អាស៊ីគូដា) |
| អ.ថ | អគ្គនាយកដ្ឋានថវិកា | DMFAS | ប្រព័ន្ធវិភាគហិរញ្ញវត្ថុ និងគ្រប់គ្រងបំណុល |
| អ.ហ.ក | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | NRMIS | ប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលមិនមែនសារពើពន្ធ |
| អ.ល.សា | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | SARMIS | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ |
| អ.ទ.ច | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | EFMS | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |

| | | | |
|---|---|---|---|
| អ.គ.ស | អគ្គនាយកដ្ឋានគោលនយោបាយ | IPSAS | គណនេយ្យសាធារណៈដែលមានលក្ខណៈជាអន្តរជាតិ |
| អ.ស.ក | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | PEFA | ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ |
| អ.ស.ប | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | PMAS | ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព |
| អ.គ.ធ | អគ្គាធិការដ្ឋាន | RBM | ការគ្រប់គ្រងផ្អែកលើលទ្ធផល |
| វ.ស.ហ | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ក.ហ.ស | ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន |

## ឧបសម្ព័ន្ធទី ៦÷ បទបង្ហាញស្តីពីរបាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់កិច្ចប្រជុំ គ.ក.ហ. នៃ កសហវ.

កិច្ចប្រជុំគណៈកម្មការកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# របាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៤ និងឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

"ការកសាង និងកែលម្អប្រព័ន្ធ៖ អភិបាលកិច្ច, ក្របខណ្ឌគតិយុត្ត, ស្ថាប័នីយកម្ម និងធនធានមនុស្ស"

ថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ត្រូវនឹងថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២៣

1

# មាតិកា


១. សេចក្តីផ្តើម

២. វឌ្ឍនភាពប្រចាំឆ្នាំ២០២២ នៃការអនុវត្ត CAP3+2

៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – *ការអនុវត្តប្រព័ន្ធ FMIS, ការវាយតម្លៃថវិកាយេនឌ័រ និង ការវាយតម្លៃចំណាយសាធារណៈ*

៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៥. បញ្ហាប្រឈម និងសំណូមពរវិធានការដោះស្រាយ

៦. សំណូមពរបន្ថែម

៧. សន្និដ្ឋានរួម


2

## ១. **សេចក្តីផ្តើម** – សាវតារ និងគោលបំណង

សារាចរលេខ ០៩ សរ របស់ រាជរដ្ឋាភិបាល ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០១៥

តាមដាន និងវាយតម្លៃការអនុវត្ត ផែនការសកម្មភាពរួម ដំណាក់-កាលទី៣ បូក២ (CAP3+2) ប្រចាំឆ្នាំ២០២២

របាយការណ៍នេះ ឆ្លុះបញ្ចាំងទាំងទិដ្ឋភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ និងប្រសិទ្ធភាពប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់ឧបករណ៍ស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីធានាថាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតលើវិថីកែទម្រង់ដ៏ត្រឹមត្រូវ និងបោះជំហានឈានទៅដំណាក់កាលទី៤ ប្រកបដោយជវភាព និងគណនេយ្យភាព។

3

## ១. **សេចក្តីផ្តើម** – វិធីសាស្ត្ររៀបចំរបាយការណ៍




❖ *កំណត់សម្គាល់÷ របាយការណ៍នេះ គឺជារបាយការណ៍រួមរបស់គ្រប់តួអង្គពាក់ព័ន្ធ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។*

4

## ២. វឌ្ឍនភាពប្រចាំឆ្នាំ២០២២ នៃការអនុវត្ត CAP3+2

*២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស.*

*២.២. វឌ្ឍនភាពនៃការអនុវត្ត CAP3+2*

5

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពសម្រេចបាន

❖ *ការសម្រេចរបស់ គ.ហ.ស. មានចំនួន ៣១ ចំណុច ក្នុងនោះសម្រេចបាន ១៦ និង ១២ ចំណុចកំពុងបន្តតាមដាន ព្រមទាំងបន្ថែមថ្មីចំនួន ៣ ចំណុច។*

(១). ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

(២). របាយការណ៍ PEFA ថ្នាក់ក្រោមជាតិ ឆ្នាំ២០២១

(៣). ចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

(៤). យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១

(៥). របាយការណ៍វាយតម្លៃលើបច្ច័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

(៦). ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១

(៧). របាយការណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ក្របខណ្ឌ TADAT

(៨). របាយការណ៍វាយតម្លៃការអនុវត្តក្របខណ្ឌថវិកា(ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) តាមរយៈការប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ– PER)

(៩). បច្ចុប្បន្នភាព គ.ហ.ស., គ.ក.ហ.និង ក.ហ.ស. ក្នុងក្របខណ្ឌ PFMRP

(១០). ក្របខណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ *

(១១). ការជំរុញ និងត្រួតពិនិត្យការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ តាមរយៈយន្តការ MAP4 (២១ក្រសួង ស្ថាប័ន ក្នុងនោះមាន ៥ អនុវត្តមិនទាន់ពេញលេញ) *

(១២). ការពិនិត្យលើការផ្ទេរមុខងារចំនួន ៥៥ ទៅរដ្ឋបាលក្រុង ស្រុក និងថវិកាឱ្យស្របតាមមុខងារទាំង ៥៥ *

(១៣). ការជំរុញការអនុវត្ត SARMIS ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ *

(១៤). ការជំរុញការរៀបចំបណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ *

(១៥). ការជំរុញក្រសួង-ស្ថាប័នអាទិភាពចំនួន ០៥-០៧ រៀបចំ FMM *

(១៦). ការបង្កើតក្រុមការងារអន្តរអគ្គនាយកដ្ឋាន នៃ កសហវ. សិក្សា និងវាយតម្លៃអំពីមុខងាររបស់មន្ទីរ សហវ. និងលិខិតបទដ្ឋានគតិយុត្ត តាមរយៈសេចក្តីសម្រេចលេខ ១២០ សហវ. ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២២។ *

**វិធានការត្រូវបន្តជំរុញ*

6

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

**១. សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ** *[GDB, ត.ម ២ ឆ្នាំ២០២៣]*

សេចក្តីព្រាងច្បាប់ ត្រូវបានពិនិត្យនិងសម្រេចដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៣ និងបានបញ្ជូនទៅអគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា កាលពីថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣។

**២. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ** *[GDSPNTR; តម៤, ២០២៣]*

បានរៀបចំជាទម្រង់ និងខ្លឹមសារព្រាង។ សេចក្តីព្រាងច្បាប់នេះ រង់ចាំឯកសារយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ។

**៣. ការកែសម្រួលអនុក្រឹត្យលេខ៨១ អនក្រ.បក និងអនុក្រឹត្យលេខ៨២ អនក្រ.បក** *[GDB & GDNT ; ត.ម២, ២០២៣]*

សេចក្តីព្រាងអនុក្រឹត្យលេខ ៨១+៨២ ត្រូវបានបញ្ចូលគ្នា និងកំណត់ឈ្មោះថ្មី "ការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ"។

**៤. សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** *[GSC, GDSPNTR, GDB, GDNT, GDSNAF; ត.ម.២, ២០២៣]*

ក្រុមការងារទទួលបន្ទុក បាននិងកំពុងកែសម្រួលសេចក្តីព្រាងអនុក្រឹត្យចុងក្រោយតាមចំណារដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ដើម្បីបន្តនីតិវិធីគោរពជូនប្រមុខរាជរដ្ឋាភិបាល អនុម័តដ៏ខ្ពង់ខ្ពស់។

**៥. គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល (PFMM)** *[GSC; តម៤, ២០២៣]*

សេចក្តីព្រាងគោលការណ៍ណែនាំ ត្រូវបានធ្វើបច្ចុប្បន្នភាពដោយបន្តតម្រឹមជាមួយសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និងគ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី២ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៣។

7

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន (ត...)

**៦. ក្របខណ្ឌរួមផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ** *[GSC; តម៣, ២០២៣]*

កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ ក្រុមការងារទទួលបន្ទុកបានរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍របកគំហើញរបស់ជំនាញការ។ បច្ចុប្បន្ន ក្រុមជំនាញការបាននិងកំពុងប្រមូលធាតុចូលបន្ថែមទៀតពីភាគីពាក់ព័ន្ធ។

**៧. កម្មវិធីសិក្សាភ្ជាប់វិញ្ញាបនបត្រ (Certificate Program) ដោយផ្សារភ្ជាប់មុខតំណែងឱ្យបានគ្រប់ជ្រុងជ្រោយ** *[EFI ; ត.ម៤,២០២៣]*

ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំពិគ្រោះយោបល់ជាមួយគ្រប់ក្រសួង ស្ថាប័ន និង អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទ កសហវ ដើម្បីរៀបចំជាសេចក្តីព្រាងអនុក្រឹត្យ។

**៨. ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** *[GDSPNTR; ត.ម៤, ២០២៣]*

បានរៀបចំផែនការសកម្មភាពលម្អិតដើម្បីធ្វើការជាមួយភាគីពាក់ព័ន្ធ។ ក្រុមការងារទទួលបបន្ទុកចាប់ផ្តើមប្រមូលធាតុចូលពីក្រសួង ស្ថាប័នសំខាន់ៗ។

**៩. ឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** *[GDSPNTR; ត.ម.២, ២០២៣]*

ឯកសារគោលនេះ ត្រូវបានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។ គ្រោងដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាត្រីមាសទី ១ ឆ្នាំ២០២៣

**១០. សេចក្តីព្រាងផែនការរៀបចំក្របខណ្ឌនិងវិធានស្តីពីសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** *[GI & GDIA; ត.ម៤, ២០២៣]*

មានសេចក្តីព្រាងរបាយការណ៍សិក្សាស្រាវជ្រាវរបស់ទីប្រឹក្សាបារាំងលើមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច។

8

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន (ត...)

**១១. មូលនិធិ PFMRP គ្រប់ជ្រុងជ្រោយ** *[GSC; ត.ម១, ២០២៣]*

បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគ្រោងនឹងគោរពជូន ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ពិនិត្យនិងសម្រេច ដើម្បីបន្តនីតិវិធីគោរពជូនប្រមុខរាជរដ្ឋាភិបាលដើម្បីអនុម័តនៅក្នុងខែមករា ឆ្នាំ២០២៣។

**១២. សន្ទានកម្មរវាង FMIS និង EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា លើមុខងារការទិញ (PO) និងមុខងារគណនីត្រូវសង (AP)** *[FMIS & MoEYS ; ត.ម៤, ២០២៣]*

ក្រុមការងារទទួលបន្ទុកទាំងពីរបានប្រជុំពិភាក្សា និង ផ្តល់នូវទិន្នន័យសំខាន់ៗសម្រាប់បង្កើតប្រតិបត្តិការក្នុងប្រព័ន្ធ FMIS។

**១៣. ការដកស្រង់បទពិសោធន៍ និងការសិក្សាឧត្តមានុវត្តន៍អន្តរជាតិ អំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំក្របខណ្ឌគតិយុត្តបន្ថែម និងយន្តការ នៃការគ្រប់គ្រងគ្រឹះស្ថាន។** *[ក្រុមការងារបច្ចេកទេសកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាល(GDB); ត.ម. ៤. ២០២៣]*

.....

**១៤. ឯកសារយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ** *[ក្រុមការងារបច្ចេកទេសកែទម្រង់សហគ្រាសសាធារណៈ (GDSPNTR); ត.ម. ៤, ២០២៣]*

បានប្រជុំពិនិត្យកែសម្រួលខ្លឹមសារ ដែលបានព្រាង។

**១៥. របាយការណ៍សិក្សានិងវាយតម្លៃអំពីមុខងារភារកិច្ចរបស់មន្ទីរ សហវ. ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ក្រោម PFMRP និងសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)** *[GSMEF; ត.ម. ៣, ២០២៣]*

បានបង្កើតក្រុមការងារសិក្សានិងវាយតម្លៃតាមរយៈសេចក្តីសម្រេចលេខ ១២០ សហវ. ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២២។

9

## ២.២. វឌ្ឍនភាពនៃការអនុវត្ត CAP3+2

*ផ្នែកទី ១ ÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា*

*ផ្នែកទី ២ ÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ*

*ផ្នែកទី ៣ ÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*

*ផ្នែកទី ៤ ÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម*

*ផ្នែកទី ៥ ÷ ការកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡានៃការកែទម្រង់*

10



ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា – សូចនាករសមិទ្ធកម្មគន្លឹះទាំង៦
មិនមាន
១០៣,៥ %
(ទំហំ ២៦ ១៩១ ប៊ីលានរៀល)
សូចនាករ សមិទ្ធកម្មគន្លឹះ ទាំង៦
១
ចំណូលថវិការដ្ឋសម្រេចបាន +/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់
២
ស្ថានភាពចំណាយមិនត្រូវតិចជាង (តម ៤ : ៩៦%)
៣
លទ្ធផលចំណាយតាមប្រភេទធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷ បៀវត្ស : ៩៨ % ទំនិញ/សេវា : ៩៥ % មូលធន : ៨៥ %
៤
ការរួមចំណែកទៅក្នុង ផ.ស.ស នៃ ចំណូលសរុបមានការកែលម្អដោយបង្កើនប្រមាណ ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ
៥
រាល់ផ្នែកសំខាន់ៗនៃចំណូល និងចំណាយសាធារណៈ ត្រូវបានដាក់បញ្ចូលក្នុងថវិកា និងគណនីរបស់រាជរដ្ឋាភិបាល
៦
ចំណាយកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២%នៃចំណាយសរុប (៦០ថ្ងៃ)
៧៨,៩២% (ធៀបច្បាប់ថវិកា)
(ទំហំ ២២ ៦៧៩ ប៊ីលានរៀល)
១២៥ គណនី
បៀវត្ស ៩៥,៩១% (ធៀបច្បាប់),
ទំនិញ-សេវា ៧៨,៣០% (ធៀបច្បាប់),
មូលធន ៧០,១១% (ធៀបច្បាប់),
១,២ ពិន្ទុភាគរយ នៃ ផ.ស.ស.
ទំហំ ផ.ស.ស. ឆ្នាំ២០២២= ១២០ ៣១២ ប៊ីលានរៀល
(ប្រភព÷ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣-២០២៥)។
ចំណូលចរន្តធៀបនឹង ផ.ស.ស. ÷ ឆ្នាំ២០២១ = ២០,៤៨% នៃ ផ.ស.ស, ឆ្នាំ២០២២ = ២១.៦៨% នៃ ផ.ស.ស។
ប្រភព÷អគ្គនាយកដ្ឋានរតនាគារជាតិ។ ទិន្នន័យចំណូល-ចំណាយថវិកាគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២(ទិន្នន័យបណ្ដោះអាសន្ន) ។
❖ ការប្រមូលចំណូលថវិកាថ្នាក់ជាតិ
គយ និងរដ្ឋាករ÷ ១០៤%
ពន្ធដារ÷ ១១៤,៧ %
ចំណូលមិនមែនសារពើពន្ធ ÷ ១០១%
❖ ការប្រមូលចំណូលថវិកាថរដ្ឋបាលថ្នាក់-ក្រោមជាតិ (រដ្ឋបាលរាជធានី ខេត្ត)
ចំណូលសារពើពន្ធ÷ ១១៥,៧%
ចំណូលមិនមែនសារពើពន្ធ÷៨៣,២%
ផ្សេងៗ÷ ៩០,៥៦%
បន្ទុកហិរញ្ញវត្ថុ ៧៨,៤៤%, អត្ថប្រយោជន៍សង្គម ៨៥,៨៥%,
ឧបត្ថម្ភធន ១១២,៦៤%, និង ពន្ធនិងអាករ ១៣៨,៣៥%
11




ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា – ការអនុវត្តចំណាយថវិកាតាមត្រីមាស
វិវត្តនៃការអនុវត្តថវិការដ្ឋតាមត្រីមាស ឆ្នាំ ២០១៦-២០២២
ត.ម១ ត.ម២ ត.ម៣ ត.ម៤
% អនុវត្តធៀបនឹងច្បាប់ហិរញ្ញវត្ថុ
98.21% 100.68% 99.00% 99.05% 83.21% 104.40% 78.86%
58.71% 58.79% 60.93% 54.74% 57.49% 65.13% 58.64%
34.10% 35.04% 34.46% 32.87% 36.75% 40.12% 37.39%
15.19% 15.40% 15.61% 14.90% 16.23% 19.98% 17.91%
2016 2017 2018 2019 2020 2021 2022 ឆ.
ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ។ ទិន្នន័យចំណាយថវិកាគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២(ទិន្នន័យបណ្ដោះអាសន្ន)។
12

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

## ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

### ❖ ការគ្រប់គ្រងចំណូលសារពើពន្ធ

- ភាគរយនៃអ្នកជាប់ពន្ធបង់ប្រាក់ពន្ធទាន់ពេលវេលាប្រចាំឆ្នាំ២០២២ សម្រេចបានជារួមប្រមាណ ៨៨.៧០%
- ការប្រមូលបំណុលពន្ធក្នុងឆ្នាំ២០២២ សម្រេចបានប្រមាណ ១៤.៧៤% នៃបំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២១
- បានដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ដំណាក់កាលទី៣
- ចំនួនសមាជិកក្រុមធុរជនល្អបំផុត ត្រូវបានបង្កើនចំនួន ៦។

### ❖ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- សារាចរណែនាំលេខ០១១ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើ-ប្រាស់ ប្រព័ន្ធ NRMIS ដំណាក់កាលទី២ ជំហានទី២ ដល់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ
- សារាចរលេខ ០០៣ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ E-payment ជំហានទី៣
- ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធចូលជាធរមាន
- ឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងNTR ត្រូវបានរៀបចំជាសេចក្តីព្រាង។

### ❖ ការគ្រប់គ្រងកិច្ចលទ្ធកម្ម

- អនុម័តផែនការលទ្ធកម្មឆ្នាំ២០២៣ បាន ១១០/១១៥ ស្ថាប័ន (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ឬប្រមាណ ៩៦%
- ផ្តល់របាយការណ៍លទ្ធកម្មឆ្នាំ២០២១ បាន ៤៥៧/៦៣៩ (អង្គភាពថវិកា) ឬប្រមាណ ៧១%
- ការអនុវត្តសិទ្ធិសម្រេចលទ្ធកម្មជំហានទី២ បានរៀបចំជាសេចក្តីព្រាងប្រកាស
- ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង(ថវិកាចរន្ត)ក្នុងឆ្នាំ២០២១ បានប្រមាណ ៥៦%
- សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ(ថ្មី) បានឆ្លងថ្នាក់ដឹកនាំ កសហវ.។

### ❖ ការអនុវត្តថវិកា

- ការទូទាត់តាម E-Transfer អនុវត្តបាន ១០០%
- ក្រសួង ស្ថាប័នចំនួន១៣ បានរៀបចំFMM
- ផែនការរជ្ជទេយ្យបុរេប្រទានសម្រាប់ចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័ន (១០០%)
- ក្របខណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាព សម្រាប់ដោះស្រាយចំណាយកកស្ទះ
- ការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ÷ ២១ក្រសួង ស្ថាប័ន ក្នុងនោះមាន ៥ ពុំទាន់អនុវត្តពេញលេញ។

13

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

## ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

### សន្និដ្ឋាន

ចំណូលថវិកាជាតិនៅតែមានស្ថានភាពរឹងមាំ ប៉ុន្តែវិហ្វរ និងប្រសិទ្ធភាពចំណាយថវិកាត្រូវបន្តយកចិត្តទុកដាក់។ ការដាក់ចេញនូវវិធានការនៃ**ការភ្ជាប់ផែនការរជ្ជទេយ្យបុរេប្រទានអំឡុងពេលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ** និង **ការអនុម័តផែនការលទ្ធកម្មប្រចាំឆ្នាំ** មានវឌ្ឍនភាពល្អប្រសើរ ប៉ុន្តែពុំទាន់មានបច្ច័យខ្ពស់គ្រប់គ្រាន់នៅឡើយសម្រាប់ពន្លឿនការអនុវត្តថវិកាតាមត្រីមាសនីមួយៗ ពោលគឺការអនុវត្តថវិកានៅក្នុងត្រីមាសទី៣ នៅទាបជាងពិតាន (៧០%) ដែលមាននិន្នាការគរការអនុវត្តថវិកានៅចុងឆ្នាំ និងប្រតិបត្តិការថវិកានៅបន្ត។

ការជំរុញបញ្ចប់ការរៀបចំ **ក្របខណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ** នឹងរួមចំណែកកំណត់បញ្ហាប្រឈមជាក់ស្តែងនៃការគរការអនុវត្តថវិកានៅចុងឆ្នាំ ខណៈការបញ្ចប់ការដាក់ឱ្យអនុវត្ត **សិទ្ធិសម្រេចលទ្ធកម្ម ជំហានទី២** ក៏នឹងរួមចំណែកដល់ការពន្លឿនការអនុវត្តថវិកាផងដែរ។ ដោយឡែក ការប្រើប្រាស់វិធីសាស្ត្រប្រកួត-ប្រជែងក្នុងកិច្ចលទ្ធកម្មនៅមានកម្រិត ដែលកិច្ចការនេះ នឹងត្រូវបានពង្រឹងតាមរយៈការធ្វើ **វិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ**។

14

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

## ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

### ❖ ការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS

- កសហវ. និង ក្រសួងបរិស្ថានបានអនុវត្តនីតិវិធីចំណាយថវិកាចរន្តលើគ្រប់មុខសញ្ញា តាមប្រព័ន្ធ FMIS ទាំងស្រុង
- ក្រសួង ស្ថាប័នចំនួន ៣៤/៣៧ បានអនុវត្តនីតិវិធីចំណាយបៀវត្ស និងនីតិវិធីចំណាយទូទាត់ត្រង់ តាមប្រព័ន្ធ FMIS ទាំងស្រុង។

### ❖ ការអនុវត្តមុខងារថ្មីចំនួន ២ ក្នុងប្រព័ន្ធ FMIS

- ក្រសួង ស្ថាប័នចំនួន ១១ បន្ថែមថ្មី និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ បានអនុវត្តមុខងាររៀបចំផែនការថវិកា ជាផ្លូវការ
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ បានអនុវត្តមុខងារលទ្ធកម្មពេញលេញ ជាផ្លូវការ។

### ❖ ការដ្ឋានបន្ថែមបានអនុវត្តប្រព័ន្ធ FMIS ជាផ្លូវការ

- រដ្ឋបាលរាជធានី ខេត្ត ទាំង២៥ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ បានអនុវត្តប្រព័ន្ធ FMIS ជាផ្លូវការ
- រដ្ឋបាលស្រុកចំនួន ៧៥ និង រដ្ឋបាលឃុំចំនួន ១៨៥ បានប្រើប្រាស់សាកល្បងប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ជាផ្លូវការ។

### ❖ ការដ្ឋានបន្ថែមសម្រាប់ដំឡើងប្រព័ន្ធ FMIS

- ប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ត្រូវបានអភិវឌ្ឍ និង តេស្តសម្រាប់ត្រៀមដាក់ឱ្យប្រើប្រាស់នៅរដ្ឋបាលក្រុងចំនួន ៦, រដ្ឋបាលស្រុកចំនួន ៦១, រដ្ឋបាលឃុំចំនួន ៤៤៧ និង រដ្ឋបាលសង្កាត់ចំនួន ២៨
- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មីនៅថ្នាក់កណ្តាលចំនួន ១០ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS
- គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៤ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS។

15

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥


## ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ


### ❖ ប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងរបាយការណ៍

- ការបិទបញ្ជីគណនេយ្យ (ឆ្នាំ២០២១) ក្នុងខែកញ្ញា ឆ្នាំ២០២២
- របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០ មូលដ្ឋានសាច់ប្រាក់ត្រូវបានរៀបចំរួចរាល់លើមូលដ្ឋានចេញពីប្រព័ន្ធ FMIS
- យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ ត្រូវបានដាក់ឱ្យអនុវត្ត។

### ❖ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២១ ទទួលបាន ៨៧ % (២៦៤៣/៣០៥៣)
- ប្រកាសស្តីពីវិធាន និងនីតិវិធីផ្ទេរនីត្យានុកូលកម្មឡើងវិញនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងដែលមិនមានការឯកភាពពី កសហវ. បានរៀបចំជាសេចក្តីព្រាង
- ការដាក់ពាក្យស្នើសុំធ្វើបណ្ណកម្មសិទ្ធិ មានចំនួន ៥៣៨៨ កន្លែង។(ទិន្នន័យបឋម១៨ ខេត្ត)
- SARMIS ដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (វិកិលទៅឆ្នាំ២០២៣)។

### ❖ ការគ្រប់គ្រងបំណុលសាធារណៈ

- សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតាន (ឆ្នាំ២០២២ ប៉ាន់)÷ *តម្លៃបច្ចុប្បន្ននៃបំណុលសារធារណៈសរុប ២៥,២% ធៀបនឹង ផសស, តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ២៤,៩០% ធៀបនឹង ផសស និង ៣៣,៩០% ធៀបនឹងការនាំចេញ សេវាបំណុលសាធារណៈក្រៅប្រទេស ២,១០% ធៀបនឹងការនាំចេញ និង ៧,៨% ធៀបនឹងចំណូលថវិកាជាតិ។*
- ក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២២-២០២៨ (មានសេចក្តីព្រាង)
- សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។

### ❖ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ

- លក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានរៀបចំ
- គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២៧ បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ ស្របតាមគោលការណ៍ណែនាំ
- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ (វិកិលទៅឆ្នាំ២០២៣)។

16

ផ្នែកទី១ | **ផ្នែកទី២** | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

## ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

### សន្និដ្ឋាន

ប្រព័ន្ធ FMIS ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ហើយត្រូវបានពង្រីកដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី ខេត្ត។ ទន្ទឹមនេះ ប្រព័ន្ធ FMIS ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ព្រមទាំងការដាក់ឱ្យអនុវត្តមុខងារលទ្ធកម្មពេញលេញ និងមុខងាររៀបចំថវិកា តាមក្រសួង ស្ថាប័នជាបណ្តើរៗ។ **ការបន្តជំរុញការអនុវត្តនីតិវិធីថ្មី តាមប្រព័ន្ធ FMIS ទាំងស្រុង** អាចសម្រេចបានជោគជ័យពេញលេញទៅតាមផែនការ តម្រូវឱ្យមានចូលរួមកាន់តែខ្លាំងឡើង និងការគាំទ្រទាំងកម្រិតបច្ចេកទេស និងនយោបាយ ពីគ្រប់ភាគីពាក់ព័ន្ធទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ និន្នាការនេះ ឬឌីជីថលូបនីយកម្ម តម្រូវឱ្យមានការគិតគូរអំពីហត្ថលេខាអេឡិច-ត្រូនិក និងគោលនយោបាយឌីជីថល។

ដោយឡែក **ការបិទបញ្ជីគណនេយ្យ** ត្រូវបន្តយកចិត្តទុកដាក់ ស្របតាមទិសដៅនៃការកែទម្រង់ ដែលកិច្ចការនេះ តម្រូវឱ្យមានការជំរុញពីគ្រប់ភាគីពាក់ព័ន្ធ។ ខាងផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមានកម្រិតដែលនឹងត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្ត **ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**។ ចំណែកឯ **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល** និង **សហគ្រាសសាធារណៈ** ត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀត។ វិធានការគន្លឹះទាំងនេះនឹងជួយពង្រឹងប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងថវិកា។

17

ផ្នែកទី១ | ផ្នែកទី២ | **ផ្នែកទី៣** | ផ្នែកទី៤ | ផ្នែកទី៥

## ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

### ❖ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម

- MTFF ២០២៣-២០២៥ មានសេចក្តីព្រាង ប៉ុន្តែពុំទាន់ត្រូវបានអនុវត្តដោយបន្តអនុវត្តក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ថវិកាឆ្នាំ២០២៣
- MTBF មានពិតានថវិកាតាមវិស័យ និងតាមក្រសួង ស្ថាប័ន
- គ្រប់ក្រសួង ស្ថាប័ន បានរៀបចំ BSP ដោយមានសូចនាករសមិទ្ធកម្មគន្លឹះ។

### ❖ ការគ្រប់គ្រងការវិនិយោគសាធារណៈ

- ប្រកាសស្តីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងគម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ត្រូវបានដាក់ឱ្យអនុវត្ត
- ប្រកាសស្តីពីនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ត្រូវបានដាក់ឱ្យអនុវត្ត
- ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ឱ្យអនុវត្ត។

### ❖ ថវិកាកម្មវិធីផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា

- គម្លាតរវាងពិតានចំណាយគោលដែលកំណត់ក្នុងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងលទ្ធផលកញ្ចប់ថវិកាប្រចាំឆ្នាំ ទាបជាង ១៥%
- អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិចំនួន ៩ និងអង្គភាពថវិកាថ្មីចំនួន ២៨ បានបង្កើតឡើងនៅឆ្នាំ ២០២២
- គម្រោងចំណាយមូលធនក្នុងស្រុករបស់ក្រសួងសុខាភិបាលត្រូវបានណែនាំដាក់បញ្ចូលទៅក្នុង BSP របស់ក្រសួង ទៅតាមកម្មវិធីនីមួយៗ។

### ❖ វិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

- MTBF ២០២៣-២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ
- សមាហរណកម្ម BSP រដ្ឋបាលរាជធានី ខេត្ត រវាងរដ្ឋបាលរាជធានី ខេត្ត ជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ នៅគ្រប់រាជធានី ខេត្ត
- បទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងការប្រព្រឹត្យទៅនៃមូលនិធិភាតរភាព (មានសេចក្តីព្រាងបឋម)។

18

ផ្នែកទី១ | ផ្នែកទី២ | **ផ្នែកទី៣** | ផ្នែកទី៤ | ផ្នែកទី៥

## ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

### សន្និដ្ឋាន

ថវិការយៈពេលមធ្យមបាននិងកំពុងដាក់ឱ្យអនុវត្ត និងកែលម្អ។ ប៉ុន្តែ MTFF ត្រូវបានរៀបចំជាសេចក្តីព្រាងដោយពន្យារការដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ដោយសារស្ថានភាពសេដ្ឋកិច្ចក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដោយបន្តអនុវត្តក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ថវិកាឆ្នាំ២០២៣។ ការបង្កើន **អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ** នៅមានកម្រិតនៅឡើយដែលកិច្ចការនេះគួរត្រូវបន្តជំរុញបន្ថែមទៀត ខណៈប្រព័ន្ធថវិកាកម្ពុជា បាននិងកំពុងឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ដែលសិទ្ធិអំណាច និងថវិកានឹងត្រូវធ្វើវិមជ្ឈការទៅអង្គភាពអនុវត្តផ្ទាល់កាន់តែច្រើន។ បន្ថែមពីនេះ ការធ្វើ **សមាហរណកម្មរវាងចំណាយថវិកាមូលធន និងថវិកាចរន្ត** ព្រមទាំង **គុណភាព BSP និង PB** ត្រូវបន្តយកចិត្តទុកដាក់។

ការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្ររដ្ឋបាលរាជធានី ខេត្ត រវាងរដ្ឋបាលរាជធានី ខេត្តជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ និងការតម្រឹមជាមួយថវិកាមន្ទីរជំនាញ នឹងរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពនៃការវិភាជ និងការអនុវត្តថវិកា។ ដោយឡែក ត្រូវពង្រឹងវិមជ្ឈការហិរញ្ញវត្ថុ ក្នុងនោះ **មុខងារ ៥៥ ពីការិយាល័យជំនាញ ២០ វិស័យ ដែលបានធ្វើសមាហរណកម្មចូលក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក** ពុំទាន់អនុវត្តបានរលូននៅឡើយ ដែលកិច្ចការនេះគួរពន្លឿនការដោះស្រាយទាំងការផ្ទេរធនធានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ឱ្យស្របនឹងមុខងារទាំង ៥៥ នេះ។

19

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | **ផ្នែកទី៤** | ផ្នែកទី៥

## ការបញ្ជប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម

### ❖ ក្របខណ្ឌគតិយុត្តថវិកាព័ត៌មានសមិទ្ធកម្ម

- សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)
- អនុក្រឹត្យលេខ ៨១ និង ៨២ មានជាសេចក្តីព្រាង និងបានរៀបចំបញ្ចូលគ្នា ហើយត្រូវបានកំណត់ឈ្មោះថ្មី “**សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ**”
- កិច្ចព្រមព្រៀងលទ្ធផលក្នុងឆ្នាំរវាងជាមួយក្រសួង ៧ ត្រូវបានចុះហត្ថលេខា
- សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម និងត្រួតពិនិត្យថវិកា (មានមាតិកា)។ *(ក្របខណ្ឌពេលវេលាថ្មី ត.ម.២, ឆ្នាំ២០២៤)*

### ❖ ប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្ម

- សេចក្តីព្រាងក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- ប្រកាសលេខ ១២៧ សហវ.អ ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដារអធិការកិច្ចហិរញ្ញវត្ថុ
- ការអនុវត្តសវនកម្មសមិទ្ធកម្មសាកល្បងជាករណីសិក្សានៅក្រសួងចំនួន ៦ និងសវនកម្ម ICT នៅក្រសួងចំនួន ៤
- ៥ របាយការណ៍សវនកម្មកិច្ចប្រតិបត្តិការដែលត្រូវបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិ។

### ❖ ប្រព័ន្ធតាមដាន និងពិនិត្យសមិទ្ធកម្មតាមក្រសួង ស្ថាប័ន

- គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្ត
- ទម្រង់ផែនការប្រតិបត្តិត្រូវបានអនុម័ត *(បច្ចុប្បន្នភាពថ្មី BSRS ត.ម.១, ឆ្នាំ២០២៣)*
- ដាក់ឱ្យអនុវត្តសាកល្បងការតាមដាននៅតាមក្រសួង ស្ថាប័ន ចំនួន ៦ *(បច្ចុប្បន្នភាពថ្មី BSRS ឆ្នាំ២០២៥)*។

### ❖ ការលើកកម្ពស់តម្លាភាពថវិកា

- វេទិកាសាធារណៈស្តីពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ
- ខ្លឹមសារសង្ខេបស្តីពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០២៣ និងសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២៣ ត្រូវបានផ្សព្វផ្សាយ បន្ទាប់ពីត្រូវបានអនុម័តពីគណៈរដ្ឋមន្ត្រី
- សៀវភៅថវិកាសង្ខេបនៃច្បាប់ថវិកាឆ្នាំ ២០២៣ ត្រូវបានផ្សព្វផ្សាយ។

20

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | **ផ្នែកទី៤** | ផ្នែកទី៥

## ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម

### សន្និដ្ឋាន

ការឈានទៅអនុវត្តដំណាក់កាលទី៤ ត្រូវបានត្រៀមខ្លួនរួចរាល់ចាប់ពីឆ្នាំ២០២៣ តទៅ តាមរយៈសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ ដែលនឹងត្រូវចូលជាធរមាននៅក្នុងអំឡុងឆមាសទី១ ឆ្នាំ២០២៣។

ក្របខណ្ឌតាមដាន និងវាយតម្លៃ និងមុខងារសវនកម្មផ្ទៃក្នុងដែលផ្តោតលើសវនកម្មសមិទ្ធកម្មនិងបច្ចេកវិទ្យាព័ត៌មានព្រមទាំងមុខងារអធិការកិច្ច នៅគ្រប់ក្រសួង-ស្ថាប័ន ត្រូវពង្រឹងបន្ថែមជាបណ្តើរៗ ដើម្បីធានាថាក្រសួង ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យតាមដានរឹងមាំ ស្របពេលរាជរដ្ឋាភិបាល បាននិងកំពុងធ្វើវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នកាន់តែច្រើន។ ទោះជាយ៉ាងនេះក្តី មុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅបន្តស្ទួននៅឡើយ ដែលកិច្ចការនេះនឹងត្រូវបានដោះស្រាយតាមរយៈការដាក់ឱ្យអនុវត្ត ក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច។

21

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | **ផ្នែកទី៥**

## ការកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡានៃការកែទម្រង់

### ❖ ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់

- របាយការណ៍វឌ្ឍនភាពរបស់អង្គភាពក្រោមឱវាទ កសហវ. ១៨/១៨
- របាយការណ៍វឌ្ឍនភាពរបស់ក្រសួង ស្ថាប័ន ៣៩/៤០
- របាយការណ៍វឌ្ឍនភាពរបស់មន្ទីរ សហវ. រាជធានី ខេត្ត ២៥/២៥
- លក្ខខណ្ឌយោង តួនាទី ភារកិច្ច នៃសមាជិកក្រុមការងារកែទម្រង់តាមអង្គភាពក្រោមឱវាទ កសហវ រួមទាំងមន្ទីរ សហវ. និងក្រសួង ស្ថាប័ន ត្រូវបានរៀបចំតាមយន្តការផ្តល់ប្រាក់ឧបត្ថម្ភ។

### ❖ ការកសាងសមត្ថភាពក្នុងក្រខណ្ឌ PFMRP

- ផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខណ្ឌ PFMRP ត្រូវបានរៀបចំ
- ការរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍អំពី PFMRP សម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ
- ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំសម្រាប់រៀបចំសេចក្តីព្រាងអនុក្រឹត្យ។

### ❖ ចលនការនៃកែទម្រង់

- ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព (PMAS) ត្រូវបានដាក់ឱ្យអនុវត្តនៅ អ.គ.ហ.
- ការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រមាណ ១៥ ៨៦១ លានរៀល ឬប្រមាណជិត ៤ លានដុល្លា ក្នុងនោះ បានផ្តល់ជូនអង្គភាពក្រោមឱវាទ កសហវ. ចំនួន ៤៨៥ រូប, មន្ទីរ សហវ. រាជធានី ខេត្ត ចំនួន ៧៥ រូប, និងក្រសួង ស្ថាប័ន ចំនួន ៣៤៧។

### ❖ ភាពប្រទាក់ក្រឡានៃករកែទម្រង់ ៣ បូក១

- ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១
- យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ ត្រូវដាក់ឱ្យអនុវត្ត
- សេចក្តីណែនាំស្តីពីការពិពណ៌នាមុខដំណែង (មានសេចក្តីព្រាង)។

22

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

## ការកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡានៃការកែទម្រង់

### សន្និដ្ឋាន

ក្រុមការងារកែទម្រង់ នៅតាមអង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរ សហវ. រាជធានី ខេត្ត និងក្រសួង ស្ថាប័ន បានអនុវត្តផែនការ និងបានផ្ញើរបាយការណ៍សមិទ្ធកម្មមក អ.គ.ហ. ទាន់ពេលវេលា បើទោះជាមានភាពយឺតយ៉ាវចំពោះក្រសួង ស្ថាប័នតិចតួចក្តី។ ចលនការនៃការកែទម្រង់ត្រូវបានបន្តចីរភាព ដែលឆ្លុះបញ្ចាំងតាមរយៈការចូលរួមអនុវត្តកម្មវិធីកែទម្រង់ពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។ ការងារកែទម្រង់ប្រទាក់ក្រឡា ត្រូវបានពង្រឹងតាមរយៈ ការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្រ្តស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១។

ទោះជាយ៉ាងនេះក្តី ការថែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹង PFMRP (ដំណាក់កាលទី៤) ផ្តោតលើការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ នៅពុំទាន់បានរៀបចំនៅឡើយ។ ចលនការឆ្ពោះទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម នឹងតម្រូវឱ្យស្ថាប័ននីតិប្បញ្ញត្តិ ផ្តោតលើព័ត៌មានសមិទ្ធកម្មច្រើនជាងការអនុវត្តបច្ចុប្បន្ន។ ដោយឡែក តួនាទីមន្ត្រីរាជការនឹងត្រូវបានរៀបចំកាន់តែច្បាស់តាមរយៈការដាក់ឱ្យអនុវត្ត សេចក្តីណែនាំស្តីពីការពិពណ៌នាមុខដំណែង។ បន្ថែមពីនេះ សមត្ថភាពជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិញ្ញាបនបត្រ។

23

## ❖ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២




24

## ❖ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ប្រចាំឆ្នាំ២០២២




## ❖ វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំត្រីមាសទី ៤ ឆ្នាំ២០២២



## ❖ វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំឆ្នាំ២០២២




## ❖ វឌ្ឍនភាព (%) តាមក្រសួង ស្ថាប័នប្រចាំត្រីមាសទី ៤ ឆ្នាំ២០២២



## ❖ វឌ្ឍនភាព (%) តាមក្រសួង ស្ថាប័នប្រចាំឆ្នាំ២០២២

ការអនុវត្តថវិកា និងវឌ្ឍនភាពជាភាគរយ (%) ប្រចាំឆ្នាំ២០២២ របស់ក្រសួង-ស្ថាប័ន ក្រោម PFMRP




29

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ

ដើម្បីឆ្លុះបញ្ចាំងគ្រប់ទិដ្ឋភាពនៃការកែទម្រង់ទៅលើការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា, អ.គ.ហ. បានស្នើ និងសហការជាមួយដៃគូអភិវឌ្ឍន៍ (មូលនិធិរូបិយវត្ថុអន្តរជាតិ - IMF និងធនាគារពិភពលោក - WB) រៀបចំការវាយតម្លៃទៅលើទិដ្ឋភាពចំនួន ៣។

1. ការអនុវត្តប្រព័ន្ធ FMIS (IMF)
2. ការវាយតម្លៃថវិកាយេនឌ័រ (IMF)
3. ការវាយតម្លៃចំណាយសាធារណៈ (WB)

*(ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, វិស័យធនធានទឹក និងធារាសាស្ត្រ, វិស័យសុខាភិបាល, វិស័យកសិកម្ម, និងរដ្ឋបាលថ្នាក់ក្រោមជាតិ÷ ករណីរដ្ឋបាលខេត្តព្រះសីហនុ)។*

30


៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – ការអនុវត្តប្រព័ន្ធ FMIS
-ចលនការឆ្ពោះទៅឌីជីថលូបនីយកម្ម មានតម្រូវការហត្ថលេខាឌីជីថល និងរៀបចំគោលនយោបាយឌីជីថល។
-ឧបករណ៍តាមដាន (Dashboard) ការអនុវត្តចំណាយតាម FMIS នឹងបង្ហាញអំពីពេលវេលាសម្រាប់ការអនុម័តចំណាយ និងកន្លែងកកស្ទះ (blockages)។
ការតម្រង់ទិសនីតិវិធីអនុវត្តការងារតាម FMIS
-ក្រសួង ស្ថាប័ននៅប្រើប្រាស់ Excel សម្រាប់កត់ត្រាការអនុវត្តចំណាយ ដោយសារហេតុផលចម្បងគឺប្រតិបត្តិការចំណាយមួយចំនួន ស្ថិតនៅក្រៅ TSA។ IMF ផ្តល់អនុសាសន៍ពង្រីកវិសាលភាពប្រព័ន្ធ FMIS ដោយក្នុងនោះបូកបញ្ចូលទាំងគ្រប់ប្រភពមូលនិធិ ផងដែរ។
-កសហវ. ស្នើក្រសួង ស្ថាប័ន រៀបចំចុះហត្ថលេខា និងផ្ញើរបាយការណ៍ផ្អែកលើក្រដាស។ IMF ផ្តល់អនុសាសន៍ធ្វើឌីជីថលូបនីយកម្ម លើរបាយការណ៍នេះ មានន័យថាត្រូវប្រើប្រាស់ក្នុងប្រព័ន្ធ FMIS តែម្តង។
ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ
ឌីជីថលូបនីយកម្មទៅលើការគ្រប់គ្រងសាច់ប្រាក់
-ឧបករណ៍ Web-based ត្រូវបានប្រើប្រាស់សម្រាប់អង្គភាពចំណាយ ដើម្បីផ្តល់ការគ្រោងលំហូរសាច់ប្រាក់ (Cash flow)។ ប៉ុន្តែ ការអនុវត្តជាក់ស្តែង ក្រសួង ស្ថាប័នជាច្រើនមិនបានផ្តល់ការគ្រោងសាច់ប្រាក់តាមប្រព័ន្ធនេះទេ ឬក៏ទិន្នន័យមួយចំនួនមិនពេញលេញ។ ដូចនេះ ការព្យាករសាច់ប្រាក់ផ្អែកបឋមលើទិន្នន័យមុនៗ។
-IMF ផ្តល់អនុសាសន៍ធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្តគោល-ការណ៍ណែនាំស្តីការគ្រប់គ្រងសាច់ប្រាក់ (Cash Management Manual) និងផ្តល់ការបណ្តុះបណ្តាលជូនក្រសួង ស្ថាប័ន។
-IMF ផ្តល់អនុសាសន៍គួរមានការវាយតម្លៃអំពីតម្រូវការដែលប្រព័ន្ធ FMIS អាចគាំទ្រលើការគ្រប់គ្រងសាច់ប្រាក់។
31


៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – លទ្ធផលបឋមនៃការវាយតម្លៃថវិកាយេនឌ័រ
- ថវិកាយេនឌ័រ ជាអភិក្រមដែលប្រើប្រាស់គោលនយោបាយសារពើពន្ធ និងឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការអភិវឌ្ឍកុមារី និងស្ត្រី។
❖ សមាសធាតុមូលដ្ឋានសម្រាប់ថវិកាយេនឌ័រ
១. មូលដ្ឋានគតិយុត្តសម្រាប់សមភាពយេនឌ័រ បានកំណត់ក្នុងច្បាប់រដ្ឋធម្មនុញ្ញ។
២. ការគាំទ្រផ្នែកនយោបាយកម្រិតខ្ពស់លើសមភាពយេនឌ័រ
៣. មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខណ្ឌគោល-នយោបាយ ពាក់ព័ន្ធនឹងយេនឌ័រ
៤. ការចូលរួមយ៉ាងសកម្មពីក្រសួងកិច្ចការនារី
៥. ការបញ្ជ្រាបយេនឌ័រ ត្រូវបានជ្រួតជ្រាបទូទាំងក្រសួង ស្ថាប័ន និងមានការយល់ដឹងអំពីបញ្ហាសមភាពយេនឌ័រ ជាពិសេសមានក្រុមការងារយេនឌ័រ
៦. មានក្របខណ្ឌថវិកាសមិទ្ធកម្ម និងកម្មវិធី
៧. មានទិន្នន័យបែងចែកតាមយេនឌ័រ (ស្ត្រី និងបុរស)
៨. មានប្រព័ន្ធ FMIS សម្រាប់ការអនុវត្តថវិកា។
ពង្រឹងក្របខណ្ឌស្ថាប័ន និងគតិយុត្តសម្រាប់ថវិកាយេនឌ័រ
(១) រៀបចំមូលដ្ឋានគតិយុត្តអចិន្ត្រៃយ៍, (២) កំណត់រចនាសម្ព័ន្ធស្ថាប័ន, (៣) កសហវ. ធ្វើសមាហរណកម្មទិដ្ឋភាពយេនឌ័រ ចូលក្នុងវដ្តថវិកា, និង (៤) ពង្រឹងទំនាក់ទំនង និងការយល់ដឹងអំពីថវិកាយេនឌ័រ។
ដាក់ឱ្យអនុវត្តនូវឧបករណ៍គាំទ្រថវិកាយេនឌ័រ
(១) ការវិភាជ និងចំណាយថវិកា ដែលមានបច្ច័យដល់សមភាពយេនឌ័រ, (២) រៀបចំ និងអនុវត្តការវាយតម្លៃបច្ច័យយេនឌ័រ, (៣) រៀបចំ និងផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ថវិកាយេនឌ័រ និង (៤) ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំពាក់ព័ន្ធនឹងការរៀបចំថវិកា ដើម្បីឆ្លុះបញ្ចាំងអំពីឧបករណ៍យេនឌ័រ។
សមាហរណកម្មឧបរណ៍ថវិកាយេន-ឌ័រទៅក្នុងដំណើរការរៀបចំថវិកា
(១) ពង្រឹងការកំណត់អាទិភាពសម្រាប់ការរៀបចំគោល-នយោបាយ និងការវិភាជធនធាន, (២) កែលម្អក្របខណ្ឌរបាយការណ៍, (៣) រៀបចំ និងអនុវត្តក្របខណ្ឌសម្រាប់វាយតម្លៃកម្មវិធី, (៤) និងប្រើប្រាស់ប្រព័ន្ធ FMIS។
ប្រើប្រាស់យន្តការកែទម្រង់ PFM ដើម្បីគាំទ្រការអនុវត្តថវិកាយេនឌ័រ
ការកែទម្រង់ថវិកាកម្មវិធីត្រូវបានពិនិត្យឃើញថាមានឱកាស តាមរយៈ ការធ្វើសមាហរណកម្មចំណាយមូលធន ទៅក្នុងរចនាសម្ព័ន្ធកម្មវិធី។ ចំណាយទាំងអស់បូករួមទាំងចំណាយហិរញ្ញប្បទានគម្រោងដោយដៃគូអភិវឌ្ឍន៍ ត្រូវបានកត់សម្គាល់ក្នុងថវិកាដើម្បីបង្ហាញអំពីទិដ្ឋភាពពេញលេញនៃបច្ច័យគោលនយោបាយលើយេនឌ័រ។
32

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – ការវាយតម្លៃចំណាយសាធារណៈ

❖ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Fiscal Management) (របាយការណ៍បឋម)

**០១**

**ចំណាយមូលធន និងបៀវត្សរ៍**

- ចំណាយមូលធន និងបៀវត្សរ៍ ត្រូវបានបង្កើនខ្លាំង ប៉ុន្តែត្រូវបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពចំណាយ។

**០២**

**គណនេយ្យភាព និងសមត្ថភាព**

- កែលម្អគណនេយ្យភាព និងសមត្ថភាព ដើម្បីសម្រេចបានលទ្ធផលចុងក្រោយតាមវិស័យ។ ការណ៍នេះគាំទ្រដល់ការអនុវត្តថវិកាព័តិមានសមិទ្ធកម្ម ដែលជាដំណាក់កាលទី៤ នៃ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**០៣**

**ចំណូលថវិការដ្ឋ**

- គិតគូរអំពីបន្ទុកសារពើពន្ធ, និង ពង្រីកមូលដ្ឋានពន្ធ (ពន្ធលើរូបវន្តបុគ្គល, ពន្ធលើចំណេញមូលធន, ពន្ធកាបូន និងពន្ធលើសេវាឌីជីថល)។

**០៤**

**គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ផ្អែកតាមគោលការណ៍អាកាសធាតុ(climate smart fiscal policy)**

- គិតគូរទទួលយកគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ផ្អែកតាមគោលការណ៍អាកាសធាតុ ដែលជាផ្នែកនៃការលើកកម្ពស់ភាពធន់ និងលើកទឹកចិត្តការវិនិយោគឯកជន សម្រាប់គម្រោងប្រកបដោយចីរភាព។

**ការកសាងលំហថវិកា ខណៈពិចារណាអំពីបន្ទុកសារពើពន្ធ**

❖ **រយៈពេលខ្លី**

- កសាងសមត្ថភាពអំពីម៉ូឌែលបន្ទុកសារពើពន្ធ
- រៀបចំរបាយការណ៍បន្ទុកសារពើពន្ធ
- បង្កើតមូលដ្ឋានទិន្នន័យ (Database) អ្នកជាប់ពន្ធ គ្រប់ជ្រុងជ្រោយសម្រាប់ GDCE និង GDT។

❖ **រយៈពេលមធ្យម**

- គិតគូរឡើងវិញអំពីគោលដៅលើកទឹកចិត្តពន្ធ (ឧទា. វិស័យផ្តោតលើការនាំចេញ។
- លុបចេញការលើកលែងអាករលើតម្លៃបន្ថែម (VAT)
- បញ្ឈប់ជាបណ្តើរៗនូវការលើកទឹកចិត្តពន្ធផ្អែកលើប្រាក់ចំណេញ
- វិភាគ Cost-benefit សម្រាប់បន្ទុកសារពើពន្ធ ប្រចាំឆ្នាំនីមួយៗ
- ផ្សព្វផ្សាយបន្ទុកសារពើពន្ធជាសាធារណៈប្រចាំឆ្នាំ
- GDT និង GDCE គួរតែអនុវត្តការវាយតម្លៃសវនកម្មផ្អែកលើហានិភ័យ
- ដោះស្រាយបញ្ហាគម្លាតទិន្នន័យ។

33

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – ការវាយតម្លៃចំណាយសាធារណៈ

❖ **វិស័យធនធានទឹកនិងធារាសាស្ត្រ (របាយការណ៍បឋម)**

**ការវិភាជថវិកា**

- ការវិភាជថវិកាត្រូវអនុវត្តតាមអាទិភាពគោលនយោបាយ ដែលផ្សារភ្ជាប់ទៅនឹងកសិកម្ម, ការគ្រប់គ្រងទឹក និងបម្រែបម្រួលអាកាសធាតុ
- លើកកម្ពស់សហថាមពល (Synergy) រវាងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងថវិកាជាតិ
- ពង្រឹងការវិភាជថវិការវាងថ្នាក់កណ្តាល មន្ទីរ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ដោះស្រាយបញ្ហាពង្រាយបុគ្គលិករវាងថ្នាក់កណ្តាល និងមន្ទីរ។

**ការអនុវត្តថវិកា**

- កែលម្អការវាយតម្លៃ និងជ្រើសរើសគម្រោង និងបង្កើនការប្រកួតប្រជែងកិច្ចលទ្ធកម្ម
- គួរមានគោលការណ៍ណែនាំបច្ចេកទេសអំពីការស្តារប្រព័ន្ធធារាសាស្ត្រ (ផ្សារភ្ជាប់ទៅនឹងប្រែប្រួលអាកាសធាតុ)
- ព្យាករណ៍ការជួសជុលការខូចខាត ដែលជួយកាត់បន្ថយការងារចំពោះកិច្ច
- គិតគូរផ្ទេរថវិកាប្រតិបត្តិការនិងថែទាំ (O&M) ទៅ មន្ទីរ (ហោចណាស់ ៣០%)
- រៀបចំគោលការណ៍ណែនាំច្បាស់លាស់អំពីរបៀបដែលគម្រោង O&M ត្រូវបានជ្រើសរើសម្រាប់ផ្តល់ហិរញ្ញប្បទាន
- រៀបចំគោលការណ៍ណែនាំបច្ចេកទេសលើការងារ O&M
- អនុវត្តមុខងារដែលបានផ្ទេរ សម្រាប់គាំទ្រសហគមន៍អ្នកប្រើប្រាស់ទឹក។

**តួនាទីតួអង្គពាក់ព័ន្ធ**

- ក្រសួងធនធានទឹកនិងឧតុនិយម គួរផ្តោតលើការរៀបចំគោលការណ៍ណែនាំបច្ចេកទេស និងប្រព័ន្ធ M&E និងផ្តោតតិចតួចលើការអនុវត្តជាក់ស្តែង
- គួរមានថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅរដ្ឋបាលក្រុង ស្រុក
- តួនាទីរបស់វិស័យឯកជន ចាំបាច់ត្រូវលើកទឹកចិត្ត។

**ការផ្តោតគោលនយោបាយ និងសមធម៌ចំណាយ**

- កែសម្រួលគោលនយោបាយដោយផ្សារភ្ជាប់ទៅកសិកម្ម, ការគ្រប់គ្រងទឹក, និងបម្រែបម្រួលអាកាសធាតុ។
- បន្តយកចិត្តទុកដាក់លើទិដ្ឋភាពសមធម៌នៃចំណាយ

**ការរួមចំណែករបស់វិស័យឯកជន, PPP និងការគ្រប់គ្រងទិន្នន័យ**

- លើកកម្ពស់ការចូលរួមពីវិស័យឯកជនក្នុងវិស័យទឹក
- រៀបចំតួនាទីរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការរួមចំណែករបស់វិស័យឯកជន
- កែលម្អការគ្រប់គ្រងទិន្នន័យ÷ ទិន្នន័យធនធានទឹក ប្រព័ន្ធធារាសាស្ត្រ និងសហគមន៍អ្នកប្រើប្រាស់ទឹក។

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – ការវាយតម្លៃចំណាយសាធារណៈ

❖ វិស័យសុខាភិបាល (របាយការណ៍បឋម)

**កែលម្អការធ្វើសមាហរណកម្មទិន្នន័យចំណាយថ្នាក់ខេត្ត**

**ពង្រឹងការធ្វើសមាហរណកម្មចំណាយមូលធនហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍**

- គិតគូរកែសម្រួលពេលវេលានៃដំណើរការជ្រើសរើស និងពិនិត្យគម្រោង សម្រាប់ការរៀបចំផែនការ និង BSP។

**ពង្រឹងក្របខណ្ឌសមិទ្ធកម្ម**

- ពង្រឹងសង្គតិភាពសូចនាករនីមួយៗក្នុង BSP, ពិនិត្យសូចនាករសមិទ្ធកម្ម, ដាក់ឱ្យអនុវត្តជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្មនៅក្នុងសំណើថវិកា។

**ពង្រឹងការធ្វើសមាហរណកម្ម BSP និង PB**

- តម្រឹមរចនាសម្ព័ន្ធ PB និង BSP, វិភាជចំណាយបន្ទុកបុគ្គលិកតាមកម្មវិធីនីមួយៗ។

35

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – ការវាយតម្លៃចំណាយសាធារណៈ

❖ វិស័យកសិកម្ម

**០១**

**ការផ្សារភ្ជាប់ PB និង BSP**

- តម្រឹម BSP ជាមួយ MTFF
- តម្រឹមរចនាសម្ព័ន្ធ PB និង BSP
- រៀបចំសេចក្តីណែនាំពន្យល់អំពីសកម្មភាពផ្អែកលើកម្មវិធី។

**០២**

**ការចូលរួមរៀបចំផែនការថវិកាមូលធនពីក្រសួង ស្ថាប័ន**

- គិតគូរកែសម្រួលពេលវេលានៃការត្រួតពិនិត្យ និងជ្រើសរើសគម្រោង
- ពង្រឹងតួនាទី MAFF ក្នុងការសិក្សាសមិទ្ធិលទ្ធភាព
- ពង្រឹងការសម្របសម្រួលក្នុងវិស័យពាក់ព័ន្ធកសិកម្ម។

**០៣**

**ម៉ាទ្រីសសមិទ្ធកម្ម**

- កាត់បន្ថយ និងធ្វើសមញ្ញកម្មចំនួនសូចនាករសមិទ្ធកម្ម
- ពង្រឹងសង្គតិភាពសូចនាករសមិទ្ធកម្ម
- ត្រួតពិនិត្យប្រចាំឆ្នាំគ្រប់ជ្រុងជ្រោយទៅលើសមិទ្ធកម្ម
- រៀបចំកម្មវិធីពង្រឹងសមត្ថភាពអំពីការរៀបចំ តាមដាន របាយការណ៍ និងប្រើប្រាស់ម៉ាទ្រីសសមិទ្ធកម្ម។

**០៤**

**BSP និងម៉ាទ្រីសសមិទ្ធកម្ម មិនទាន់ត្រូវបានគិតគូរសម្រាប់ការវិភាជ និងចរចាថវិកា**

- ដាក់បញ្ចូលព័ត៌មានសមិទ្ធកម្មជាបណ្តើរៗ នៅក្នុងសំណើថវិកាប្រចាំឆ្នាំ
- រៀបចំបឋមនូវទស្សនាទាននៃក្របខណ្ឌរាយការណ៍សមិទ្ធកម្មគ្រប់ជ្រុងជ្រោយ។

**០៥**

**ដំណើរការថវិកាវែង និងនីតិវិធីនិយ័តកម្មតឹងរឹង**

- ប្រតិភូកម្មសិទ្ធិអំណាចនិយ័តថវិកា ដើម្បីគាំទ្រភាពបត់បែនក្នុងការអនុវត្តថវិកា
- កសហវ. និង MAFF ត្រួតពិនិត្យនីតិវិធីចំណាយសម្រាប់សំណើធានាចំណាយ និងដំណើរការកិច្ចលទ្ធកម្ម
- MAFF រៀបចំផែនការអនុវត្តថវិកា ចែករំលែកជាមួយអ្នកគ្រប់គ្រងកម្មវិធី។

**០៦**

**ការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្ម**

- ពង្រឹងការទទួលខុសត្រូវ តួនាទី និងសមត្ថភាពសវនកម្មផ្ទៃក្នុង និងអធិការកិច្ច សម្រាប់ការត្រួតពិនិត្យថវិកាផ្ទៃក្នុង និងការផ្តោតទៅលើសមិទ្ធកម្ម។

36

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – ការវាយតម្លៃចំណាយសាធារណៈ

### ❖ រដ្ឋបាលខេត្តព្រះសីហនុ

#### ថ្នាក់ខេត្ត

- **ពង្រឹងសមត្ថភាពរៀបចំផែនការ÷** BSP រាជធានី ខេត្ត និង PB, ការគ្រប់គ្រងទិន្នន័យ (ICT),
- **កែលម្អសមត្ថភាពព្យាករចំណូលសារពើពន្ធ÷** ពង្រឹងបន្ទាត់គណនេយ្យភាពរវាង GDT និង រដ្ឋបាលខេត្ត, ការបង្កើនភាគរយចែករំលែកពន្ធពីខេត្តទៅក្រុង ស្រុក និងឃុំ សង្កាត់, ផ្ទេរពន្ធបន្ថែមទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- **កែលម្អការព្យាករចំណូលមិនមែនសារពើពន្ធ÷** ពង្រឹងការព្យាករ និងគ្រប់គ្រងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, ពង្រឹងការអនុវត្តប្រព័ន្ធ NRMIS, គិតគូរផ្ទេរចំណូលមិនមែនពន្ធពីក្រសួង ស្ថាប័នទៅរដ្ឋបាលក្រុង ស្រុក និង រដ្ឋបាលឃុំ សង្កាត់
- **ពង្រឹងភាពច្បាស់លាស់នៃមុខងារ÷** ពង្រឹងមុខងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ជាពិសេសលើការកសាងហេដ្ឋារចនាសម្ព័ន្ធ, ពង្រឹងយន្តការការងារជាមួយវិស័យឯកជន
- **ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ÷**ទ្រព្យសកម្មដែលឆ្លុះបញ្ចាំងអំពីស្ថានភាពជាក់ស្តែង និងរៀបចំអភិបាលកិច្ចរឹងមាំសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- **កែលម្អដំណើរការអនុវត្តថវិកា÷** កែលម្អពេលវេលានៃការរៀបចំនិងកិច្ចលទ្ធកម្មគម្រោង, កែលម្អសេចក្តីណែនាំស្តីពីការអនុវត្តថវិកា, ធានាភាពទាន់ពេលក្នុងការផ្សព្វផ្សាយចំពោះនីតិវិធី និងការកែទម្រង់ថ្មីៗ។

#### ថ្នាក់ស្រុក

- **កែលម្អលទ្ធភាពថវិកា និងភាពច្បាស់លាស់នៃមុខងារ÷** គ្រោងតម្លៃលម្អិតសម្រាប់មុខងារជាក់លាក់, ដោះស្រាយគម្លាតថវិកានៅថ្នាក់ក្រុង ស្រុក, កំណត់គតិយុត្តដែលត្រូវកែសម្រួល ស្របទៅនឹងការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ការរៀបចំផែនការ និងផែនការថវិកា), បង្កើតយន្តការច្បាស់លាស់ និងបច្ចុប្បន្នភាពទិន្នន័យសម្រាប់ទាញការចូលរួមពីវិស័យឯកជន
- **ការកែលម្អការគ្រប់គ្រងធនធានមនុស្ស÷** ដោះស្រាយបញ្ហាកង្វះបុគ្គលិករដ្ឋសម្រាប់សេវាគន្លឹះ (ការផ្គត់ផ្គង់ទឹក និងសំណល់រឹង), រៀបចំលក្ខខណ្ឌយោងការងារសម្រាប់ រដ្ឋបាលក្រុង ស្រុក។

#### ថ្នាក់ឃុំ សង្កាត់

- **ដោះស្រាយភាពយឺតពេលនៃការរៀបចំ និងអភិវឌ្ឍន៍គម្រោង÷** គាំទ្រមន្ត្រីឃុំ សង្កាត់អនុវត្តសារាចរពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍, តាមដានការអនុវត្ត និងទទួលមតិត្រឡប់ដើម្បីធ្វើការពង្រឹងនាពេលខាងមុខ។

37

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – មតិរបស់ អ.គ.ហ. លើរបាយការណ៍របកគំហើញ

### ❖ ការអនុវត្តប្រព័ន្ធ FMIS

- គិតគូររៀបចំហត្ថលេខាអេឡិចត្រូនិក និងគោលនយោបាយឌីជីថល
- ពង្រឹងការប្រើប្រាស់ឧបករណ៍គ្រប់គ្រងសាច់ប្រាក់
- ពង្រីកវិសាលភាពប្រព័ន្ធ FMIS ដោយបូកបញ្ចូលទាំងគ្រប់ប្រភពមូលនិធិ
- ឌីជីថលូបនីយកម្មទៅការរៀបចំ និងការផ្ញើរបាយការណ៍។

### ❖ ការវាយតម្លៃថវិកាយេនឌ័រ

- រៀបចំមូលដ្ឋានគតិយុត្តអចិន្ត្រៃយ៍
- កំណត់រចនាសម្ព័ន្ធស្ថាប័ន
- សមាហរណកម្មទិដ្ឋភាពយេនឌ័រ ចូលក្នុងវដ្តថវិកា
- ប្រើប្រាស់ FMIS ដើម្បីកត់ត្រាថវិកាយេនឌ័រ
- រៀបចំ និងអនុវត្តការវាយតម្លៃបច្ច័យយេនឌ័រ។



38

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – មតិរបស់ អ.គ.ហ. លើរបាយការណ៍របកគំហើញ

### ❖ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Fiscal Management)

- បន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពចំណាយ
- គិតគូរអំពីបន្ទុកសារពើពន្ធ, និងពង្រីកមូលដ្ឋានពន្ធ (ពន្ធលើរូបវន្តបុគ្គល, ពន្ធលើចំណេញមូលធន, ពន្ធកាបូន និងពន្ធលើសេវាឌីជីថល)។

### ❖ វិស័យធនធានទឹកនិងធារាសាស្ត្រ

- កំណត់តួនាទីភារកិច្ចរបស់ថ្នាក់កណ្តាល និងថ្នាក់មន្ទីរ
- អនុវត្តមុខងារដែលបានផ្ទេរទៅក្រុងស្រុក
- លើកកម្ពស់សហថាមពល (Synergy) រវាងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងថវិកាជាតិ
- ពង្រឹងសហថាមពល (Synergy) ជាមួយវិស័យកសិកម្ម ផ្សារភ្ជាប់នឹងបម្រែបម្រួលអាកាសធាតុ។

### ❖ វិស័យសុខាភិបាល

- តម្រឹមរចនាសម្ព័ន្ធ PB និង BSP
- ដាក់ឱ្យអនុវត្តជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្មនៅក្នុងសំណើថវិកា
- ពង្រឹងការធ្វើសមាហរណកម្មចំណាយមូលធនហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- វិភាជចំណាយបន្ទុកបុគ្គលិកតាមកម្មវិធីនីមួយៗ។

### ❖ វិស័យកសិកម្ម

- តម្រឹមរចនាសម្ព័ន្ធ PB និង BSP
- ដាក់បញ្ចូលព័ត៌មានសមិទ្ធកម្មជាបណ្តើរៗនៅក្នុងសំណើថវិកាប្រចាំឆ្នាំ
- ពង្រឹងការសម្របសម្រួលក្នុងវិស័យពាក់ព័ន្ធកសិកម្ម
- ប្រតិភូកម្មសិទ្ធិអំណាចនិយ័តថវិកា ដើម្បីគាំទ្រភាពបត់បែនក្នុងការអនុវត្តថវិកា។

### ❖ រដ្ឋបាលខេត្តព្រះសីហនុ

- ពង្រឹងសមត្ថភាពរៀបចំផែនការ (BSP&PB)
- កែលម្អសមត្ថភាពព្យាករចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ និងពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការអនុវត្តមុខងារទាំង ៥៥
- គាំទ្រមន្ត្រីឃុំ សង្កាត់អនុវត្តសារាចរពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍។

39

## ៣. របកគំហើញនៃរបាយការណ៍វាយតម្លៃ – មតិរបស់ អ.គ.ហ. លើរបាយការណ៍របកគំហើញ

តាមរយៈរបកគំហើញនៃរបាយការណ៍វាយតម្លៃ, ធាតុចូលមួយចំនួន ត្រូវបានដាក់បញ្ចូលក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤ រួចរាល់។ បន្ថែមពីនេះ ធាតុចូលមួយចំនួនទៀតដែលផ្តល់តម្លៃបន្ថែម នឹងត្រូវគិតគូរដាក់បញ្ចូល ដោយមានកិច្ចពិគ្រោះយោបល់ជាមួយអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

40

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ

### លទ្ធផលនៃការវាយតម្លៃPEFA ថ្នាក់ជាតិ

ក្របខណ្ឌ PEFA ត្រូវបានប្រើប្រាស់សម្រាប់**វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា** ដែលសរុបការវាយតម្លៃទាំងអស់ចំនួនបីលើក គឺនៅឆ្នាំ២០១០, ឆ្នាំ២០១៥ និងឆ្នាំ២០២១។ អភិក្រមនៃការវាយតម្លៃ គឺប្រៀបធៀបលើលទ្ធផលទាំងបីលើកនេះ ហើយទាញការសន្និដ្ឋានលើលទ្ធផលវាយតម្លៃជាកម្រិតម៉ាក្រូ ដោយក្នុងនោះរួមមាន÷ (១) វិន័យថវិកា, (២) ប្រសិទ្ធភាពវិភាជន៍ថវិកា និង (៣) ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

របកគំហើញពីការវាយតម្លៃ PEFA ឆ្នាំ២០២១ ដែលប្រើប្រាស់ក្របខណ្ឌ PEFA ឆ្នាំ២០១១ បង្ហាញថាមានការកែលម្អក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងពិន្ទុនៃសូចនាករសមិទ្ធកម្ម (PIs) ចំនួន ១០ ក្នុងនោះរួមមាន÷ PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI19, PI-21, PI-23 និង PI-25។ រីឯ PI-3 ទទួលបានពិន្ទុទាបដោយសារមានគម្លាតខ្ពស់រវាងផែនការនិងលទ្ធផលប្រមូលចំណូលចាប់ពីឆ្នាំ២០១៧, ២០១៨ និង២០១៩។

PEFA

41

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ (ត...)

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០២១ | បម្រែបម្រួល |
|---|---|---|---|---|---|
| ១ | លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ ភាពជឿទុកចិត្តនៃថវិកា | | | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | B | A | A | មិនមាន |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | D | D+ | B+ | ʌ |
| PI-3 | ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | A | A | D | v |
| PI-4 | សន្និធិបំណុលកកស្ទះ និងការត្រួតពិនិត្យតាមដានចំណាយកកស្ទះ | C+ | D+ | D+ | មិនមាន |
| ២ | ការងារត្រួតស៊ីគ្នាសំខាន់ៗ ÷ ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា | | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | C | C | C | មិនមាន |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | B | C | B | ʌ |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | C | C | B | ʌ |
| PI-8 | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល(ថ្នាក់ជាតិនិងក្រោមជាតិ) | C+ | B | B | មិនមាន |
| PI-9 | ការត្រួតពិនិត្យហានិភ័យថវិកា ពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ | C+ | C+ | C+ | មិនមាន |
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | C | D | C | 42 ʌ |

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ (ត...)

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០២១ | បម្រែបម្រួល |
|---|---|---|---|---|---|
| ៣ | វដ្តថវិកា | | | | |
| ៣.១ | **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | | | |
| PI-11 | កាលានុក្រម និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | A | A | A | មិនមាន |
| PI-12 | ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកាគោលនយោបាយចំណាយ និងការរៀបចំថវិកា | B | C+ | C+ | មិនមាន |
| ៣.២ | **ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា** | | | | |
| PI-13 | តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | B | C+ | B | ∧ |
| PI-14 | ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធនិងការវាយតម្លៃពន្ធ | C | D+ | C+ | ∧ |
| PI-15 | ប្រសិទ្ធភាពនៃការប្រមូលពន្ធ | D+ | D+ | NA | មិនអាចប្រៀបធៀប |
| PI-16 | ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ | C+ | C+ | C+ | មិនមាន |
| PI-17 | ការកត់ត្រា និងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា | C+ | C+ | C+ | មិនមាន |
| PI-18 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស | D+ | D+ | D+ | មិនមាន |
| PI-19 | តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | NA | D | C+ | ∧ |
| PI-20 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស | C | C | C | មិនមាន |
| PI-21 | ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង | D+ | C | C+ | ∧ |

43

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ (ត...)

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០២១ | បម្រែបម្រួល |
|---|---|---|---|---|---|
| ៣ | វដ្តថវិកា (ត...) | | | | |
| ៣.៣ | **គណនេយ្យ, ការកត់ត្រា និងរបាយការណ៍** | | | | |
| PI-22 | ភាពទាន់ពេល និងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី | C | C | C | មិនមាន |
| PI-23 | អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា | C | D | B | ∧ |
| PI-24 | គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | C+ | C+ | C+ | មិនមាន |
| PI-25 | គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | D+ | D+ | C+ | ∧ |
| ៣.៤ | **ការត្រួតពិនិត្យ និងសវនកម្មខាងក្រៅ** | | | | |
| PI-26 | វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មពីខាងក្រៅ | D+ | NR | NA | មិនអាចប្រៀបធៀប |
| PI-27 | ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិបញ្ញត្តិ | NU | C+ | C+ | មិនមាន |
| PI-28 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅ ដោយអង្គនីតិបញ្ញត្តិ | NU | B | B | មិនមាន |
| ៤ | **ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍** | - | - | ពុំវាយតម្លៃ | - |

44

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ (ត...)

### វិន័យថវិកា

ចំពោះការអនុវត្តចំណាយថវិកាបង្ហាញថាមានភាពកាន់តែប្រសើរ ប៉ុន្តែចាំបាច់ត្រូវដោះស្រាយលើចំណាយកកស្ទះ (ទាំងផ្នែកនិយមន័យ និងបំណុលចាស់) និងការអនុវត្តចំណូលថវិកាត្រូវបន្តពង្រឹងការព្យាករចំណូល, ពង្រឹងរដ្ឋបាលប្រមូលចំណូលជាពិសេសអនុលោមភាព និងការគ្រប់គ្រងហានិភ័យ, ព្រមទាំងតាមដានលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ។

### ប្រសិទ្ធភាពវិភាជន៍ថវិកា

ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំស្របតាមប្រតិទិនថវិកា ប៉ុន្តែចាំបាច់ត្រូវបង្កើនគុណភាពឯកសារថវិកាបន្ថែមទៀត។ ការរៀបចំថវិការយៈពេលមធ្យមគឺស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ដោយហេតុថាក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម ពុំទាន់ត្រូវបានអនុវត្ត និងថវិការយៈពេលមធ្យមត្រូវបានអនុវត្តសាកល្បងចាប់ពីឆ្នាំ២០១៩។

### ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ

មិនទាន់អនុវត្តបានល្អនៅឡើយ ជាពិសេសកង្វះប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម, ការប្រកួត-ប្រជែងក្នុងកិច្ចលទ្ធកម្មនៅមានកម្រិត, និង តម្លាភាពថវិកា ក៏នៅមានកម្រិត ផងដែរ។



## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ (ត...)




**ពិនិត្យពិនិស្ច័យថវិកា**

- ជំនួយបច្ចេកទេសដើម្បីពិនិត្យលើសេចក្តីព្រាងច្បាប់ថវិកា និងរបាយការណ៍សវនកម្ម
- យន្តការតាមដានអនុសាសន៍សវនកម្មផ្ទៃក្រៅ ។

**រៀបចំផែនការ**

- ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រតាមវិស័យទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រតាមវិស័យ និងធនធាន ។

**រៀបចំថវិកា**

- សមាហរណកម្មថវិកាចរន្ត និងមូលធន
- ថវិការយៈពេលមធ្យម
- គុណភាព BSP និង PB (រចនាសម្ព័ន្ធកម្មវិធី និងសូចនាករ)
- ការប្រើប្រាស់ចំណាត់ថ្នាក់មុខងារ
- ការផ្សារភ្ជាប់រវាងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផែនការយុទ្ធសាស្ត្រថវិកា ។

**អនុវត្តថវិកា**

- ចំណាយកកស្ទះ និងបំណុលពន្ធ
- ការប្រើប្រាស់វិធីសាស្ត្រកិច្ចលទ្ធកម្ម រួមទាំងតម្លាភាព
- ការវិភាគ និងវាយតម្លៃហានិភ័យពន្ធ
- ការអនុវត្តមុខងារអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករ
- ភាពទាន់ពេលវេលានៃការផលិតរបាយការណ៍ហិរញ្ញវត្ថុ
- សមាហរណកម្មប្រព័ន្ធបៀវត្ស និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ។

**ត្រួតពិនិត្យ និងវាយតម្លៃ**

- ការវាយតម្លៃសមិទ្ធកម្មនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល
- ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម
- សវនកម្មលើសមិទ្ធកម្មស្ថិតក្នុងដំណាក់កាលចាប់ផ្តើម
- សវនកម្មលើបៀវត្ស
- មុខងារសវនកម្ម និងអធិការកិច្ច
- គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ។

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ក្រោមជាតិ

### លទ្ធផលនៃការវាយតម្លៃPEFA ថ្នាក់ក្រោមជាតិ

ការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ ផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធ និងដំណើរការរបស់រដ្ឋបាលរាជធានីភ្នំពេញ។ ការជ្រើសរើសយករដ្ឋបាលរាជធានីភ្នំពេញសម្រាប់ការវាយ-តម្លៃ គឺផ្អែកលើសនិទានភាពមួយចំនួន ជាអាទិ៍÷ រាជធានីភ្នំពេញ មិនត្រឹមតែជារាជធានីដែលមានចំនួនប្រជាជនច្រើនជាងគេនោះទេ ប៉ុន្តែមានស្ថានភាពលេចធ្លោពាក់ព័ន្ធនឹងសេដ្ឋកិច្ច សកម្មភាពអាជីវកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីនេះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលរាជធានីភ្នំពេញ មានលក្ខណៈខុសប្លែកមួយចំនួន បើធៀបជាមួយនឹងរដ្ឋបាលខេត្តដ៏ទៃទៀត។

PEFA

47

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ក្រោមជាតិ (ត...)

**ពិន្ទុវាយតម្លៃសូចនាករ PEFA ថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ**




48

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ក្រោមជាតិ (ត...)

- បង្កើនគុណភាព និងភាពទាន់ពេលវេលានៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- ការដាក់ឱ្យអនុវត្តថវិការយៈពេលមធ្យម (MTBF)

- ពង្រឹងមុខងារប្រតិតុល្យភាព
- ពង្រឹងការត្រួតពិនិត្យវដ្តថវិកា




- គុណភាពថវិកាកម្មវិធី (រចនាសម្ព័ន្ធកម្មវិធី, លទ្ធផលចុងក្រោយ និងលទ្ធផលចុងក្រោយ (សូចនាករ និងគោលដៅ)
- ការប្រើប្រាស់ចំណាត់ថ្នាក់មុខងារ
- ការគ្រប់គ្រងវិនិយោគសាធារណៈ
- បង្កើនតម្លាភាពថវិកា និងការចូលរួមពីសាធារណជន

- ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម
- សវនកម្មលើបៀវត្ស
- មុខងារសវនកម្ម

- ចំណាយកកស្ទះ
- ការប្រើប្រាស់វិធីសាស្ត្រកិច្ចលទ្ធកម្ម រួមទាំងតម្លាភាព
- ការអនុវត្តមុខងារអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករ
- ភាពទាន់ពេលវេលានៃការផលិតរបាយការណ៍ហិរញ្ញវត្ថុ

49

## ៥. បញ្ហាប្រឈម និងសំណូមពរវិធានការដោះស្រាយ

| ល.រ | បញ្ហាប្រឈម | សំណូមពរវិធានការដោះស្រាយ |
|---|---|---|
| *ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា* | | |
| ០១ | ការប្រមូលចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ មិនទាន់អស់សក្តានុពល ដែលទាមទារឱ្យមានការត្រួតពិនិត្យគ្រប់កិច្ចសន្យាជួលឡើងវិញ។ | - អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បានបញ្ចូល**សកម្មភាពត្រួតពិនិត្យកិច្ចសន្យាជួល** ទៅក្នុងផែនការសកម្មភាពលម្អិត (GDAP4) ឆ្នាំ២០២៣។<br>- *កិច្ចការនេះ គួរមានជាផែនការសកម្មភាពលម្អិតសម្រាប់ត្រួតពិនិត្យនិងកែសម្រួលកិច្ចសន្យាជួល ជាជំហានៗ។* |
| ០២ | នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាននៅរដ្ឋបាលថ្នាក់ជាតិ (ប្រកាសលេខ ៦៦៣) និងថ្នាក់ក្រោមជាតិ (ប្រកាសលេខ ៥៤៨)÷ ការបង្កើតរជ្ជទេយ្យបុរេប្រទានមិនឱ្យលើស ៣០% សម្រាប់គណនី និងអនុគណនី ដែលមានកញ្ចប់ថវិកាតូច (ឧទាហរណ៍. ២០ ឬ ១០ លានរៀលចុះ), អង្គភាពអនុវត្តជួបប្រទះបញ្ហាប្រឈមចំពោះការអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសម្រាប់ឥណទានថវិកានៅសល់ក្រោយដករជ្ជទេយ្យបុរេប្រទាន។ | - **នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាននៅរដ្ឋបាលថ្នាក់ជាតិ** បាននិងកំពុងដោះស្រាយដោយអគ្គនាយកដ្ឋានថវិកា និងអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ.។<br>- **នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ÷** អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងដោះស្រាយកិច្ចការនេះ ដោយពិនិត្យលើគតិយុត្តពាក់ព័ន្ធ និងបញ្ហាប្រឈមនៃការអនុវត្ត។<br>- *កិច្ចការនេះ គួរពន្លឿនការដោះស្រាយឱ្យបានរួចរាល់ត្រឹមឆ្នាំ២០២៣ សំដៅសម្រួលដល់ការអនុវត្តថវិកាទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានបច្ច័យដល់ការផ្តល់សេវាសាធារណៈ។* |

50

## ៥. បញ្ហាប្រឈម និងសំណូមពរវិធានការដោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណូមពរវិធានការដោះស្រាយ |
|---|---|---|
| ***ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ*** | | |
| ០៣ | ទម្រង់របាយការណ៍ដែលទាញចេញពីប្រព័ន្ធFMIS មិនទាន់មានសង្គតិភាពជាមួយទម្រង់របាយការណ៍ដែលកំណត់ក្នុងសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា ដែលជាហេតុនាំឱ្យអង្គភាពអនុវត្ត ត្រូវធ្វើការងារស្ទួនសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុ មានន័យថាត្រូវទាញចេញពីប្រព័ន្ធផង និងបំពេញទិន្នន័យដោយដៃផង។ | ក្រុមការងារគ្រប់គ្រងគម្រោង FMIS នឹងសហការជាមួយអគ្គនាយកដ្ឋានថវិកា រៀបចំទម្រង់របាយការណ៍ក្នុងប្រព័ន្ធ FMIS ឱ្យមានសង្គតិភាពជាមួយទម្រង់របាយការណ៍ក្នុងសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា។ |
| ០៤ | រដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងអនុវត្តប្រព័ន្ធ NRMIS, ប្រព័ន្ធ FMIS និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាពច្រកចេញចូលតែមួយ។ ប្រព័ន្ធ NRMIS និង ប្រព័ន្ធ FMIS នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធ្វើសន្ទានកម្មរួចរាល់ ប៉ុន្តែពុំទាន់ធ្វើសន្ទាកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាពច្រកចេញចូលតែមួយ នៅឡើយ ដែលផ្តល់ជាបន្ទុកការងារដល់អ្នកអនុវត្តប្រព័ន្ធ។ | ក្រុមការងារគ្រប់គ្រងគម្រោង FMIS នឹងសហការជាមួយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងក្រសួងមហាផ្ទៃ ធ្វើសន្ទានកម្មរវាងប្រព័ន្ធទាំង៣។ |



## ៥. បញ្ហាប្រឈម និងសំណូមពរវិធានការដោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណូមពរវិធានការដោះស្រាយ |
|---|---|---|
| ***ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ*** | | |
| ០៥ | រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ត្រូវបានស្នើឱ្យកែសម្រួលគម្រោងថវិកាប្រចាំឆ្នាំ បើទោះបីជាគម្រោងថវិកានេះ បានឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត និងកិច្ចប្រជុំចចារថវិកានៅកសហវ នាខែសីហា រួចហើយក៏ដោយ។ ការកែសម្រួលនេះ អាចប៉ះពាល់ដល់ផែនការថវិកា និងផែនការលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។ | ស្នើអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិពង្រឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ០៦ | បញ្ហាប្រឈម នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ រួមមាន៖<br>- ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមានវឌ្ឍនភាព ប៉ុន្តែប្រសិទ្ធភាពនិងគុណភាពនៅមានកម្រិត(ការរៀបចំពុំទាន់ពេលវេលា គ្រប់ចំនួន និងសុក្រឹតភាព)<br>- ការធ្វើបណ្ណកម្មសិទ្ធិដីរដ្ឋមានភាពយឺតយ៉ាវ ដែលទាមទារឱ្យមានការជំរុញ គាំទ្រ និងត្រួតពិនិត្យតាមដានជាប្រចាំ និងការចូលរួមពីអង្គភាពនៅគ្រប់កម្រិត និង<br>- យន្តការជម្រះបញ្ជីសារពើភណ្ឌនៅមានកម្រិត។ | - អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នឹងជំរុញការរៀបចំបញ្ចប់ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រឹមឆ្នាំ២០២៣ ស្របតាមគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ។** |

## ៥. បញ្ហាប្រឈម និងសំណូមពរវិធានការដោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណូមពរវិធានការដោះស្រាយ |
|---|---|---|
| *ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* | | |
| ០៧ | ការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសគុណភាពនៃការរៀបចំ និងការអនុវត្តសូចនាករកម្មវិធី នៅមានកម្រិត ដែលឆ្លុះបញ្ចាំងតាមរយៈការអនុវត្តថវិកានៅតែផ្ដោតសំខាន់លើមាតិកាសេដ្ឋកិច្ច។ | ស្នើអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បន្តជំរុញ និងពង្រឹងការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ០៨ | មុខងារ ៥៥ បានផ្ទេទៅរដ្ឋបាលក្រុង ស្រុក ដែលរដ្ឋបាលក្រុង ស្រុក ទទួលបានថវិកាតិច និងមិនមានការផ្ទេរថវិកាទៅតាមមុខងារទាំង ៥៥។ ថវិកាមួយចំនួនត្រូវបានផ្ទេរទៅរដ្ឋបាលក្រុង ស្រុក ប៉ុន្តែនីតិវិធីនៃការអនុវត្តថវិកា ពុំទាន់យល់ជាទស្សនាទានរួមគ្នានៅឡើយ។ ចំពោះទ្រព្យសម្បត្តិរដ្ឋរបស់ការិយាល័យក្រុង ស្រុក មានការយល់ខុសគ្នា ថាតើគួរផ្ទេរទៅរដ្ឋបាលក្រុងស្រុក ឬទុកជូនមន្ទីរជំនាញរាជធានី ខេត្ត។ | - ផ្អែកតាមសេចក្ដីណែនាំលេខ ០១៦ ស្ដីពីការលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការពាក់ព័ន្ធនឹងការរៀបចំថវិកាប្រចាំឆ្នាំ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពង្រីកវិសាលភាពក្រុមការងារផ្ទៃក្នុង កសហវ. ដោយបង្កើតជាក្រុមការងារអន្តរក្រសួង ដែលមានសមាសភាពពី គ.ជ.អ.ប. និងអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ. ដើម្បីសិក្សា និងវាយតម្លៃលើការផ្ទេរមុខងារ ៥៥ នេះ ក្នុងគោលដៅសម្របសម្រួល និងធានាថាធនធានហិរញ្ញវត្ថុ, ធនធានមិនមែនហិរញ្ញវត្ថុ (រួមទាំងធនធានមនុស្ស) និងចំណូលដែលបានផ្ទេរទៅដល់អង្គភាពអនុវត្តផ្ទាល់ នឹងមានភាពសមស្របទៅនឹងមុខងារដែលបានប្រគល់ជូនរដ្ឋបាលក្រុង ស្រុង។<br>- *កិច្ចការនេះ គួរបញ្ចប់ឱ្យបានរួចរាល់នៅក្នុងឆ្នាំ២០២៣ ដើម្បីចៀសវាងបច្ច័យលើការផ្ដល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។* |

53

## ៥. បញ្ហាប្រឈម និងសំណូមពរវិធានការដោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណូមពរវិធានការដោះស្រាយ |
|---|---|---|
| *ផ្នែកទី៤÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម* | | |
| ០៩ | ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម នឹងជួបប្រទះទៅបញ្ហាប្រឈម បើសិនក្រសួង ស្ថាប័ន ពុំទាន់ត្រៀមខ្លួនឱ្យបានរួចរាល់ ជាពិសេសយន្តការនៃការតាមដានត្រួត-ពិនិត្យនិងវាយតម្លៃថវិកាសមិទ្ធកម្ម ខណៈហិរញ្ញវត្ថុនឹងត្រូវវិមជ្ឈការកាន់តែច្រើនឡើងទៅក្រសួង ស្ថាប័ន។ | ស្នើក្រសួង ស្ថាប័ន សាកល្បងត្រៀមរៀបចំយន្តការនៃតាមដានត្រួតពិនិត្យនិងវាយតម្លៃថវិកាសមិទ្ធកម្មនៅផ្ទៃក្នុងក្រសួង ស្ថាប័ន។ |
| ១០ | ក្រសួង ស្ថាប័នមួយចំនួនធំ ពុំទាន់គិតគូរចាប់ផ្ដើមសាកល្បងអនុវត្តសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ខណៈនិន្នាការនៃការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម តម្រូវឱ្យមានការពង្រឹងការធ្វើសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ | ស្នើក្រសួង ស្ថាប័ន ចាប់ផ្ដើមគិតគូរសាកល្បងធ្វើសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ |

54

## ៥. បញ្ហាប្រឈម និងសំណូមពរវិធានការដោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណូមពរវិធានការដោះស្រាយ |
|---|---|---|
| *ផ្នែកទី៥÷ ការកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡានៃការកែទម្រង់* | | |
| ១១ | ការបែងចែកប្រាក់រង្វាន់ពីចំណូលសេវាសាធារណៈ នៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ពុំទាន់មានគោលការណ៍រួម ( *គោលការណ៍បែងចែកប្រាក់រង្វាន់ផ្ទៃក្នុងស្ថាប័ន, ឧទា. ការអនុវត្តប្រកាស ៦១៦ របស់ កសហវ.*) ដែលពុំទាន់ធានាបាននូវប្រសិទ្ធភាពនៃការបែងចែក ក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ។ | ស្នើអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ រៀបចំបទដ្ឋានគតិយុត្តស្តីពីការគោលការណ៍រួមសម្រាប់ការបែងចែករង្វាន់ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ |
| ១២ | ការរៀបចំផែនការ និងការរាយការណ៍របស់អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង ស្ថាប័ន ក្នុងក្របខណ្ឌ PFMRP មានភាពប្រសើរឡើងជាលំដាប់។ ប៉ុន្តែពុំទាន់មានសង្គតិភាពពេញលេញទៅនឹងផែនការសកម្មភាពរួម(CAP) នៅឡើយ។ | - ស្នើអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង ស្ថាប័នបន្តគាំទ្រការអនុវត្តផែនការសកម្មភាពរួម ជាពិសេសក្នុងដំណាក់កាលទី៤។<br>- *ដើម្បីពង្រឹងលើកិច្ចការនេះ គួរមាន ការគិតគូររៀបចំជាកិច្ចព្រមព្រៀងសមិទ្ធកម្មក្នុងក្របខណ្ឌ PFMRP ដោយផ្សារភ្ជាប់ ជាមួយការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត។* |

55

## ៦. សំណូមពរបន្ថែម

(១). ស្នើក្រសួង ស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធ ដាក់បញ្ចូលការរៀបចំ និងកែសម្រួលប្រកាសអន្តរក្រសួងពាក់ព័ន្ធ ក្នុង MAP ឆ្នាំ២០២៣ បន្ទាប់ពី *សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ* ចូលជាធរមាន។

(២). ស្នើក្រសួង ស្ថាប័នរួមមាន÷ *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសុខាភិបាល, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ* រៀបចំវេទិកាសាធារណៈអំពីកញ្ចប់ថវិកាប្រចាំឆ្នាំ និងរៀបចំសៀវភៅថវិកាពលរដ្ឋ ដោយពិនិត្យលទ្ធភាពយកគំរូតាមសៀវភៅថវិកាសង្ខេបដែលចេញដោយ កសហវ.។

(៣). ស្នើអគ្គនាយកដ្ឋានថវិកាបន្តបណ្តុះបណ្តាលអំពីការរៀបចំ ការអនុវត្ត និងការតាមដានការអនុវត្តថវិកាព័តិមានសមិទ្ធកម្ម ជូនក្រសួង ស្ថាប័ន ក្នុងករណីមានតម្រូវការជាក់ស្តែង។

(៤). ស្នើអគ្គនាយកដ្ឋានគោលនយោបាយ បន្តជំរុញការរៀបចំស្តង់ដាតម្លៃ ដែលជាគន្លឹះជួយដល់ផ្នែកចរចាថវិកា ការអនុវត្តកិច្ចលទ្ធកម្ម និងសវនកម្ម។

(៥). ស្នើរៀបចំវិបស្សនារបស់ កសហវ. ប្រចាំឆ្នាំ២០២២។

(៦) ស្នើក្រុមការងារគ្រប់គ្រងគម្រោង FMIS សហការជាមួយក្រសួងមុខងារសាធារណៈ ជំរុញការធ្វើសន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិល ឱ្យបានពេញលេញ។

(៧). ស្នើក្រុមការងារគ្រប់គ្រងគម្រោង FMIS បន្តជំរុញការរៀបចំការអនុវត្ត FMIS តាមអនឡាញសម្រាប់ថ្នាក់ដឹកនាំ ដើម្បីងាយស្រួលក្នុងការអនុម័តចំណាយនៅពេលមានបេសកកម្មនៅក្នុង និងក្រៅប្រទេស។

(៨). ស្នើបញ្ចូលរដ្ឋបាលរាជធានី ខេត្ត ចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខណៈរដ្ឋបាលរាជធានី ខេត្តបាននិងកំពុងដើរតួនាទីសំខាន់ក្នុងការអនុវត្តវិធានការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

(៩). ស្នើអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ជំរុញការសិក្សាបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅតាមរដ្ឋបាលរាជធានី ខេត្ត ជាជំហានៗ ដោយផ្តោតជាអាទិភាពលើរាជធានី ខេត្ត ដែលមានទំហំថវិកាច្រើន។ រដ្ឋបាលរាជធានី ខេត្ត ពុំទាន់មានអង្គភាពសវនកម្មផ្ទៃក្នុង ដែលជាយន្តការសម្រាប់ធានាប្រតិតុល្យការ រវាងក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈអភិបាលរាជធានី ខេត្ត។

(១០). ស្នើអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ពង្រឹងគុណភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយសហការជាមួយអគ្គនាយកដ្ឋានថវិកា និង អ.គ.ហ. ដែលកិច្ចការនេះ រួមចំណែកជួយដល់ផ្នែកចរចាថវិកាទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

(១១) ស្នើអង្គភាព/ស្ថាប័នពាក់ព័ន្ធ រៀបចំផែនការលម្អិតសម្រាប់អនុវត្តវិធានការ បន្ទាប់ពីមានការសម្រេចពី គ.ហ.ស.។

56

## ៧. សន្និដ្ឋានរួម

ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំ២០២២, សកម្មភាពជាច្រើនសម្រេចបានតាមគោលដៅ ខណៈសកម្មភាពមួយចំនួនកំពុងមានវឌ្ឍនភាព និង បន្តអនុវត្តក្នុងផែនការសកម្មភាពរួម ចំណាក់កាលទី៤ ហើយ **សកម្មភាពគន្លឹះពាក់ព័ន្ធនឹងការបញ្ចប់ការត្រៀមខ្លួន សម្រាប់ជំហានបន្ទាប់** ត្រូវបាននិងកំពុងឈានទៅបញ្ចប់ជាបណ្តើរៗ។ គុណភាពនៃការរៀបចំ GDAP/PDAP/MAP និងរបាយការណ៍ មានភាពប្រសើរជាងមុន ប៉ុន្តែការពង្រឹង**សង្គតិភាពឱ្យបានពេញលេញ ទៅនឹងផែនការសកម្មភាពរួម** ត្រូវបន្តយកចិត្តទុកដាក់។

ការវាយតម្លៃ **PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** បានផ្តល់ជាបន្ទាត់មូលដ្ឋានអំពីស្ថានភាព នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា និងការពិនិត្យលើប្រសិទ្ធភាពប្រព័ន្ធ និងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់ **PER** ដែលជាធាតុចូលសម្រាប់រៀបចំ **ក្របខណ្ឌផែនការសកម្មភាពរួម** តាមរយៈការកំណត់ការងារអាទិភាព។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺចាំបាច់ត្រូវពង្រឹងជាប្រចាំ និងកសាងសមាសធាតុសំខាន់ៗបន្ថែមទៀត ដើម្បីឆ្លើយតបបានទៅនឹងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗដែលអាចកើតមានជាយថាហេតុ។

**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ តាមរយៈការធានានូវ **កំណើនសេដ្ឋកិច្ចដែលស្ថិតក្នុងនិន្នាការសុទិដ្ឋិនិយម** និងប្រកបដោយបរិយាប័ន្ន និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាជន ព្រមទាំងរួមចំណែក**សម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា**។



## ៧. សន្និដ្ឋានរួម (ត...)

### ភាពជឿទុកចិត្តនៃថវិកា

ភាពជឿទុកចិត្តនៃថវិកា នៅតែរក្សាបាននូវ**ស្ថានភាពរឹងមាំ** ដែលបានបន្តក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច ដែលស្ថិតក្នុងទស្សនវិស័យសុទិដ្ឋិនិយម ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ មានភាពធូរស្បើយ។ ប៉ុន្តែត្រូវធ្វើ **ពិពិធកម្មចំណូលបន្ថែម** និងពង្រឹងការកៀរគរចំណូលឱ្យអស់សក្តានុពល ទន្ទឹមនឹងត្រូវ**ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តចំណាយ** ជាពិសេសរំហូរចំណាយតាមត្រីមាស។

### គណនេយ្យភាពហិរញ្ញវត្ថុ

បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពហិរញ្ញវត្ថុ ត្រូវបានកសាង និងពង្រឹងបន្ថែមដែលជាឆ្លុះបញ្ចាំងតាមរយៈការពង្រីកការដ្ឋាន និងពង្រឹង**ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**។ ប្រព័ន្ធគណនេយ្យនឹងត្រូវពង្រឹងបន្ថែមទៀត តាមរយៈការអនុវត្តជាដំណាក់កាលនូវ **យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១**។

### ការផ្សារភ្ជាប់ថវិកាគោលនយោបាយ

ក្របខណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំពង្រឹង និងពង្រីកការអនុវត្តទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបករណ៍សំខាន់ សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ប៉ុន្តែត្រូវបន្តយកចិត្តទុកដាក់លើ**ការបង្កើនអង្គភាពថវិកា និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ** ខណៈការឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម សិទ្ធិអំណាច និងថវិកានឹងត្រូវធ្វើវិមជ្ឈការ ទៅអង្គភាពអនុវត្តផ្ទាល់កាន់តែច្រើន។

### គណនេយ្យភាពសមិទ្ធកម្ម

បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពសមិទ្ធកម្ម ត្រូវបាននិងកំពុងរៀបចំបញ្ចប់ដែលឆ្លុះបញ្ចាំង តាមរយៈការរៀបចំ **សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** និង **សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ** ដែលរំពឹងថានៅត្រូវចូលជាធរមានក្នុងឆមាសទី១ ឆ្នាំ២០២៣។ ទន្ទឹមនេះ ត្រូវបន្តយកចិត្តទុកដាក់លើការពង្រឹងការអនុវត្ត **ក្របខណ្ឌតាមដាន និងវាយតម្លៃ** និង **ការអនុវត្តសវនកម្មសមិទ្ធកម្ម និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** នៅតាមក្រសួង ស្ថាប័ន។

## ៧. សន្និដ្ឋានរួម (ត...)

ជារួម កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខឿន ៣ និងដំណាក់កាលទី៣ ដែលមានរយៈពេល ៧ ឆ្នាំ (២០១៦-២០២២) **សម្រេចបានជាសារវ័ន្ត** តាមរយៈការកសាង និងកែលម្អប្រព័ន្ធ គតិយុត្ត យន្តការស្ថាប័ន និងធនធានមនុស្ស ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់អនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង និងបញ្ជ្រាប "**វប្បធម៌សមិទ្ធកម្ម**" នៅក្នុងក្របខណ្ឌរាជរដ្ឋាភិបាល និងទូទាំងមន្ត្រីរាជការ។

ស្ថាប័នរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តថវិកាសមិទ្ធកម្ម ជាមួយនឹងការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មផ្សារភ្ជាប់នឹងគោលនយោបាយ (NSDP/BSP/PB) ដែលមានបច្ច័យដល់ (១) ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច, (២) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៣) ការផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលអាចបោះជំហានទៅកាន់ខឿនទី៤ និងដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ប្រកបដោយភាពជឿជាក់ ប្រាកដនិយម និង ប្រកាន់ខ្ជាប់នូវអភិក្រមឆ្លងស្ទឹងស្មាបថ្ម ព្រមទាំងយន្តការបុរេសកម្ម សកម្ម និងអន្តរសកម្ម។



## អភិក្រមការងារ ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១. អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ
២. អនុវត្តការងារជាក្រុម
៣. អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និងគោលការណ៍ប្រសិទ្ធភាពថវិកា
៤. មិនត្រូវមើលរំលងកំហុសខ្លួនឯង

**សូមអរគុណ!**

# ឧបសម្ព័ន្ធទី ៧÷ បទបង្ហាញស្តីពីរបាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់កិច្ចប្រជុំត្រួត-ពិនិត្យប្រចាំឆ្នាំ២០២២ (ភាសាខ្មែរ)

កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២
ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ (PFM-TWG)

# របាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៤ និងឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

"ការកសាង និងកែលម្អប្រព័ន្ធ÷ អភិបាលកិច្ច, ក្របខណ្ឌគតិយុត្ត, ស្ថាប័នីយកម្ម និងធនធានមនុស្ស"

ថ្ងៃពុធ ៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ត្រូវនឹងថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២៣

1

## មាតិកា


១. សេចក្តីផ្តើម
២. វឌ្ឍនភាពប្រចាំឆ្នាំ២០២២ នៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣
៣. មតិ អ.ត.ហ. លើរបកគំហើញនៃរបាយការណ៍វាយតម្លៃ
៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៥. មតិយោបល់ដៃគូអភិវឌ្ឍន៍ និងការឆ្លើយតប
៦. សំណូមពរបន្ថែម
៧. សន្និដ្ឋានរួម


2

## ១. សេចក្តីផ្តើម – សាវតារ និងគោលបំណង

សារាចរលេខ ០៩ សរ របស់ រាជរដ្ឋាភិបាល ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០១៥

តាមដាន និងវាយតម្លៃការអនុវត្ត ផែនការសកម្មភាពរួម ដំណាក់-កាលទី៣ ប្រចាំឆ្នាំ២០២២

របាយការណ៍នេះ ឆ្លុះបញ្ចាំងទាំងទិដ្ឋភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់ឧបករណ៍ស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីធានាថាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតលើវិថីកែទម្រង់ដ៏ត្រឹមត្រូវ និងបោះជំហានឈានទៅដំណាក់កាលទី៤ ប្រកបដោយជវភាព និងគណនេយ្យភាព។

3

## ១. សេចក្តីផ្តើម – វិធីសាស្ត្ររៀបចំរបាយការណ៍




❖ *កំណត់សម្គាល់÷ របាយការណ៍នេះ គឺជារបាយការណ៍រួមរបស់គ្រប់តួអង្គពាក់ព័ន្ធ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។*

4

## ២. វឌ្ឍនភាពប្រចាំឆ្នាំ២០២២ នៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣

*២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស.*

*២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣*

5

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពសម្រេចបាន

❖ *ការសម្រេចរបស់ គ.ហ.ស. មានចំនួន ៣១ ចំណុច ក្នុងនោះសម្រេចបាន ១៦ និង ១៥ ចំណុចកំពុងបន្តតាមដាន។*

(១). ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

(២). របាយការណ៍ PEFA ថ្នាក់ក្រោមជាតិ ឆ្នាំ២០២១

(៣). ចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

(៤). យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១

(៥). របាយការណ៍វាយតម្លៃលើបច្ច័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

(៦). ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១

(៧). របាយការណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ក្របខណ្ឌ TADAT

(៨). របាយការណ៍វាយតម្លៃការអនុវត្តក្របខណ្ឌថវិកា(ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) តាមរយៈការប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈ– PER)

(៩). បច្ចុប្បន្នភាព គ.ហ.ស., គ.ក.ហ.និង ក.ហ.ស. ក្នុងក្របខណ្ឌ PFMRP

(១០). ក្របខណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ *

(១១). ការជំរុញ និងត្រួតពិនិត្យការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ តាមរយៈយន្តការ MAP4 (២១ក្រសួង ស្ថាប័ន ក្នុងនោះមាន ៥ អនុវត្តមិនទាន់ពេញលេញ) *

(១២). ការពិនិត្យលើការផ្ទេរមុខងារចំនួន ៥៥ ទៅរដ្ឋបាលក្រុង ស្រុក និងថវិកាឱ្យស្របតាមមុខងារទាំង ៥៥ *

(១៣). ការជំរុញការអនុវត្ត SARMIS ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ *

(១៤). ការជំរុញការរៀបចំបណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ *

(១៥). ការជំរុញក្រសួង-ស្ថាប័នអាទិភាពចំនួន ៥ - ៧ រៀបចំ FMM *

(១៦). ការបង្កើតក្រុមការងារអន្តរអគ្គនាយកដ្ឋាន នៃ កសហវ. សិក្សា និងវាយតម្លៃអំពីមុខងាររបស់មន្ទីរ សហវ. និងលិខិតបទដ្ឋានគតិយុត្ត តាមរយៈសេចក្តីសម្រេចលេខ ១២០ សហវ. ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២២។ *

**វិធានការសម្រេចបាន ប៉ុន្តែត្រូវបន្តជំរុញបន្ថែមទៀត។* 6

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

**១. សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ** *[GDB, ត.ម ២ ឆ្នាំ២០២៣]*

សេចក្តីព្រាងច្បាប់ ត្រូវបានពិនិត្យនិងសម្រេចដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៣ និងបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិនៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២៣។

**២. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ** *[GDSPNTR; តម៤, ២០២៣]*

បានរៀបចំជាទម្រង់ និងខ្លឹមសារព្រាង។ សេចក្តីព្រាងច្បាប់នេះ រង់ចាំឯកសារយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ។

**៣. ការកែសម្រួលអនុក្រឹត្យលេខ៨១ អនក្រ.បក និងអនុក្រឹត្យលេខ៨២ អនក្រ.បក** *[GDB & GDNT ; ត.ម២, ២០២៣]*

សេចក្តីព្រាងអនុក្រឹត្យលេខ ៨១+៨២ ត្រូវបានបញ្ចូលគ្នា និងកំណត់ឈ្មោះថ្មី "ការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ"។

**៤. សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** *[GSC, GDSPNTR, GDB, GDNT, GDSNAF; ត.ម.២, ២០២៣]*

ក្រុមការងារទទួលបន្ទុក បាននិងកំពុងកែសម្រួលសេចក្តីព្រាងអនុក្រឹត្យចុងក្រោយតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ដើម្បីបន្តនីតិវិធីគោរពជូនប្រមុខរាជរដ្ឋាភិបាល អនុម័តដ៏ខ្ពង់ខ្ពស់។

**៥. គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល (PFMM)** *[GSC; តម៤, ២០២៣]*

សេចក្តីព្រាងគោលការណ៍ណែនាំ ត្រូវបានធ្វើបច្ចុប្បន្នភាពដោយបន្តតម្រឹមជាមួយសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និងគ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី២ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៣។

7

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន (ត...)

**៦. ក្របខណ្ឌរួម ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ** *[GSC; តម៣, ២០២៣]*

ក្រុមការងារទទួលបន្ទុកបានរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍របកគំហើញរបស់ជំនាញការ។ បច្ចុប្បន្ន ក្រុមជំនាញការបាននិងកំពុងប្រមូលធាតុចូលបន្ថែមទៀតពីភាគីពាក់ព័ន្ធ។

**៧. កម្មវិធីសិក្សាភ្ជាប់វិញ្ញាបនបត្រ (Certificate Program) ដោយផ្សារភ្ជាប់មុខតំណែងឱ្យបានគ្រប់ជ្រុងជ្រោយ** *[EFI ; ត.ម៤,២០២៣]*

ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំពិគ្រោះយោបល់ជាមួយគ្រប់ក្រសួង ស្ថាប័ន និង អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទ កសហវ ដើម្បីរៀបចំជាសេចក្តីព្រាងអនុក្រឹត្យ។

**៨. ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** *[GDSPNTR; ត.ម៤, ២០២៣]*

បានរៀបចំផែនការសកម្មភាពលម្អិតដើម្បីធ្វើការជាមួយភាគីពាក់ព័ន្ធ។ ក្រុមការងារទទួលបន្ទុកចាប់ផ្តើមប្រមូលធាតុចូលពីក្រសួង ស្ថាប័នសំខាន់ៗ។

**៩. ឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** *[GDSPNTR; ត.ម.២, ២០២៣]*

ឯកសារគោលនេះ ត្រូវបានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។ គ្រោងដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាត្រីមាសទី ១ ឆ្នាំ២០២៣

**១០. សេចក្តីព្រាងផែនការរៀបចំក្របខណ្ឌនិងវិធានស្តីពីសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** *[GI & GDIA; ត.ម៤, ២០២៣]*

មានសេចក្តីព្រាងរបាយការណ៍សិក្សាស្រាវជ្រាវរបស់ទីប្រឹក្សាបារាំងលើមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច។

8

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន (ត...)

**១១. មូលនិធិ PFMRP គ្រប់ជ្រុងជ្រោយ** *[GSC; ត.ម១, ២០២៣]*

បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគ្រោងនឹងគោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យនិងសម្រេច ដើម្បីបន្តនីតិវិធីគោរពជូនប្រមុខរាជរដ្ឋាភិបាលដើម្បីអនុម័តនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៣។

**១២. សន្ទានកម្មរវាង FMIS និង EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា លើមុខងារការទិញ (PO) និងមុខងារគណនីត្រូវសង (AP)** *[FMIS & MoEYS ; ត.ម៤, ២០២៣]*

ក្រុមការងារទទួលបន្ទុកទាំងពីរបានប្រជុំពិភាក្សា និង ផ្តល់នូវទិន្នន័យសំខាន់ៗសម្រាប់បង្កើតប្រតិបត្តិការក្នុងប្រព័ន្ធ FMIS។

**១៣. ការដកស្រង់បទពិសោធន៍ និងការសិក្សាឧត្តមានុវត្តន៍អន្តរជាតិ អំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំក្របខណ្ឌគតិយុត្តបន្ថែម និងយន្តការ នៃការគ្រប់គ្រងគ្រឹះស្ថាន។** *[ក្រុមការងារបច្ចេកទេសកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាល(GDB); ត.ម. ៤. ២០២៣]*

.....

**១៤. ឯកសារយុទ្ធសាស្រ្តកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ** *[ក្រុមការងារបច្ចេកទេសកែទម្រង់សហគ្រាសសាធារណៈ (GDSPNTR); ត.ម. ៤, ២០២៣]*

បានប្រជុំពិនិត្យកែសម្រួលខ្លឹមសារ ដែលបានព្រាង។

**១៥. របាយការណ៍សិក្សានិងវាយតម្លៃអំពីមុខងារភារកិច្ចរបស់មន្ទីរ សហវ. ស្របតាមទិសដៅយុទ្ធសាស្រ្តនៃការកែទម្រង់ក្រោម PFMRP និងសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)** *[GSMEF; ត.ម. ៣, ២០២៣]*

បានបង្កើតក្រុមការងារសិក្សានិងវាយតម្លៃតាមរយៈសេចក្តីសម្រេចលេខ ១២០ សហវ. ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២២។

9

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វិធានការបន្ថែម

❖ *គ.ហ.ស. បានសម្រេចជាវិធានការបន្ថែមចំនួន ២៤ ចំណុច*

(១) ត្រួតពិនិត្យគ្រប់កិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ដោយមានរៀបចំជាផែនការសកម្មភាពត្រួតពិនិត្យជាក់លាក់ *[GDSPNTR; ២០២៣-២០២៤]*

(២) ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការបង្កើតរជ្ជទេយ្យបុរេប្រទានមិនឱ្យលើស ៣០% សម្រាប់គណនី និងអនុគណនី ដែលមានកញ្ចប់ថវិកាតូច *[GDB, GDSNAF, GDNT, GDPP; ២០២៣]*

(៣) បញ្ចប់ការរៀបចំសេចក្តីព្រាងអនុក្រឹត្យពាក់ព័ន្ធនឹងការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ។ ក្រសួង ស្ថាប័ន ជំរុញការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ *[GDNT, LMs; ២០២៣]*

(៤) ក្រសួង ស្ថាប័ន ជំរុញការរៀបចំ FMM ដើម្បីសម្រួលដល់ការអនុវត្តនីតិវិធីហិរញ្ញវត្ថុនៅផ្ទៃក្នុងក្រសួង ស្ថាប័ន *[LMs, ២០២៤-២០២៥]*

(៥) ក្រសួង ស្ថាប័ន ជំរុញការប្រើប្រាស់ឧបករណ៍ Web-based ឱ្យបានពេញលេញសម្រាប់ការគ្រោងរំហូរសាច់ប្រាក់ នៅតាមត្រីមាសនីមួយៗ *[LMs; ២០២៣]*

(៦) សន្ទានកម្មរវាងប្រព័ន្ធ NRMIS និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាពច្រកចេញចូលតែមួយ *[GDSPNTR, NCDD; ២០២៣]*

(៧) រៀបចំទម្រង់របាយការណ៍ក្នុងប្រព័ន្ធ FMIS ឱ្យមានសង្គតិភាពជាមួយទម្រង់របាយការណ៍ក្នុងសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា *[FMWG, ២០២៣]*

(៨) ពង្រឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចៀសវាងផលប៉ះពាល់ដល់ផែនការថវិកា និងផែនការលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ *[GDSNAF; ២០២៣]*

(៩) ជំរុញការរៀបចំបញ្ចប់ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ *[GDSPNTR; ២០២៣]*

(១០) ពង្រឹងការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចៀសវាងការអនុវត្តថវិកានៅតែផ្តោតសំខាន់លើមាតិកាសេដ្ឋកិច្ច *[GDSNAF; ២០២៣]*

(១១) វាយតម្លៃការផ្ទេរមុខងារ ៥៥ ក្នុងគោលដៅសម្របសម្រួល និងធានាថាធនធានហិរញ្ញវត្ថុ, ធនធានមិនមែនហិរញ្ញវត្ថុ (រួមទាំងធនធានមនុស្ស) និងចំណូលដែលបានផ្ទេរទៅដល់អង្គភាពអនុវត្តផ្ទាល់ នឹងមានភាពសមស្របទៅនឹងមុខងារដែលបានប្រគល់ជូនរដ្ឋបាលក្រុង ស្រុក *[GDSNAF; ២០២៣]*

(១២) រៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មក្នុងក្របខណ្ឌ PFMRP ដោយផ្សារភ្ជាប់ជាមួយការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត *[GSC; ២០២៣]*

10

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វិធានការបន្ថែម

(១៣) សិក្សាអំពីការរៀបចំបទដ្ឋានគតិយុត្តស្តីពីគោលការណ៍រួមសម្រាប់ការបែងចែករង្វាន់លើកទឹកចិត្តទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ *[GSC; ២០២៣]*

(១៤) ជំរុញការរៀបចំស្តង់ដាតម្លៃ *[GDP; ២០២៣]*

(១៥) ជំរុញការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង នៅតាមរដ្ឋបាលរាជធានី ខេត្ត *[GDSNAF; ២០២៣]*

(១៦) បន្តជំរុញការរៀបចំការអនុវត្ត FMIS តាមអនឡាញ *[FMWG; ២០២៣]*

(១៧) សិក្សាបញ្ចូលរដ្ឋបាលរាជធានី ខេត្ត ចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ *[GDSNAF, GSC; ២០២៣]*

(១៨) បន្តបណ្តុះបណ្តាលអំពីការរៀបចំ ការអនុវត្ត និងការតាមដានការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ជូនក្រសួង ស្ថាប័ន *[GDB; ២០២៣]*

(១៩) ជំរុញការធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិលឱ្យបានពេញលេញ *[FMWG, MCS; ២០២៣]*

(២០) ពង្រឹងគុណភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ *[GDSNTR, LMs; ២០២៣]*

(២១) រៀបចំ និងកែសម្រួលប្រកាសអន្តរក្រសួងពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ [LMs; ២០២៣]

(២២) រៀបចំវេទិកាសាធារណៈអំពីកញ្ចប់ថវិកាប្រចាំឆ្នាំ និងរៀបចំសៀវភៅថវិកាពលរដ្ឋ *[MoWRAM, MISTI, MoYES, MoSAVYR; ២០២៣]*

(២៣) រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃថវិកាសមិទ្ធកម្មនៅផ្ទៃក្នុងក្រសួង ស្ថាប័ន *[LMs; ២០២៣]*

(២៤) គិតគូរធ្វើសវនកម្មសមិទ្ធកម្ម និងសវនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន *[LMs; ២០២៣]*



## ២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី ៣

*ផ្នែកទី ១ ÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា*

*ផ្នែកទី ២ ÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ*

*ផ្នែកទី ៣ ÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*

*ផ្នែកទី ៤ ÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម*

*ផ្នែកទី ៥ ÷ ការកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡានៃការកែទម្រង់*







| | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 ប. |
|---|---|---|---|---|---|---|---|
| ត. ម៤ | 98.21% | 100.68% | 99.00% | 99.05% | 83.21% | 104.40% | 81.69% |
| ត. ម៣ | 58.71% | 58.79% | 60.93% | 54.74% | 57.49% | 65.13% | 58.64% |
| ត. ម២ | 34.10% | 35.04% | 34.46% | 32.87% | 36.75% | 40.12% | 37.39% |
| ត. ម១ | 15.19% | 15.40% | 15.61% | 14.90% | 16.23% | 19.98% | 17.91% |

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

# ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

### ❖ ការគ្រប់គ្រងចំណូលសារពើពន្ធ

- ភាគរយនៃអ្នកជាប់ពន្ធបង់ប្រាក់ពន្ធទាន់ពេលវេលាប្រចាំឆ្នាំ២០២២ សម្រេចបានជារួមប្រមាណ ៨៨.៧០%
- ការប្រមូលបំណុលពន្ធក្នុងឆ្នាំ២០២២ សម្រេចបានប្រមាណ ១៤.៧៤% នៃបំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២១
- បានដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ដំណាក់កាលទី៣
- ចំនួនសមាជិកក្រុមធុរជនល្អបំផុត ត្រូវបានបង្កើនចំនួន ៦។

### ❖ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- សារាចរណែនាំលេខ០១១ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើ-ប្រាស់ ប្រព័ន្ធ NRMIS ដំណាក់កាលទី២ ជំហានទី២ ដល់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ
- សារាចរលេខ ០០៣ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ E-payment ជំហានទី៣
- ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធចូលជាធរមាន
- ឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានរៀបចំជាសេចក្តីព្រាង។

### ❖ ការគ្រប់គ្រងកិច្ចលទ្ធកម្ម

- អនុម័តផែនការលទ្ធកម្មឆ្នាំ២០២៣ បាន ១១០/១១៥ ស្ថាប័ន (ថ្នាក់ជាតិ និងថ្នាក់-ក្រោមជាតិ) ឬប្រមាណ ៩៦%
- ផ្តល់របាយការណ៍លទ្ធកម្មឆ្នាំ២០២១ បាន ៤៥៧/៦៣៩ (អង្គភាពថវិកា) ឬប្រមាណ ៧១%
- ការអនុវត្តសិទ្ធិសម្រេចលទ្ធកម្មជំហានទី២ បានរៀបចំជាសេចក្តីព្រាងប្រកាស
- ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលើថវិកាចរន្ត និងមូលធន ក្នុងឆ្នាំ២០២១ បាន ប្រមាណ ៥៦%
- សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ថ្មី)។

### ❖ ការអនុវត្តថវិកា

- ការទូទាត់តាម E-Transfer អនុវត្តបាន ១០០%
- ក្រសួង ស្ថាប័នចំនួន ១៣ បានរៀបចំ FMM (៣ ក្រសួង មានសេចក្តីព្រាង)
- ផែនការរជ្ជទេយ្យបុរេប្រទានសម្រាប់ចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័ន (១០០%)
- ក្របខណ្ឌផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាព សម្រាប់ដោះស្រាយចំណាយកកស្ទះ
- ការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ÷ ២១ក្រសួង ស្ថាប័ន ក្នុងនោះមាន ៥ ពុំទាន់អនុវត្តពេញលេញ។

15

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

# ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

### សន្និដ្ឋាន

ចំណូលថវិកាជាតិនៅតែមានស្ថានភាពរឹងមាំ ប៉ុន្តែវិហូរ និងប្រសិទ្ធភាពចំណាយថវិកាត្រូវបន្តយកចិត្តទុកដាក់។ ការដាក់ចេញនូវវិធានការនៃ**ការភ្ជាប់ផែនការរជ្ជទេយ្យបុរេប្រទានអំឡុងពេលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ** និង **ការអនុម័តផែនការលទ្ធកម្មប្រចាំឆ្នាំមុនឆ្នាំអនុវត្តថវិកា** មានវឌ្ឍនភាពល្អប្រសើរ ប៉ុន្តែពុំទាន់មានបច្ច័យខ្ពស់គ្រប់គ្រាន់នៅឡើយសម្រាប់ពន្លឿនការអនុវត្តថវិកាតាមត្រីមាសនីមួយៗ ពោលគឺការអនុវត្តថវិកានៅក្នុងត្រីមាសទី៣ នៅទាបជាងពិតាន (៧០%) ដែលមាននិន្នាការគរការអនុវត្តថវិកានៅចុងឆ្នាំ និងប្រតិបត្តិការថវិកានៅបន្ត។

ការជំរុញបញ្ចប់ការរៀបចំ **ក្របខណ្ឌ ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ** នឹងរួមចំណែកកំណត់បញ្ហាប្រឈមជាក់ស្តែងនៃការគរការអនុវត្តថវិកានៅចុងឆ្នាំ ខណៈការបញ្ចប់ការដាក់ឱ្យអនុវត្ត **សិទ្ធិសម្រេចលទ្ធកម្ម ជំហានទី២** ក៏នឹងរួមចំណែកដល់ការពន្លឿនការអនុវត្តថវិកាផងដែរ។ ដោយឡែក ការប្រើប្រាស់វិធីសាស្ត្រប្រកួត-ប្រជែងក្នុងកិច្ចលទ្ធកម្មនៅមានកម្រិត ដែលកិច្ចការនេះ នឹងត្រូវបានពង្រឹងតាមរយៈការធ្វើ **វិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ**។

16

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

## ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

### ❖ ការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS

- កសហវ. និង ក្រសួងបរិស្ថានបានអនុវត្តនីតិវិធីចំណាយថវិកាចរន្តលើគ្រប់មុខសញ្ញា តាមប្រព័ន្ធ FMIS ទាំងស្រុង
- ក្រសួង ស្ថាប័នចំនួន ៣៤/៣៧ បានអនុវត្តនីតិវិធីចំណាយបៀវត្ស និង នីតិវិធីចំណាយទូទាត់ត្រង់ តាមប្រព័ន្ធ FMIS ទាំងស្រុង។

### ❖ ការអនុវត្តមុខងារថ្មីចំនួន ២ ក្នុងប្រព័ន្ធ FMIS

- ក្រសួង ស្ថាប័នចំនួន ១១ បន្ថែមថ្មី និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ បានអនុវត្តមុខងាររៀបចំផែនការថវិកា ជាផ្លូវការ
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ បានអនុវត្តមុខងារលទ្ធកម្មពេញលេញ ជាផ្លូវការ។

### ❖ ការដ្ឋានបន្ថែមបានអនុវត្តប្រព័ន្ធ FMIS ជាផ្លូវការ

- រដ្ឋបាលរាជធានី ខេត្ត ទាំង២៥ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ បានអនុវត្តប្រព័ន្ធ FMIS ជាផ្លូវការ
- រដ្ឋបាលស្រុកចំនួន ៧៥ និង រដ្ឋបាលឃុំចំនួន ១៨៥ បានប្រើប្រាស់សាកល្បងប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ជាផ្លូវការ។

### ❖ ការដ្ឋានបន្ថែមសម្រាប់ដំឡើងប្រព័ន្ធ FMIS

- ប្រព័ន្ធឯកសារឌីជីថល (FMIS Portal V1) ត្រូវបានអភិវឌ្ឍ និង តេស្តសម្រាប់ត្រៀមដាក់ឱ្យប្រើប្រាស់នៅរដ្ឋបាលក្រុងចំនួន ៦, រដ្ឋបាលស្រុកចំនួន ៦១, រដ្ឋបាលឃុំចំនួន ៤៤៧ និង រដ្ឋបាលសង្កាត់ចំនួន ២៨
- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មីនៅថ្នាក់កណ្តាលចំនួន ១០ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS
- គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៤ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS។

17

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥


## ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ


### ❖ ប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងរបាយការណ៍

- ការបិទបញ្ជីគណនេយ្យ (ឆ្នាំ២០២១) ក្នុងខែកញ្ញា ឆ្នាំ២០២២
- របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០ មូលដ្ឋានសាច់ប្រាក់ត្រូវបានរៀបចំរួចរាល់លើមូលដ្ឋានចេញពីប្រព័ន្ធ FMIS
- យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ ត្រូវបានដាក់ឱ្យអនុវត្ត។

### ❖ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២១ ទទួលបាន ៨៧ % (២៦៤៣/៣០៥៣)
- ប្រកាសស្តីពីវិធាន និងនីតិវិធីធ្វើនិត្យានុកូលកម្មឡើងវិញនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងដែលមិនមានការឯកភាពពី កសហវ. បានរៀបចំជាសេចក្តីព្រាង
- ការដាក់ពាក្យស្នើសុំធ្វើបណ្ណកម្មសិទ្ធិ មានចំនួន ៥៣៨៨ កន្លែង។(ទិន្នន័យបឋម១៨ ខេត្ត)
- SARMIS ដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (វិកិលទៅឆ្នាំ២០២៣)។

### ❖ ការគ្រប់គ្រងបំណុលសាធារណៈ

- សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតាន (ឆ្នាំ២០២២ ប៉ាន់)÷ *តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ២៥,២% ធៀបនឹង ផសស, តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ២៤,៩០% ធៀបនឹង ផសស និង ៣៣,៩០% ធៀបនឹងការនាំចេញ សេវាបំណុលសាធារណៈក្រៅប្រទេស ២,១០% ធៀបនឹងការនាំចេញ និង ៧,៨% ធៀបនឹងចំណូលថវិកាជាតិ។*
- ក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២២-២០២៨ (មានសេចក្តីព្រាង)
- សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។

### ❖ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ

- លក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានរៀបចំ
- គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២៧ បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ ស្របតាមគោលការណ៍ណែនាំ
- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ (វិកិលទៅឆ្នាំ២០២៣)។

18

ផ្នែកទី១ | **ផ្នែកទី២** | ផ្នែកទី៣ | ផ្នែកទី៤ | ផ្នែកទី៥

## ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

### សន្និដ្ឋាន

ប្រព័ន្ធ FMIS ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ហើយត្រូវបានពង្រីកដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី ខេត្ត។ ទន្ទឹមនេះ ប្រព័ន្ធ FMIS ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ព្រមទាំងការដាក់ឱ្យអនុវត្តមុខងារលទ្ធកម្មពេញលេញ និងមុខងាររៀបចំថវិកា តាមក្រសួង ស្ថាប័នជាបណ្តើរៗ។ **ការបន្តជំរុញការអនុវត្តនីតិវិធីថ្មី តាមប្រព័ន្ធ FMIS ទាំងស្រុង** អាចសម្រេចបានជោគជ័យពេញលេញទៅតាមផែនការ តម្រូវឱ្យមានចូលរួមកាន់តែខ្លាំងឡើង និងការគាំទ្រទាំងកម្រិតបច្ចេកទេស និងនយោបាយ ពីគ្រប់ភាគីពាក់ព័ន្ធទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ និន្នាការនេះ ឬឌីជីថលូបនីយកម្ម តម្រូវឱ្យមានការគិតគូរអំពីហត្ថលេខាអេឡិចត្រូនិក និងគោលនយោបាយឌីជីថល។

ដោយឡែក **ការបិទបញ្ជីគណនេយ្យ** ត្រូវបន្តយកចិត្តទុកដាក់ ស្របតាមទិសដៅនៃការកែទម្រង់ ដែលកិច្ចការនេះ តម្រូវឱ្យមានការជំរុញពីគ្រប់ភាគីពាក់ព័ន្ធ។ ខាងផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមានកម្រិតដែលនឹងត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្ត **ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**។ ចំណែកឯ **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល** និង **សហគ្រាសសាធារណៈ** ត្រូវបន្តយកចិត្តទុកដាក់បន្ថែមទៀត។ វិធានការគន្លឹះទាំងនេះនឹងជួយពង្រឹងប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងថវិកា។



ផ្នែកទី១ | ផ្នែកទី២ | **ផ្នែកទី៣** | ផ្នែកទី៤ | ផ្នែកទី៥

## ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

### ❖ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម

- MTFF ២០២៣-២០២៥ មានសេចក្តីព្រាង ប៉ុន្តែពុំទាន់ត្រូវបានអនុវត្តដោយបន្តអនុវត្តក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ថវិកាឆ្នាំ២០២៣
- MTBF មានពិតានថវិកាតាមវិស័យ និងតាមក្រសួង ស្ថាប័ន
- គ្រប់ក្រសួង ស្ថាប័ន បានរៀបចំ BSP ដោយមានសូចនាករសមិទ្ធកម្មគន្លឹះ។

### ❖ ការគ្រប់គ្រងការវិនិយោគសាធារណៈ

- ប្រកាសស្តីពីគោលការណ៍រួមសម្រាប់ការគ្រប់គ្រងគម្រោងថៃទាំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ត្រូវបានដាក់ឱ្យអនុវត្ត
- ប្រកាសស្តីពីនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រង រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ត្រូវបានដាក់ឱ្យអនុវត្ត
- ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យអនុវត្ត។

### ❖ ថវិកាកម្មវិធីផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា

- គម្លាតរវាងពិតានចំណាយគោលដែលកំណត់ក្នុងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងលទ្ធផលកញ្ចប់ថវិកាប្រចាំឆ្នាំ ទាបជាង ១៥%
- អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិចំនួន ៩ និងអង្គភាពថវិកាថ្មីចំនួន ២៨ បានបង្កើតឡើងនៅឆ្នាំ ២០២២
- គម្រោងចំណាយមូលធនក្នុងស្រុករបស់ក្រសួងសុខាភិបាលត្រូវបានណែនាំដាក់បញ្ចូលទៅក្នុង BSP របស់ក្រសួង ទៅតាមកម្មវិធីនីមួយៗ។

### ❖ វិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

- MTBF ២០២៣-២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ
- សមាហរណកម្ម BSP រដ្ឋបាលរាជធានី ខេត្ត រវាងរដ្ឋបាលរាជធានី ខេត្ត ជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ នៅគ្រប់រាជធានី ខេត្ត
- បទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិភាតរភាព (មានសេចក្តីព្រាងបឋម)។

ផ្នែកទី១ | ផ្នែកទី២ | **ផ្នែកទី៣** | ផ្នែកទី៤ | ផ្នែកទី៥

## ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

### សន្និដ្ឋាន

ថវិការយៈពេលមធ្យមបាននិងកំពុងដាក់ឱ្យអនុវត្ត និងកែលម្អ។ ប៉ុន្តែ MTFF ត្រូវបានរៀបចំជាសេចក្តីព្រាង ដោយពន្យារការដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ដោយសារស្ថានភាពសេដ្ឋកិច្ចក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដោយបន្តអនុវត្តក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ថវិកាឆ្នាំ២០២៣។ ការបង្កើន **អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ** នៅមានកម្រិតនៅឡើយ ដែលកិច្ចការនេះគួរត្រូវបន្តជំរុញបន្ថែមទៀត ខណៈប្រព័ន្ធថវិកាកម្ពុជា បាននិងកំពុងឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ដែលសិទ្ធិអំណាច និងថវិកានឹងត្រូវធ្វើវិមជ្ឈការទៅអង្គភាពអនុវត្តផ្ទាល់កាន់តែច្រើន។ បន្ថែមពីនេះ ការធ្វើ **សមាហរណកម្មរវាងចំណាយថវិកាមូលធន និងថវិកាចរន្ត** ព្រមទាំង **គុណភាព BSP និង PB** ត្រូវបន្តយកចិត្តទុកដាក់។

ការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្ររដ្ឋបាលរាជធានី ខេត្ត រវាងរដ្ឋបាលរាជធានី ខេត្តជាមួយថវិកាក្រុង ស្រុក និងថវិកាឃុំ សង្កាត់ និងការតម្រឹមជាមួយថវិកាមន្ទីរជំនាញ នឹងរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពនៃការវិភាជ និងការអនុវត្តថវិកា។ ដោយឡែក ត្រូវពង្រឹងវិមជ្ឈការហិរញ្ញវត្ថុ ក្នុងនោះ **មុខងារ ៥៥ ពីការិយាល័យជំនាញ ២០ វិស័យ ដែលបានធ្វើសមាហរណកម្មចូលក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក** ពុំទាន់អនុវត្តបានរលូននៅឡើយ ដែលកិច្ចការនេះគួរពន្លឿនការដោះស្រាយទាំងការផ្ទេរធនធានហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ឱ្យស្របនឹងមុខងារទាំង ៥៥ នេះ។

21

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | **ផ្នែកទី៤** | ផ្នែកទី៥

## ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម

### ❖ ក្របខណ្ឌគតិយុត្តថវិកាព័ត៌មានសមិទ្ធកម្ម

- សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)
- អនុក្រឹត្យលេខ ៨១ និង ៨២ មានជាសេចក្តីព្រាង និងបានរៀបចំបញ្ចូលគ្នា ហើយត្រូវបានកំណត់ឈ្មោះថ្មី "**សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ**"
- កិច្ចព្រមព្រៀងលទ្ធផលក្នុងឆ្នាំរវាងជាមួយក្រសួង ៧ ត្រូវបានចុះហត្ថលេខា
- សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម និងត្រួតពិនិត្យថវិកា (មានមាតិកា)។ *(ក្របខណ្ឌពេលវេលាថ្មី ត.ម. ២, ឆ្នាំ២០២៤)*

### ❖ ប្រព័ន្ធតាមដាន និងពិនិត្យសមិទ្ធកម្មតាមក្រសួង ស្ថាប័ន

- គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្ត
- ទម្រង់ផែនការប្រតិបត្តិត្រូវបានអនុម័ត *(កែសម្រួលសូចនាករថ្មី)*
- ដាក់ឱ្យអនុវត្តសាកល្បងការតាមដាននៅតាមក្រសួង ស្ថាប័ន ចំនួន ៦ *(បច្ចុប្បន្នភាពថ្មី BSRS ឆ្នាំ២០២៥)*។

### ❖ ប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្ម

- សេចក្តីព្រាងក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- ប្រកាសលេខ ១២៧ សហវ.អ ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដារអធិការកិច្ចហិរញ្ញវត្ថុ
- ការអនុវត្តសវនកម្មសមិទ្ធកម្មសាកល្បងជាករណីសិក្សានៅក្រសួងចំនួន ៦ និងសវនកម្ម ICT នៅក្រសួងចំនួន ៤
- ៥ របាយការណ៍សវនកម្មកិច្ចប្រតិបត្តិការដែលត្រូវបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិ។

### ❖ ការលើកកម្ពស់តម្លាភាពថវិកា

- វេទិកាសាធារណៈស្តីពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ
- ខ្លឹមសារសង្ខេបស្តីពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០២៣ និងសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២៣ ត្រូវបានផ្សព្វផ្សាយ បន្ទាប់ពីត្រូវបានអនុម័តពីគណៈរដ្ឋមន្ត្រី
- សៀវភៅថវិកាសង្ខេបនៃច្បាប់ថវិកាឆ្នាំ ២០២៣ ត្រូវបានផ្សព្វផ្សាយ។

22

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | **ផ្នែកទី៤** | ផ្នែកទី៥

## ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម

### សន្និដ្ឋាន

ការឈានទៅអនុវត្តដំណាក់កាលទី៤ ត្រូវបានត្រៀមខ្លួនរួចរាល់ចាប់ពីឆ្នាំ២០២៣ តទៅ តាមរយៈសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ ដែលនឹងត្រូវចូលជាធរមាននៅក្នុងអំឡុងឆមាសទី១ ឆ្នាំ២០២៣។

**ក្របខណ្ឌតាមដាន និងវាយតម្លៃ និងមុខងារសវនកម្មផ្ទៃក្នុងដែលផ្តោតលើសវនកម្មសមិទ្ធកម្មនិងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងមុខងារអធិការកិច្ច** នៅគ្រប់ក្រសួង-ស្ថាប័ន ត្រូវពង្រឹងបន្ថែមជាបណ្តើរៗ ដើម្បីធានាថាក្រសួង ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យតាមដានរឹងមាំ ស្របពេលរាជរដ្ឋាភិបាល បាននិងកំពុងផ្ទេរិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នកាន់តែច្រើន។ ទោះជាយ៉ាងនេះក្តី មុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅបន្តស្ទួននៅឡើយ ដែលកិច្ចការនេះនឹងត្រូវបានដោះស្រាយតាមរយៈការដាក់ឱ្យអនុវត្ត **ក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច**។

23

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | **ផ្នែកទី៥**

## ការកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡានៃការកែទម្រង់

### ❖ ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់

- របាយការណ៍វឌ្ឍនភាពរបស់អង្គភាពក្រោមឱវាទ កសហវ. ១៨/១៨
- របាយការណ៍វឌ្ឍនភាពរបស់ក្រសួង ស្ថាប័ន ៤០/៤០
- របាយការណ៍វឌ្ឍនភាពរបស់មន្ទីរ សហវ. រាជធានី ខេត្ត ២៥/២៥
- លក្ខខណ្ឌយោង តួនាទី ភារកិច្ច នៃសមាជិកក្រុមការងារកែទម្រង់តាមអង្គភាពក្រោមឱវាទ កសហវ រួមទាំងមន្ទីរ សហវ. និងក្រសួង ស្ថាប័ន ត្រូវបានរៀបចំតាមយន្តការផ្តល់ប្រាក់ឧបត្ថម្ភ។

### ❖ ការកសាងសមត្ថភាពក្នុងក្របខណ្ឌ PFMRP

- ផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខណ្ឌ PFMRP ត្រូវបានរៀបចំ
- ការរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍អំពី PFMRP សម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ
- ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំសម្រាប់រៀបចំសេចក្តីព្រាងអនុក្រឹត្យ។

### ❖ ចលនការនៃការកែទម្រង់

- ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព (PMAS) ត្រូវបានដាក់ឱ្យអនុវត្តនៅ អ.គ.ហ.
- ការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រមាណ ១៥ ៨៦១ លានរៀល ឬប្រមាណជិត ៤ លានដុល្លា ក្នុងនោះ បានផ្តល់ជូនអង្គភាពក្រោមឱវាទ កសហវ. ចំនួន ៤៨៥ រូប, មន្ទីរ សហវ. រាជធានី ខេត្ត ចំនួន ៧៥ រូប, និងក្រសួង ស្ថាប័ន ចំនួន ៣៤៧។

### ❖ ភាពប្រទាក់ក្រឡានៃការកែទម្រង់ ៣ បូក១

- ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១
- យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ ត្រូវដាក់ឱ្យអនុវត្ត
- សេចក្តីណែនាំស្តីពីការពិពណ៌នាមុខដំណែង (មានសេចក្តីព្រាង)។

24

ផ្នែកទី១ | ផ្នែកទី២ | ផ្នែកទី៣ | ផ្នែកទី៤ | **ផ្នែកទី៥**

## ការកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡានៃការកែទម្រង់

### សន្និដ្ឋាន

ក្រុមការងារកែទម្រង់ នៅតាមអង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរ សហវ. រាជធានី ខេត្ត និងក្រសួង ស្ថាប័ន បានអនុវត្តផែនការ និងបានផ្ញើរបាយការណ៍សមិទ្ធកម្មមក អ.គ.ហ. ទាន់ពេលវេលា បើទោះជាមានភាពយឺតយ៉ាវចំពោះក្រសួង ស្ថាប័នតិចតួចក្តី។ ចលនការនៃការកែទម្រង់ត្រូវបានបន្តចីរភាព ដែលឆ្លុះបញ្ចាំងតាមរយៈការចូលរួមអនុវត្តកម្មវិធីកែទម្រង់ពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។ ការងារកែទម្រង់ប្រទាក់ក្រឡា ត្រូវបានពង្រឹងតាមរយៈ ការដាក់ឱ្យអនុវត្តឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ និងយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១។

ទោះជាយ៉ាងនេះក្តី ការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹង PFMRP (ដំណាក់កាលទី៤) ផ្តោតលើការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ នៅពុំទាន់បានរៀបចំនៅឡើយ។ ចលនការឆ្ពោះទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម នឹងតម្រូវឱ្យស្ថាប័ននីតិប្បញ្ញត្តិ ផ្តោតលើព័ត៌មានសមិទ្ធកម្មច្រើនជាងការអនុវត្តបច្ចុប្បន្ន។ ដោយឡែក តួនាទីមន្ត្រីរាជការនឹងត្រូវបានរៀបចំកាន់តែច្បាស់តាមរយៈការដាក់ឱ្យអនុវត្ត សេចក្តីណែនាំស្តីពីការពិពណ៌នាមុខដំណែង។ បន្ថែមពីនេះ សមត្ថភាពជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្ត អនុក្រឹត្យស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីវិញ្ញាបនបត្រ។

25

## ❖ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២




26

## ❖ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ប្រចាំឆ្នាំ២០២២




## ❖ វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំត្រីមាសទី ៤ ឆ្នាំ២០២២




28


❖ វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំឆ្នាំ២០២២
ការអនុវត្តថវិកា និងវឌ្ឍនភាពជាភាគរយ(%) ប្រចាំឆ្នាំ២០២២ របស់មន្ទីរ សហវ. រាជធានី-ខេត្ត ក្រោម PFMRP
35,000
30,000
25,000
20,000
15,000
10,000
5,000
-
7/7, 100%
6/7, 96%
7/7, 100%
7/7, 100%
8/8, 100%
8/8, 100%
8/8, 100%
7/8, 93%
7/8, 96%
7/7, 100%
8/8, 100%
7/7, 100%
7/7, 100%
8/8, 100%
7/7, 100%
4/7, 86%
6/8, 96%
7/7, 100%
7/7, 100%
7/7, 100%
7/7, 100%
7/7, 99%
7/7, 100%
8/8, 100%
6/7, 99%
5.9%
4.4%
5.9%
5.5%
3.5%
4.5%
4.3%
5.7%
3.6%
3.9%
3.5%
2.6%
2.8%
5.0%
3.6%
2.2%
2.6%
4.1%
2.6%
3.9%
5.2%
4.0%
3.6%
3.8%
3.4%
ការអនុវត្តថវិកា PFM
% ថវិកា (អនុវត្ត+ ឧបត្ថម្ភ) ធៀបនឹងថវិកាអង្គភាព សរុប
N/N, % ចំនួនសកម្មភាព និងពិន្ទុសមិទ្ធកម្ម
29


❖ វឌ្ឍនភាព (%) តាមក្រសួង ស្ថាប័នប្រចាំត្រីមាសទី ៤ ឆ្នាំ២០២២
វឌ្ឍនភាព(%) តាមក្រសួង ស្ថាប័ន ប្រចាំត្រីមាសទី ៤ ឆ្នាំ២០២២
100%
90%
80%
70%
60%
50%
40%
30%
20%
10%
0%
9/9, 100%
14/18, 92%
28/29, 99%
41/45, 98%
31/31, 100%
16/27, 82%
21/21, 100%
20/23, 99%
14/21, 93%
24/25, 95%
32/32, 100%
14/19, 81%
22/25, 96%
18/24, 86%
25/29, 97%
14/16, 98%
18/30, 77%
10/14, 93%
16/24, 94%
17/21, 95%
17/22, 90%
24/24, 100%
9/16, 88%
18/21, 97%
13/14, 95%
14/20, 60%
13/14, 100%
12/13, 89%
12/14, 100%
5/9, 82%
6/11, 91%
12/12, 100%
10/18, 98%
8/15, 63%
17/21, 92%
19/21, 99%
7/15, 99%
18/18, 100%
15/15, 100%
18/19, 99%
MoI-Admin
MoI-SEC
MoE
MoLMUPC
MoND
MoCS
CDC
MoNASRI
OCM
MOP
MoFAIC
MoI
MISTI
SSCA
MoME
MoC
MoAFF
MoRD
MoPWT
MoWRAM
MoLVT
MoT
MoPT
NEC
NAA
NA
ACU
SN
SCoM
CoA
SC
CC
MoRP
MoJ
MoEYS
MoSAVYR
MoCR
MoCFA
MoWA
MoH
30

## ❖ វឌ្ឍនភាព (%) តាមក្រសួង ស្ថាប័នប្រចាំឆ្នាំ២០២២




31

## ៣. មតិ អ.គ.ហ. លើរបកគំហើញនៃរបាយការណ៍វាយតម្លៃ

ដើម្បីឆ្លុះបញ្ចាំងគ្រប់ទិដ្ឋភាពនៃការកែទម្រង់ទៅលើការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា, អ.គ.ហ. បានស្នើ និងសហការជាមួយដៃគូអភិវឌ្ឍន៍ (មូលនិធិរូបិយវត្ថុអន្តរជាតិ - IMF និងធនាគារពិភពលោក - WB) រៀបចំការវាយតម្លៃទៅលើទិដ្ឋភាពចំនួន ៣។

- ១ ការអនុវត្តប្រព័ន្ធ FMIS (IMF)
- ២ ការវាយតម្លៃថវិកាយេនឌ័រ (IMF)
- ៣ ការវាយតម្លៃចំណាយសាធារណៈ (WB)

*(ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, វិស័យធនធានទឹក និងធារាសាស្ត្រ, វិស័យសុខាភិបាល, វិស័យកសិកម្ម, និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖ករណីរដ្ឋបាលខេត្តព្រះសីហនុ)។*

32

## ៣.មតិ អ.គ.ហ. លើរបកគំហើញនៃរបាយការណ៍វាយតម្លៃ (ត...)

### ❖ ការអនុវត្តប្រព័ន្ធ FMIS

- គិតគូររៀបចំហត្ថលេខាអេឡិចត្រូនិក និងគោលនយោបាយឌីជីថល
- ពង្រឹងការប្រើប្រាស់ឧបករណ៍គ្រប់គ្រងសាច់ប្រាក់
- ពង្រីកវិសាលភាពប្រព័ន្ធ FMIS ដោយប្ញូកបញ្ចូលទាំងគ្រប់ប្រភពមូលនិធិ
- ឌីជីថលូបនីយកម្មទៅការរៀបចំ និងការផ្សើរបាយការណ៍។

### ❖ ការវាយតម្លៃថវិកាយេនឌ័រ

- រៀបចំមូលដ្ឋានគតិយុត្តអចិន្ត្រៃយ៍
- កំណត់រចនាសម្ព័ន្ធស្ថាប័ន
- សមាហរណកម្មទិដ្ឋភាពយេនឌ័រ ចូលក្នុងវដ្តថវិកា
- ប្រើប្រាស់ FMIS ដើម្បីកត់ត្រាថវិកាយេនឌ័រ
- រៀបចំ និងអនុវត្តការវាយតម្លៃបច្ច័យយេនឌ័រ។



33

## ៣.មតិ អ.គ.ហ. លើរបកគំហើញនៃរបាយការណ៍វាយតម្លៃ (ត...)

### ❖ ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(Fiscal Management)

- បន្ថយកចិត្តទុកដាក់លើប្រសិទ្ធភាពចំណាយ
- គិតគូរអំពីបន្ទុកសារពើពន្ធ, និងពង្រីកមូលដ្ឋានពន្ធ (ពន្ធលើរូបវន្តបុគ្គល, ពន្ធលើចំណេញមូលធន, ពន្ធកាបូន និងពន្ធលើសេវាឌីជីថល)។

### ❖ វិស័យធនធានទឹកនិងធារាសាស្ត្រ

- កំណត់តួនាទីភារកិច្ចរបស់ថ្នាក់កណ្តាល និងថ្នាក់មន្ទីរ
- អនុវត្តមុខងារដែលបានផ្ទេរទៅក្រុងស្រុក
- លើកកម្ពស់សហថាមពល (Synergy) រវាងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងថវិកាជាតិ
- ពង្រឹងសហថាមពល (Synergy) ជាមួយវិស័យកសិកម្ម ផ្សារភ្ជាប់នឹងបម្រែបម្រួលអាកាសធាតុ។



### ❖ វិស័យសុខាភិបាល

- តម្រឹមរចនាសម្ព័ន្ធ PB និង BSP
- ដាក់ឱ្យអនុវត្តជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្មនៅក្នុងសំណើថវិកា
- ពង្រឹងការធ្វើសមាហរណកម្មចំណាយមូលធនហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- វិភាជចំណាយបន្ទុកបុគ្គលិកតាមកម្មវិធីនីមួយៗ។

### ❖ វិស័យកសិកម្ម

- តម្រឹមរចនាសម្ព័ន្ធ PB និង BSP
- ដាក់បញ្ចូលព័ត៌មានសមិទ្ធកម្មជាបណ្តើរៗនៅក្នុងសំណើថវិកាប្រចាំឆ្នាំ
- ពង្រឹងការសម្របសម្រួលក្នុងវិស័យពាក់ព័ន្ធកសិកម្ម
- ប្រតិភូកម្មសិទ្ធិអំណាចនិយ័តថវិកា ដើម្បីគាំទ្រភាពបត់បែនក្នុងការអនុវត្តថវិកា។

### ❖ រដ្ឋបាលខេត្តព្រះសីហនុ

- ពង្រឹងសមត្ថភាពរៀបចំផែនការ (BSP&PB)
- កែលម្អសមត្ថភាពព្យាករចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ និងពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការអនុវត្តមុខងារទាំង ៥៥
- គាំទ្រមន្ត្រីឃុំ សង្កាត់អនុវត្តសារាចរពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍។

34

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ

### លទ្ធផលនៃការវាយតម្លៃPEFA ថ្នាក់ជាតិ

ក្របខណ្ឌ PEFA ត្រូវបានប្រើប្រាស់សម្រាប់**វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា** ដែលសរុបការវាយតម្លៃទាំងអស់ចំនួនបីលើក គឺនៅឆ្នាំ២០១០, ឆ្នាំ២០១៥ និងឆ្នាំ២០២១។ អភិក្រមនៃការវាយតម្លៃ គឺប្រៀបធៀបលើលទ្ធផលទាំងបីលើកនេះ ហើយទាញការសន្និដ្ឋានលើលទ្ធផលវាយតម្លៃជាកម្រិតម៉ាក្រូ ដោយក្នុងនោះរួមមាន÷ (១) វិន័យថវិកា, (២) ប្រសិទ្ធភាពវិភាជន៍ថវិកា និង (៣) ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

របកគំហើញពីការវាយតម្លៃ PEFA ឆ្នាំ២០២១ ដែលប្រើប្រាស់ក្របខណ្ឌ PEFA ឆ្នាំ២០១១ បង្ហាញថាមានការកែលម្អក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងពិន្ទុនៃសូចនាករសមិទ្ធកម្ម (PIs) ចំនួន ១០ ក្នុងនោះរួមមាន÷ PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI19, PI-21, PI-23 និង PI-25។ រីឯ PI-3 ទទួលបានពិន្ទុទាបដោយសារមានគម្លាតខ្ពស់រវាងផែនការនិងលទ្ធផលប្រមូលចំណូលចាប់ពីឆ្នាំ២០១៧, ២០១៨ និង២០១៩។

35

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ (ត...)

### វិន័យថវិកា

ចំពោះការអនុវត្តចំណាយថវិកាបង្ហាញថាមានភាពកាន់តែប្រសើរ ប៉ុន្តែចាំបាច់ត្រូវដោះស្រាយលើចំណាយកកស្ទះ (ទាំងផ្នែកនិយមន័យ និងបំណុលចាស់) និងការអនុវត្តចំណូលថវិកាត្រូវបន្តពង្រឹងការព្យាករចំណូល, ពង្រឹងរដ្ឋបាលប្រមូលចំណូលជាពិសេសអនុលោមភាព និងការគ្រប់គ្រងហានិភ័យ, ព្រមទាំងតាមដានលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ។

### ប្រសិទ្ធភាពវិភាជន៍ថវិកា

ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំស្របតាមប្រតិទិនថវិកា ប៉ុន្តែចាំបាច់ត្រូវបង្កើនគុណភាពឯកសារថវិកាបន្ថែមទៀត។ ការរៀបចំថវិការយៈពេលមធ្យមគឺស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ដោយហេតុថាក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម ពុំទាន់ត្រូវបានអនុវត្ត និងថវិការយៈពេលមធ្យមត្រូវបានអនុវត្តសាកល្បងចាប់ពីឆ្នាំ២០១៩។

### ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ

មិនទាន់អនុវត្តបានល្អនៅឡើយ ជាពិសេសកង្វះប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម, ការប្រកួត-ប្រជែងក្នុងកិច្ចលទ្ធកម្មនៅមានកម្រិត, និង តម្លាភាពថវិកា ក៏នៅមានកម្រិត ផងដែរ។

36

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ជាតិ (ត...)

**ចំណុចគន្លឹះ ត្រូវពង្រឹងបន្ថែម តាមវដ្តថវិកា**

**រៀបចំផែនការ**

- ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រតាមវិស័យទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រតាមវិស័យ និងធនធាន ។

**រៀបចំថវិកា**

- សមាហរណកម្មថវិកាចរន្ត និងមូលធន
- ថវិការយៈពេលមធ្យម
- គុណភាព BSP និង PB (របាយការណ៍សមិទ្ធកម្មវិធី និងសូចនាករ)
- ការប្រើប្រាស់ចំណាត់ថ្នាក់មុខងារ
- ការផ្សារភ្ជាប់រវាងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផែនការយុទ្ធសាស្ត្រថវិកា ។

**អនុវត្តថវិកា**

- ចំណាយកកស្ទះ និងបំណុលពន្ធ
- ការប្រើប្រាស់វិធីសាស្ត្រកិច្ចលទ្ធកម្ម រួមទាំងតម្លាភាព
- ការវិភាគ និងវាយតម្លៃហានិភ័យពន្ធ
- ការអនុវត្តមុខងារអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករ
- ភាពទាន់ពេលវេលានៃការផលិតរបាយការណ៍ហិរញ្ញវត្ថុ
- សមាហរណកម្មប្រព័ន្ធបៀវត្ស និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ។

**ត្រួតពិនិត្យ និងវាយតម្លៃ**

- ការវាយតម្លៃសមិទ្ធកម្មនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល
- ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម
- សវនកម្មលើសមិទ្ធកម្មស្ថិតក្នុងដំណាក់កាលចាប់ផ្តើម
- សវនកម្មលើបៀវត្ស
- មុខងារសវនកម្ម និងអធិការកិច្ច
- គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ។

**ពិនិត្យពិនិស្ស័យថវិកា**

- ជំនួយបច្ចេកទេសដើម្បីពិនិត្យលើសេចក្តីព្រាងច្បាប់ថវិកា និងរបាយការណ៍សវនកម្ម
- យន្តការតាមដានអនុសាសន៍សវនកម្មផ្ទៃក្រៅ ។

37

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ក្រោមជាតិ

### លទ្ធផលនៃការវាយតម្លៃPEFA ថ្នាក់ក្រោមជាតិ

ការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ ផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធ និងដំណើរការរបស់រដ្ឋបាលរាជធានីភ្នំពេញ។ ការជ្រើសរើសយករដ្ឋបាលរាជធានីភ្នំពេញសម្រាប់ការវាយតម្លៃ គឺផ្អែក លើសនិទានភាពមួយចំនួន ជាអាទិ៍÷ រាជធានីភ្នំពេញ មិនត្រឹមតែជា រាជធានីដែលមានចំនួនប្រជាជនច្រើនជាងគេ (ក្នុងចំណោមខេត្តដ៏ទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជា) នោះទេ ប៉ុន្តែមានស្ថានភាពលេចធ្លោពាក់ព័ន្ធនឹងសេដ្ឋកិច្ច សកម្មភាពអាជីវកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីនេះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលរាជធានីភ្នំពេញ មានលក្ខណៈខុសប្លែកមួយចំនួន បើធៀបជាមួយនឹងរដ្ឋបាលខេត្តដ៏ទៃទៀត។

លទ្ធផលនៃការវាយតម្លៃបង្ហាញថា សូចនាករចំនួន ៤ ក្នុងចំណោម ៣៤ ទទួលពិន្ទុ “A” ឬ “B” ដែលស្របទៅនឹងការអនុវត្តល្អ (Good practice) ជាអន្តរជាតិ; សូចនាករចំនួន ៦ ទទួលបានពិន្ទុ “C” ឬ “C+” ដែលស្ថិតក្នុងកម្រិតមូលដ្ឋាន ហើយសូចនាករចំនួន ១៨ ទទួលបានពិន្ទុ “D” ឬ “D+” ដែលបង្ហាញពីការអនុវត្តខ្សោយ។ ដោយឡែក សូចនាករចំនួន ៣ គឺ “NA-Not Applicable” មានន័យថាពុំមានមុខងារនៅរដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះរួមមានសូចនាករ PI-13, PI-19 និង PI-31 និងសូចនាករចំនួន ៣ គឺ “NU-Not Use” មានន័យថាពុំត្រូវបានប្រើប្រាស់សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងនោះរួមមាន សូចនាករ PI-15, PI-16 និង PI-30។

38

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ក្រោមជាតិ (ត...)

**ពិន្ទុវាយតម្លៃសូចនាករ PEFA ថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ**




39

## ៤. ការឆ្លុះបញ្ចាំងអំពីបច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – PEFA ថ្នាក់ក្រោមជាតិ (ត...)

- ពង្រឹងមុខងារប្រតិតុល្យភាព
- ពង្រឹងការត្រួតពិនិត្យវដ្តថវិកា




- បង្កើនគុណភាព និងភាពទាន់ពេលវេលានៃការរៀបចំផែនការយុទ្ធសាស្រ្តថវិកា
- ការដាក់ឱ្យអនុវត្តថវិការយៈពេលមធ្យម (MTBF)

- គុណភាពថវិកាកម្មវិធី (រចនាសម្ព័ន្ធកម្មវិធី, លទ្ធផលចុងក្រោយ និងលទ្ធផលចុងក្រោយ (សូចនាករ និងគោលដៅ)
- ការប្រើប្រាស់ចំណាត់ថ្នាក់មុខងារ
- ការគ្រប់គ្រងវិនិយោគសាធារណៈ
- បង្កើនតម្លាភាពថវិកា និងការចូលរួមពីសាធារណជន

- ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម
- សវនកម្មលើបៀវត្ស
- មុខងារសវនកម្ម

- ចំណាយកកស្ទះ
- ការប្រើប្រាស់វិធីសាស្រ្តកិច្ចលទ្ធកម្ម រួមទាំងតម្លាភាព
- ការអនុវត្តមុខងារអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករ
- ភាពទាន់ពេលវេលានៃការផលិតរបាយការណ៍ហិរញ្ញវត្ថុ

40

## ៥. មតិយោបល់ដៃគូអភិវឌ្ឍន៍ និងការឆ្លើយតប

| ល.រ | មតិយោបល់ដៃគូអភិវឌ្ឍន៍ | ការឆ្លើយតប |
|---|---|---|
| ០១ | ដៃគូអភិវឌ្ឍន៍ អបអរសាទររាជរដ្ឋាភិបាលកម្ពុជា ចំពោះវឌ្ឍនភាពប្រកបដោយចីរភាពនៅគ្រប់ទិដ្ឋភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពិសេសវឌ្ឍនភាពនៃការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)។ ដៃគូអភិវឌ្ឍន៍គូសបញ្ជាក់អំពីការប្តេជ្ញារឹងមាំ ក្នុងការបន្តគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**"។ | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបាននិងកំពុងធ្វើទំនើបកម្មជាបណ្តើរៗ និងកាន់តែស៊ីជម្រៅលើគ្រប់សមាសធាតុស្នូលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការកសាង និងកែលម្អប្រព័ន្ធ, ក្របខណ្ឌគតិយុត្ត, ស្ថាប័ននីយកម្ម និងធនធានមនុស្ស។ គ.ហ.ស. សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់សហគមន៍អឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, មូលនិធិរូបិយវត្ថុអន្តរជាតិ, អង្គការយូនីសែហ្វ, រដ្ឋាភិបាលបារាំង/AFD, រដ្ឋាភិបាលអូស្ត្រាលី, និងស្ថាប័នអន្តរជាតិផ្សេងទៀត ដែលបាននិងបន្តផ្តល់ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស ក្នុងការ-អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ (GSC) |
| ០២ | វឌ្ឍនភាព និងសមធមិពន្ធដារ និង ភាពជឿទុកចិត្តនៃថវិកា÷<br>ក. ការកែលម្អគោលនយោបាយពន្ធដារឱ្យប្រសើរថែមទៀត ក្នុងនោះរួមមាន ពន្ធលើចំណូលរូបវន្តបុគ្គល, ពន្ធលើចំណេញមូលធន, និងសេវាឌីជីថល;<br>ខ. ការដាក់ឱ្យអនុវត្តប្រភេទពន្ធដែលជួយលើកកម្ពស់ដល់សុខភាព និងចីរភាពបរិស្ថាន; និង<br>គ. ការបង្កើនសមត្ថភាពវិភាគ និងផ្តល់សនិទានកម្មលើបន្ទុកសារពើពន្ធ។ | (ក.ខ.) អគ្គនាយកដ្ឋានគោលនយោបាយ កំពុងរៀបចំទស្សនាទានសម្រាប់រៀបចំយុទ្ធសាស្ត្រកៀរគរចំណូលដំណាក់កាលទី៣ (RMSIII)។ ចំណុចដែលលើកឡើងដោយដៃគូអភិវឌ្ឍន៍ កំពុងត្រូវបានគិតគូរក្នុងទស្សនាទាននេះ ក្នុងនោះរួមមានទាំងប្រព័ន្ធពន្ធ និងប្រភេទពន្ធដែលលើកកម្ពស់សុខភាព និងចីរភាពបរិស្ថាន។ (GDP)<br>(គ) អ.គ.ហ. បានដាក់បញ្ចូលការងារពាក់ព័ន្ធនឹងបន្ទុកសារពើពន្ធ ទៅក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4)។ (GSC) |

41

## ៥. មតិយោបល់ដៃគូអភិវឌ្ឍន៍ និងការឆ្លើយតប (ត...)

| ល.រ | មតិយោបល់ដៃគូអភិវឌ្ឍន៍ | ការឆ្លើយតប |
|---|---|---|
| ០៣ | ការឆ្ពោះទៅសម្រេចគោលបំណងនៃគណនេយ្យភាពសមិទ្ធកម្ម÷<br>ក. បង្កើតឧបករណ៍ត្រួតពិនិត្យចំណាយ,<br>ខ. បង្កើតប្រព័ន្ធកំណត់ និងប្រមូលទិន្នន័យសមិទ្ធកម្មមិនមែនហិរញ្ញវត្ថុ,<br>គ. ពង្រឹងបន្ថែមនូវសវនកម្មផ្ទៃក្នុង និងពង្រីកការធ្វើសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន, និង<br>ឃ. ពង្រឹងការចូលរួមពីក្រសួង ស្ថាប័ន ពិសេសលើការងារត្រួតពិនិត្យនិងតាមដាន និងការបង្កើនសិទ្ធិអង្គភាពថវិកា ព្រមទាំងបង្កើនការចូលរួមពីស្ថាប័ននីតិបញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ លើការងារពិនិត្យហិរញ្ញវត្ថុ។ | (ក, ខ, ឃ) នាយកដ្ឋាន M&E នៃអគ្គនាយកដ្ឋានថវិកា កំពុងសិក្សារៀបចំទស្សនាទាននៃការ-ត្រួតពិនិត្យចំណាយ ដែលគ្រោងបញ្ចប់ក្នុងឆ្នាំ២០២៣។ វគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំស្តីពី M&E នឹងបន្តរៀបចំសម្រាប់ក្រសួង ស្ថាប័ន ក្នុងឆ្នាំ២០២៣។ (GDB)<br>(គ) មុខងារសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័ន ត្រូវបានបន្តពង្រឹង ពិសេសសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន។ (GDIA) |
| ០៤ | ការបន្តតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS (Business Process Streamlining) និងការគិតគូរកំណត់តួនាទី នៃមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ចៀសវាងការងារត្រួតគ្នាជាមួយគណនេយ្យករសាធារណៈ។ | - ការបន្តដាក់ឱ្យអនុវត្តនូវនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ត្រូវបានបញ្ចូលក្នុង CAP4 និងត្រូវអនុវត្តជាជំហានៗ ពីឆ្នាំ២០២៣-២០២៧។ (FMWG)<br>- សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ បានកំណត់អំពីដំណើរការត្រួតពិនិត្យថវិកាដែលផ្តល់ភាពទន់ភ្លន់ និងគណនេយ្យភាពជូនក្រសួង ស្ថាប័ន ពិសេសអង្គភាពថវិកា។ (GDB)<br>- គណនេយ្យករសាធារណៈផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកា ដោយពិនិត្យអនុលោមភាពជាមួយនឹងលិខិតបទដ្ឋានគតិយុត្តិជាធរមាន, ផ្ទៀងផ្ទាត់លើសេវាបានបំពេញដោយផ្អែកលើការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក និងផ្ទៀងផ្ទាត់ឯកសារគាំទ្រ មុននឹងចុះកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការ និងធ្វើការទូទាត់។ (GDNT) |

42

## ៥. មតិយោបល់ដៃគូអភិវឌ្ឍន៍ និងការឆ្លើយតប (ត...)

| ល.រ | មតិយោបល់ដៃគូអភិវឌ្ឍន៍ | ការឆ្លើយតប |
|---|---|---|
| ០៥ | **ថវិកាព័ត៌មានសមិទ្ធកម្ម÷** ការត្រួតពិនិត្យមុខងារ(Functional Review) ដើម្បីកែលម្អបន្ថែមនូវរចនាសម្ព័ន្ធកម្មវិធី ពិសេសសម្រាប់ក្រសួង ស្ថាប័ន ដែលបានសាកល្បងអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម។ | រចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធរដ្ឋបាល មានភាពខុសប្លែកគ្នាខ្លាំងពីស្ថាប័នមួយទៅស្ថាប័នមួយ។ ការសាកល្បងអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម គឺជាឱកាសសម្រាប់ក្រសួង ស្ថាប័ន ទន់ភ្លន់ទទួលយកប្រព័ន្ធថវិកាថ្មី ដោយផ្អែកលើរចនាសម្ព័ន្ធរដ្ឋបាល និងកម្មវិធីរបស់សាមីក្រសួង ស្ថាប័ន។ (GDB) |
| ០៦ | **តម្លាភាពថវិកា÷** ការផ្សព្វផ្សាយឯកសារ ដូចខាងក្រោម÷<br>ក. ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF),<br>ខ. របាយការណ៍ហិរញ្ញវត្ថុស្តង់ដា IPSAS,<br>គ. ផែនការ និងរបាយការណ៍សមិទ្ធកម្ម និងហិរញ្ញវត្ថុប្រចាំឆ្នាំ,<br>ឃ. របាយការណ៍សមិទ្ធកម្ម និងហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និង<br>ង. ការធ្វើសវនកម្មច្បាប់ទូទាត់ថវិកា។ | **ក.** ឯកសារ MTFF រំពឹងថានឹងត្រូវរៀបចំរួចរាល់ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ និងផ្សព្វផ្សាយក្នុងត្រីមាសទី២ ឆ្នាំ២០២៤។ (GDP)<br>**ខ.** តួលេខសង្ខេបនៃរបាយការណ៍ហិរញ្ញវត្ថុស្តង់ដា IPSAS នឹងគ្រោងបោះផ្សាយនៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានរតនាគារជាតិ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៣ តទៅ។ (GDNT)<br>**គ.** កសហវ. ប្តេជ្ញាក្នុងការអនុញ្ញាតឱ្យសាធារណជនទទួលបានព័ត៌មាន ដែលមានក្នុងច្បាប់ថវិកា បន្ទាប់ពីទទួលបានការអនុម័ត។ (GDB)<br>**ឃ.** របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន តម្រូវឱ្យផ្សព្វផ្សាយលើគេហទំព័ររបស់សាមីក្រសួង ស្ថាប័ន។(GDB)<br>**ង.** អាជ្ញាធរសវនកម្មជាតិ បានបញ្ចប់ការធ្វើសវនកម្ម និងចេញផ្សាយរបាយការណ៍លើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាសម្រាប់ការិយបរិច្ឆេទឆ្នាំ ២០២១ ក្នុងខែវិច្ឆិកា ឆ្នាំ២០២២។ (NAA) |
| ០៧ | **ថវិកាយេនឌ័រ÷** ការរៀបចំក្របខណ្ឌស្ថាប័ន និងគតិយុត្ត, ការដាក់ចេញនូវឧបករណ៍គាំទ្រថវិកាយេនឌ័រ, ការធ្វើសមាហរណកម្មឧបករណ៍ថវិកាយេនឌ័រទៅក្នុងដំណើរការថវិកា និងការប្រើប្រាស់យន្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គាំទ្រដល់ការអនុវត្តថវិកាយេនឌ័រ។ | ថវិកាយេនឌ័រ ជាជំហានដ៏សំខាន់សម្រាប់កម្ពុជាក្នុងការកែលម្អសមភាពយេនឌ័រ។ ប៉ុន្តែ មិនអាចបញ្ចូលជាមូលដ្ឋានគតិយុត្តសម្រាប់ថវិកាយេនឌ័រនោះទេ ទោះជានៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)។ សារាចរស្តីពីការរៀបចំ BSP បានលើទឹកចិត្តឱ្យក្រសួង ស្ថាប័នបញ្ចូលទិដ្ឋភាពយេនឌ័រទៅក្នុងផែនការថវិកា។ បន្ថែមពីនេះ សមភាពយេនឌ័រ ត្រូវបានរំលេចនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ (GDB និង MOWA) |

43

## ៥. មតិយោបល់ដៃគូអភិវឌ្ឍន៍ និងការឆ្លើយតប (ត...)

| ល.រ | មតិយោបល់ដៃគូអភិវឌ្ឍន៍ | ការឆ្លើយតប |
|---|---|---|
| ០៨ | **លទ្ធកម្មសាធារណៈ÷** ការបង្កើនវិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្មលើថវិកាចរន្តនិងមូលធន និង ការធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដើម្បីបង្កើនគណនេយ្យភាព ភាពប្រកួតប្រជែង និងតម្លាភាពលទ្ធកម្មសាធារណៈ ក្នុងនោះរួមមានកិច្ចលទ្ធកម្មប្រកបដោយចីរភាព និងកិច្ចលទ្ធកម្មអេឡិចត្រូនិក។ | - កសហវ. នឹងត្រួតពិនិត្យតឹងរឹងលើសំណើប្រើប្រាស់វិធីសាស្ត្រលទ្ធកម្ម មុនពេលផ្តល់ការឯកភាពជាគោលការណ៍។ (GDPP)<br>- សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ថ្មី) ត្រូវបានដាក់ឆ្លងកម្រិតថ្នាក់ដឹកនាំ កសហវ. នៅក្នុងខែធ្នូ ឆ្នាំ២០២២។ សេចក្តីព្រាងច្បាប់ចុងក្រោយ គ្រោងនឹងដាក់ឆ្លងគណៈរដ្ឋមន្ត្រីនៅក្នុងខែមីនា ឆ្នាំ២០២៣ ខាងមុខ។ (GDPP) |
| ០៩ | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមគោលការណ៍បៃតង (Green PFM) ÷ ដៃគូអភិវឌ្ឍន៍កោតសរសើរកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈ និងការបង្កើតមូលនិធិអភិវឌ្ឍន៍គម្រោង ដើម្បីធ្វើសមាហរណកម្មបន្ថែម និងអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមគោលការណ៍បៃតង។ | កសហវ. កត់សម្គាល់អំពីសារៈសំខាន់នៃការគិតគូរអំពីការប្រែប្រួលអាកាសធាតុ ក្នុងការគ្រប់គ្រងការវិនិយោគសាធារណៈ។ កសហវ. ស្វាគមន៍ការគាំទ្រពីគ្រប់ដៃគូអភិវឌ្ឍន៍លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមគោលការណ៍បៃតង។ ប៉ុន្តែ កសហវ. ត្រូវធ្វើការសិក្សាឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយទៅលើកិច្ចការនេះ។ (GSC) |

44

## ៥. មតិយោបល់ដៃគូអភិវឌ្ឍន៍ និងការឆ្លើយតប (ត...)

| ល.រ | មតិយោបល់ដៃគូអភិវឌ្ឍន៍ | ការឆ្លើយតប |
|---|---|---|
| ១០ | ការផ្លាស់ប្តូរទិន្នន័យទៅវិញទៅមកពាក់ព័ន្ធទិន្នន័យពន្ធដារ, ស្ថិតិ និង ការអភិវឌ្ឍប្រកបដោយចីរភាព។ | ការផ្លាស់ប្តូរទិន្នន័យទៅវិញទៅមកពាក់ព័ន្ធទិន្នន័យពន្ធដារ, ស្ថិតិ និង ការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានចាត់ទុកជាការងារសំខាន់ និងត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៤ (CAP4) គឺការបង្កើតថ្នាលចែករំលែកទិន្នន័យ (Data Sharing Platform)។ (GDP) |
| ១១ | **សញ្ញាបណ្ណរដ្ឋធិបតេយ្យ (Sovereign Bonds)** ៖ ដៃគូអភិវឌ្ឍន៍គាំទ្រការប្តេជ្ញារបស់រដ្ឋាភិបាល ក្នុងការបន្តបោះផ្សាយសញ្ញាបណ្ណរដ្ឋធិបតេយ្យ សម្រាប់ហិរញ្ញប្បទាន និងសម្រាប់គាំទ្រផែនការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍មូលបត្ររដ្ឋ។ ដៃគូអភិវឌ្ឍន៍ត្រៀមខ្លួនរួចរាល់សម្រាប់កិច្ចសហប្រតិបត្តិការជាមួយ កសហវ. ទៅលើកិច្ចការនេះ។ | រដ្ឋាភិបាលប្តេជ្ញារៀបចំទាំងមូលបត្ររដ្ឋ និងទីផ្សារហិរញ្ញវត្ថុ ដោយដាក់ឱ្យអនុវត្តនូវឯកសារគោលនយោបាយ ពិសេសយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៩-២០២៥ និងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣។ ច្បាប់ស្តីពីមូលបត្ររដ្ឋត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត។ ក្របខណ្ឌបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋត្រូវបានដាក់ឱ្យអនុវត្ត។ បន្ថែមពីនេះ កសហវ. បាននិងកំពុងបញ្ចប់ការរៀបចំក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ដែលរំពឹងថារួចរាល់នៅត្រីមាសទី៤ ឆ្នាំ២០២៣។ (GDICDM) |
| ១២ | ការផ្លាស់ប្តូរមូលដ្ឋាន ផ.ស.ស. (GDP rebasing)។ ដៃគូអភិវឌ្ឍន៍ស្នើបញ្ជាក់អំពីពេលវេលាដែលគណនីជាតិថ្មី ត្រូវផ្សព្វផ្សាយ និងពេលវេលាដែលការផ្លាស់ប្តូរមូលដ្ឋាន ផ.ស.ស. ត្រូវដាក់ឱ្យអនុវត្តក្នុងស្ថិតិជាតិ។ | - ការចងក្រងគណនីជាតិ គឺស្ថិតក្រោមទំនួលខុសត្រូវរបស់វិទ្យាស្ថានជាតិស្ថិតិ (GDP)<br>- ការផ្លាស់ប្តូរមូលដ្ឋាន ផ.ស.ស. (GDP rebasing) នឹងលេចរូបរាងក្នុងឆ្នាំ២០២៣។ (GDP) |

45

## ៦. សំណូមពរបន្ថែម

❖ *សម្រាប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន៖*

(១) ស្នើពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់លើការរៀបចំ **កិច្ចព្រមព្រៀងសមិទ្ធកម្ម** ជាមួយអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០២៣ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ *សម្គាល់៖ កិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត បានរៀបចំ និងចុះហត្ថលេខារួចរាល់នៅក្នុងខែមករា ឆ្នាំ២០២៣។*

(២) ស្នើពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់លើ **ការជំរុញបញ្ចប់ការរៀបចំ GDAP4 និង MAP4 ២០២៣** ត្រឹមចុងខែកុម្ភៈ ឆ្នាំ២០២៣។ គិតត្រឹមថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣, អ.គ.ហ. បានទទួលផែនការសកម្មភាពលម្អិត MAP4/GDAP4/PDAP4 និងសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) ដែលបានឯកភាពគ្នាដូចខាងក្រោម៖

អង្គភាពក្រោមឱវាទ កសហវ. ៖ GDAP4 ៖ ១៦/១៨ និង KPIs ១៦/១៨

ក្រសួង-ស្ថាប័ន៖ MAP4 ៖ ៣០/៤០ និង KPIs ៣០/៤០

មន្ទីរ កសហវ. ៖ PDAP4 ៖ ២៥/២៥ (ប្លូកសរុបរួចរាល់)

46

## ៧. សន្និដ្ឋានរួម

ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំ២០២២, សកម្មភាពជាច្រើនសម្រេចបានតាមគោលដៅ ខណៈសកម្មភាពមួយចំនួនកំពុងមានវឌ្ឍនភាព និង បន្តអនុវត្តក្នុងផែនការសកម្មភាពរួម ចំណាក់កាលទី៤ ហើយ **សកម្មភាពគន្លឹះពាក់ព័ន្ធនឹងការបញ្ចប់ការត្រៀមខ្លួន សម្រាប់ជំហានបន្ទាប់** ត្រូវបាននិងកំពុងឈានទៅបញ្ចប់ជាបណ្តើរៗ។ គុណភាពនៃការរៀបចំ GDAP/PDAP/MAP និងរបាយការណ៍ មានភាពប្រសើរជាងមុន ប៉ុន្តែការពង្រឹង**សង្គតិភាពឱ្យបានពេញលេញ ទៅនឹងផែនការសកម្មភាពរួម** ត្រូវបន្តយកចិត្តទុកដាក់។

ការវាយតម្លៃ **PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** បានផ្តល់ជាបន្ទាត់មូលដ្ឋានអំពីស្ថានភាព នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា និងការពិនិត្យលើប្រសិទ្ធភាពប្រព័ន្ធ និងថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់ **PER** ដែលជាធាតុចូលសម្រាប់រៀបចំ **ក្របខណ្ឌផែនការសកម្មភាពរួម** តាមរយៈការកំណត់ការងារអាទិភាព។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺចាំបាច់ត្រូវពង្រឹងជាប្រចាំ និងកសាងសមាសធាតុសំខាន់ៗបន្ថែមទៀត ដើម្បីឆ្លើយតបបានទៅនឹងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗដែលអាចកើតមានជាយថាហេតុ។

**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ តាមរយៈការធានានូវ **កំណើនសេដ្ឋកិច្ចដែលស្ថិតក្នុងនិន្នាការសុទិដ្ឋិនិយម** និងប្រកបដោយបរិយាប័ន្ន និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាជន ព្រមទាំងរួមចំណែក**សម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា**។

47

## ៧. សន្និដ្ឋានរួម (ត...)

ជារួម កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខឿន ៣ និងដំណាក់កាលទី៣ ដែលមានរយៈពេល ៧ ឆ្នាំ (២០១៦-២០២២) **សម្រេចបានជាសារវ័ន្ត** តាមរយៈការកសាង និងកែលម្អប្រព័ន្ធ គតិយុត្ត យន្តការស្ថាប័ន និងធនធានមនុស្ស ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់អនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង និងបញ្ជ្រាប "**វប្បធម៌សមិទ្ធកម្ម**" នៅក្នុងក្របខណ្ឌរាជរដ្ឋាភិបាល និងទូទាំងមន្ត្រីរាជការ។

ស្ថាប័នរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តថវិកាសមិទ្ធកម្ម ជាមួយនឹងការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មផ្សារភ្ជាប់នឹងគោលនយោបាយ (NSDP/BSP/PB) ដែលមានបច្ច័យដល់ (១) ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច, (២) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៣) ការផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលអាចបោះជំហានទៅកាន់ខឿនទី៤ និងដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ប្រកបដោយភាពជឿជាក់ ប្រាកដនិយម និង ប្រកាន់ខ្ជាប់នូវអភិក្រមឆ្លងស៊ីងស្ថាបថ្ន ព្រមទាំងយន្តការបុរេសកម្ម សកម្ម និងអន្តរសកម្ម។

48

## អភិក្រមការងារ ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១. អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ
២. អនុវត្តការងារជាក្រុម
៣. អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និងគោលការណ៍ប្រសិទ្ធភាពថវិកា
៤. មិនត្រូវមើលរំលងកំហុសខ្លួនឯង

**សូមអរគុណ!**

## ឧបសម្ព័ន្ធទី ៨÷ ការឆ្លើយតបទៅនឹងមតិយោបល់របស់ដៃគូអភិវឌ្ឍន៍ (ភាសាខ្មែរ)

# ការឆ្លើយតបទៅនឹងមតិយោបល់ដៃគូអភិវឌ្ឍន៍
# របាយការណ៍ត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០២២ និងការវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| ល.រ. | មតិយោបល់ |
|---|---|
| I. | មតិយោបល់ទូទៅ |
| 1 | **មតិយោបល់ដោយដៃគូអភិវឌ្ឍន៍**<br>ដៃគូអភិវឌ្ឍន៍សូមអបអរសាទររាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំពោះការសម្រេចបាននូវលទ្ធផលល្អនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសការរៀបចំ**ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)** ដែលគណៈរដ្ឋមន្ត្រីបានពិនិត្យនិងសម្រេច នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ និងរដ្ឋសភា បានពិនិត្យនិងអនុម័តនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣។ ដៃគូអភិវឌ្ឍន៍ សូមគូសបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបន្តការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ លើ**ការងារទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤** "គណនេយ្យភាពសមិទ្ធកម្ម" ឆ្នាំ២០២៣-២០២៧ ដែលដើរតួនាទីសំខាន់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបន្ទាប់ និងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ប្រកបដោយចីរភាព។ |
| | **1.1. ការឆ្លើយតបដោយ អ.គ.ហ. លើការសម្រេចបាននូវលទ្ធផលល្អនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**<br>- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីកែទម្រង់ស្នូលមួយ នៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច តាមរយៈការប្រកាន់ខ្ជាប់ការអនុវត្តនូវអភិក្រមជាខឿន ឬជាដំណាក់កាល។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានកំណត់ចក្ខុវិស័យ ប្រកបដោយមហិច្ឆតា និងប្រាកដនិយម ពោលគឺកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ ដែលមានគោលដៅផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូល និង មានលក្ខណៈមជ្ឈការ ឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬ លទ្ធផល និងវិមជ្ឈការ។ ក្នុងទស្សនវិស័យដ៏ពិសិដ្ឋនេះ, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបាននិងកំពុងធ្វើទំនើបកម្មជាបណ្តើរៗ និងកាន់តែស៊ីជម្រៅលើគ្រប់សមាសធាតុស្នូលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការកសាង និងកែលម្អប្រព័ន្ធ, ក្របខ័ណ្ឌគតិយុត្ត, ស្ថាប័ននីយកម្ម និងធនធានមនុស្ស។ |

- ដៃគូអភិវឌ្ឍន៍គឺជាតួអង្គមួយដ៏សំខាន់ក្នុងដំណើរការនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ។ ក្នុងពេលរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤ ថ្មីៗនេះ, អ.គ.ហ. បានទទួលធាតុចូលល្អៗជាច្រើន ដែលរំលេចពីចំណុចត្រូវបន្តពង្រឹង ដើម្បីឱ្យសមាសធាតុ និងមុខងារតាមការដ្ឋានកែទម្រង់អាចដំណើរការទៅកាន់តែប្រសើរនិងស្របតាមឧត្តមានុវត្តន៍។ ក្នុងឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤, អ.គ.ហ. មានមោទកភាពនឹងបន្តកិច្ចសហប្រតិបត្តិការល្អជាមួយតំណាងដៃគូអភិវឌ្ឍន៍ទាំងអស់ ក្នុងការសម្រេចនូវលទ្ធផលនៃការកែទម្រង់ និងការអភិវឌ្ឍ។
- គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះដល់សហគមន៍អឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, មូលនិធិរូបិយវត្ថុអន្តរជាតិ, អង្គការយូនីសេហ្វ, រដ្ឋាភិបាលបារាំង/AFD, រដ្ឋាភិបាលអូស្ត្រាលី, និងស្ថាប័នអន្តរជាតិផ្សេងទៀត ដែលបាននិងគ្រោងបន្តផ្តល់ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ នេះ ឱ្យប្រព្រឹត្តទៅដោយរលូន និងមានសន្ទុះល្អទៅមុខ ហើយខ្ញុំរំពឹងទុកចំពោះស្មារតីសហការបែបនេះ ក្នុងដំណាក់កាលទី៤ បន្ត ទៀត។

### 1.2. ការឆ្លើយតបដោយអគ្គនាយកដ្ឋានថវិកា លើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី

- អគ្គនាយកដ្ឋានថវិកាស្វាគមន៍ចំពោះការបន្តគាំទ្រពីដៃគូអភិវឌ្ឍន៍ ដោយហេតុថានៅពេលចាប់ផ្តើមអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី), លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ថ្មីនេះនឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ដូចមានកំណត់ក្នុងច្បាប់ ក្នុងគោលដៅនាំលម្អិត ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ដូចនេះ, លិខិតបទដ្ឋានគតិយុត្តគាំទ្រច្បាប់ថ្មីនេះនឹងការរៀបចំនាឆ្នាំបន្តបន្ទាប់គ្នា។

## II. មតិយោបល់ជាក់លាក់

### 2 មតិយោបល់ដោយដៃគូអភិវឌ្ឍន៍

ការបង់ពន្ធតាមថ្នាក់ (Progressive tax) និងសមធម៌ពន្ធដារ និង ភាពជឿទុកចិត្តនៃថវិកា÷ ដៃគូអភិវឌ្ឍន៍កត់សម្គាល់នូវសមិទ្ធកម្មនៃការកៀរគរចំណូលដ៏រឹងមាំដែលសម្រេចបានក្នុងឆ្នាំ២០២២ និងស្វាគមន៍ការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ នៅក្នុងខែសីហា ឆ្នាំ២០២២ ដើម្បីពង្រឹងចំណូលមិនមែនសារពើពន្ធ។ ដើម្បីពង្រីកមូលដ្ឋានពន្ធបន្ថែម និងការគាំទ្រការផ្តល់សេវាក្នុងបរិបទនៃយុទ្ធសាស្ត្រគ្រប់គ្រងចំណូលថ្មីនាពេលខាងមុខ (ក្រោយឆ្នាំ២០២៣) ដៃគូអភិវឌ្ឍន៍ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលកម្ពុជាពិចារណាលើចំណុចខាងក្រោម÷

ក. ការកែលម្អគោលនយោបាយសារពើពន្ធឱ្យប្រសើរជាងមុន ដែលនាំមកនូវស្ថិរភាពជាងមុន រួមទាំងពន្ធលើចំណូលរូបវន្តបុគ្គល, ពន្ធលើចំណេញមូលធន និងសេវាឌីជីថល។

| | |
|---|---|
| | ខ. ការដាក់ឱ្យអនុវត្ត ឬបង្កើនពន្ធដែលអាចលើកកម្ពស់ចីរភាពបរិស្ថាន និងសុខភាពសាធារណៈ ដូចជាការយកពន្ធបរិស្ថានសម្រាប់ការប្រើប្រាស់ប្លាស្ទិក, ពន្ធលើផលិតផលពិសារ (Content) មានជាតិស្ករកម្រិតខ្ពស់, ពន្ធលើថ្នាំជក់, និងពន្ធលើផលិតផលគ្រឿងស្រវឹង។ ការបង់ពន្ធទាំងនេះអាចមានសារៈសំខាន់ដែលផ្សារភ្ជាប់ទៅនឹងការវិភាជធនធានបន្ថែម សម្រាប់ការលើកកម្ពស់សិទ្ធិទទួលបានការអប់រំប្រកបដោយសមធម៌ ការទទួលបានសមធម៌ក្នុងការថែទាំសុខភាព និងការអភិវឌ្ឍវិស័យសង្គមទាំងមូល រួមទាំងការពង្រីកការគ្របដណ្តប់ការពារសង្គម, ធានាបាននូវការផ្តល់អត្ថប្រយោជន៍ គ្រប់គ្រាន់, និងបង្កើនលទ្ធភាពទទួលបាន និងគុណភាពសេវាសាធារណៈ។<br>គ. ការបង្កើនសមត្ថភាពវិភាគ និងផ្តល់សនិទានកម្មលើបន្ទុកសារពើពន្ធ (Tax expenditure)។ |
| | **2.1. ការឆ្លើយតបដោយអគ្គនាយកដ្ឋានគោលនយោបាយ លើចំណុច (ក), (ខ) និង (គ)**<br>- អគ្គនាយកដ្ឋានគោលនយោបាយ (អ.គ.ប.) បាននិងកំពុងរៀបចំឯកសារទស្សនទាននៃយុទ្ធសាស្ត្រគៀរគរចំណូលដំណាក់កាលទី ៣ ។ ជារួម ចំណុចដែលបានលើកឡើងដោយ DPs សម្រាប់ការរៀបចំយុទ្ធសាស្ត្រនេះ កំពុងត្រូវបានពិចារណាសម្រាប់ជាធាតុចូលនៃការរៀបចំដោយបញ្ចូលរួមទាំងប្រព័ន្ធពន្ធដារ ដែលរួមបញ្ចូលប្រព័ន្ធពន្ធដារបង់ពន្ធតាមថ្នាក់ (Progressive tax system) និងប្រព័ន្ធពន្ធដារដែលលើកកម្ពស់និរន្តរភាពបរិស្ថាន និងសុខភាព។<br>- ទាក់ទងនឹងការចំណាយពន្ធ, អ.គ.ប. ពិនិត្យឃើញពីសារៈសំខាន់របស់វា ហើយវាត្រូវបានរួមបញ្ចូលរួចហើយនៅក្នុងផែនការសកម្មភាពរួមទី៤ (CAP4)។ ទោះបីជាយ៉ាងណាក៏ដោយ យើងក៏ពិនិត្យឃើញពីតម្រូវពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសសម្រាប់ការវិភាគការបន្ទុកពន្ធ និងការពង្រឹងយន្តការចែករំលែកទិន្នន័យ ទាំងគុណភាពទិន្នន័យ និងភាពអាចរកបាន។<br><br>**2.2. ការឆ្លើយតបដោយ អ.ព.ដ.**<br>- ថ្មីៗនេះ រាជរដ្ឋាភិបាលទើបចេញអនុក្រឹត្យស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ។ ហេតុនេះ រាជរដ្ឋាភិបាលអាចនឹងមិនទាន់ពិចារណាលើគោលនយោបាយបង្កើតពន្ធថ្មីក្នុងរយៈពេលខ្លីនេះទេ។ បច្ចុប្បន្ន បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល (PIT) គឺកំពុងស្ថិតក្រោមការរៀបចំសម្រាប់ការអនុវត្តនៅឆ្នាំ២០២៥ ហើយអត្រាពន្ធតាមថ្នាក់ (progressive tax) ក៏នឹងត្រូវបានយកមកសិក្សាផងដែរ។ ម្យ៉ាងវិញទៀត ពន្ធលើចំណេញមូលធន (CGT) តាមអត្រាពន្ធថេរ ២០% ក៏នឹងត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០២៤ នេះ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏ទើបបានដាក់ឱ្យអនុវត្តអាករលើតម្លៃបន្ថែមតាមអត្រា ១០% ចំពោះ<br>- អនិវាសនជនដែលធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Tax on E-Commerce) ផងដែរ។ ជារួមគោលនយោបាយរបស់រដ្ឋាភិបាល គឺមិនដាក់ចេញនូវពន្ធថ្មី ដែលអាចបន្ថែមបន្ទុកដល់អ្នកជាប់ពន្ធនោះទេ។ ក៏ប៉ុន្តែរដ្ឋាភិបាលកំពុងនិងពិចារណាការដំឡើងអត្រាអាករពិសេសដែលមានស្រាប់លើភេ- |

សជ្ជៈមានជាតិស្រវឹង និងភេសជ្ជៈគ្មានជាតិអាល់កុល ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពប្រជា-ពលរដ្ឋ បរិស្ថាន និងសង្គម។

### 2.3. ការឆ្លើយតបដោយ អ.គ.ហ. លើចំណុច (ក)

- តាមរយៈកិច្ចសហការជាមួយតំណាងអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានគោលនយោបាយ ព្រមទាំងជំនាញការនៃធនាគារពិភពលោក, អ.គ.ហ. បានបញ្ចូលការគ្រប់គ្រងបន្ទុកសារពើពន្ធក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤ ក្នុងគោលបំណង (ទី១) រៀបចំយន្តការសម្រាប់អនុវត្តមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងបន្ទុកសារពើពន្ធ និង (ទី២) កសាងសមត្ថភាពមន្ត្រី ក្នុងការប៉ូកសរុប និងវិភាគបន្ទុកសារពើពន្ធ។ ផែនការសកម្មភាពរួម ដំណាក់កាលទី៤ ក៏ជំរុញអង្គភាពក្រោមឱវាទ កសហវ. រៀបចំរបាយការណ៍បន្ទុកសារពើពន្ធប្រចាំឆ្នាំ/រៀងរាល់២ឆ្នាំម្តង ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសម្រេចលើការធ្វើវិចារណកម្មបន្ទុកសារពើពន្ធ។

### 3 មតិយោបល់ដោយដៃគូអភិវឌ្ឍន៍

ដៃគូអភិវឌ្ឍន៍ស្វាគមន៍លើវឌ្ឍនភាពឆ្ពោះទៅកាន់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈខឿនទី៤/ដំណាក់កាលទី៤ ដែលមានគោលបំណងសម្រេច "គណនេយ្យភាពសមិទ្ធកម្ម" ដូចនេះដៃគូអភិវឌ្ឍន៍លើកទឹកចិត្តជំរុញការងារដូចខាងក្រោម៖

ក. បង្កើតឧបករណ៍ពិនិត្យវិភាគបន្ថែមទៀត ដូចជា ត្រួតពិនិត្យលើការចំណាយសាធារណៈ ដើម្បីតម្រង់ទិសសម្រាប់ការកែលម្អគុណភាពថវិកា, ការកំណត់អាទិភាព, និងវិភាជន៍ថវិកាភ្ជាប់ជាមួយព័ត៌មានសមិទ្ធកម្ម។ ឧបករណ៍ទាំងនេះនឹងជួយពង្រឹងដំណើរការសម្រាប់ការកែលម្អគុណភាពថវិកា និងការ-កំណត់អាទិភាពគោលនយោបាយ ដើម្បីដោះស្រាយការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ និងពង្រឹងភាពធន់នៃហិរញ្ញវត្ថុសាធារណៈ ។

ខ. បង្កើតប្រព័ន្ធដែលមានប្រសិទ្ធភាពដើម្បីកំណត់ និងប្រមូលទិន្នន័យសមិទ្ធកម្មដែលមិនមែនជាហិរញ្ញវត្ថុពាក់ព័ន្ធ ហើយផ្តល់ជូនព័ត៌មាននេះជូន អ្នកគ្រប់គ្រងកម្មវិធី និងមន្ត្រីថវិកាដោយផ្ទាល់។ នេះផ្តល់នូវយន្តការមតិត្រឡប់ (feedback) ដែលអាចឱ្យអ្នកគ្រប់គ្រងកម្មវិធី និងរដ្ឋមន្ត្រីយល់ថាតើកម្មវិធីកំពុងអនុវត្តនេះមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពដែរឬទេ។

គ. បន្តពង្រឹងសវនកម្មផ្ទៃក្នុង និងពិចារណាពង្រីកសវនកម្មលើបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងដាក់ឱ្យអនុវត្តសវនកម្មសមិទ្ធកម្ម

ឃ. ពង្រឹងការងារពាក់ព័ន្ធនឹង៖

i. ក្រសួង ស្ថាប័ន ពិសេសការត្រួតពិនិត្យតាមដានសមិទ្ធកម្ម និងត្រួតពិនិត្យ និងបង្កើនចំនួនអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេលលេញ

| | |
|---|---|
| | ii. អាជ្ញាធរសវនកម្មជាតិ, រដ្ឋសភា និងព្រឹទ្ធសភាលើមុខងារពិនិត្យពិនិស្ស័យហិរញ្ញវត្ថុសាធារណៈ។ |

3.1. **ការឆ្លើយតបដោយអគ្គនាយកដ្ឋានថវិកា លើចំណុច (ឃ) និង (ខ) ,(ក)**

- នាយកដ្ឋានតាមដាននិងវាយតម្លៃនៃអគ្គនាយកដ្ឋានថវិកាគឺស្ថិតក្នុងដំណើរការនៃការស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងឯកសារទស្សនាទានស្តីពីការត្រួតពិនិត្យចំណាយសាធារណៈ (Spending review) ដែលគ្រោងនឹងបញ្ចប់ក្នុងឆ្នាំ២០២៣ និងប្រកាសដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០២៤។
- ស្របតាមផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២០, ការបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីត្រូវផ្តល់ជូនក្រសួង ស្ថាប័នចំនួន៨ ក្នុងត្រីមាសទី៤ ឆ្នាំ ២០២២។ នាយកដ្ឋានតាមដាននិងវាយតម្លៃគ្រោងនឹងផ្តល់ការបណ្តុះបណ្តាល ដោយមានការធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាល តាមការផ្តល់ព័ត៌មានត្រលប់ដែលទទួលបានពីអ្នកចូលរួមលើកវគ្គបណ្តុះបណ្តាលលើកមុន ជូនក្រសួង ស្ថាប័នផ្សេងទៀតនៅក្នុងឆ្នាំ២០២៣នេះ ដូចនេះក្រសួង ស្ថាប័នអាចចាប់ផ្តើមរៀបចំផែនការសមិទ្ធកម្ម និងប្រមូលព័ត៌មានសមិទ្ធកម្ម (មិនមែនហិរញ្ញវត្ថុ) ជាទៀងទាត់ក្នុងគោលបំណងតាមដាន និងយល់កាន់តែច្បាស់លើកម្មវិធីទាំងក្រសួង ស្ថាប័ន និងក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ ស្របតាមសិទ្ធិលើការសម្រេចចំណាយថវិកា ដែលផ្តល់ជូនក្រសួង ស្ថាប័នសម្រាប់ការអនុវត្តថវិកា។

3.2. **ការឆ្លើយតបដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង លើចំណុច (ឥ)**

- ការពង្រឹងបន្ថែមទៀតនូវប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង÷ មុខងារសវនកម្មផ្ទៃក្នុងរបស់ ក្រសួង ស្ថាប័ន ត្រូវបានពង្រឹងជាបន្តបន្ទាប់ ជាពិសេសសវនកម្មសមិទ្ធកម្ម និងសវនកម្មព័ត៌មានវិទ្យា តាមរយៈការចេញសេចក្តីណែនាំទាក់ទងនឹងជំនាញសវនកម្ម រួមមាន÷
    - សៀវភៅណែនាំសវនកម្មផ្ទៃក្នុងរបស់រដ្ឋាភិបាល ឆ្នាំ)២០១៧)
    - ស្តង់ដារសវនកម្ម និងគោលការណ៍ណែនាំ (ឆ្នាំ ២០២០)
    - គោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មាន (ឆ្នាំ ២០២០)
    - គោលការណ៍ណែនាំសវនកម្មសម្រាប់គម្រោងហិរញ្ញប្បទានពីខាងក្រៅ ,(២០២០)
    - គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បច្ចេកវិទ្យាព័ត៌មាន (២០២១)

  សៀវភៅណែនាំ និងគោលការណ៍ណែនាំទាំងនេះត្រូវបានផ្សព្វផ្សាយតាមរយៈសិក្ខាសាលាផ្តល់ដល់សវនករផ្ទៃក្នុងនៃ ក្រសួង ស្ថាប័ននានាសម្រាប់ការអនុវត្ត។
- ការពង្រីកសវនកម្ម ICT និងសវនកម្មសមិទ្ធកម្ម÷ សម្រាប់ការអនុវត្តសវនកម្មសមិទ្ធកម្ម (PA) និងសវនកម្មព័ត៌មានវិទ្យា (IT audit), GDIA តែងយកចិត្តទុកដាក់ក្នុងការរៀបចំសម្រាប់ការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលទី ៤ “គណនេយ្យភាពសមិទ្ធកម្ម”។ ជាលទ្ធផល GDIA មាន វឌ្ឍនភាពក្នុងឆ្នាំ២០២១ និង២០២២ដូចខាងក្រោម÷

| | |
|---|---|
| | ○ វឌ្ឍនភាពនៃមុខងារ PA: នៅឆ្នាំ ២០២១, GDIA បានបណ្ដុះបណ្ដាល និងអនុវត្តករណីសិក្សាសាកល្បងដល់ក្រសួងចំនួន ៦ (ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម)។ នៅឆ្នាំ ២០២២, GDIA បានបណ្ដុះបណ្ដាល និងអនុវត្តករណីសិក្សាសាកល្បងទៅកាន់ ក្រសួង ស្ថាប័នចំនួន ៦ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងផែនការ, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងទេសចរណ៍ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។<br>○ វឌ្ឍនភាពនៃមុខងារសវនកម្ម IT÷ នៅឆ្នាំ ២០២១, GDIA បានបណ្ដុះបណ្ដាល និងធ្វើការសិក្សាសាកល្បងដល់ក្រសួង ស្ថាប័នចំនួន១០ សម្រាប់ឆ្នាំ២០២១ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងផែនការ, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងទេសចរណ៍, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងបរិស្ថាន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងធម្មការ និងសាសនា និងក្រសួងយុត្តិធម៌)។ នៅឆ្នាំ២០២២, GDIA បានបណ្ដុះបណ្ដាល និងអនុវត្តករណីសិក្សាសាកល្បងសម្រាប់ក្រសួង ស្ថាប័នចំនួន ៤ បន្ថែមទៀត (ក្រសួងពាណិជ្ជកម្ម, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងកិច្ចការនារី, ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច)។<br>- ចាប់ពីឆ្នាំ ២០២៣ដល់ឆ្នាំ ២០២៧, GDIA នៃកសហវ. នឹងពង្រីកវិសាលភាពនៃការបណ្ដុះបណ្ដាល និងធ្វើតេស្តសាកល្បងនៃ PA និង IT audit ដល់ ក្រសួង ស្ថាប័នទាំងអស់ ជាមួយនឹងផែនការសាកល្បងជាជំហានៗ ដែលរួមបញ្ចូលយ៉ាងហោចណាស់ក្រសួង ស្ថាប័ន ៤ សម្រាប់ ការដាក់ឱ្យប្រើប្រាស់សាកល្បង PA ក្នុងមួយឆ្នាំ និងក្រសួង ស្ថាប័នចំនួន៤ សម្រាប់ធ្វើការដាក់ឱ្យប្រើប្រាស់សាកល្បង IT audit pilot ក្នុងមួយឆ្នាំ។<br>- បញ្ហាប្រឈមដែលអាចពន្យារដល់ការអនុវត្តសវនកម្មព័ត៌មានវិទ្យានៅតាមក្រសួង ស្ថាប័ន មួយចំនួនដោយសារកង្វះធនធានមនុស្សដែលមានជំនាញ IT។ បញ្ហានេះតម្រូវឱ្យ កសហវ. ពង្រឹងក្រសួង ស្ថាប័ន និងថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធដើម្បីឱ្យអង្គភាពសវនកម្មផ្ទៃក្នុងអាចជ្រើសរើសធនធានមនុស្សសមស្របពាក់ព័ន្ធជំនាញ IT។ |
| 4 | **មតិយោបល់ដោយដៃគូអភិវឌ្ឍន៍**<br>**ការ** កាត់បន្ថយនីតិវិធីអនុវត្តការងារ និងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ ដៃគូអភិវឌ្ឍន៍ស្វាគមន៍ចំពោះវឌ្ឍនភាពក្នុងឆ្នាំ២០២២ ដែលគួរឱ្យកត់សម្គាល់រួមមាន ÷ (ក) ការដាក់ឱ្យអនុវត្តឧបករណ៍តាមដាននៃការកាត់បន្ថយនីតិវិធីអនុវត្តការងារ ដោយបង្ហាញពេលវេលា |

ត្រូវការសម្រាប់អនុម័ត និងកន្លែងស្នះឯកសារ, (ខ) ការដាក់ឱ្យអនុវត្តលើការកាត់បន្ថយនីតិវិធីអនុវត្តការងារសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន, និង (គ) សន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធប្រមូលចំណូលរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីគាំទ្រការធ្វើឌីជីថលូនីយកម្ម (digitalization) និងស្វ័យប្រវត្តិកម្មការកត់ត្រាចំណូលគយ។

យុទ្ធសាស្ត្រនៃការទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ (BSRS) កំណត់គោលបំណងដើម្បីធ្វើឱ្យប្រព័ន្ធត្រួតពិនិត្យថវិកាមានភាពសាមញ្ញ ដោយដាក់ចេញនូវនីតិវិធីច្បាស់លាស់ និងខ្លីសម្រាប់ការគ្រប់គ្រងថវិកាទាំងនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន។ ដៃគូអភិវឌ្ឍន៍ សូមផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបន្តការសម្រួលនីតិវិធីអនុវត្តការងារ និងពិចារណាលើការកំណត់តួនាទីរបស់មន្ត្រីត្រួតពិនិត្យថវិកា (BCs) នៅដើមទី ដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីការកែទម្រង់ដែលបានកណត់ក្នុងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី ពិសេស មាត្រា ៧៥ "ការត្រួតពិនិត្យថវិកា អាចធ្វើបានក្នុងនីតិវិធីខ្លី សាមញ្ញ និងទន់ភ្លន់"។ មន្ត្រីត្រួតពិនិត្យថវិកាគួរតែត្រូវបានបើកឱ្យអនុវត្តការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងប្រស័ក្តិសិទ្ធភាព ហើយជៀសវាងការងារត្រួតមុខងារគ្នា ជាមួយនឹងគណនេយ្យករសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។

### 4.1. ការឆ្លើយតបដោយ FMWG លើកែលម្អនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS

- បន្ទាប់ពីទទួលបានជោគជ័យពីការដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចន្តគ្រប់មុខសញ្ញា នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន កាលពីខែតុលា ឆ្នាំ២០២២ កន្លងទៅនេះ ក្រុមការងារគ្រប់គ្រងគម្រោង FMIS បានត្រៀមរួចរាល់សម្រាប់បន្តដំណើរការនៃការដាក់នីតិវិធីអនុវត្តការងារគំរូតាមប្រព័ន្ធ FMIS ទាំងស្រុង ទៅកាន់ក្រសួង ស្ថាប័នផ្សេងបន្ថែមទៀត និងបានដាក់ចេញនូវផែនការច្បាស់លាស់ទៅតាមឆ្នាំជាជំហានៗ រហូតដល់ឆ្នាំ ២០២៧ នៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៤ (២០២៣-២០២៧) ស្របតាមការអនុម័តរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷
    - **ឆ្នាំ ២០២៣**
        - ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា, ចលនាឥណទានថវិកា និង ចំណូលថវិកានៅ ៦ ក្រសួង ស្ថាប័ន និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ
        - ដាក់ឱ្យអនុវត្តនីតិវិធីចលនាឥណទានថវិកា និង ចំណូលថវិកានៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន និង ៦ ក្រសួង ស្ថាប័ន រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ។
    - **ឆ្នាំ ២០២៤**

- បន្តដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា, ចលនាឥណទានថវិកា និង ចំណូលថវិកានៅ ១០ ក្រសួង ស្ថាប័ន បន្ថែម និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ
- ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាវិនិយោគហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិគ្រប់មុខសញ្ញា នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន។

○ **ឆ្នាំ ២០២៥**

- បន្តដាក់ឱ្យនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា, ចលនាឥណទានថវិកា និង ចំណូលថវិកានៅ ក្រសួង ស្ថាប័ន ១៥ បន្ថែម និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ
- បន្តដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាវិនិយោគហិរញ្ញប្បទាន ដោយថវិកាថ្នាក់ជាតិគ្រប់មុខសញ្ញានៅ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និង ឧតុនិយម
- ដាក់ឱ្យអនុវត្តនីតិវិធីលទ្ធកម្មពេញលេញនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន។

○ **ឆ្នាំ ២០២៦**

- បន្តដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា, ចលនាឥណទានថវិកា និង ចំណូលថវិកានៅក្រសួង ស្ថាប័ន ៤ បន្ថែម និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ
- បន្តដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាវិនិយោគហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិគ្រប់មុខសញ្ញានៅក្រសួង ស្ថាប័នសេសសល់
- បន្តដាក់ឱ្យអនុវត្តនីតិវិធីលទ្ធកម្មពេញលេញ នៅក្រសួង ស្ថាប័នសេសសល់។

○ **ឆ្នាំ ២០២៧**

- ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា, នីតិវិធីចំណាយថវិកាវិនិយោគហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិគ្រប់មុខសញ្ញា, ចលនាឥណទានថវិកា, ចំណូលថវិកា និង នីតិវិធីលទ្ធកម្មពេញលេញ នៅ ២៥ រដ្ឋបាលរាជធានី ខេត្ត និង ២៥ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- ជាមួយគ្នានេះ, ក្រុមការងារគ្រប់គ្រងគម្រោង FMIS ក៏បានអភិវឌ្ឍរួចរាល់នូវឧបករណ៍តាមដានប្រតិបត្តិការ (Monitoring Tool) ជាប្រភេទ Dashboard សម្រាប់អ្នកប្រើប្រាស់ធ្វើការត្រួតនិត្យតាម-ដាន និង វាយតម្លៃលើការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុង ដែលត្រូវអនុវត្តតាមផែនការខាងលើនេះ។

### 4.2 ការឆ្លើយតបដោយអគ្គនាយកដ្ឋានថវិកា លើការកំណត់មុខងាររបស់មន្ត្រីត្រួតពិនិត្យថវិកា និង ជៀសវាងការងារត្រួតមុខងារគ្នា ជាមួយនឹងគណនេយ្យករសាធារណៈ

- សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យករសាធារណៈ (សេចក្តីព្រាងអនុក្រឹត្យលេខ ៨១ និង៨២) ត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវដំណើរការត្រួតពិនិត្យថវិកាប្រកបដោយភាព

ទន់ភ្លន់ និងគណនេយ្យភាពបន្ថែមទៀតដល់ ក្រសួង ស្ថាប័ន ពិសេសអង្គភាពថវិកា។ លើសពីនេះ, សេចក្តីប្រកាសជាបន្តបន្ទាប់ស្តីពីគោលការណ៍ណែនាំការអនុវត្តថវិកា នឹងរៀបរាប់លម្អិតបន្ថែមទៀតអំពីរបៀបសម្រួលនីតិវិធីដំណើរការ។

### 4.3 ការឆ្លើយតបដោយអគ្គនាយកដ្ឋានរតនាគារជាតិ លើការកំណត់មុខងាររបស់មន្ត្រីត្រួតពិនិត្យថវិកា និងជៀសវាងការងារត្រួតមុខងារគ្នា ជាមួយនឹងគណនេយ្យករសាធារណៈ

- គណនេយ្យករសាធារណៈទទួលបន្ទុកលើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ។ គណនេយ្យករសាធារណៈផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកា ដោយពិនិត្យអនុលោមភាពជាមួយនឹងលិខិតបទដ្ឋានគតិយុត្តជាធរមាន, ផ្ទៀងផ្ទាត់លើសេវាបានបំពេញដោយផ្អែកលើការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក និងផ្ទៀងផ្ទាត់ឯកសារគាំទ្រ មុននឹងចុះកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការនិងធ្វើការទូទាត់។ យន្តការនេះជាឧត្តមានុវត្តន៍នៅប្រទេសបារាំង និងបណ្តាប្រទេសផ្សេងទៀត។

## 5 មតិយោបល់ដោយដៃគូអភិវឌ្ឍន៍

**ថវិកាព័ត៌មានសមិទ្ធកម្ម÷** ដៃគូអភិវឌ្ឍន៍កត់សម្គាល់ថាថវិកាព័ត៌មានសមិទ្ធកម្មត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តសាកល្បង សម្រាប់ថវិកាឆ្នាំ២០២៣ ក្នុងនោះរួមមាន ការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដៃគូអភិវឌ្ឍន៍ក៏កត់សម្គាល់ផងដែរថា ថវិកាកម្មវិធីត្រូវបានរៀបចំតាមរចនាសម្ព័ន្ធរដ្ឋ-បាលដែលមានស្រាប់ និងមិនទាន់ឆ្លើយតបពេញលេញថវិកាសមិទ្ធកម្ម។ ក្នុងន័យនេះ, ដៃគូអភិវឌ្ឍន៍លើកទឹកចិត្តលើការត្រួតពិនិត្យមុខងារ ដើម្បីបន្តកែលម្អរចនាសម្ព័ន្ធកម្មវិធី ពិសេសសម្រាប់ក្រសួង ស្ថាប័នចំនួន៧ ដែលត្រូវអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្ម។

### 5.1. ការឆ្លើយតបដោយអគ្គនាយកដ្ឋានថវិកា លើការត្រួតពិនិត្យមុខងារ ដើម្បីបន្តកែលម្អរចនាសម្ព័ន្ធកម្មវិធី

- ដោយសាររចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធកម្មវិធីមានភាពខុសគ្នាយ៉ាងខ្លាំងពីក្រសួង ស្ថាប័នមួយទៅក្រសួង ស្ថាប័នមួយទៀត ដំណាក់កាលសាកល្បងនេះគឺជាឱកាសសម្រាប់ ក្រសួង ស្ថាប័ន ដើម្បីសម្របខ្លួនទៅនឹងប្រព័ន្ធថវិកាថ្មីដោយផ្អែកលើរចនាសម្ព័ន្ធកម្មវិធី និងរដ្ឋបាលដែលមានស្រាប់។ ដោយសារតែ ក្រសួង ស្ថាប័ន គឺជាជំនាញការបច្ចេកទេសនៅក្នុងផ្នែកដែលខ្លួនទទួលខុសត្រូវ ដែលយល់ច្បាស់ជាងថាតើរចនាសម្ព័ន្ធណាមួយមានប្រសិទ្ធភាពខ្ពស់ជាងដើម្បីអនុវត្តកម្មវិធី និងគោល-បំណងរបស់ក្រសួង ស្ថាប័ន។ នេះមិនមែនមានន័យថា អ.ថ. ជំទាស់ការពិនិត្យមុខងារឡើងវិញនោះទេ ផ្ទុយទៅវិញ អ.ថ. ពិនិត្យមើលទស្សនៈវិស័យដើម្បីអនុវត្ត, និងរៀនបណ្តើរ ផ្លាស់ប្តូរបណ្តើរ ផ្អែកលើមេរៀននិងបទពិសោធន៍ របស់ខ្លួនកន្លងមក។
- លើសពីនេះ, ស្របតាមផែនការសកម្មភាពនៃ យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកា ថវិកាព័ត៌មានសមិទ្ធកម្មត្រូវបានដាក់សាកល្បងជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ថវិកាឆ្នាំ ២០២៣ ដើម្បីឱ្យ

គុណភាពនៃសូចនាករសមិទ្ធកម្ម និងសូចនាករគោលដៅត្រូវបានកែលម្អ។ ទន្ទឹមនេះ, កិច្ចព្រមព្រៀងសមិទ្ធកម្មត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងជាមួយ ក្រសួង ស្ថាប័នចំនួន៧ ក្នុងទម្រង់បីនៃកិច្ចព្រម-ព្រៀងការអនុវត្ត រួមមាន÷

- ○ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី សម្រាប់ការអនុវត្តថវិកាកម្មវិធី/ថវិកាសមិទ្ធកម្ម
- ○ រវាងក្រសួង ស្ថាប័ន និងប្រធានគ្រប់គ្រងកម្មវិធីនិង
- ○ រវាងប្រធានគ្រប់គ្រងកម្មវិធី និងប្រធានអង្គភាពថវិកា

- កិច្ចព្រមព្រៀងសមិទ្ធកម្មរវាង កសហវ. និង ក្រសួង ស្ថាប័ន នឹងត្រូវបានចុះហត្ថលេខានៅក្នុងប៉ុន្មានសប្តាហ៍ខាងមុខនេះ ខណៈដែលកិច្ចព្រមព្រៀងនីមួយៗ គឺកំពុងស្ថិតក្រោមការពិនិត្យ និងអនុម័តផ្ទៃក្នុងនៃក្រសួង ស្ថាប័ន។

6 **មតិយោបល់ដោយដៃគូអភិវឌ្ឍន៍**

**តម្លាភាពថវិកា÷** ដៃគូអភិវឌ្ឍន៍គាំទ្រពេញទំហឹងលើការលើកកម្ពស់តម្លាភាពថវិកា, គណនេយ្យភាព, ការពិនិត្យពិនិស្ស័យ និងការចូលរួមជាសាធារណៈ។ ក្នុងបរិបទនេះ, ដៃគូអភិវឌ្ឍន៍ សូមស្វាគមន៍ចំពោះការផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២៣ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដៃគូអភិវឌ្ឍន៍ សូមលើកទឹកចិត្តរាជរដ្ឋាភិបាលពិចារណាផ្សព្វផ្សាយឯកសារថវិកាជាទៀងទាត់ រួមមាន÷

ក. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF)
ខ. របាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដា IPSAS
គ. របាយការណ៍ និងផែនការហិរញ្ញវត្ថុនិងសមិទ្ធកម្មប្រចាំឆ្នាំ ដែលកំណត់ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី
ឃ. របាយការណ៍សមិទ្ធកម្ម និងហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន
ង. របាយការណ៍សវនកម្មស្តីពីសេចក្តីព្រាងច្បាប់ទូទាត់ថវិកា។

### 6.1. ការឆ្លើយតបដោយអគ្គនាយកដ្ឋានគោលនយោបាយលើចំណុច (ក)

- **អ.គ.ប. ទទួលស្គាល់សារៈសំខាន់នៃការអនុវត្ត MTFF ដែលជាផ្នែកមួយដែលធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃផែនការថវិកា និងការចំណាយ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំនេះត្រូវបានពន្យារពេលរយៈពេល ដោយសារកត្តាសត្យានុម័តមួយចំនួនដូចជា ភាពមិនប្រាកដប្រជាដែលបណ្តាល មកពីជំងឺកូវីដ-១៩, សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការកែសម្រួលមូលដ្ឋានគណនាផលិតផលក្នុងស្រុកសរុប (Rebasing GDP)។**
- ឯកសារ MTFF ត្រូវបានគេរំពឹងថានឹងត្រូវរៀបចំឡើងដើម្បីជំនួសក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០២៤ នឹងរំពឹងបោះពុម្ពផ្សាយនៅក្នុងត្រីមាសទី ២ ឆ្នាំ ២០២៤។

6.2. **ការឆ្លើយតបដោយអគ្គនាយកដ្ឋានរតនាគារជាតិលើចំណុច (ខ)**

- របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ និងត្រូវបានវាយតម្លៃដោយនិយ័តករគណនេយ្យ និងសវនកម្ម និងជំនាញការមូលនិធិរូបិយវត្ថុអន្តរជាតិថា មានអនុលោមភាពស្របតាមស្តង់ដា IPSAS មូលដ្ឋានសាច់ប្រាក់។ បច្ចុប្បន្ន របាយការណ៍ហិរញ្ញវត្ថុនេះ មិនទាន់បានធ្វើសវនកម្មនៅឡើយទេ និងជាកម្មវត្ថុនៃការធ្វើសវនកម្មជាផ្លូវការចាប់ពីឆ្នាំ២០២៦ ស្របតាមស្មារតីនៃសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី។
- តួលេខសង្ខេបនៃរបាយការណ៍ហិរញ្ញវត្ថុនេះ នឹងគ្រោងបោះផ្សាយនៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានរតនាគារជាតិ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៣តទៅ។

6.3. **ការឆ្លើយតបដោយអគ្គនាយកដ្ឋានថវិកាលើចំណុច (គ) និង (ឃ)**

- **(គ)** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្តេជ្ញាពង្រឹងតម្លាភាពថវិកាស្ថិតក្នុងក្របខ័ណ្ឌច្បាប់ជាតិ ដែលអនុវត្តសម្រាប់ការបើកចំហរនិងផ្សព្វផ្សាយព័ត៌មានហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។ ជាមួយគ្នានេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្តេជ្ញាក្នុងការអនុញ្ញាតឱ្យសាធារណៈជនទាញយកព័ត៌មាន ដែលមានក្នុងច្បាប់ថវិកាបន្ទាប់ពីត្រូវអនុម័ត។
- ច្បាប់ថវិកាសង្ខេបត្រូវបានរៀបចំឡើងឱ្យមានលក្ខណៈសាមញ្ញ និងផ្សព្វផ្សាយលើគេហរទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (www.mef.gov.kh)។ ឯកសារនេះនឹងបន្តត្រូវបន្តកែសម្រួល ដើម្បីងាយស្រួលក្នុងការអាន និងភាពទាក់ទាញ ដោយពុំមានពាក់បច្ចេកទេស។ សៀវភៅថវិកាសង្ខេបមានប្រភេទតារាង និងក្រាហ្វបង្ហាញចំណូល, ចំណាយតាមវិស័យ និងសូចនាករម៉ាក្រូសេដ្ឋកិច្ច។
- រដ្ឋាភិបាលក៏បានរៀបចំវេទិកាសាធារណៈស្តីពីច្បាប់ថវិកា បន្ទាប់ពីអនុម័ត ដែលផ្តល់ជាទម្រង់មួយដើម្បីពិភាក្សាបញ្ហាពាក់ព័ន្ធនឹងថវិការដ្ឋ និងវិមជ្ឈការហិរញ្ញវត្ថុ។ ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, គ្រឹះស្ថានសិក្សា និងអង្គភាពសាព័ត៌មាននៅក្នុងប្រទេសនឹងត្រូវអញ្ជើញឱ្យចូលរួម។ វេទិកានេះដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- បន្ថែមពីនេះ, ជាមួយផ្នែកមួយនៃតម្លាភាពថវិកា, គណនេយ្យភាព និងការពិនិត្យពិនិស្ស័យ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្សព្វផ្សាយឯកសារជាច្រើនពាក់ព័ន្ធថវិកា ក្នុងនោះឯកសារថវិកាមួយចុងក្រោយនោះគឺសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២៣ បន្ទាប់ពីត្រូវបានបញ្ជូនរដ្ឋសភាក្នុងរយៈពេល ២សប្តាហ៍។ បន្ថែមពីនេះ, អនុលោមតាមមាត្រា៦០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផែនការសមិទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននឹងត្រូវភ្ជាប់ជាមួយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ដែលនឹងបញ្ជូនទៅរដ្ឋសភា និងព្រឹទ្ធសភា។ ចាប់ពីឆ្នាំ២០២៣, ក្រសួង ស្ថាប័នចំនួន ៧ចុះហត្ថលេខាកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកលើកញ្ចប់ថវិការបស់ខ្លួន។ សម្រាប់របាយការណ៍

| | |
|---|---|
